# អដ្ឋកថា ព្រះសុត្តន្តបិដក

## ជាតកដ្ឋកថា

## តតិយភាគ តឹសនិបាត

## ភាគ ៦០

ពុទ្ធសករាជ ២៥៦៦

# អដ្ឋកថា ព្រះសុត្តន្តបិដក

## ខុទ្ទកនិកាយ

## ជាតកដ្ឋកថា

## តតិយភាគ តឹសនិបាត

# លេខ ៦០

ពុទ្ធសករាជ ២៥៦៦

អធិប្បាយ

តឹសនិបាត

# អដ្ឋកថា ខុទ្ទកនិកាយ

# ជាតកដ្ឋកថា

# ភាគ ៦០

## តតិយភាគ

សរុបក្នុងនិបាតនេះ មាន ១និបាត

១. តឹសនិបាត មាន ១០ អដ្ឋកថា

សរុប ១០ អដ្ឋកថា

# ស្រៈនិងសរ័យ

# *Signes et accents:*



# ស្រះពេញតួ
# Voyelles:

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រ៉ូម Romain | a | .ā | i | i | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| សិង្ហ Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

# *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| ឡូប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຊ | ຍ |
| សឹង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| ឡាតាំង Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម Siamois | ฎ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ຏ | ຐ | ຑ | ຒ | ຓ |
| លង្កា Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| បាលី Pâli | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ᨲ | ᨳ | ᨴ | ᨵ | ᨶ |
| សិង្ហល Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ប | ផ | ព | ភ | ម |
| រ៉ូម<br>Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម<br>Siamois | ป | ผ | พ | ภ | ม |
| លាវ<br>Laotien | ປ | ຜ | ບ | ພ | ມ |
| លង្កា<br>Cinghalais | ප | ඵ | බ | භ | ම |
| ភូមា<br>Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | យ្យ | រ្រ | ល្ល | វ្វ | ស្ស | ហ្ហ | ឡ | ំ | ។ |
| រ៉ូម Romain | *y* | *r* | *l* | *v* | *s* | *h* | *ḷ* | *ṃ* | ·/. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| សិង្ហ Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | । |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ။ |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ មានអង្គ ៩ គឺ ៖*

***សុត្តៈ** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេងៗ មានមង្គលសូត្រជាដើម ។*

***គេយ្យៈ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណៈ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធៗ ដែលមិនមានឈ្មោះ ពោលដល់ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តកៈ** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្លៈ** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបានទូវសេចក្ដី*

រីករាយ និងសាកសួរជាបន្តៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេងៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រតិបត្តិ ។

ព្រះមានព្រះភាគទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឈ្លាសក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថាការបានស្តាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលពួកខ្លះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេងៗ គ្នា មានសីល និងទិដ្ឋិផ្សេងៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយព្រមទាំងអត្ថ និងព្យញ្ជនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងមានឧស្សាហៈដ៏ខ្លាំងក្លា បានអធិ-ប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក ចំពោះសេចក្តីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់ក្នុងគម្ពីរព្រះពុទ្ធសាសនាខាងក្រោយមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេងៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុព្វាចារ្យជំនាន់ក្រោយៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកពោល អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួនឧឡូទូន្មានទុកជាមួយអត្តនោមតិ គឺ ទៅតាមមតិរបស់ខ្លួនឯងដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលជាគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះប្រកបដោយការយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់ជាមួយព្រះត្រៃបិដក ពុទ្ធសាសនិកជនល្អប្រកាន់ថា ធ្វើមិនបានដូចគ្នា ។

សូមអានុភាពនៃព្រះរតនត្រ័យ  ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌  ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ ។ លុះព្រះពុទ្ធសាសនាកន្លងបាន ១០០ ឆ្នាំ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌-វិន័យ គឺ ៖

១. ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២. ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣. ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន មិនមែនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤. ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥. ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦. ការបដិបត្តិដែលឧបជ្ឈាយ៍-អាចារ្យ ធ្លាប់ប្រព្រឹត្តមកខុសត្រូវយ៉ាងណាប្រព្រឹត្តតាម គួរ ។

៧. ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨. ភិក្ខុផឹកស្រាខ្សោយៗ គួរ ។

៩. ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០. ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា **កាកណ្ឌកៈ** បានស្ដាប់វត្ថុ ១០ ប្រការនោះហើយ បានកាន់យកព្រះចៅអសោករាជដែលជាព្រះឱរសរបស់ព្រះបាទសុសុនាគៈធ្វើជាសម្ចាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំណោមភិក្ខុ ១.២០០.០០០ អង្គ គឺ (ដប់ពីរសែន) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកព្រះសីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ តិះដៀលហើយ ទើបស្វែងរកពួកគណៈ លុះបានពួកដែលជាទុព្វលៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា **មហាសង្ឃិកៈ** និង**ឯកព្យោហារិកៈ** ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យ ២ ពួកដទៃទៀត គឺ **បញ្ញត្តិវាទៈ** និង**ពហុលិយៈ** ដែលមានឈ្មោះម្យ៉ាងទៀតថា **ពហុស្សុតិកៈ** ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀត ឈ្មោះថា **ចេតិយវាទ** កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះៗ ឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈ ដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា ៦ ត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកអំពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តចរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១

សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំនោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញអំពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកអំពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមទាំងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទ និងនិកាយអាចរិយវាទ ៦ ដែលបែកចេញមកអំពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយនោះ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះរបស់និកាយដែលពោលមកហើយនោះឯង ។ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញអំពីគ្នា, ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្សទី ៣




*ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ៗ*

*(ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ)*

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា របស់គម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង (គម្ពីរអដ្ឋសាលិនី) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈ អារាធនាឲ្យព្រះពុទ្ធឃោសៈតែងគម្ពីរនេះ ជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ ។ កើតក្នុងត្រកូលព្រាហ្មណ៍ នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេងៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិ-បញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតអស់ទាំងសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថា ជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេងៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានសេចក្តីសង្ស័យមិនយល់ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទា ក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដនាមថា **ព្រះពុទ្ធឃោសៈ** ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្តនាតំបន់ពុទ្ធគយានោះ លោកបានរចនាបករណ៍ឈ្មោះ **ញាណោទយ័** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថាឈ្មោះ **អដ្ឋសាលិនី** ដែលជាអដ្ឋកថាគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺអដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈបានឃើញអដ្ឋកថា ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែលង្កាទ្វីបនៅមាន ព្រោះព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចព្រះអគ្គសាវក) ជាដើម បានរចនាទុក និងតមក ព្រះមហិន្ទត្ថេរបានត្រួតពិនិត្យហើយ រចនាទុកជាភាសាសីហឡៈ

សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈក៏មានបីតិ-សោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅ រហូតដល់កំពង់ផែក្រុងលង្កាសម័យនោះ គឺ ជាកាលរបស់ក្សត្រិយ៍លង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា (សិរិនិវាស) ខ្លះ (សិរិកុថៈ) ខ្លះ (សិរិកូដ្ឋៈ) ខ្លះ ក្នុងពុទ្ធសករាជ (៩៥២-៩៧៤) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់នូវអដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគដោយពិត ទើបបានសូមការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនាអដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថា ឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈ បានរចនាបករណ៍ឈ្មោះវិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កា

ទទួលស្គាល់នូវសេចក្តីជំនាញរបស់លោក ។ តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយបាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន រចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តងទៀត គម្រប់ ៣ ដង បន្ទាប់មក ក៏បានប្រគេនគម្ពីរដែលបានរចនាទាំងពីរលើកនោះវិញ វេលានោះទើបបានគម្ពីរវិសុទ្ធិមគ្គជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នា ទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬដោយព្រះបាលីទាំងឡាយ ក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារ បានឃើញសេចក្តីអស្ចារ្យ ក៏នាំគ្នាត្រេកអរកោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះ ជាព្រះមេត្តេយ្យពោធិសត្វដោយពិត នឹងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះមហានាមក្សត្រិយ៍នៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយឈ្មោះ **បធានឃរ** នាទិសទក្សិណនៃមហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ មកជាអដ្ឋកថាព្រះ

ត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១. មហាអដ្ឋកថា

២. បច្ចរិយអដ្ឋកថា

៣. កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា ព្រះមហិន្ទត្ថេរនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈ ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ (ផ្ទះទឹក) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ មានច្រើនជាងពាក់កណ្ដាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១. **សមន្តបាសាទិកា** អដ្ឋកថាព្រះវិន័យបិដក

២. **កង្ខាវិតរណី ឬមាតិកដ្ឋកថា** អដ្ឋកថាព្រះបាតិមោក្ខ

៣. **សុមង្គលវិលាសនី** អដ្ឋកថាទីឃនិកាយ

៤. **បបញ្ចសូទនី** អដ្ឋកថាមជ្ឈិមនិកាយ

៥. **សារត្ថប្បកាសិនី** អដ្ឋកថាសំយុត្តនិកាយ

៦. **មនោរថបូរណី** អដ្ឋកថាអង្គុត្តរនិកាយ

៧. **បរមត្ថជោតិកា** អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨. **ធម្មបទដ្ឋកថា** អដ្ឋកថាធម្មបទ

៩. **ជាតកដ្ឋកថា** អដ្ឋកថាជាតក

១០. **អដ្ឋសាលិនី** អដ្ឋកថាធម្មសង្គណីបករណ៍

១១. **សម្មោហវិនោទនី** អដ្ឋកថាវិភង្គបករណ៍

១២. **បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី** ជាព្រះអដ្ឋកថាព្រះអភិធម្ម ទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣. **វិសុទ្ធិមគ្គ** បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤. **ញាណោទ័យ** តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥. **បរិត្តដ្ឋកថា** អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេងៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅបានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យដ៏សំខាន់ក្រៃលែងរបស់លោកយើងនេះ ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុជាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្លាត ហ៊ិន
ឧបាសក ឆាក់ ម៉ៅ
ឧបាសក កុំ ធ្នួន
ឧបាសក ហុក សីដហួត
ឧបាសក ជីម ជំនិត
ឧបាសក កើត និត្យ
ឧបាសក សន ម៉ារទី
ឧបាសក ហាយ ចំរើន
ឧបាសក អ៊ឹម វ៉ៃយ៉ា
ឧបាសក សុក្រ ហ៊ិត
ឧបាសក សោម រតនៈ
ឧបាសក សំ ឆាយ
ឧបាសក ម៉ៅ ផុន
ឧបាសក ជា ស៊ីថាន
ឧបាសិកា ថាប់ លៀម
ឧបាសិកា ហាយ សារ៉ាត់
ឧបាសិកា ប៊ុត សុម៉ាលី
ឧបាសិកា យស សម្បត្តិ
ឧបាសិកា ពូ ហ៊ាង
ឧបាសិកា ប៊ុត សេដាដួង
ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ឧបាសក ហាយ ចំរើន

ឧបាសក ជីម ជំនិត

ឧបាសក សុន ម៉ារឌី

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ–

ឧទ្ទិសថ្វាយ និងគោរពជូនៈ

–ព្រះមហាវរក្សត្រិយ៍ និងមហាវរក្សត្រិយានី

–ព្រះមហាក្សត្រិយ៍នៃព្រះរាជាណាចក្រកម្ពុជា

–សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

–មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

–លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

–លោកគ្រូធម្មបណ្ឌិត រស់ សុជាត

–សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

–សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

ឈ្មោះរឿង ធំព័រ

## តឹសនិបាត


១-អដ្ឋកថា កឹធន្ធជាតក ១
២-អដ្ឋកថា កុម្ភជាតក ៤៨
៣-អដ្ឋកថា ជយទ្ទិសជាតក ៩១
៤-អដ្ឋកថា ឆទ្ទន្តជាតក ១៤៨
៥-អដ្ឋកថា សម្ភវជាតក ២២៤
៦-អដ្ឋកថា មហាកបិជាតក ២៧០
៧-អដ្ឋកថា ទករក្ខសជាតក ៣០៧
៨-អដ្ឋកថា បណ្ឌរកជាតក ៣០៨
៩-អដ្ឋកថា សម្ពុលាជាតក ៣៦២
១០-អដ្ឋកថា ភណ្ឌុតិណ្ឌុកជាតក ៤០៨

# តឹសនិបាត

# បរមត្ថទីបនី អដ្ឋកថាខុទ្ទកនិកាយ

# ជាតកដ្ឋកថា

## អដ្ឋកថា កឹឆន្ទជាតកទី ១

(រឿងទោសព្រោះដណ្តើមយកប្រយោជន៍អ្នកដទៃ)

*ព្រះសាស្តាកាលស្តេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បាន ប្រារព្ធឧបោសថកម្ម ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា កឹឆន្ទោ កិមធិប្បាយោ "លោកមានសេចក្តីពេញចិត្តអ្វី បំណងអ្វី" ដូច្នេះ ។*

*សេចក្តីសង្ខេបថា ថ្ងៃមួយ ព្រះសាស្តាត្រាស់សួរឧបាសក ឧបាសិកាជាច្រើនដែលរក្សាឧបោសថ ដែលមកអង្គុយដើម្បីស្តាប់ ព្រះធម៌ទេសនានៅត្រង់ធម្មសភាថា "ម្នាលឧបាសកឧបាសិកាទាំង*

ឡាយ ពួកអ្នករក្សាឧបោសថឬ? កាលគេក្រាបទូលថ្វាយទ្រង់ជ្រាបហើយ ទើបត្រាស់ថា "ម្នាលអ្នកទាំងឡាយនាំគ្នារក្សាឧបោសថ រាប់ថា បានធ្វើសេចក្តីល្អហើយ បុរាណកបណ្ឌិតទាំងឡាយបានទទួលយសដ៏ធំ ព្រោះផលនៃឧបោសថកម្មពាក់កណ្តាល" ពួកឧបាសក-ឧបាសិកាទាំងនោះក្រាបទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះ ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងព្រះនគរពារាណសីដោយធម៌ ព្រះអង្គទ្រង់ជាអ្នកមានបសាទសទ្ធាមិនប្រមាទក្នុងទាន សីល និងឧបោសថកម្ម ។ ព្រះអង្គត្រាស់នឹងជនដ៏សេសមានអាមាត្យជាដើម ឲ្យតាំងនៅក្នុងកុសលចរិយាមានទានជាដើម ។ តែបុរោហិតរបស់ព្រះអង្គមានប្រក្រតីរើបជាន់ប្រជា-ជន ស៊ីសំណូក វិនិច្ឆ័យក្តីដោយអយុត្តិធម៌ ។ ក្នុងថ្ងៃឧបោសថទ្រង់ត្រាស់ឲ្យប្រជាជនមានអាមាត្យជាដើមមកគាល់ ហើយត្រាស់

ថា "ពួកអ្នកទាំងឡាយចូរមករក្សាឧបោសថ" បុរោហិតក៏មិនព្រម សមាទានឧបោសថ ។ គ្រានោះ កាលព្រះរាជាកំពុងត្រាស់សួរដល់ពួកអាមាត្យថា "អ្នកទាំងឡាយសមាទានឧបោសថឬ?" ហើយក៏បែរត្រាស់សួរបុរោហិតនោះ អ្នកទទួលសំណូក និងកាត់ក្តីដោយអយុត្តិធម៌ក្នុងវេលាថ្ងៃ ដែលមកគាល់ថា "លោកអាចារ្យ លោកសមាទានឧបោសថហើយឬ?" បុរោហិតនោះក៏ទូលកុហកថា សមាទានព្រះអង្គ" ហើយចុះចាកប្រាសាទទៅ ។ គ្រានោះ អាមាត្យម្នាក់សួរថា "លោកមិនបានសមាទានឧបោសថមិនមែនឬ?" បុរោហិតនោះនិយាយកែខ្លួនថា "ខ្ញុំបរិភោគអាហារចំពោះតែក្នុងកាលប៉ុណ្ណោះ ខ្ញុំនឹងត្រឡប់ទៅផ្ទះហើយ នឹងប្រឹងប្រែងអធិដ្ឋានឧបោសថ មិនបរិភោគអាហារក្នុងវេលាល្ងាចទេ ខ្ញុំនឹងរក្សាឧបោសថសីលក្នុងវេលាយប់ដោយអាការយ៉ាងនេះ ខ្ញុំនឹងបាននូវឧបោសថកម្មពាក់កណ្តាល" ។ អាមាត្យនោះពោលថា "ប្រពៃហើយ លោកអាចារ្យ" ។ គេត្រឡប់

ទៅផ្ទះហើយក៏បានធ្វើយ៉ាងនោះ ។

តមកថ្ងៃមួយ កាលបុរោហិតនោះនៅក្នុងសាលា ស្ត្រីអ្នកមានសីលម្នាក់មកឈរបើ្លងភ្លើង កាលមិនបានឱកាសនឹងត្រឡប់ទៅផ្ទះ ក៏គិតថាយើងនឹងមិនលះបង់ឧបោសថកម្មឡើយ លុះជិតដល់កាលនាងទើបផ្តើមខ្ពុរមាត់ ។ ខណៈនោះ មានអ្នកនាំផ្លែស្វាយទុំមកឲ្យព្រាហ្មណ៍បុរោហិតមួយចង្កោម ។ ព្រាហ្មណ៍បុរោហិតដឹងថា ស្ត្រីនោះនឹងសមាទានឧបោសថ ទើបបេះផ្លែស្វាយឲ្យ ព្រមទាំងនិយាយថា "នាងចូរទទួលទានស្វាយទុំទាំងនេះចុះ ហើយសឹមសមាទាននូវឧបោសថ" ស្ត្រីនោះក៏បានធ្វើតាមនោះ កុសលកម្មរបស់ព្រាហ្មណ៍បុរោហិតមានត្រឹមប៉ុណ្ណោះ ។

ក្នុងវេលាតមក ព្រាហ្មណ៍បុរោហិតនោះក៏ធ្វើកាលកិរិយាទៅបានទៅកើតនៅលើសិរីសេយ្យាសនៈដែលប្រដាប់ហើយក្នុងវិមានមាសដ៏ស្អាតរុងរឿង មានភូមិភាគជារមណីយដ្ឋាន ក្នុងសួនអម្ពវ័ន

ដែលមានបរិមណ្ឌល ៣ យោជន៍ ក្បែរមាត់ទឹកកោសិកគង្គាក្នុង ហិមវន្តប្បទេស ដូចបុគ្គលដេកលក់ហើយភ្ញាក់ឡើង មានរូបរាងដែលប្រដាប់ល្អហើយ ទ្រង់នូវរូបឆោមស្រស់សង្ហា ហែហមដោយនាងទេពកញ្ញា ១៦.០០០ នាក់ជាបរិវារ គេបានសោយសិរីសម្បត្តិនោះ តែក្នុងវេលាយប់ប៉ុណ្ណោះ ។ ពិតហើយ ទេវបុត្តនោះបានសោយវិបាកសមទឹងកម្មដែលខ្លួនបានធ្វើទុក ដោយភាវៈជាវេមានិ-កប្រេត ។ ព្រោះដូច្នោះ វេលាអរុណរះឡើង គេក៏ត្រូវទៅកាន់សួនអម្ពវ័ន ។ ក្នុងខណៈដែលគេចូលទៅកាន់សួនអម្ពវ័នប៉ុណ្ណោះ អត្តភាពដែលជាទិព្វរបស់គេក៏អន្តរធានទៅ ហើយកើតនូវអត្តភាពប្រមាណប៉ុនដើមត្នោត កម្ពស់ ៨០ ហត្ថជំនួស ភ្លើងឆេះជាប់ទូទាំងរាងកាយ ប្រៀបដូចជាផ្កាចារដែលរីកដូច្នោះ ម្រាមដៃម្រាមជើងទាំងសងខាង មានក្រចកដុះវែងប្រមាណប៉ុនចបជំ ។ គេបានយកក្រចកទាំងនោះ ខ្វាចខ្វេះសាច់ខ្នងខ្លួនឯងមកស៊ី សោយទុក្ខវេទនាស្រែក

យំហើយ ។ កាលព្រះអាទិត្យអស្តង្គតទៅ រាងកាយនោះក៏អន្តរធាន ទៅ រាងកាយជាទិព្វក៏កើតឡើងជំនួស ។ ពួកស្រីទេពអប្សរដែល ជាទិព្វប្រដាប់តាក់តែងខ្លួនដោយទិព្វាលង្ការ នាំគ្នាកាន់គ្រឿងតន្ត្រី មកប្រគំបម្រើ ។ កាលនឹងសោយមហាសម្បត្តិ ក៏ឡើងទៅកាន់ ប្រាសាទដែលជាទិព្វ ក្នុងសួនអម្ពវ័នដែលជារមណីយដ្ឋាន ។ វេ-មានិកប្រេតនោះ បានចំពោះនូវសួនអម្ពវ័នដែលមានមណ្ឌលប្រមាណ ៣ យោជន៍ ព្រោះផលនៃការឲ្យផ្លែស្វាយដល់ស្ត្រីអ្នកសមាទានឧបោ-សថ តែព្រោះផលនៃការស៊ីសំណូក កាត់ក្តីដោយអយុត្តិធម៌ ទើប ត្រូវខ្វេះសាច់ខ្នងរបស់ខ្លួនស៊ី និងព្រោះតែផលនៃឧបោសថកម្មពាក់ កណ្តាល ទើបបានសោយយសជាទិព្វ ហែហមដោយស្រីទេពអប្សរ ១៦.០០០ នាក់ជាបរិវារ ទំនុកបម្រុងដោយប្រការដូច្នោះ ។

កាលនោះ ព្រះបាទពារាណសីឃើញទោសក្នុងកាម ទើបស្តេច ទ្រង់យាងបួសជាតាបស ឲ្យធ្វើបណ្ណសាលាត្រង់ភូមិប្រទេសមួយ

ដែលគួរមនោរម្យ ផ្នែកខាងក្រោមទន្លេគង្គា ប្រថាប់នៅញុាំងអត្ត-
ភាព ឲ្យប្រព្រឹត្តទៅដោយឧញ្ឆាចរិយាវត្ត (ត្រាច់កិក្ខាចិញ្ចឹមជីវិត) ។
ថ្ងៃមួយ ផ្លែស្វាយទុំប្រមាណប៉ុនឆ្នាំង ធ្លាក់មកអំពីសួនអម្ពវ័ននោះ
អណ្តែតមកតាមក្រសែទឹកទន្លេគង្គា មកដល់ត្រង់កំពង់ទឹកដែលជា
ទីប្រើប្រាស់របស់តាបសនោះ ។ តាបសកំពុងតែលុបលាងមុខមាត់
ក្រឡេកឃើញ ផ្លែស្វាយទុំនោះអណ្តែតមកត្រង់កណ្តាលទឹក ទើបចុះ
ទឹកហែលទៅយកមក នាំទៅកាន់អាស្រមបទទុកក្នុងរោងបូជាភ្លើង
ហើយចិតដោយកាំបិតបានល្មមដល់ការចិញ្ចឹមជីវិត ចំណែកដែល
សល់យកស្ងួតចេកគ្របទុក តមកក៏ឆាន់ផ្លែស្វាយនោះរាល់ៗ ថ្ងៃ
រហូតអស់ ។ កាលផ្លែស្វាយនោះអស់ហើយ ក៏មិនប្រាថ្នាឆាន់ផ្លែ
ឈើដទៃៗ ព្រោះជាប់នឹងរស ទើបតាំងចិត្តថា “យើងនឹងឆាន់តែ
ផ្លែស្វាយទុំប្រភេទនោះប៉ុណ្ណោះ” ទើបទៅអង្គុយចាំមើលនៅត្រង់មាត់
ទន្លេ សម្រេចចិត្តថា “បើមិនបានផ្លែស្វាយទុំ នឹងមិនក្រោកឡើង”

ហើយអង្គុយវង់ចាំនៅក្នុងទីនោះ ៗ តាបសនោះមិនព្រមឆាន់ ទ្រាំអង្គុយវង់ចាំមើលផ្លែស្វាយនៅត្រង់មាត់ទឹកនោះអស់ ១ ថ្ងៃ ២ ថ្ងៃ ៣ ថ្ងៃ ៤ ថ្ងៃ ៥ ថ្ងៃ ដល់ ៦ ថ្ងៃ រហូតដល់រាងកាយស្ងួតស្គាំង ព្រោះខ្យល់ និងកំដៅថ្ងៃ ។

លុះដល់ថ្ងៃទី ៧ នាងទេពធីតាមួយអង្គអ្នករក្សាទន្លេ ពិចារណាមើលដឹងហេតុនោះ ទើបគិតថា "តាបសនេះជាអ្នកធ្លាក់នៅក្នុងអំណាចនៃសេចក្តីប្រាថ្នា ស៊ូអត់អាហារដល់ ៧ ថ្ងៃ មកអង្គុយចាំមើលត្រង់ទន្លេគង្គា ការដែលយើងមិនប្រគេនស្វាយទុំដល់តាបសនេះ មិនសមគួរឡើយ កាលតាបសនេះមិនបានផ្លែស្វាយទុំប្រាកដជាមរណៈ យើងនឹងប្រគេនដល់លោក" ទើបមកឈរក្នុងអាកាសលើទន្លេគង្គា កាលនឹងសន្ទនាជាមួយតាបស ទើបពោលគាថាទី ១ ថា

[៤១៤] កឹឆន្ទោ កិមធិប្បាយោ ឯកោ សម្មសិ ឃម្មនិ

កឹ បត្ថយានោ កឹ ឯសំ កេន អត្ថេន ព្រាហ្មណ ។

ព្រាហ្មណ៍ លោកមានសេចក្តីពេញចិត្តអ្វី បំណងអ្វី ប្រាថ្នាអ្វី ស្វែងរកអ្វី ទើបមកអង្គុយតែម្នាក់ឯងក្នុងរដូវក្តៅ ព្រោះត្រូវការអ្វី លោកទើបមកអង្គុយមើលទន្លេ ។

បណ្តាបទទាំងនោះ បទថា ឆន្ទោ "ពេញចិត្ត" គឺ អធ្យាស្រ័យ ។ បទថា អធិប្បាយោ[១] "បំណង" បានដល់ ការគិត ។ បទថា សម្មសិ "ប្រាថ្នា" សេចក្តីថា លោកប្រាថ្នា (អ្វី) ។ បទថា ឃម្មនិ "ក្នុងរដូវក្តៅ" បានដល់ ក្នុងរដូវក្តៅ ។ បទថា ឯសំ "ស្វែងរក" បានដល់ ស្វែងរក ។

ទេពធីតាហៅតាបសនោះថា "ព្រាហ្មណ៍" ព្រោះបួសហើយ ។ លោកអធិប្បាយទុកថា "ព្រាហ្មណ៍ លោកបំណងអ្វី គិតដល់អ្វី ប្រាថ្នាអ្វី ស្វែងរកអ្វី ព្រោះត្រូវការអ្វី លោកទើបមកអង្គុយមើល

---

១.បិដក. កិមធិប្បាយោ ។

ទឹកនៅត្រង់មាត់ទន្លេគង្គានេះ” ។

ព្រះតាបសបានស្តាប់ដូច្នោះ ទើបពោល ១០ គាថាថា

[៤១៥] យថា មហា វារិធរោ   កុម្ភោ សុបរិណាហវា
តថូបមំ អម្ពបក្កំ   វណ្ណគន្ធរសុត្តមំ ។
តំ វុយ្ហមានំ សោតេន   ទិស្វានាមលមជ្ឈិមេ
បាណីភិ នំ គហេត្វាន   អគ្យាយតនមាហរឹ ។
តតោ កទលិបត្តេសុ   និក្ខិបិត្វា សយំ អហំ
សត្ថេន នំ វិកប្បេត្វា   ខុប្បិបាសំ អហាសិ មេ ។
សោហំ អបេតទរថោ   ព្យន្តីភូតោ ទុក្ខក្ខមោ
អស្សាទំ នាធិគច្ឆាមិ   ផលេស្វញ្ញេសុ កេសុចិ ។
សោសិត្វា នូន មរណំ   តំ មមំ អាវហិស្សតិ
អម្ពំ យស្ស ផលំ សាទុំ   មធុរគ្គំ មនោរមំ ។
យមុទ្ធរឹ វុយ្ហមានំ   ឧទធិស្មា មហណ្ណវេ

អក្ខាតំ តេ មយា សព្វំ    យស្មា ឧបវសាមហំ ។
វម្មំ    បដិនិសិន្នោស្មិ    បុថុលោមាយុតា បុថុ
តញ្ច[១] ខោ មេវ អក្ខាហិ    អត្តានមបលាយិនី ។
កា វា ត្វមសិ កល្យាណី    កិស្ស វា ត្វំ សុមជ្ឈិមេ
រូបបដ្ដប្ចមដ្ឋីវ[២]    ព្យគ្ឃីវ គិរិសានុជា ។
យា សន្តិ នារិយោ ទេវេសុ    ទេវានំ បរិចារិកា
យា ច មនុស្សលោកស្មឹ    រូបេនន្វាគតិត្ថិយោ ។
រូបេន តេ សទិសី នត្ថិ    ទេវគន្ធព្វមានុសេ[៣]
បុដ្ឋាសិ មេ ចារុបុព្វង្គី    ព្រូហិ នាមញ្ច ពន្ធវេ[៤] ។

ក្អមទឹកធំមានរូបស្អាតយ៉ាងណា ផ្លែស្វាយទុំដែលមានពណ៌ មានក្លិន និងរសដ៏កំពូល ក៏មានឧបមេយ្យដូច្នោះ ។

---

១.ឱ. ត្វញ្ច ខោ, ម. ត្វំ ច ខោ ។ ២.ឱ. រូបបដ្ដបលិមដ្ឋីវ, ម. រូបបដ្ដបមដ្ឋីវ ។ ៣.ឱ.ម. ទេវេសុ គន្ធព្វមនុស្សលោកេ ។ ៤.ឱ.ម. អក្ខាហិ មេ នាមញ្ច ពន្ធវេ ច ។

យើងបានឃើញផ្លែស្វាយនោះ ដែលក្រសែទឹកបន្សាត់នាំមក កណ្ដាលខ្សែទឹកថ្លា ទើបបានចាប់យកមកទុកក្នុងរោងបូជាភ្លើង ។

តពីនោះក៏ដាក់ទុកលើស្លឹកចេក ធ្វើវិកប្ប (ចិត) ដោយកាំបិតហើយក៏ឆាន់ សេចក្ដីស្រេកឃ្លានរបស់យើងក៏បាត់ទៅ ។

យើងនោះអស់សេចក្ដីខ្វល់ខ្វាយចិត្ត លុះស្វាយនោះអស់ យើងត្រូវអត់ទ្រាំដល់សេចក្ដីទុក្ខ ព្រោះមិនបានប្រសព្វសេចក្ដីពេញចិត្តក្នុងផ្លែឈើប្រភេទដទៃណាមួយឡើយ ។

ផ្លែស្វាយណាកើតមានដល់ខ្ញុំ ផ្លែស្វាយនោះមានរសឆ្ងាញ់ដ៏លើសជាទីរីករាយនៃចិត្ត គង់នឹងនាំសេចក្ដីស្លាប់មកដល់ខ្ញុំដោយពិត ព្រោះស្គមស្គាំងបន្ទាប់ពីអត់អាហារ ។

ខ្ញុំរក្សាផ្លែស្វាយទុំ ដែលអណ្ដែតមកតាមទឹកក្នុងអន្លង់ដ៏ធំបាន ខ្ញុំយល់ថា ផ្លែស្វាយទុំនោះ គង់នឹងនាំសេចក្ដីស្លាប់មក

ដល់ខ្ញុំ ខ្ញុំត្រូវមកអន្ទុយនៅទីនេះព្រោះហេតុណា ហេតុទាំងអស់នោះខ្ញុំប្រាប់នាងហើយ ។

ខ្ញុំអន្ទុយចាំហើយនៅត្រង់ទន្លេដែលគួររីករាយ ទន្លេនេះធំទូលាយ មានត្រីលោមាជាអាស្រ័យនៅ គួរតែនឹងមានសេចក្ដីសប្បាយ បពិត្រនាងដែលឈរនៅចំពោះមុខនៃយើងដែលមិនគេចទៅណា នាងចូរប្រាប់សេចក្ដីនោះដល់យើងចុះ ។

ម្នាលនាងអ្នកមានរូបកាយដ៏សមសួនស្អាត នាងមានរូបរាងដ៏ល្អ ដូចជាតម្បារមាសទាំងផែន ឬដូចជាមេខ្លាដែលសញ្ចរទៅតាមញកភ្នំ នាងជានរណា ឬថា នាងមកទីនេះដើម្បីអ្វី ។

ទេពនារីទាំងឡាយក្នុងលោក ដែលជាបរិចារិកានៃទេវតាក្នុងឆកាមាវចរសួគ៌ពួកណា ឬស្ត្រីមានរូបរាងស្អាតក្នុងមនុស្សលោកណា ទេពនារី និងស្ត្រីទាំងឡាយនោះ ក្នុងពួកទេវតាគន្ធព្វ និងមនុស្សមិនមានស្មើដូចនាងដោយរូប ម្នាលនាងអ្នក

មានត្រគាកដ៏ស្អាតប្រដូចមាស យើងសួរនាងហើយ សូមចូរ
ប្រាប់ឈ្មោះ និងផៅពង្សចុះ ។

បណ្ដាបទទាំងនោះ បទថា **វារិធរេ កុម្ភោ** “ក្អមទឹកធំ” គឺក្អមទឹក ។ បទថា **សុបរិណាហវា** “មានទ្រង់ទ្រាយល្អ” បានដល់មានទ្រង់ទ្រាយស្អាត ។ បទថា **វណ្ណគន្ធរសុត្តមំ** “ដែលមានពណ៌ក្លិន និងរសដ៏ឧត្តម” សេចក្ដីថា ឧត្តមដោយពណ៌ ក្លិន និងរសទាំងឡាយ ។ បទថា **ទិស្វាន** ស្មើនឹង **ទិស្វា** ប្រែថា ឃើញហើយ ។ បទថា **អមលមជ្ឈិមេ** “ត្រង់កណ្ដាលខ្សែទឹកថ្លា” បានដល់ កណ្ដាលខ្សែទឹកដែលប្រាសចាកមន្ទិល ។ តាបសកាលនឹងសន្ទនាប្រាស្រ័យជាមួយទេវតា ទើបពោលយ៉ាងនេះ ។ បទថា **បាណិភិ**[១] “ចាប់យក” សេចក្ដីថា ដោយដៃទាំងពីរ ។ បទថា **អគ្យាយតនមាហរី** “មកទុកក្នុងរោងបូជាភ្លើង” សេចក្ដីថា បាននាំមកកាន់រោងពិធីបូជាភ្លើងរបស់ខ្លួន ។ បទថា **វិកប្បេត្វា** “វិកប្ប” បានដល់ កាត់ហើយ ។

---

១.បិដក. បាណីភិ ។

បាឋៈថា **វិកន្តេត្វា** ដូច្នេះក៏មាន ។ នៅមានបាឋៈដ៏សេសមួយបទ គឺ បទថា **ខាទី** ។

បទថា **អហាសិ មេ** “របស់យើងក៏បាត់ទៅ” សេចក្តីថា គ្រាខ្ញុំដាក់ស្វាយចុះត្រង់ចុងអណ្តាតប៉ុណ្ណោះ រសស្វាយទុំនោះក៏ផ្សាយទៅគ្រប់សរសៃទទួលរសទាំង ៧.០០០ ធ្វើឲ្យបាត់នូវសេចក្តីស្រេកឃ្លានរបស់ខ្ញុំបាន ។ បទថា **អបេតទរថោ** “**អស់សេចក្តីខ្វល់ខ្វាយ**” សេចក្តីថា មានសេចក្តីខ្វល់ខ្វាយផ្លូវកាយ និងផ្លូវចិត្តប្រាសទៅហើយ ព្រោះថា ផ្លែស្វាយទុំនោះកម្ចាត់សេចក្តីខ្វល់ខ្វាយរបស់ខ្ញុំបាន ដូចបរិភោគអ្វីដែលមានរសល្អ ។ បទថា **ព្យន្តីកូតោ** “**វេលាផ្លែស្វាយអស់**” សេចក្តីថា ផ្លែស្វាយនោះបានអស់ទៅ ។ អធិប្បាយថា ជាអ្នកមានផ្លែស្វាយទុំអស់ទៅហើយ ។

បទថា **ទុក្ខក្ខមោ** “**អត់ទ្រាំដល់សេចក្តីទុក្ខ**” សេចក្តីថា ប្រកបទៅដោយសេចក្តីទុក្ខដែលមិនគួររីករាយ គឺ ដោយសេចក្តីលំបាក

កាយ និងលំបាកចិត្ត ។ តាបសសម្ដែងក្នុងន័យថា ក៏ព្រោះខ្ញុំមិនដល់នូវសេចក្ដីត្រេកអរស្ទួម្បីតិចតួចក្នុងផ្លែចេក និងផ្លែខ្នុរ ជាដើមយ៉ាងដទៃ ផ្លែចេកផ្លែខ្នុរទាំងអស់នោះ ពេលខ្ញុំដាក់ប៉ះអណ្ដាត ក៏សម្រេចនូវការផ្អែតមួយរំពេច (គឺ មិនប្រាថ្នានឹងស៊ី)” ។ បទថា **សោសិត្វា “ព្រោះស្គមស្គាំង”** សេចក្ដីថា ព្រោះស្គមបន្ទាប់អំពីការអត់អាហារ ។ បទថា **តំ មមំ “នោះ... ដល់ខ្ញុំ”** សេចក្ដីថា ផ្លែស្វាយទុំនោះ (គង់នឹងនាំសេចក្ដីស្លាប់) មកដល់ខ្ញុំ ។ បទថា **យស្ស “ណា”** សេចក្ដីថា ផ្លែស្វាយណាគប្បីមាន គឺ ផ្លែស្វាយរមែងមាន ។ លោកអធិប្បាយថា “ផ្លែស្វាយណា បានញ៉ាំងប្រយោជន៍ឲ្យសម្រេចដល់ខ្ញុំ” បទថា **វុយ្ហមានំ “ដែលអណ្ដែតមក”** សេចក្ដីថា កំពុងអណ្ដែតមកក្នុងអន្លង់ទឹក ពោលគឺ ជារទឹកដែលមានក្រសែដ៏ជ្រៅនិងធំ ។ អធិប្បាយថា “ខ្ញុំកាន់យកផ្លែស្វាយទុំឡើងអំពីទន្លេនោះ ខ្ញុំយល់ថា ផ្លែស្វាយទុំនោះគង់នឹងនាំសេចក្ដីស្លាប់មកឲ្យខ្ញុំ ព្រោះ

កាលខ្ញុំមិនបានផ្ទៃស្វាយទុំនោះ ជីវិតគង់នឹងប្រព្រឹត្តទៅមិនបាន" ។ បទថា **ឧបវសាមិ**[១] **"អន្ទុយនៅ"** សេចក្តីថា ខ្ញុំត្រូវសេចក្តីស្រេកឃ្លានបៀតបៀនហើយ ទើបត្រូវនៅក្នុងទីនេះ ។ បទថា **រម្មំ បដិនិសិន្នាស្មិ "អន្ទុយនៅចាំត្រង់ទន្លេដែលគួររីករាយ"** សេចក្តីថា ខ្ញុំអន្ទុយនៅចាំត្រង់ទន្លេដែលគួរមនោរម្យ ។ បទថា **បុថុលោមាយុតា បុថូ**[២] **"ទន្លេនេះធំទូលាយមានត្រីលោមាធំអាស្រ័យនៅ"** សេចក្តីថា ទន្លេនេះធំទូលាយណាស់ ដែលត្រីលោមាធំអាស្រ័យនៅ ។ អធិប្បាយថា ស្ថានទីដូច្នេះគួរជាស្ថានទីដែលមានសេចក្តីសុខដល់ខ្ញុំ ។

បទថា **អបលាយិនី "អ្នកមិនរត់ទៅ"** បានដល់ មិនគេចទៅ ។ តាបសហៅទេពធីតានោះថា **មម សម្មុខា ឋិតេ (ម្នាលនាងដែលឈរនៅចំពោះមុខនៃយើង"** ។ បាឋៈថា **អបលាមិនី** ដូច្នេះក៏មាន ។ អធិប្បាយថា មានសរីរៈរាងកាយរកតិះដៀលមិនបាន ដូចជាមាស

---

១.បិដក. ឧបវសាមហំ ។ ២. បុថុលោមាយុតា បុថុ ។

ដែលដេញមន្ទិលជាទោសចេញហើយ ។ បទថា **កិស្ស វា** “ឬថា... **ដើម្បីអ្វី**” សេចក្ដីថា តាបសសួរថា “ឬនាងមកក្នុងទីនេះព្រោះហេតុ អ្វី?” ។ បទថា **រូបបដ្ដប្ចមត្តីវ**[(១)] “**អ្នកមានរូបដ៏ស្អាតដូចជាផ្ទាំងតម្បារ មាស**” សេចក្ដីថា មានរូបរាងក្លីរលោងដូចតម្បារមាស ។ បទថា **ព្យគ្ឃីវ** “**ដូចខ្លាញី**” សេចក្ដីថា ដូចស្ដេចខ្លាជំទង់ស្អាតមានដំណើរ កែក្រាយ[(២)] ។ បទថា **ទេវានំ** “**នៃពួកទេវតា**” បានដល់ ទេវតា ជាន់កាមាវចរសួគ៌ទាំង ៦ ជាន់ ។ បទថា **យា ច មនុស្សលោកស្មឹ** “**ឬក្នុងមនុស្សលោកពួកណា**” សេចក្ដីថា ឬស្ត្រីក្នុងមនុស្សលោក ពួកណា ។ បទថា **រូបេនន្វាគតិត្ថិយោ** “**ស្ត្រីមានរូបស្អាត**” បាន ដល់ ស្ត្រីដែលសម្បូរដោយរូបសម្បត្តិ ។

បទថា **នត្ថិ** “**មិនមាន**” សេចក្ដីថា ព្រោះដែលខ្លួនបំណងនឹង សរសើរទេពធីតា តាបសទើបពោលយ៉ាងនេះ ។ ក៏តាបសនោះ

---

១.បិដក. រូបបដ្ដប្ចមដ្ឋីវ ។ ២. សេចក្ដីនេះដូចមិនស៊ីគ្នានឹងបាលី (អ្នកប្រែ) ។

មានបំណងថា (ទេពនារី និងស្ត្រីទាំងឡាយនោះ) មិនមានអ្នកស្មើ ដូចនាងដោយរូប ។ បទថា **គន្ធព្វមានុសេ**[១] “គន្ធព្វ និងមនុស្ស” សេចក្ដីថា ក្នុងពួកគន្ធព្វ និងមនុស្សលោក ដែលអាស្រ័យក្លិនក្រអូប អំពីឫសជាដើមប្រោះព្រំ ។ បទថា **ចារុបុព្វង្គី** “ម្នាលនាងអ្នកមាន ត្រគាកល្អដូចជាមាស” សេចក្ដីថា អ្នកប្រកបដោយអវយវៈដើម ភ្លៅស្អាតដូចមាស ។ បទថា **នាមញ្ច ពន្ធវេ** “ឈ្មោះ និងផៅពង្ស” សេចក្ដីថា តាបសពោលថា “នាងចូរប្រាប់ នាមគោត្រ និងផៅពង្ស របស់ខ្លួនដល់ខ្ញុំចុះ” ។

លំដាប់នោះ ទេពធីតាបានពោល ៨ គាថាថា

[៤១៦] **យំ ត្វំ បដិនិសិន្នាសិ  រម្មំ ព្រាហ្មណ កោសិ កី**
**សាហំ កុសាលយា វុត្ថា  វរវារិវហោឃសា ។**
**នានាទុមគណាកិណ្ណា  ពហុកា គិរិកន្ទរា**

១.បិដក. ទេវគន្ធព្វមានុសេ ។

មមេវ បមុខា ហោន្តិ អភិសន្ទន្តិ បាវុសេ ។
អថោ ពហូ វនតោទា នីលវារិវហិន្ធរា
ពហុកា នាគចិត្តោទា[១] អភិសន្ទន្តិ វារិនា ។
តា អម្ពជម្ពុលពុជា និបាតាលមុទុម្ពរា[២]
ពហូនិ ផលជាតានិ អាវហន្តិ អភិណ្ហសោ ។
យង្កិញ្ចិ ឧភតោ តីរេ ផលំ បតតិ អម្ពុនិ
អសំសយន្តំ សោតស្ស ផលំ ហោតិ វសានុគំ ។
ឯតទញ្ញាយ មេធាវី បុថុបញ្ញ សុណោហិ មេ
មា រោចយ អភិសង្គំ[៣] បដិសេធ ជនាធិប ។
ន វាហំ វឌ្ឍវំ មញ្ញេ យំ ត្វំ រដ្ឋាភិវឌ្ឍន
អាចេយ្យមានោ រាជិសិ មរណំ អភិកង្ខសិ ។
តស្ស ជានន្តិ បិតរោ គន្ធព្វា សទេវកា
យេ ចាបិ ឥសយោ លោកេ សញ្ញតត្តា តបស្សិនោ

---

អដ្ឋ.បាលី និងឆដ្ឋ. ១. នាគវិត្តោទា, ២.នីបា តាលា ចុទុម្ពរា, ៣. មភិសង្គំ ។

អសំសយន្តេបិ ជានន្តិ បជ្ជកូតា យសស្សិនោ ។

ព្រាហ្មណ៍តាបស លោកអង្គុយចាំត្រង់ទន្លេកោសិកិគង្គា ដែលគួរមនោរម្យ កោសិកិគង្គានោះមានខ្សែទឹកខៀវជាអន្លង់ ទឹកជំ ខ្ញុំស្ថិតនៅក្នុងវិមានដែលតាំងនៅត្រង់ទន្លេនោះ ។

មានជង្ងជ្រោះ និងជង្ងស្ទឹង ហូរមកអំពីភ្នំច្រើនកន្លែង ដេ-រជាសទៅដោយពពួកឈើច្រើនប្រភេទ រមែងហូរមករួមត្រង់ ទីនៅរបស់ខ្ញុំ ។

មិនតែប៉ុណ្ណោះ នៅមានទឹកដែលហូរមកអំពីព្រៃ មានខ្សែ ទឹកពណ៌ខៀវហូរមកច្រើនទៀត និងទឹកដែលពួកនាគធ្វើឲ្យមាន ពណ៌វិចិត្រផ្សេងៗ រមែងហូរមកតាមខ្សែទឹកនោះ ។

ស្ទឹងទាំងនោះរមែងហូរនាំយកផ្លែស្វាយ ផ្លែព្រីង ផ្លែខ្នុរ សម្ទ ផ្លែក្តម្ព ផ្លែត្នោត និងផ្លែល្វាជាច្រើនមករឿយៗ ។

ផ្លែឈើប្រភេទណាមួយត្រង់ប្រាំងទាំងសងខាងធ្លាក់ចុះក្នុង

ទឹកហើយ ផ្លែឈើនោះរមែងប្រព្រឹត្តទៅក្នុងអំណាចនៃក្រសែ ទឹករបស់ខ្ញុំ ដោយមិនត្រូវសង្ស័យ ។

លោកជាអ្នកប្រាជ្ញមានបញ្ញាច្រើន ដែលជាធំជាងនរជន លោកដឹងយ៉ាងនេះហើយចូរស្តាប់ខ្ញុំ លោកកុំពេញចិត្តជាប់ជំពាក់ដោយតណ្ហាយ៉ាងនេះឡើយ ចូរលះបង់គំនិតនេះចេញចុះ ។

ព្រះរាជឥសីអ្នកញ៉ាំងរដ្ឋឲ្យចម្រើន ខ្ញុំមិនយល់ថា លោកនឹងចម្រើនរុងរឿងទៅបានយ៉ាងណា កាលបើលោកនៅក្នុងវេលាចម្រើនវ័យ តែប្រាថ្នាសេចក្តីស្លាប់ទៅវិញ ។

ព្រហ្ម គន្ធព្វ ទេវតា និងឥសីទាំងឡាយក្នុងលោកនេះ ដែលសន្រ្ទួមខ្លួនហើយ មានតបៈ ផ្តើមតាំងសេចក្តីព្យាយាម អ្នកមានយស រមែងដឹងសេចក្តីដែលលោកធ្លាក់នៅក្នុងអំណាចនៃតណ្ហា ដោយមិនត្រូវសង្ស័យឡើយ ។

បណ្ដាបទទាំងនោះ បទថា **កោសិកី** **“ទន្លេកោសិកិគង្គា”** គឺ ព្រាហ្មណ៍តាបសអង្គុយចាំនៅត្រង់ច្រាំងទន្លេកោសិកិគង្គា ដែលជាទីមនោរម្យណា ។ បទថា **កូសាលយា វុត្ថា** **“ស្ថិតនៅក្នុងវិមានដែលតាំងនៅត្រង់ទន្លេនោះ”** សេចក្ដីថា ខ្ញុំអាស្រ័យនៅត្រង់ទន្លេនោះដែលមានក្រសែទឹកដ៏ខៀវ ជាអន្លង់ទឹកដ៏ធំ ។ អធិប្បាយថា ខ្ញុំស្ថិតនៅត្រង់វិមានដែលតាំងនៅត្រង់ទន្លេគង្គា ។ បទថា **វេរោរិវហោយរា**[1] **“មានក្រសែទឹកដ៏ខៀវជាអន្លង់ទឹកធំ”** សេចក្ដីថា មានទឹកហូរពណ៌ខៀវប្រកបដោយអន្លង់ទឹកធំ ។ បទថា **សម្មុខា**[2] **“មករួមគ្នា”** សេចក្ដីថា ទេវតាសម្ដែងថា “ត្រោះ និងស្ទឹងនៃភ្នំមានប្រការដូចពោលហើយ រមែងមានមុខព្រមគ្នាមកកាន់យើង យើងជាប្រធាននៃស្ទឹងទាំងឡាយនោះ” ។

បទថា **អភិសន្ទន្តិ** **“ហូរមក”** បានដល់ រមែងហូរទៅ អធិ-

---

១.ឋិដក. វេរោរិវហោយសា ។ ២. បមុខា ។

ប្បាយថា នទីធារទាំងឡាយហូរមកអំពីទីនោះៗ រមែងចូលទៅកាន់យើង គឺ ស្ទឹងកោសិកិគង្គាទាំងអស់ ។ បទថា **វនតោទា** **“ទឹកដែលហូរមកអំពីព្រៃ”** សេចក្ដីថា មិនមែនតែអំពីជ្រោះ ស្ទឹង ភ្នំប៉ុណ្ណោះទេ ដែលពិត ទឹកក្នុងព្រៃក៏ហូរមកអំពីព្រៃ គឺ ទឹកដែលហូរមកអំពីព្រៃនោះយ៉ាងច្រើន រមែងហូរមក ។ បទថា **នីលវារិវហិន្ទរា** **“ក្រសែទឹកមានពណ៌ខៀវ”** សេចក្ដីថា ឧបត្ថម្ភដល់អន្ទង់ទឹក ពោលគឺ ក្រសែទឹកប្រកបដោយទឹកមានពណ៌ខៀវដូចកែវមណី ។ បទថា **នាគចិត្តោទា** **“ទឹកដែលពួកនាគធ្វើឲ្យមានពណ៌ដ៏វិចិត្រ”** គឺ ទឹកដែលប្រកបដោយទឹក ពោលគឺ ដែលនាគទាំងឡាយធ្វើឲ្យវិចិត្រ ក្ដី ។ បទថា **ផវារិនា**[១] **“តាមក្រសែទឹក”** សេចក្ដីថា នាងទេពធីតាសម្ដែងថា “ដែលពិត ស្ទឹងទាំងឡាយដ៏ច្រើនបែបនេះ រមែងហូរទៅតាមក្រសែទឹក គឺ ញុំាងយើងឲ្យពេញបរិបូណ៌ដោយទឹកតែម្យ៉ាង” ។

---

១.បិដក. ភារិនា ។

បទថា **តា** "**ទាំងនោះ**" បានដល់ ស្ទឹងទាំងឡាយនោះ ។ បទថា **អាវហន្តិ** "**រមែងហូរនាំ**" សេចក្តីថា ស្ទឹងទាំងឡាយនោះរមែងហូរនាំផ្លែស្វាយជាដើមទាំងនោះមក ។ ក៏ពាក្យទាំងឡាយនេះជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃទុតិយាវិភត្តិ ។ម្យ៉ាងទៀត បទថា **តា** ជាទុតិយាវិភត្តិ ពហុវចនៈ ។

បទថា **អាវហន្តិ** "**រមែងហូរនាំ**" សេចក្តីថា ស្ទឹងទាំងនោះរមែងហូរនាំផ្លែស្វាយជាដើមទាំងនេះមក ។ អធិប្បាយថា និងផ្លែស្វាយជាដើមដែលត្រូវហូរនាំទៅយ៉ាងនេះ រមែងចូលទៅកាន់ក្រសែរបស់យើង ។ បទថា **សោតស្ស** "**នៃក្រសែ**" សេចក្តីថា ផ្លែឈើប្រភេទណាមួយជ្រុះចាកដើមឈើ ដែលដុះត្រង់មាត់ច្រាំងទាំងសងខាង ក៏អណ្តែតទៅតាមទឹក ផ្លែឈើទាំងអស់នោះជាការចូលដល់អំណាចនៃក្រសែទឹករបស់យើងតែម្យ៉ាង ដោយមិនត្រូវមានសេចក្តីសង្ស័យក្នុងរឿងនេះ ។ ទេពធីតានោះប្រាប់ហេតុដែលផ្លែស្វាយទុំ

នោះអណ្ដែតមកតាមក្រសែទឹកយ៉ាងនេះ ។ បទទាំងពីរ គឺ **មេធាវី** **បុថុបញ្ញា**[១] “លោកជាអ្នកប្រាជ្ញមានបញ្ញាច្រើន” ជាអាលបនៈ (ជាពាក្យហៅ) នោះឯង ។ បទថា **មា រោចយ** “**កុំពេញចិត្ត**” សេចក្ដីថា លោកកុំពេញចិត្តនឹងសេចក្ដីជាប់ជំពាក់ដោយតណ្ហាយ៉ាងនេះឡើយ ។ បទថា **បដិសេធ** “**ចូរឈប់គិត**” បានដល់ ចូរហាមចុះ ។ បទថា **តំ**[២] “**នោះ**” សេចក្ដីថា នាងទេពធីតាពោលទូន្មានព្រះរាជា ។ បទថា **វុទ្ធិំ**[៣] “**ចម្រើនរុងរឿង**” បានដល់ សេចក្ដីចម្រើនដោយបញ្ញា គឺ ភាពជាបណ្ឌិត ។ បទថា **រដ្ឋាភិវឌ្ឍន** “**អ្នកញ៉ាំងរដ្ឋឲ្យចម្រើន**” គឺ លោកជារាជឥសីញ៉ាំងនូវរដ្ឋមណ្ឌលឲ្យចម្រើន ។ បទថា **អាចយមានោ**[៤] “**នៅក្នុងវយៈចម្រើនវ័យ**” សេចក្ដីថា លោកចូរញ៉ាំងអត្តភាព គឺ ចម្រើនដោយសាច់ និងឈាម ជាកំលោះវិញចុះ ។ នាងទេពធីតាហៅតាបសនោះថា **រាជិសិ** “**ព្រះរាជឥសី**”

---

១.បិដក. បុថុបញ្ញ ។ ២. រកមិនឃើញ ។ ៣. វឌ្ឍិំ ។ ៤. អាចេយ្យមានោ ។

លោកអធិប្បាយទុកថា "លោកនៅកំលោះ តែស្គមស្គាំងព្រោះអត់អាហារ សន្សឹមនឹងបាននូវសេចក្តីស្លាប់ព្រោះលោកៈក្នុងផ្ទៃស្វាយ យើងមិនសម្គាល់ភាពជាបណ្ឌិតដូច្នេះរបស់លោកឡើយ" ។ បទថា **តស្ស** "នោះ" សេចក្តីថា បុគ្គលណាជាអ្នកធ្លាក់នៅក្នុងអំណាចនៃតណ្ហា រមែងដឹងបុគ្គលនោះជាអ្នកធ្លាក់នៅក្នុងអំណាចតណ្ហាដោយមិនបាច់សង្ស័យ ។

កាលទេពធីតា ឲ្យតាបសនោះកើតសេចក្តីសង្វេគទើបពោលយ៉ាងនេះថា "ព្រហ្មដែលដល់នូវការរាប់ថាជាបិតា គន្ធព្វព្រមទាំងកាមាវចរទេវតា និងឥសីអ្នកមានចក្ខុទិព្វដូចដែលពោលមកហើយ រមែងដឹងសេចក្តីបុគ្គលនោះជាអ្នកធ្លាក់នៅក្នុងអំណាចតណ្ហា ដោយមិនបាច់សង្ស័យ តែប្រការដែលលោកអ្នកមានឫទ្ធិទាំងនោះដឹងថា តាបសឈ្មោះឯណោះ ជាអ្នកធ្លាក់នៅក្នុងអំណាចរបស់តណ្ហា" មិនគួរអស្ចារ្យ សូម្បីបរិចារិកជនរបស់ឥសីអ្នកផ្តើមតាំងសេចក្តីព្យាយាម

អ្នកមានយសទាំងនោះក៏ទឹងជឹង ព្រោះស្តាប់ពាក្យរបស់ជនទាំងនោះនិយាយគ្នា ព្រោះដែលឈ្មោះថា សេចក្តីលាក់បាំងរបស់បុគ្គលអ្នកធ្វើអាក្រក់រមែងមិនមាន ។

លំដាប់នោះ តាបសបានពោល ៤ គាថាថា

[៤១៧] ឯវំ វិទិត្វា វិទូ សព្វធម្មំ
វិទ្ធំសនំ ចវនំ ជីវិតស្ស
ន ចីយតី តស្ស នរស្ស បាបំ
សចេ ន ចេតេតិ វធាយ តស្ស ។

ឥសិបូគសមញ្ញាតេ ឯវំ លោក្យា វិទិតា បតិ[1]
អនរិយំ បរិសម្ភាសេ បាបកម្មំ ជិគីសសិ ។

សចេ អហំ មរិស្សាមិ តីរេ តេ បុប្ផុស្សោណិ
អសំសយន្តំ អសិលោកោ មយិ មតេ អាគមិស្សតិ ។

១.ឱ. សតិ ។

តស្មា ហិ បាបកំ កម្មំ រក្ខស្សុ[1] ច សុមជ្ឈិមេ

មា តំ[2] សព្ពោ ជនោ បច្ឆា បក្កុដ្ឋាសិ[3] មយិ មតេ ។

បាបរមែងមិនចម្រើនដល់នរជនអ្នកដឹងធម៌ទាំងពួង ដឹងសេចក្ដីបែកធ្លាយ និងការចុតិនៃជីវិត បើនរៈនោះមិនគិតចង់នឹងសម្លាប់បុគ្គលដទៃ ។

នាងដែលពួកឥសីដឹងទូទៅហើយ នាងជាអ្នកដែលជនអ្នកបណ្ឌិតបាបដឹងច្បាស់ហើយថា ជាអ្នកចម្រើនដល់លោក តែក៏ប្រាថ្នាបាបកម្មដល់ខ្លួន ព្រោះប្រើពាក្យចរចាដែលមិនប្រសើរ ។

នាងដែលត្រគាកស្រាយស្អាត បើយើងនឹងស្លាប់នៅត្រង់មាត់ច្រាំងស្ទឹងរបស់នាង កាលយើងស្លាប់ទៅ ការតិះដៀលក៏នឹងមានដល់នាងដោយមិនត្រូវសង្ស័យ ។

នាងអ្នកមានចង្កេះមូលក្លំ ព្រោះដូច្នោះឯង នាងចូររវាំង

---

១.ឱ.ម. រក្ខស្សេវ ។ ២.ឱ.ម. មា តំ ។ ៣.ឱ. បកុត្ថាសិ, ម. បកុដ្ឋាយិ ។

បាបកម្មចុះ កុំឲ្យមនុស្សទាំងពួងតិះដៀលនាងបានក្នុងកាលជា
ខាងក្រោយ ក្នុងវេលាយើងស្លាប់ទៅហើយ ។

បណ្តាបទទាំងនោះ បទថា **ឯវំ វិទិត្វា** “**ដឹងយ៉ាងនេះ**” គឺ ខ្ញុំដឹងនូវសីល និងសេចក្តីមិនទៀងយ៉ាងណា បាបរមែងមិនកពូន គឺ មិនចម្រើនដល់នរៈអ្នកដឹងហើយតាំងនៅយ៉ាងនោះ ។ បទថា **វិទូ** “**អ្នកប្រាជ្ញ**” បានដល់ អ្នកដឹងច្បាស់ ។ បទថា **សព្វធម្មំ** “**ធម៌ទាំងពួង**” បានដល់ សុចរិតធម៌គ្រប់យ៉ាង ។ ព្រោះក្នុងគាថានេះ សុចរិតធម៌ ៣ យ៉ាង បំណងយកជាសព្វធម្មៈ ។ បទថា **វិទ្ធំសនំ** “**ការបែកធ្លាយ**” បានដល់ ការរលត់ ។ បទថា **ចវនំ** “**ការចុតិ**” បានដល់ ចុតិ ។ បទថា **ជីវិតស្ស** “**នៃជីវិត**” បានដល់ អាយុ ។ លោកពោលអធិប្បាយទុកថា “បាបរមែងមិនកពូន គឺ មិនចម្រើនដល់នរៈជាបណ្ឌិត ដឹងច្បាស់ហើយតាំងនៅយ៉ាងនេះ គឺ ដឹងច្បាស់ដល់សុចរិតធម៌ទាំងពួង និងសេចក្តីមិនទៀងនៃជីវិត” ។

បទថា **សចេ ន ចេតេតិ វធាយ តស្ស** “ប្រសិនបើនរៈនោះមិនគិតតាំងចិត្តនឹងសម្លាប់បុគ្គលដទៃ” សេចក្តីថា ប្រសិនបើនរៈនោះមិនគិត គឺ មិនត្រិះរិះដើម្បីនឹងសម្លាប់បុគ្គលដទៃអ្នកដល់នូវសេចក្តីសុខ បានដល់ មិនញុំាងបុគ្គលដទៃ ឬសូម្បីទ្រព្យមតិករបស់គេឲ្យវិនាស ក៏ខ្ញុំមិនបានគិតដើម្បីនឹងសម្លាប់នរណាៗ អង្គុយចាំមើលទឹកស្ទឹង ធ្វើសេចក្តីក្នុងអាល័យក្នុងផ្ទៃស្វាយទុំតែម្យ៉ាង នាងពិចារណាឃើញនូវអកុសលកម្មអ្វីរបស់ខ្ញុំហ្ន៎ ។ បទថា **ឥសិបូគសមញ្ញាតេ** “អ្នកដែលពួកឥសីបានដឹងទូទៅហើយ” សេចក្តីថា អ្នកដែលពួកឥសីបានដឹងហើយដោយល្អ គឺ ដែលឥសីទាំងឡាយបានដឹងហើយ ។ បទថា **ឯវំ លោក្យា** “ជាអ្នកចម្រើនដល់លោកយ៉ាងនេះ” សេចក្តីថា នាងជាអ្នកដែលជនអ្នកបណ្តេតបាបដឹងទូទៅយ៉ាងនេះថា “ជាអ្នកចម្រើនដល់លោក” ។ បទថា **សតិ**[1] នេះ ជាអា-

---

១.បិដក. បតិ ។

លបន: ហៅថា ម្នាលនាងអ្នកមានរូបស្អាត ។ បទថា **អនរិយំ បរិសម្ភាសេ** “ប្រើពាក្យចរចាដែលមិនប្រសើរ” សេចក្តីថា ប្រកបទៅដោយពាក្យចរចាដែលមិនស្អាតជាដើមថា រំលើកដល់មាតាបិតារបស់គេ ។ បទថា **ជិគីសតិ**[១] “ប្រាថ្នា” សេចក្តីថា សូម្បីបើបាបក្នុងខ្លួនរបស់ខ្ញុំមិនមាន នាងក៏មកបរិភាសខ្ញុំដល់យ៉ាងនេះ ទាំងសម្តីងសេចក្តីស្អប់ចំពោះខ្ញុំ ឈ្មោះថា ស្វែងរកបាបកម្មធ្វើឲ្យកើតឡើងដល់ខ្លួន ។

បទថា **តីរេ តេ** “ត្រង់មាត់ច្រាំងទឹករបស់នាង” សេចក្តីថា ត្រង់មាត់ច្រាំងទឹករបស់នាង ។ បទថា **បុថុសុស្សោណិ** “ត្រគាកសាយ” សេចក្តីថា ប្រកបទៅដោយត្រគាកសាយស្អាត ។ បទថា **បេតេ**[២] “ស្លាប់ទៅហើយ” សេចក្តីថា កាលខ្ញុំស្លាប់ទៅកាន់បរលោកហើយ ព្រោះមិនបានផ្ទៃស្វាយទុំ ។ បទថា **បក្ខក្ខាសិ** “តិះ-

---

១.បិដក. ជិគីសសិ ។ ២. មតេ ។

ដៀល" សេចក្តីថា ជនទាំងឡាយកុំពោលអាក្រក់ ជេរ តិះដៀល និន្ទា ។ បាឋៈថា បក្ខត្ថាសិ ដូច្នេះក៏មាន ។

នាងទេពធីតាបានស្តាប់ដូច្នោះ ទើបពោល ៥ គាថាថា

[៤១៨] អញ្ញាតមេតំ អវិសយ្ហសាហិ
អត្តានមម្ពញ្ច ទទាមិ តេ តំ
យោ ទុច្ចជេ កាមគុណេ បហាយ
សន្តិញ្ច ធម្មញ្ច អធិដ្ឋិតោសិ ។

យោ ហិត្វា បុព្វសញ្ញោគំ បច្ឆាសញ្ញោជនេ ឋិតោ
អធម្មញ្ចេវ ចរតិ បាបញ្ចស្ស បវឌ្ឍតិ ។

ឯហិ តំ បាបយិស្សាមិ កាមំ អប្បោស្សុកោ ភវ
ឧបានយាមិ សីតស្មឹ វិហរាហិ អនុស្សុកោ ។

តំ បុប្ផរសមត្តេហិ វគ្គុគ្គេហិ អរិន្ទម
កោញ្ចា មយូរា ទិវិយា កោយដ្ឋិមធុសាលិយា

កូជិតា ហំសបូគេហិ កោកិលេត្ថ បពោធរេ ។

អម្ពេត្ថ វិប្បសូនគ្គា[១] បលាលខលសន្និភា

កោសុម្ភសលឡទីបា[២] បក្កតាលវិលម្ពិនោ ។

ហេតុនោះខ្ញុំជ្រាបហើយ លោកចូរអត់ទ្រាំសិនចុះ ខ្ញុំនឹងព្រមឧទ្ទិសខ្លួន និងឲ្យផ្លែស្វាយដល់លោក ព្រោះលោកលះកាមគុណដែលលះបានលំបាក ហើយតាំងទុកនូវសន្តិ និងធម៌ ។

បុគ្គលណាលះសំយោជនៈ ដែលជាចំណែកខាងដើមបាន តែនៅជាប់ក្នុងសំយោជនៈ ដែលជាចំណែកខាងចុង ប្រព្រឹត្តអធម៌ បាបរមែងចម្រើនដល់បុគ្គលនោះ ។

មកចុះ ខ្ញុំនឹងនាំលោកទៅកាន់ចម្ការស្វាយ លោកចូរជាអ្នកមានសេចក្តីខ្វល់ខ្វាយតិចតែម្យ៉ាងចុះ ខ្ញុំនឹងនាំលោកទៅកាន់ចម្ការស្វាយដែលមូប់ត្រជាក់ លោកចូរជាអ្នកកុំខ្វល់ខ្វាយ

---

១.ម. វិប្បឌិនគ្គា ។ ២.ម. កោសម្ពសលឡានិម្ពា ។

ឡើយ ។

លោកដែលហាមសត្រូវ ចម្ការនោះប្រជុំច្រើនទៅដោយពួកបក្សី ដែលស្រវឹងហើយក្នុងរសនៃផ្កាឈើ មានសត្វក្រៀល សត្វក្ងោក សត្វលលក មានកក្កក់គួររីករាយ មានពួកហង្សស្រែកយំរងំ ហ្វូងតាវៅដែលយំជាសស់សត្វទាំងឡាយក្នុងចម្ការស្វាយនោះ ។

ផ្លែស្វាយក្នុងសួននោះធ្លាក់ជាចង្កោមៗ ដូចជាកណ្តាប់ស្រូវតាមចុងមែកសំយុងចុះមក មានទាំងដកគាំ ដើមស្រល់ ដើមកុម្ភ និងផ្កាយនៃផ្លែត្នោតទុំ ។

បណ្តាបទទាំងនោះ បទថា **អញ្ញាតមេតំ** “ហេតុនោះខ្ញុំបានជ្រាបហើយ” សេចក្តីថា ហេតុដែលលោកអាងថា “ការនិន្ទានឹងមានដល់លោក ក៏ពោលអាងទុកដើម្បីត្រូវការផ្លែស្វាយទុំនោះឯងខ្ញុំបានដឹងហើយ” ។ បទថា **អវិសយ្ហសាហិ** “ចូរអត់ទ្រាំ” សេចក្តី

ថា ដែលឈ្មោះថា ព្រះរាជាទាំងឡាយរមែងអត់ទ្រាំក្នុងវត្ថុដែលអត់-ទ្រាំបានលំបាក ព្រោះហេតុនោះ នាងទេពធីតាកាលប្រារព្ធដល់ហេតុនោះ ទើបពោលយ៉ាងនេះ ។ បទថា **អត្ថានំ** “**ខ្ញុំន**” សេចក្តីថា បើខ្ញុំបីលោកនាំទៅកាន់ព្រៃស្ងាយ ឈ្មោះថា រមែងថ្វាយខ្លួនដល់លោក និងនឹងថ្វាយផ្លែស្វាយទុំនោះដល់លោកផង ។ បទថា **កាមគុណោ** “**កាមគុណ**” បានដល់ វត្ថុកាមទាំងឡាយដែលប្រដាប់ហើយដោយកាញ្ចនមាលា និងស្វេតឆត្រ ។

បទថា **សន្តិញ្ច ធម្មញ្ច** “**នូវសន្តិ និងធម៌**” បានដល់ សីលពោលគឺ សន្តិ ដែលញុំាងការទ្រុស្តសីលឲ្យស្ងប់រម្ងាប់ និងសុចរិតធម៌ ។ បទថា **អធិដ្ឋិតោសិ** “**តាំងទុក**” សេចក្តីថា លោកជាអ្នកចូលដល់គុណធម៌ទាំងនេះ និងជាបុគ្គលដែលតាំងមាំនៅក្នុងគុណធម៌ទាំងនេះ ។ បទថា **បុព្វសំយោគំ**[១] “**សំយោជនៈជាចំណែកខាង**

---

១.បិដក. បុព្វសញ្ញោគំ ។

ដើម" បានដល់ ចំណង់ដែលមានក្នុងកាលមុន ។ បទថា បច្ឆា-សំយោជនេ[1] "តែនៅជាប់ក្នុងសំយោជនៈដែលជាចំណែកខាងចុង" បានដល់ ចំណង់ដែលមានក្នុងកាលជាខាងក្រោយ ។ លោកអធិប្បាយទុកថា "តាបសដ៏ចម្រើន បុគ្គលណាលះបង់សិរីរាជសម្បត្តិដ៏ធំក្រៃលែង ហើយមកជាប់ក្នុងរសតណ្ហាត្រឹមតែផ្លែស្វាយទុំ មិនគិតដល់ខ្យល់ និងកំដៅថ្ងៃ ទ្រាំអត្តយសុបសៅនៅត្រង់មាត់ស្ទឹង បុគ្គលនោះឆ្លងមហាសមុទ្របាន ក៏ដូចជាអ្នកលិចចុះក្នុងទីបំផុតប្រាំង ជនណាជាអ្នកធ្លាក់នៅក្នុងអំណាចរសតណ្ហា ប្រព្រឹត្តអធម៌តែម្យ៉ាង បាបដែលធ្វើដោយអំណាចនៃរសតណ្ហា រមែងបន្ថែមដល់ជននោះ" នាងទេពធីតានោះបានពោលតិះដៀលតាបសយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា កាមំ អបេ្បាស្សុកោ ភវ "ជាអ្នកមានសេចក្តីខ្វល់

---

១.បិដក. បច្ឆាសញ្ញោជនេ ។

**ខ្វាយតិចចុះ**" សេចក្ដីថា លោកត្រូវជាអ្នកមិនមានអាល័យនៅក្នុងផ្លែស្វាយទុំនោះចុះ ។ បទថា **តស្មឹ**(១) "**នោះ**" សេចក្ដីថា ខ្ញុំនឹងជាអ្នកនាំលោកទៅព្រៃស្វាយដ៏ត្រជាក់នោះ ។ បទថា **តំ** "**នោះ**" គឺកាលនាងទេពធីតាពោលយ៉ាងនេះហើយ ទើបបីតាបសផ្គោបទ្រូងហោះទៅក្នុងអាកាស ឃើញទិព្វអម្ពវ័នដែលមានបរិមណ្ឌលប្រមាណ ៣ យោជន៍ និងបានស្ដាប់សំឡេងសកុណបក្សី ហើយទើបប្រាប់ដល់តាបស ពោលយ៉ាងនេះថា **តំ** ជាដើម ។ បទថា **បុប្ផសមត្តេហិ** "**ស្រវឹងក្នុងរសផ្កាឈើ**" សេចក្ដីថា ស្រវឹងដោយរសនៃបុប្ផជាតិ ។

បទថា **វគ្គុវគ្គិ**(២) "**កក្ញក់**" សេចក្ដីថា ព្រៃអម្ពវ័ននោះ សម្បូរទៅដោយហ្វូងបក្សីទាំងឡាយដែលមានកក្ញក់ និងឥឡូវនេះ កាលនាងទេពធីតានឹងប្រាប់ឈ្មោះហ្វូងបក្សីទាំងនោះ ទើបពោលពាក្យ

---

១.បិដក. សីតស្មឹ ។ ២. វគ្គុវគ្គុហិ ។

មានជាអាទិថា **កោញ្ចា** "សត្វក្រៀល" ។ បណ្តាបទទាំងនោះ បទថា **ទិវិយា** ប្រែថា ដែលជាទិព្វ ។ បទថា **កោយដ្ឋិមធុសាលិយា** "កក្ងក់ដែលគួរស្រឡាញ់" សេចក្តីថា នាងទេពធីតាសម្តែងថា "ទិព្វសកុណបក្សីទាំងនេះ គឺ (សត្វក្រៀល ក្ងោក លលក និងសារិកាកែវ) ដែលមានកក្ងក់គួរស្រឡាញ់ រមែងមាននៅក្នុងព្រៃស្វាយនេះ ។ បទថា **កុជ្ជិតា ហំសបូគេភិ**[១] "ពួកហង្សស្រែកយំ" គឺ មានហ្វូងហង្សរងាវបន្លឺសំឡេងរងំ ។ បទថា **កោកិលេត្ថ បពោធរេ** "ហ្វូងសត្វតាវ៉ៅស្រែកដាស់សត្វទាំងឡាយនៅក្នុងព្រៃស្វាយនោះ" សេចក្តីថា សត្វតាវ៉ៅទាំងឡាយនៅក្នុងព្រៃស្វាយនោះ ធ្វើសំឡេងជាសញ្ញាដាស់នូវសត្វទាំងឡាយឲ្យក្រោកហើយ ។ បទថា **អម្ពេត្ថ** "ស្វាយក្នុងព្រៃនោះ" សេចក្តីថា មានដើមស្វាយនៅក្នុងព្រៃស្វាយនោះ ។ បទថា **វិប្បសូនគ្គា** "ធ្លាក់ជាចង្កោមៗ" សេចក្តីថា មាន

---

១.បិដក. កូជិតា ហំសបូគេភិ ។

ចុងមែកទោរទន់ចុះព្រោះធ្ងន់នឹងចង្កោមនៃផ្លែ ។ បទថា **បលាលខ-លសន្និភា** “ដូចកណ្ដាប់ស្រូវ” សេចក្ដីថា មានផ្លែដូចជាកណ្ដាប់ស្រូវសាលី ព្រោះសន្សំទៅដោយស្មែង និងផ្កា ។ បទថា **បក្កតាល-វិលម្ពិនោ** “ចុងមែកក៏ទោរទន់ចុះមក... និងផ្កាយផ្លែត្នោតទុំ” ន័យថា នាងទេពធីតាពណ៌នាដល់សួនអម្ពវ័នថា “មានផ្លែត្នោតទុំទាំងផ្កាយៗ និងដើមឈើបែបនេះ មាននៅក្នុងសួនអម្ពវ័ននេះ” ។

ក៏គ្រានាងទេពធីតាពណ៌នាហើយ នាំតាបសមកកាន់អម្ពវ័ន ហើយប្រាប់ថា “សូមលោកឆាន់ផ្លែស្វាយទាំងឡាយ ញុំាងសេចក្ដីពេញចិត្តរបស់ខ្លួនឲ្យពេញបរិបូណ៌ក្នុងសួនអម្ពវ័ននេះចុះ” ហើយចៀសចេញទៅ ។ គ្រាតាបសឆាន់ផ្លែស្វាយរហូតឆ្អែតតាមបំណងហើយ សម្រាកបន្តិច ទើបត្រាច់ទៅក្នុងសួនអម្ពវ័ននោះ បានឃើញប្រេតនោះកំពុងសោយទុក្ខ (តែ) មិនអាចនិយាយអ្វីបាន ។ លុះព្រះអាទិត្យអស្ដង្គតហើយ ឃើញប្រេតនោះមានស្រីអប្សរហែហម

បម្រើ សោយទិព្វសម្បត្តិវិញ ទើបពោល ៣ គាថាថា

[៤១៩] មាលី តិរីដិ កាយុរី អង្គទី ចន្ទនុស្សទោ
រត្តឹ តុំ បរិចារេសិ ទិវា វេទេសិ វេទនំ ។
សោឡសិត្ថីសហស្សានិ យា តេមា បរិចារិកា
ឯវំ មហានុភាវោសិ អព្ភុតោ លោមហំសនោ ។
កឹ កម្មមករិ បុព្វេ បាបំ អត្តទុខាវហំ
យំ ករិត្វា មនុស្សេសុ បិដ្ឋិមំសានិ ខាទសិ ។

លោកប្រដាប់នូវទិព្វមាលា សំពត់ជួតសីសៈ និងគ្រឿងអាភរណៈសុទ្ធតែជាទិព្វ មានកងមាសត្រង់ដើមដៃលាបដោយលម្អិតចន្ទន៍ ពេលយប់មានស្រី ១៦.០០០ នាក់ជាបរិវារបម្រើលោក តែពេលថ្ងៃត្រូវសោយទុក្ខវេទនា ។

ស្រីទាំងនេះបានជាបរិចារិការបស់លោក មានដល់មួយម៉ឺនប្រាំមួយពាន់នាក់ លោកមានអានុភាពច្រើនយ៉ាងនេះ មិនធ្លាប់

មានក្នុងមនុស្សលោក គួរឲ្យព្រឺរោម ។

ក្នុងកាលមុន លោកធ្វើបាបកម្មអ្វីទុក ទើបត្រូវនាំទុក្ខវេទនា មកឲ្យខ្លួន លោកធ្វើកម្មអ្វីទុកក្នុងមនុស្សលោក ទើបត្រូវទំពាស៊ីសាច់ខ្នងរបស់ខ្លួនឯងក្នុងពេលនេះ ។

បណ្ដាបទទាំងនោះ បទថា **មាលី** "ប្រដាប់ទិព្វមាលា" បានដល់ អ្នកទ្រទ្រង់មាលាទិព្វ ។ បទថា **តិរីដិ** "សំពត់ជួតសីសៈ" បានដល់ អ្នកប្រដាប់សំពត់ជួតដែលជាទិព្វ ។ បទថា **កាយុរី** "គ្រឿងអាភរណៈសុទ្ធតែជាទិព្វ" បានដល់ ប្រដាប់អាភរណៈដែលជាទិព្វ ។ បទថា **អង្គទី** "មានមាសត្រង់ដើមដៃ" សេចក្ដីថា ប្រកបដោយកងដៃ និងដើមដៃដែលជាទិព្វ ។ បទថា **ចន្ទនុស្សទោ** "លាបដោយលម្អិតខ្លឹមចន្ទន៍" សេចក្ដីថា មានរាងកាយលាបលនដោយខ្លឹមចន្ទន៍ដែលជាទិព្វ ។ បទថា **បរិចារេសិ** "បម្រើ" សេចក្ដីថា បម្រើនូវឥន្ទ្រិយដោយទិព្វសម្បត្តិ ។ បទថា **ទិវា** "ពេលថ្ងៃ"

សេចក្ដីថា តែក្នុងវេលាថ្ងៃលោកត្រូវសោយមហាទុក្ខវេទនា ។ បទថា **យា តេមា** កាត់បទជា **យា តេ ឥមា** (ប្រែថា ស្រីទាំងនោះ) ។ បទថា **អត្ថុតោ** **"មិនធ្លាប់មាន"** សេចក្ដីថា មិនធ្លាប់មានឡើយក្នុងមនុស្សលោក ។ បទថា **លោមហំសនោ** **"ធ្វើឲ្យព្រឺរោម"** សេចក្ដីថា ជនទាំងឡាយណាឃើញលោក រោមរបស់ជនទាំងនោះរមែងបះឡើង ។ បទថា **បុព្វេ** **"ក្នុងភពមុន"** បានដល់ ក្នុងភពមុន ។ បទថា **អត្តទុក្ខាវហំ** **"នាំទុក្ខវេទនាមកកាន់ខ្លួន"** សេចក្ដីថា ជាហេតុនាំទុក្ខវេទនាមកកាន់ខ្លួន ។ បទថា **មនុស្សេសុ** **"ក្នុងមនុស្សលោក"** សេចក្ដីថា តាបសសួរថា "លោកបានធ្វើកម្មអ្វីទុកក្នុងមនុស្សលោក ទើបត្រូវមកទំពាស៊ីសាច់ខ្នងរបស់ខ្លួន ក្នុងពេលនេះ?" ។

ប្រេតចាំតាបសបានទើបទូលថា "ព្រះអង្គគង់ចាំខ្ញុំព្រះអង្គមិនបាន ខ្ញុំព្រះអង្គ គឺ ជាបុរោហិតរបស់ព្រះអង្គ ខ្ញុំព្រះអង្គត្រូវសោយសុខក្នុងវេលាយប់នេះ ព្រោះផលនៃឧបោសថពាក់កណ្ដាលដែល

ខ្ញុំបានធ្វើមក ព្រោះអាស្រ័យព្រះអង្គ តែដែលបានសោយនូវទុក្ខ-វេទនាក្នុងវេលាថ្ងៃ ព្រោះផលនៃបាបកម្មដែលធ្វើទុកហើយដូចគ្នាពិតណាស់ ខ្ញុំព្រះអង្គ ដែលព្រះអង្គទ្រង់តាំងទុកក្នុងតំណែងជាអ្នកពិភាក្សា បានជម្រះក្តីដោយអយុត្តិធម៌ ទទួលសំណូក កោសរូសសាច់ឈាមប្រជាជនអំពីខាងក្រោយ ព្រោះផលនៃកម្មដែលធ្វើទុកនោះ ពេលថ្ងៃ ខ្ញុំព្រះអង្គទើបបានសោយទុក្ខវេទនានេះ” ហើយពោល ២ គាថាថា

[៤២០] អជ្ឈេនានិ បដិគ្គយ្ហ កាមេសុ គិទ្ធិតោ អហំ
អចរឹ ទីឃមទ្ធានំ បរេសំ អហិតាយហំ ។
យោ បិដ្ឋិមំសិកោ ហោតិ ឯវំ ឧក្កច្ច ខាទតិ
យថាហមជ្ជ ខាទាមិ បិដ្ឋិមំសានិ អត្តនោតិ ។

ខ្ញុំរៀនចប់ត្រៃវេទ ត្រូវប្រព័ន្ធនៅក្នុងកាមទាំងឡាយ បានប្រព្រឹត្តដើម្បីសេចក្តីវិនាស មិនមែនជាប្រយោជន៍ដល់ជនដទៃ

អស់កាលដ៏យូរ ។

បុគ្គលណាកោសរូសសាច់ឈាមជនដទៃ បុគ្គលនោះរមែង ត្រូវខ្វេះសាច់ខ្នងរបស់ខ្លួនស៊ី ដូចគ្នានឹងខ្ញុំព្រះអង្គ ស៊ីសាច់ខ្នង របស់ខ្លួនរហូតសព្វថ្ងៃនេះ ។

បណ្ដាបទទាំងនោះ បទថា **អជ្ឈេនានិ** "ត្រៃវេទ" បានដល់ វេទទាំងឡាយ ។ បទថា **បដិគ្គយ្ហ** "រៀន" សេចក្ដីថា រៀនសូត្រ ចាំទុក ។ បទថា **អចរិ** "បានប្រព្រឹត្ត" បានដល់ បដិបត្តិហើយ ។ បទថា **អហិតាយហំ** "ខ្ញុំ... មិនមែនប្រយោជន៍" សេចក្ដីថា ខ្ញុំព្រះ អង្គបានបដិបត្តិនូវសេចក្ដីវិនាសដែលមិនមែនជាប្រយោជន៍ ។ បទ ថា **យោ បិដ្ឋិមំសិកោ** "បុគ្គលណាជាអ្នកកោសរូសស៊ីសាច់ឈាម អ្នកដទៃ" សេចក្ដីថា បុគ្គលណាស៊ីសាច់ខ្នងរបស់អ្នកដទៃ រមែង ជាអ្នកនិយាយអុជអាលញុះញង់ ។ បទថា **ឧក្កច្ច** "ខ្វេះ" បានដល់ ត្រូវខ្វាចត្រូវខ្វេះ ។

ក៏គ្រាប្រេតក្រាបទូលយ៉ាងនេះហើយ ទើបទូលសួរតាបសថា "ព្រះអង្គស្តេចយាងមកក្នុងទីនេះ បានដូចម្តេច?" តាបសក៏តំណាលរឿងទាំងអស់ឲ្យស្តាប់ដោយពិស្តារ ។ ប្រេតបានទូលសួរទៀតថា "លោកម្ចាស់ដ៏ចម្រើន ក៏ឥឡូវនេះ ព្រះអង្គនឹងប្រថាប់នៅក្នុងទីនេះតទៅ ឬស្តេចនឹងទៅកាន់ទីដទៃ?" តាបសត្រាស់ថា "យើងមិននៅទីនេះទេ នឹងត្រលប់ទៅកាន់អាស្រមបទវិញ" ប្រេតទូលថា "ប្រពៃហើយព្រះអង្គ ខ្ញុំព្រះអង្គនឹងទំនុកបម្រុងព្រះអង្គដោយផ្លែស្វាយទុំជាប្រចាំ" ហើយនាំតាបសទៅកាន់អាស្រមបទដោយអានុភាពរបស់ខ្លួន ទូលសូមបដិញ្ញាថា "សូមព្រះអង្គកុំមានការសោប់សោល់ ចូរប្រថាប់នៅក្នុងទីនេះចុះ" ហើយទូលលាទៅ ។ តាំងអំពីនោះមកប្រេតនោះក៏ទំនុកបម្រុងតាបសដោយផ្លែស្វាយទុំជានិច្ច ។ តាបសកាលបានឆាន់ផ្លែស្វាយទុំនោះ ក៏ធ្វើកសិណបរិកម្ម ធ្វើឈាន និងអភិញ្ញាឲ្យកើត ហើយបានជាអ្នកមានព្រហ្មលោកជាទីទៅក្នុងខាង

មុខ ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម្មទេសនានេះមកត្រាស់សម្តែង ដល់ឧបាសកឧបាសិកាទាំងឡាយហើយ ទ្រង់ក៏បានប្រកាសសច្ចៈទាំងឡាយ និងទ្រង់ប្រជុំជាតក ។ ក្នុងវេលាចប់សច្ចៈ ពួកខ្លះក៏បានជាព្រះសោតាបន្ន ពួកខ្លះក៏បានជាព្រះសកទាគាមី ពួកខ្លះក៏បានជាព្រះអនាគាមី នាងទេពធីតាក្នុងគ្រានោះ បានមកជានាងឧប្បលវណ្ណាថេរី ចំណែកតាបសក្នុងកាលនោះ ក៏គឺ **តថាគត** នេះឯង ។

**ចប់អដ្ឋកថា កិឋន្តជាតកទី ១**

# អដ្ឋកថា កុម្ភជាតកទី ២

## (រឿងទោសរបស់សុរា)

ព្រះសាស្ដាកាលស្ដេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បាន ប្រារព្ធស្ត្រីអ្នកផឹកសុរា ៥០០ នាក់ ជាសម្លាញ់របស់នាងវិសាខា មហាឧបាសិកា ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា **កោ បាតុរាសិ "លោកជាអ្នកណា... ប្រាកដហើយ"** ដូច្នេះ ។

បានឮថា កាលគេប្រកាសរឿងកាលនៃសុរាក្នុងព្រះនគរសាវត្ថី ស្ត្រី ៥០០ នាក់នោះ ក៏ចាត់ចែងត្រៀមសុរាមានរសខ្លាំងទុក ដើម្បី ស្វាមីដែលទៅលេងសប្បាយ ហើយប្រឹក្សាគ្នាថា "យើងទាំងឡាយ ក៏នឹងទៅលេងមហោស្រពដែរ" ដូច្នេះហើយ ទើបគ្រប់គ្នានាំគ្នាទៅ កាន់សម្នាក់របស់នាងវិសាខាពោលបបួលថា "សម្លាញ់ ពួកយើង ទៅលេងមហោស្រពជាមួយគ្នាចុះ" កាលនាងវិសាខាបដិសេធថា "កាល នេះជាកាលនៃសុរា យើងមិនផឹកសុរាឡើយ" ទើបនាំគ្នាពោលថា

“នាងចូរថ្វាយទានចំពោះព្រះសម្មាសម្ពុទ្ធចុះ ឯពួកយើងនឹងលេងសប្បាយនឹងគ្នា” ។ នាងវិសាខាទទួលពាក្យថា “ល្អហើយ” ទើបបញ្ជូនមនុស្សទៅទូលនិមន្តព្រះសាស្តាថ្វាយមហាទាន បានកាន់យកគ្រឿងក្រអូប និងផ្កាកម្រងជាច្រើន ហែហមដោយស្ត្រីទាំងនោះទៅកាន់ព្រះវិហារជេតពន ដើម្បីស្តាប់ព្រះធម្មកថាក្នុងវេលាល្ងាច ។ ក៏ស្ត្រីទាំងនោះផឹកសុរាបណ្តើរ និងធ្វើដំណើររួមជាមួយនាងវិសាខាឈរផឹកសុរាត្រង់ខ្លោងទ្វារ ហើយទើបបានចូលទៅកាន់សម្នាក់ព្រះសាស្តាព្រមជាមួយនាងវិសាខា ។ នាងវិសាខាថ្វាយបង្គំព្រះសាស្តាហើយអង្គុយក្នុងទីម្ខាង ។ បណ្តាស្ត្រីទាំងនោះពួកខ្លះក៏រាំ ពួកខ្លះក៏វាសដៃវាសជើង រហូតមានវិវាទនឹងគ្នាក្នុងសម្នាក់របស់ព្រះសាស្តានោះឯង ។ ព្រះសាស្តាទើបទ្រង់បញ្ចេញព្រះរស្មីចេញចាកព្រះលោមាត្រង់ចន្លោះព្រះចិញ្ចើម ដោយព្រះបំណងនឹងឲ្យស្ត្រីទាំងនោះកើតនូវសេចក្តីសង្វេគ ។ ភាពងងឹតបានកើតឡើងហើយក្នុងខណៈនោះ ។

ស្ត្រីទាំងនោះតក់ស្លុតភ័យខ្លាច ព្រោះត្រូវមរណភ័យគំរាម ។ ព្រោះហេតុនោះ ស្ត្រីទាំងនោះទើបស្វាងស្រា ។ ព្រះសាស្តាក៏ទ្រង់អន្តរធានបាត់អំពីបល្ល័ង្កដែលទ្រង់ប្រថាប់ទៅ ទៅប្រថាប់ឈរនៅលើកំពូលភ្នំសិនេរុ បញ្ចេញព្រះរស្មីចាកព្រះឧណ្ណាលោម (ខណៈនោះ)ហាក់ដូចជាមានព្រះចន្ទ និងព្រះអាទិត្យឧទ័យឡើង ១.០០០ ដួង ។ ព្រះសាស្តាប្រថាប់ឈរត្រង់កំពូលសិនេរុបពិតនោះឯង ដោយព្រះបំណងនឹងឲ្យស្ត្រីទាំងនោះកើតសេចក្តីសង្វេគ ទើបត្រាស់ព្រះគាថានេះថា

កោ នុ ហាសោ កិមានន្ទោ និច្ចំ បជ្ជលិតេ សតិ
អន្ធការេ ឱនទ្ធា បទីបំ ន គវេសថ ។[១]

ម្នាលនាងទាំងឡាយនឹងរវល់តែរីករាយ នាំគ្នាសប្បាយធ្វើអ្វី ក្នុងកាលលោកសន្និវាសកំពុងមានភ្លើងឆេះជានិច្ច នាង

---

១.ចាកធម្មបទដ្ឋកថា ជរាវគ្គ ។

ទាំងឡាយដែលសេចក្តីងងឹតគ្របសង្កត់ហើយ មិននាំគ្នាស្វែងរកប្រទីប គឺ ទីពឹងហ្ន៎ ។

ក្នុងវេលាចប់ព្រះគាថា ស្ត្រីទាំង ៥០០ នាក់នោះ ក៏តាំងនៅក្នុងសោតាបត្តិផល ។ ព្រះសាស្តាស្តេចយាងមកប្រថាប់គង់លើពុទ្ធាសនៈក្រោមម្លប់ព្រះគន្ធកុដិ ។ លំដាប់នោះ នាងវិសាខាថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ទឹកផឹកដែលឈ្មោះថា សុរា ជាគ្រឿងទម្លាយហិរិឱត្តប្បៈនេះ កើតតាំងអំពីកាលណា ព្រះអង្គ" កាលព្រះសាស្តានឹងត្រាស់ប្រាប់ដល់នាងទើបទ្រង់នាំអតីតនិទានមកត្រាស់សម្តែងដូចតទៅ ។

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជ្យសម្បត្តិក្នុងព្រះនគរពារាណសី មានព្រានព្រៃម្នាក់ឈ្មោះថា សុរៈ ជាអ្នកស្រុកដែនកាសី បានទៅកាន់ព្រៃហិមពាន្តដើម្បីស្វែងរករបស់របរ ។ ក្នុងព្រៃហិមពាន្តនោះ មានដើមឈើមួយដើមត្រង់ល្អ មានទំហំប្រមាណ

មួយជួរបុរស ។ ដើមឈើនោះបានបែកចេញជាបីប្រគាប ក្នុងចន្លោះនៃប្រគាបទាំងបីរបស់ដើមឈើនោះ មានព្រង់ធំមួយប៉ុនពាង កាលភ្លៀងធ្លាក់ក៏ពេញទៅដោយទឹក មានដើមសម៉ កន្ទួតព្រៃ និងវល្លិម្រេច ដុះជុំវិញដើមឈើនោះ ។ ផ្លែនៃដើមឈើនោះៗ ទុំហើយក៏ជ្រុះបាកទងធ្លាក់ចុះក្នុងព្រង់នោះ ។ នៅក្បែរដើមឈើនោះ មានស្រូវសាលីដុះឯង និងមានសត្វសេកទាំងឡាយមកពាំយកគួរស្រូវអំពីទីនោះ ហើយក៏ហើរទៅទំស៊ីនៅលើដើមឈើនោះ ។ កាលពួកសេកនាំគ្នាចឹកស៊ីហើយ គ្រាប់ស្រូវក្តី សំបកស្រូវក្តី ក៏ធ្លាក់ចុះទៅក្នុងព្រង់នោះ ។ ទឹកក្នុងព្រង់នោះត្រូវកម្តៅថ្ងៃដុត ក៏កើតមានរសនិងមានពណ៌ក្រហមៗ ដោយប្រការដូច្នេះ ។ ក្នុងរដូវក្តៅ ហ្វូងបក្សីទាំងឡាយដែលស្រេកទឹក ហើរមកផឹកទឹកនោះ ក៏ស្រវឹងភ្ញាក់ធ្លាក់ចុះនៅត្រង់គល់ឈើនោះ សន្លប់មួយភ្លែតទើបដឹងខ្លួនបន្លឺសំឡេងហើរទៅ ។ សុម្ពីឆ្កែព្រៃ និងស្វាជាដើម ក៏មានន័យនេះដូចគ្នា ។

ព្រានព្រៃឃើញដូច្នោះក៏គិតថា "បើទឹកនេះមានពិស សត្វទាំងនេះគង់នឹងស្លាប់ តែនេះវាគ្រាន់តែសន្ទប់បន្តិច ហើយក៏ហើរទៅតាមសប្បាយ ទឹកនេះគង់មិនមានពិសទេ" គេទើបផឹងផឹក ក៏កើតការស្រវឹង និងប្រាថ្នានឹងស៊ីសាច់សត្វ ។ លំដាប់នោះ គេទើបបង្កាត់ភ្លើងឲ្យឆេះឡើង ហើយសម្លាប់បក្សីដែលភ្លាត់ធ្លាក់មកត្រង់គល់ឈើនោះ មានសត្វទទា និងមាន់ជាដើម អាំងសាច់ត្រង់ភ្នក់ភ្លើង ដៃមួយរាំ ដៃមួយកាន់សាច់ខាំស៊ី បានទៅក្នុងទីនោះឯងអស់មួយថ្ងៃពីរថ្ងៃ ។ ក៏នៅទីជិតបរិវេណនោះ មានតាបសមួយរូបឈ្មោះ *វរុណៈ* ។ ព្រានព្រៃដើរទៅកាន់សម្នាក់តាបសនោះ ដោយធុរៈយ៉ាងដទៃ គេបានកើតការគិតថា "យើងនឹងផឹកទឹកនេះរួមជាមួយតាបស?" គេទើបដងទឹកដាក់បំពង់ឫស្សីមួយរហូតពេញ កាន់ទៅជាមួយសាច់អាំងដល់បណ្ណសាលាហើយពោលបបួលថា "លោកម្ចាស់ ចូរសាកផឹកទឹកនេះមើលចុះ" ហើយទាំងពីរនាក់ក៏បរិភោគសាច់ផឹកទឹកជាមួយ

គ្នា ។ ដោយប្រការដូច្នេះ ទឹកផឹកនោះឯងក៏កើតមានឈ្មោះថា សុរា ខ្លះ វារុណីខ្លះ ព្រោះព្រានសុរៈ និងវរុណតាបសបានឃើញ ។

ចំណែកសុរព្រាន និងវរុណតាបសទាំងពីរនាក់បានគិតគ្នាថា “មានឧបាយដើម្បីរកស៊ីហើយ” ទើបដាក់សុរាក្នុងបំពង់ឫស្សីរហូតពេញ ហើយនាំគ្នាវែកទៅរហូតដល់បច្ចន្តនគរ ឲ្យមនុស្សក្រាបទូលព្រះរាជាថា “មានមនុស្សធ្វើទឹកផឹកមកគាល់” ។ ព្រះរាជាទើបត្រាស់ប្រាប់ឲ្យជនទាំងពីរចូលគាល់ ។ គេទើបនាំទឹកផឹកចូលទៅថ្វាយ ។ ព្រះរាជាទ្រង់សោយបាន ២-៣ ដង ទ្រង់ក៏ស្រវឹង ។ តែទឹកស្រវឹងនោះល្មមសោយបានត្រឹមតែមួយថ្ងៃពីរថ្ងៃប៉ុណ្ណោះ តមកព្រះរាជាត្រាស់សួរជនទាំងពីរថា “ទឹកប្រភេទនេះ មាននៅទីដទៃណាខ្លះ” គេនាំគ្នាក្រាបទូលថា “មហាបពិត្រ មានព្រះអង្គ” ។ ព្រះរាជាត្រាស់សួរថា “មាននៅទីណា” គេទូលថា “នៅព្រៃហិមពាន្ត ព្រះអង្គ” ព្រះរាជាត្រាស់បង្គាប់ថា “បើដូច្នោះ អ្នកទាំងពីរចូរទៅនាំយកមក”

ជនទាំងពីរទៅនាំយកមកជាគ្រាៗ ហើយប្រឹក្សាគ្នាថា ពួកយើងមិនអាចទៅញយៗ បានទេ ។ ទើបកំណត់ចំណាំគ្រឿងផ្សំទាំងពួងបាន ហើយយកសំបកជាដើមរបស់ដើមឈើនោះ មកដាក់ជាមួយគ្រឿងផ្សំគ្រប់យ៉ាង តាំងជាសុរាឡើងក្នុងព្រះនគរ ។ អ្នកព្រះនគរនាំគ្នាផឹកសុរាហួតដល់សេចក្តីប្រមាទស្រវឹង ធ្លាក់ខ្លួនទាល់ក្រទៅៗ គ្រប់គ្នា ។ ព្រះនគរក៏បានដូចជាក្រុងដែលគេបោះបង់ ។ ព្រោះហេតុនោះ ជនអ្នកធ្វើទឹកផឹកទាំងពីរ ទើបលបរត់គេចចេញចាកព្រះនគរនោះ ទៅកាន់ក្រុងពារាណសី ឲ្យគេក្រាបទូលព្រះរាជាថា "មានមនុស្សធ្វើទឹកផឹកមកគាល់" ។ ព្រះបាទពារាណសីត្រាស់បង្គាប់ឲ្យជនទាំងពីរចូលគាល់ ហើយព្រះរាជទានស្បៀងដល់ជនទាំងពីរ ។ គេជួយគ្នាចាត់ចែងផ្សំសុរាឡើងក្នុងក្រុងពារាណសីនោះ សូម្បីព្រះនគរនោះក៏វិនាសទៅដូច្នេះទៀត គេទាំងពីរទើបគេចអំពីក្រុងនោះ ទៅក្រុងសាកេត គេចចេញអំពីក្រុងសាកេតទៅកាន់ក្រុងសាវត្ថី ។ គ្រានោះ

ព្រះបាទសព្វមិត្តបានជាក្សត្រក្នុងព្រះនគរសាវត្ថី ទ្រង់ធ្វើការសង្គ្រោះដល់ជនទាំងពីរនោះ ហើយត្រាស់សួរថា "ពួកអ្នកត្រូវការវត្ថុអ្វីខ្លះ?" កាលគេក្រាបទូលថា "ខ្ញុំព្រះអង្គត្រូវការឫសឈើដើម្បីផ្សំជាមួយមេប្រាស្រូវសាលី និងពាង ៥០០" ក៏ត្រាស់ឲ្យប្រទានគ្រប់យ៉ាង ។ ព្រានសុរៈ និងវរុណតាបសបានផ្សំសុរាដាក់ក្នុងពាង ៥០០ តាំងទុកហើយ បំណងនឹងការពារពាងព្រោះខ្លាចមានកណ្ដុរមករុកកួន ក៏ចងសត្វឆ្មាទុកក្បែរៗ ពាង មួយក្បាលមួយ ។ ឆ្មាទាំងនោះនាំគ្នាផឹកសុរាដែលហូរត្រង់មាត់ពាងក្នុងវេលាដែលពាងពេញ រហូតស្រវឹងដេកលក់ទៅ ។ ពួកកណ្ដុរមកខាំត្រចៀក ច្រមុះ ពុកមាត់ និងកន្ទុយឆ្មា ហើយនាំគ្នារត់ទៅ ។ ពួកអាយុត្តកបុរស (ជនអ្នកយកការណ៍) គិតថា "ឆ្មាផឹកសុរានាំគ្នាងាប់អស់" ទើបទៅក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះបាទសព្វមិត្តទ្រង់យល់ឃើញថា "ជនទាំងពីរនេះនឹងធ្វើនូវថ្នាំពិស" ទើបត្រាស់ឲ្យកាត់សីសៈជនទាំងពីរនោះ ។ ជនទាំង

ពីរយ៉ាំងរៀបរាប់ទូលថា "មហាបពិត្រ ផឹកសុរាមានរសឆ្ងាញ់ ព្រះអង្គ" រហូតដាច់ខ្យល់ស្លាប់ ។ គ្រាព្រះរាជាត្រាស់ឲ្យប្រហារជីវិតជនទាំងពីរហើយ ទ្រង់មានព្រះរាជឱង្ការថា "ពួកអ្នកចូរបំបែកពាងចេញ" ចំណែកឆ្មាទាំងឡាយកាលបរិភោគសុរាស្វាងហើយ ក៏ក្រោកឡើងរត់លេងបាន ។ ពួករាជបុរសឃើញដូច្នោះ ទើបក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះរាជាទ្រង់ត្រិះរិះថា "បើទឹកសុរាមានពិស ឆ្មាគង់នឹងងាប់ ប្រហែលមានរសឆ្ងាញ់ហើយ យើងនឹងសាកផឹកមើល" ទើបត្រាស់ឲ្យប្រដាប់តាក់តែងព្រះនគរ ឲ្យសាងមណ្ឌបត្រង់ខាងមុខព្រះលានហ្លួង ស្រេចហើយទ្រង់ប្រថាប់លើរាជបល្ល័ង្ក លើកស្វេតឆត្រឡើងខាងលើមណ្ឌបដែលតាក់តែងហើយ ហែហមដោយពួកអាមាត្យ មុខមន្ត្រីផ្ដើមផឹកសុរា ។

គ្រានោះ ស្ដេចសក្កទេវរាជទ្រង់ត្រួតមើលសត្វលោកថា "ជនពួកណាខ្លះហ្ន៎ មិនប្រមាទក្នុងការទំនុកបម្រុងមាតាបិតាជាដើម ធ្វើ

នូវសុចរិត ៣ ឲ្យពេញបរិបូណ៌" ទតព្រះនេត្រឃើញព្រះបាទសព្វ-
មិត្តនោះ ដែលប្រថាប់គង់ដើម្បីនឹងផឹកសុរា ទើបព្រះតម្រិះថា "បើ
ព្រះបាទសព្វមិត្តនេះនឹងផឹកស្រាសោត សកលជម្ពូទ្វីបនឹងត្រូវវិនាស
យើងនឹងត្រូវដោះស្រាយដោយវិធីដែលនឹងឲ្យស្តេចវៀរចាកការផឹក"
ហើយទ្រង់ដាក់ក្អមមួយ ដែលពេញទៅដោយសុរាទុកត្រង់បាតព្រះ
ហត្ថ ក្លែងភេទជាព្រាហ្មណ៍ ស្តេចមកឈរនៅក្នុងអាកាស ត្រង់ទី
ចំពោះព្រះភក្ត្រព្រះបាទសព្វមិត្ត ហើយត្រាស់ថា "អ្នកទាំងឡាយ
ចូរទិញក្អមនេះ អ្នកទាំងឡាយចូរទិញក្អមនេះ" ។ ព្រះបាទសព្វមិត្ត
ទតព្រះនេត្រឃើញព្រាហ្មណ៍ក្លែងខ្លួន ឈរនិយាយនៅក្នុងអាកាស
យ៉ាងនោះ ទ្រង់សង្ស័យថា "ព្រាហ្មណ៍នេះមកអំពីទីណាហ្ន៎" កាល
នឹងទ្រង់សន្ទនាជាមួយព្រាហ្មណ៍នោះ បានត្រាស់ ៣ ព្រះគាថាថា

[៤២១] កោ បាតុរាសិ តិទិវា នភម្ហិ

ឱភាសយំ សំវរី ចន្ទិមាវ

គត្តេហិ តេ រស្មិយោ និច្ឆរន្តិ
សតេរតា វិជ្ជុរិវន្តលិក្ខេ ។
សោ ឆិន្នវាតំ កមសិ អឃម្ហិ
វេហាយសំ គច្ឆសិ តិដ្ឋសិ ច
ឥទ្ធី នុ តេ វត្ថុកតា សុភាវិតា
អនទ្ធគូនមសិ[១] ទេវតានំ ។
វេហាយសំ កមមាគម្ម[២] តិដ្ឋសិ
កុម្ភំ កិណាថាតិ យមេតមត្ថំ
កោ វា តុវំ កិស្ស វតាយំ កុម្ភោ
អក្ខាហិ មេ ព្រាហ្មណ ឯតមត្ថំ ។

លោកជានរណា មកអំពីត្រៃទិព្វឬ ទើបមានរស្មីស្វាងស្វៃ ប្រាកដនៅក្នុងអាកាស ដូចព្រះចន្ទបញ្ចេញពន្លឺក្នុងយាមរត្តិ-

១.ឱ. អនទ្ធគូនាមបិ, ម. អនន្តគណាមកិ ។ ២.ឱ. សំ កម្មាគម្ម, ម. គម្មមាគម្ម ។

កាលដូច្នោះ រស្មីផ្សាយចេញអំពីខ្លួនលោក ដូចផ្លេកបន្ទោរ

ក្នុងវេហាស៍ដូច្នោះ ។

លោកជាន់ជុំពពក ដែលប្រាសចាកខ្យល់ក្នុងអាកាសបាន

ដើរ និងឈរក្នុងអាកាសបាន ឫទ្ធិរបស់ទេវតាទាំងឡាយដែល

មិនត្រូវដើរឆ្ងាយដោយជើង លោកបានធ្វើឲ្យជាទីតាំង និងឲ្យ

ចម្រើនល្អហើយយ៉ាងណា ។

លោកជានរណាមកឈរក្នុងអាកាស ស្រែកលក់ក្អម ឬថា

ក្អមរបស់លោកនេះប្រើប្រយោជន៍អ្វីបាន ព្រាហ្មណ៍ សូមលោក

ប្រាប់សេចក្តីនោះដល់ខ្ញុំចុះ ។

បណ្តាបទទាំងនោះ បទថា **កោ បាតុរាសិ** “លោកជានរណា...

ប្រាកដហើយ” សេចក្តីថា លោកជានរណា មកអំពីណា ទើបមក

ប្រាកដ ។ អធិប្បាយថា លោកមកអំពីណា ។ បទថា **តិទិវា នភម្ហិ**

“មកអំពីត្រៃទិព្វ... ក្នុងនភាកាស” សេចក្តីថា ព្រះបាទសព្វមិត្តត្រាស់

សួរថា "លោកមកអំពីភពតាវត្តិង្សឬ ទើបបានប្រាកដក្នុងនភាកាស នេះ?" ។ បទថា **សំវរី** "**ក្នុងយាមរាត្រីកាល**" បានដល់ ក្នុងរាត្រីកាល ។ បទថា **សតេរតា** "**ព្រះចន្ទ**" បានដល់ ព្រះចន្ទដែលមានឈ្មោះយ៉ាងនេះ ។ បទថា **សោ** "**នោះ**" បានដល់ លោកនោះ ។ បទថា **ធិន្នវាតំ** "**ពពកដែលប្រាសចាកខ្យល់**" សេចក្តីថា វលាហកទេព រមែងឈានដើរតាមខ្យល់ ដែលមានក្រសែបក់ដ៏ត្រជាក់ទៅបាន សូម្បីខ្យល់នោះមិនមានដល់លោកឡើយ ព្រោះហេតុនោះ ព្រះបាទសព្វមិត្តទើបត្រាស់យ៉ាងនេះ ។ បទថា **កមសិ** "**ដើរ**" បានដល់ អណ្តែតលយទៅ ។ បទថា **អយម្ហិ** "**ក្នុងអាកាស**" បានដល់ក្នុងអាកាសដែលមិនមានអ្វីរាំង ។ បទថា **វត្ថុកតា** "**ធ្វើឲ្យជាទីតាំង**" សេចក្តីថា (ឫទ្ធិរបស់លោក) ជាវត្ថុដែលធ្វើហើយ ដូចវត្ថុដូចជាទីតាំងដូច្នោះ ។ បទថា **អនទ្ធគូនមសិ ទេវតានំ** "**ឫទ្ធិរបស់ទេវតាទាំងឡាយដែលមិនត្រូវដើរផ្លូវឆ្ងាយដោយជើង**" សេចក្តីថា

ព្រះបាទសព្វមិត្តត្រាស់សួរថា ឫទ្ធិរបស់លោកដែលអប់រំល្អហើយ ប្រហែលនឹងឫទ្ធិរបស់ទេវតា ដែលឈ្មោះថា មិនត្រូវដើរផ្លូវឆ្ងាយ ព្រោះមិនត្រូវប្រើជើងដើរទៅក្នុងផ្លូវឆ្ងាយ ។ បទថា **វេហាយសំ កមមាគម្ម "មកឈរនៅក្នុងអាកាស"** សេចក្តីថា លោកជានរណា ទើបអាស្រ័យការឈានជើងចូលទៅឈរក្នុងអាកាសបាន ។ បណ្ឌិតគប្បីភ្ជាប់សេចក្តីនៃបាទគាថានោះចូលដោយបទថា **កោ វា តុវំ** (លោកជានរណាឬ) អធិប្បាយថា លោកមកឈរយ៉ាងនេះឈ្មោះអ្វីហ្ន៎ ។ បទថា **យមេតមត្ថំ "ប្រយោជន៍អ្វីបាន"** សេចក្តីថា លោកនិយាយពាក្យនេះណា ត្រូវភ្ជាប់សេចក្តីនៃបាទគាថានេះ ជាមួយបទថា **ឥមស្ស កិស្ស វិតាយំ** (ទើបបានសេចក្តីថា លោកនិយាយពាក្យថា ចូរទិញក្អមនេះ) ។ អធិប្បាយថា លោកនិយាយថា ចូរទិញក្អមនេះ ក្អមនេះរបស់លោកមានប្រយោជន៍អ្វីឬ ។

លំដាប់នោះ សក្កទេវរាជត្រាស់ថា "បើដូច្នោះលោកចូរស្តាប់"

កាលនឹងទ្រង់សម្តែងទោសរបស់សុរា ទើបត្រាស់ថា

[៤២២] ន សប្បិកុម្ភោ នបិ តេលកុម្ភោ

ន ផាណិតស្ស ន មធុស្ស កុម្ភោ

កុម្ភស្ស វជ្ជានិ អនប្បកានិ

ទោសេ ពហូ កុម្ភគតេ សុណាថ ។

ក្អមនេះមិនមែនក្អមទឹកដោះថ្លា មិនមែនក្អមប្រេង មិនមែនក្អម
ទឹកអំពៅ មិនមែនក្អមទឹកឃ្មុំ ទោសរបស់ក្អមនេះមានមិនមែន
តិច លោកចូរស្តាប់ទោសដ៏ច្រើនដែលមានក្នុងក្អមនេះ ។

គលេយ្យ យំ បិត្វា បតេ បបាតំ

សោព្ភំ គុហំ ចន្ទនិយោឡិគល្លំ

ពហុំបិ កុញ្ជេយ្យ អភោជនេយ្យំ

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុគ្គលផឹកទឹកប្រភេទណាហើយ ដើរទ្រេតទ្រោតធ្លាក់ទៅក្នុង

អណ្តូង ជ្រោះ រណ្តៅទឹកជ្រាំ និងរណ្តៅស្មោកគ្រោក គប្បី
បរិភោគរបស់ដែលមិនគួរបរិភោគសូម្បីច្រើនបាន លោកចូរ
ទិញក្អមនេះដែលពេញទៅដោយទឹកប្រភេទនោះ ។

យំ បិត្វា ចិត្តស្មឹ អនេសមានោ
អាហិណ្ឌតិ គោរិវ ភក្ខសារី
អនាថមានោ ឧបគាយតិ នច្ចតិ ច
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុគ្គលផឹកទឹកប្រភេទណាហើយ មិនមានការគ្រប់គ្រងចិត្ត ដើរ
ចប្រប់ ដូចគោស៊ីកាកសុរាដូច្នោះ ដូចជាដាច់ទីពំនាក់ រមែង
រាំច្រៀងបាន លោកចូរទិញក្អមនេះ ដែលពេញទៅដោយទឹក
ប្រភេទនោះ ។

យំ វេ បិវិត្វា អចេលោវ នគ្គោ
ចរេយ្យ គាមេ វិសិខន្តរានិ

សមុដ្ឋចិត្តោ អតិវេលសាយី
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុគ្គលផឹកទឹកប្រភេទណាហើយ ដោះសំពត់អាក្រាតកាយដូចពួកអាចេលកៈ ត្រាច់ទៅតាមច្រក តាមផ្លូវក្នុងស្រុក មានចិត្តវង្វេងវង្វាង ដេកហួសវេលា លោកចូរទិញក្អមនេះដែលពេញទៅដោយទឹកប្រភេទនោះ ។

យំ បិត្វា ឧដ្ឋាយ បវេធមានោ
សីសញ្ច ពាហុញ្ច បចាលយន្តោ
សោ នច្ចតី ទារុកដល្លកោវ
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុគ្គលផឹកទឹកប្រភេទណាហើយ ក្រោកឡើងទ្រេតទ្រោត ញ័រក្បាល និងលើកដៃឡើងរាំ ដូចជារូបយន្តដែលធ្វើដោយឈើដូច្នោះ លោកចូរទិញក្អមនេះ ដែលពេញទៅដោយទឹកប្រភេទ

នោះ ។

យំ វេ បិវិត្វា អគ្គិទឍ្ឍា សយន្តិ

អថោ សិគាលេហិបិ ខាទិតាសេ

ពន្ធំ វធំ[១] ភោគជានិញ្ចុបេន្តិ

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុគ្គលផឹកទឹកប្រភេទណាហើយ ដេកលក់រហូតត្រូវភ្លើងឆេះ និងត្រូវស៊ីអាហារដែលជាសំណល់សុនខបាន រមែងដល់នូវការត្រូវចាប់ចង ត្រូវសម្លាប់ និងវិនាសចាកភោគៈ លោកចូរទិញក្អមនេះ ដែលពេញទៅដោយទឹកប្រភេទនោះ ។

យំ បិត្វា ភាសេយ្យ អភាសនេយ្យំ

សភាយមាសិនោ អបេតវត្ថោ

សម្មក្ខិតោ វន្តគតោ ព្យសន្នោ

១.ឱ.ម. វធំ ។

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុគ្គលផឹកទឹកប្រភេទណាហើយ និយាយនូវពាក្យដែលមិនគួរនិយាយ អន្ទុយនិយាយប៉ប៉ាច់ប៉ប៉ោចក្នុងទីប្រជុំ ប្រាសចាកសំពត់ ប្រឡាក់ប្រឡូក លិចចុះនៅក្នុងភាពអាក្រាតកាយ មានតែរឿងវិនាស លោកចូរទិញក្អមនេះ ដែលពេញទៅដោយទឹកប្រភេទនោះ ។

យំ វេ បិវិត្វា ឧក្កដ្ឋា អាវិលក្ខា
មមេវ សត្វា បឋវីតិ មញ្ញេ
ន មេ សមោ ចាតុរន្តោបិ រាជា
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុគ្គលផឹកទឹកប្រភេទណាហើយ អួតអាង ក្អែកស្រវាំង យល់ថា ផែនដីទាំងអស់ជារបស់យើងតែម្នាក់ ព្រះរាជាសូម្បីមានមហាសមុទ្ទ ៤ ជាខណ្ឌសីមា ក៏មិនស្មើនឹងយើង លោកចូរ

ទិញក្អមនេះ ដែលពេញទៅដោយទឹកប្រភេទនោះ ។

មានាតិមានា កលហានិ បេសុណី
ទុព្វណ្ណិនី នគ្គយិនី បលាយិនី
បោរាណធុត្តាន[១] គតី និកេតោ
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុគ្គលផឹកទឹកប្រភេទណាហើយ ប្រកាន់ខ្លួន បង្កការឈ្លោះវិវាទ ញុះញង់ស៊ិកសៀត មានពណ៌សម្បុរគួរខ្ពើម ជាអ្នកអាក្រាតកាយ រត់ផ្តេសផ្តាស មានអាការដូចអ្នកលេងជាន់ចាស់ លោកចូរទិញក្អមនេះ ដែលពេញទៅដោយទឹកប្រភេទនោះ ។

ឥទ្ធានិ ផីតានិ កុលានិ អស្សុ
អនេកសាហស្សធនានិ លោកេ

---

១.ឱ. បោរាណធុត្តានំ, ម. ចោរានំ ធុត្តានំ ។

ឧច្ឆិន្នទាយជ្ជកតានិមាយ

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ត្រកូលទាំងឡាយដែលស្ដុកស្ដម្ភ សម្បូរ មានទ្រព្យច្រើនពាន់មានហើយនៅក្នុងលោក សុរាប្រភេទនេះធ្វើឲ្យដាច់ចាកភាពជាទាយាទបាន លោកចូរទិញក្អមនេះដែលពេញទៅដោយទឹកប្រភេទនោះ ។

ធញ្ញំ ធនំ រជតំ ជាតរូបំ
ខេត្តំ គវំ យត្ថ វិនាសយន្តិ
ឧច្ឆេទនី វិត្តគតំ[(១)] កុលានំ
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ស្រូវអង្ករ ទ្រព្យរបស់ មាសប្រាក់ ស្រែ ចម្ការ គោ ក្របីក្នុងត្រកូលណារមែងវិនាសទៅ ត្រកូលដែលស្ដុកស្ដម្ភទាំងឡាយ

---

១.ឱ. វិត្តវតំ ។

នឹងជាច់សូន្យទៅ ព្រោះផឹកទឹកប្រភេទណា លោកចូរទិញក្អម

នេះ ដែលពេញទៅដោយទឹកប្រភេទនោះ ។

យំ វេ បិត្វា ទិត្តរូបាវ បោសោ

អក្កោសតិ បិតរំ មាតរញ្ច

សស្សុំបិ គណ្ហេយ្យ អថោបិ សុណ្ហំ

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុគ្គលផឹកទឹកប្រភេទណាហើយ ជាបុគ្គលរឹងរូស អាក្រក់ ជេរ

មាតាបិតា ចាប់ទោសម្ដាយក្មេក និងកូនប្រសារ លោកចូរទិញ

ក្អមនេះ ដែលពេញទៅដោយទឹកប្រភេទនោះ ។

យំ វេ បិត្វា ទិត្តរូបា(១) នារី

អក្កោសតិ សស្សុរំ សាមិកញ្ច

ទាសម្បិ គណ្ហេ បរិចារកម្បិ

---

១.ម. ទិស្វា រូបាវ ។

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

នារីផឹកទឹកប្រភេទណាហើយ ក្លាយជាបុគ្គលវង្វេស អាក្រក់ ជេរឪពុកក្មេក ម្តាយក្មេក និងស្វាមី ចាប់ពាល់ទាសៈ និង អ្នកបម្រើអ្នកជួយបាន លោកចូរទិញក្អមនេះ ដែលពេញទៅ ដោយទឹកប្រភេទនោះ ។

យំ វេ បិត្វាន ហនេយ្យ បោសោ

ធម្មេ ឋិតំ សមណំ ព្រាហ្មណំ វា

គច្ឆេ អបាយំបិ តតោនិទានំ

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

បុរសផឹកទឹកប្រភេទណាហើយ សម្លាប់សមណៈ ឬព្រាហ្មណ៍ អ្នកតាំងនៅក្នុងធម៌បាន គេគប្បីទៅកាន់អបាយព្រោះកម្មនោះ ជាហេតុ លោកចូរទិញក្អមនេះដែលពេញទៅដោយទឹកប្រភេទ នោះ ។

យំ វេ បិត្វា ទុច្ចរិតំ ចរន្តិ
កាយេន វាចាយ ច ចេតសា ច
និរយំ វជន្តិ ទុច្ចរិតំ ចរិត្វា
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយផឹកទឹកប្រភេទណាហើយ ប្រព្រឹត្តទុច្ចរិតតាមផ្លូវកាយ វាចា ឬផ្លូវចិត្តបាន រមែងទៅកាន់នរក ព្រោះប្រព្រឹត្តទុច្ចរិត លោកចូរទិញក្អមនេះ ដែលពេញទៅដោយទឹកប្រភេទនោះ ។

យំ យាចមានា ន លភន្តិ បុព្វេ
ពហុំ ហិរញ្ញំបិ បរិច្ចជន្តា
សោ តំ បិវិត្វា អលិកំ ភណាតិ
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយណាសូម្បីលះបង់ប្រាក់ដ៏ច្រើន មកអង្វរបុរសណា

ដែលមិនធ្លាប់ផឹកសុរាឲ្យនិយាយកុហក រមែងមិនបានក្នុងគ្រា មុន ក្រោយមកបុរសនោះគ្រាផឹកសុរាហើយ រមែងនិយាយ ឡេះឡោះផ្ដេសផ្ដាសបាន លោកចូរទិញក្អមនេះ ដែលពេញទៅ ដោយទឹកប្រភេទនោះ ។

យំ វេ បិត្វា បេសនេ បេសិយន្តោ

អច្ចាយិកេករណីយម្ហិ ជាតេ

អត្ថម្បិ សោ នប្បជានាតិ វុត្តោ

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ក្នុងការទទួលនាំសារ បុគ្គលផឹកសុរាប្រភេទណាហើយ កាល ត្រូវគេប្រើទៅក្នុងករណីយកិច្ចប្រញាប់ គេសូម្បីត្រូវសាកសួរ ក៏និយាយមិនដឹងរឿងដែរ លោកចូរទិញក្អមនេះ ដែលពេញ ទៅដោយទឹកប្រភេទនោះ ។

ហិរិមនាបិ អហិរិកភាវំ

បាតុំករោន្តិ មទនាយ មត្តា
ធីរាបិ សន្តា ពហុកំ ភណន្តិ
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយផឹកទឹកប្រភេទណាហើយ សូម្បីនឹងធ្លាប់មានការអៀនខ្មាស ក៏រមែងធ្វើនូវសេចក្តីមិនអៀនខ្មាសឲ្យប្រាកដបាន សូម្បីជាបុគ្គលល្អ មានបញ្ញា ក៏មិននិយាយច្រើនមិនបាន លោកចូរទិញក្អមនេះ ដែលពេញទៅដោយទឹកប្រភេទនោះ ។

យំ វេ បិត្វា ឯកថូបា សយន្តិ
អនាសកា ថណ្ឌិលទុក្ខសេយ្យំ
ទុព្វណ្ណិយំ អាយសក្យញ្ចុបេន្តិ
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយផឹកទឹកប្រភេទណាហើយ ច្រើនដេកត្បួរក្បាលគ្នា អត់បាយក្រហាយទឹក ដេកជាទុក្ខលើផែនដី មានសម្បុរ

អាក្រក់ អស់សិរី និងត្រូវនិន្ទា លោកចូរទិញក្អមនេះ ដែលពេញទៅដោយទឹកប្រភេទនោះ ។

យំ វេ បិត្វា បត្តក្ខន្ធា សយន្តិ
គាវោ កូដហតាវិវ ន ហិ វារុណិយា
វេគោ នរេន សុស្សហោរិវ
តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ជនទាំងឡាយផឹកទឹកប្រភេទណាហើយ ដេកផ្ងាក់ក ដូចជាគោដែលត្រូវក្រោះចងត្រង់កវាយ ឫទ្ធិសុរាមិនធ្វើឲ្យមនុស្សមានការអត់ទ្រាំដោយល្អបានឡើយ លោកចូរទិញក្អមនេះ ដែលពេញទៅដោយទឹកប្រភេទនោះ ។

យំ មនុស្សា វិវជ្ជន្តិ សប្បំ
ឃោរវិសមិវ តំ លោកេ វិសសមានំ
កោ នរោ បាតុមរហតិ

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

មនុស្សទាំងឡាយ រមែងវៀរចាកការផឹកទឹកប្រភេទណាដែល ប្រៀបដូចជាពស់មានពិស នរជនណាហ្ន៎គួរនឹងផឹកទឹកប្រភេទ នោះ ដែលដូចជាថ្នាំពិសក្នុងលោក លោកចូរទិញក្អមនេះដែល ពេញទៅដោយទឹកប្រភេទនោះ ។

យំ វេ បិត្វា អន្ធកវេណ្ហុបុត្តា

សមុទ្ទតីរេ បរិចារយន្តា

ឧបក្កមុំ មុសលេហញ្ញមញ្ញំ

តស្សា បុណ្ណំ កុម្ភមិមំ កិណាថ ។

ឱរសទាំងឡាយរបស់ស្តេចអន្ធកៈ និងវេណកៈ ផឹកទឹកប្រភេទ ណាហើយ នាំស្រីទៅបម្រើនៅត្រង់មាត់សមុទ្ទ ប្រហារគ្នា នឹងគ្នា លោកចូរទិញក្អមនេះ ដែលពេញទៅដោយទឹកប្រភេទ នោះ ។

យំ វេ បិត្វា បុព្វទេវា បមត្តា

តិទិវា ចុតា សស្សតិយា សមាយា

តំ តាទិសំ បជ្ជមិមំ និរត្ថកំ

ជានំ មហារាជ កថំ បិវេយ្យ ។

បុព្វទេព គឺ អសុរទាំងឡាយផឹកទឹកប្រភេទណាហើយស្រវឹង រហូតចុតិចាកត្រៃទិព្វ គឺ តាវត្តិង្សទេវលោក នៅសម្គាល់ខ្លួនថា ទៀង ប្រព្រឹត្តទៅជាមួយអសុរមាយា មហារាជ បុរសដែលឆ្លាតដូចជាព្រះអង្គ កាលជ្រាបថា ទឹកផឹកប្រភេទនោះ ជាទឹកស្រវឹងរកប្រយោជន៍មិនបាន នឹងផឹកធ្វើអ្វី ។

នយិមស្មិ កុម្ភស្មឹ ទធិ មធុ វា

ឯវំ អភិញ្ញាយ កិណាហិ រាជ

ឯវញ្ហិ មំ កុម្ភគតា មយា តេ

អក្ខាតរូបំ តវ សព្វមិត្តា ។

មហារាជា ក្នុងក្រុមនេះមិនមានទឹកដោះជូរ ឬទឹកឃ្មុំទេ ព្រះអង្គ
ដឹងយ៉ាងនេះហើយ សូមទ្រង់ចូរជៀចុះ បពិត្រព្រះសព្វមិត្ត
វត្ថុដែលនៅក្នុងក្រុមនេះ ខ្ញុំប្រាប់ដល់ព្រះអង្គហើយ តាមសេចក្តី
ពិតយ៉ាងនេះឯង ។

បណ្តាបទទាំងនោះ បទថា វជ្ជានិ "ទោស" បានដល់ ទោស
ទាំងឡាយ ។ បទថា គលេយ្យ "ដើរទ្រេតទ្រោត" សេចក្តីថា កាល
នឹងដើរ ក៏ដើរទ្រេតទ្រោតទៅគ្រប់ជំហាន ។ បទថា យំ បិត្វា បតេ
"ផឹកទឹកប្រភេទណាហើយ... ធ្លាក់ចុះទៅ" សេចក្តីថា បុគ្គលផឹកទឹក
ប្រភេទណាហើយ គប្បីធ្លាក់ចុះទៅ ។ បទថា សោព្ភំ "អណ្តូង"
បានដល់ រណ្តៅអណ្តូង ។ បទថា បន្ទនិយោឡិគល្លំ[១] "រណ្តៅ
ស្មោកគ្រោក" បានដល់ រណ្តៅចាក់សំរាម និងរណ្តៅដែលស្មោក-
គ្រោក ។ បទថា អភោជនេយ្យំ "របស់ដែលមិនគួរបរិភោគ" គឺ

---

១.បិដក. ចន្ទនិយោលិគល្លំ ។

របស់ដែលមិនគួរដើម្បីនឹងបរិភោគ ។ បទថា **អនេសមានោ** “មិនមានការគ្រប់គ្រងចិត្ត” បានដល់ មិនជាឥស្សរៈ ។ បទថា **គោវ** “ដូចគោ” សេចក្តីថា ឧបមាដូចគោ ។

បទថា **កក្ខសាទី**[១] **“កាកសុភ”** សេចក្តីថា ដូចគោស៊ីកាកសុភ ត្រាច់ស្វែងរករបស់ស៊ីក្នុងទីផ្សេងៗ យ៉ាងណា ជនមិនជាឥស្សរៈក្នុងចិត្ត រមែងត្រាច់ទៅយ៉ាងនោះ ។ បទថា **អនាថមានោ** “**គ្មានទីពំនាក់**” សេចក្តីថា ដូចជាបុគ្គលខ្វះទីពំនាក់ឥតទីពឹង ។ បទថា **ឧបគាយតិ** “**ស្រែកច្រៀងបាន**” សេចក្តីថា ឃើញជនដទៃគេច្រៀងរាំក៏ចូលទៅច្រៀងរាំបាន ។ បទថា **អចេលកោវ**[២] “**ដូចជាអចេលកៈ**” សេចក្តីថា អាក្រាតកាយបានដូចជាអចេលកៈ ។ បទថា **វិសិខន្តរានិ** “**តាមប្រកតាមផ្លូវ**” សេចក្តីថា (ដើរចប្រប់) តាមប្រកល្អក ។ បទថា **អតិវេលសាយី** “**ដេកហួសវេលា**” សេចក្តីថា ជាអ្នកមាន

---

១.បិដក. កក្ខសារី ។ ២. អចេលោវ ។

ប្រក្រតីដេកហួសវេលា ។ បាឋៈថា **អតិវេលាចារី** ដូច្នេះក៏មាន ។ អធិប្បាយថា ដេកលក់យូរៗ ។ បទថា **ទារុកដល្ហុកោវ** “ដូចរូបយន្តដែលធ្វើដោយឈើដូច្នោះ” បានដល់ ដូចរូបយន្តធ្វើដោយឈើ ។ បទថា **ភោគជានិញ្ហុបេន្តិ** “ដល់នូវសេចក្តីវិនាសចាកភោគៈ” បានដល់ រមែងចូលដល់ការវិនាសចាកភោគទ្រព្យ ។ អធិប្បាយថា ជនផឹកទឹកណាហើយ រមែងធ្វើទុច្ចរិតជាដើមថា បាណាតិបាត ត្រូវដាក់អាជ្ញាហើយរមែងដល់នូវសេចក្តីវិនាសទ្រព្យ និងដល់នូវទុក្ខដទៃៗមានត្រូវសម្លាប់ និងចាប់ចងជាដើម ។

បទថា **វន្តគតោ** “លិចចុះនៅក្នុងកម្ពួតរបស់ខ្លួន” សេចក្តីថា លិចនៅក្នុងកម្ពួតរបស់ខ្លួន ។ បទថា **ព្យសន្នោ** “មានតែរៀងវិនាស” បានដល់ ដល់នូវសេចក្តីវិនាស ។ បាឋៈថា **វិសន្នោ** ដូច្នេះក៏មាន ។ សេចក្តីថា ដេកជ្រមុជក្នុងគំនរកម្ពួតនោះ ។ បទថា **ឧក្កដ្ឋោ** “អួតអាង” សេចក្តីថា បុគ្គលផឹកទឹកប្រភេទណា លើកខ្លួនថា “យើង

មានកងទាហានច្រើន មាននរណាស្មើនឹងយើង” ។ បទថា **អារិ-លក្ខោ** “**ក្អែកករល្អក់**” បានដល់ មានក្អែកក្រហម (ក្អែកស្រវាំង) ។ បទថា **សព្វបឋវី**[១] “**ផែនដីទាំងអស់**” បានដល់ ផែនដីទាំងពួង ។ បាឋៈថា **សញ្ញបឋវី** ដូច្នេះក៏មាន ។ បទថា **ចាតុរន្តោ** “**មហាសមុទ្រ ៤**” សេចក្ដីថា ជាធំក្នុងផែនដីដែលមានមហាសមុទ្រ ៤ ជាព្រំដែន ។ បទថា **មានា** “**ប្រកាន់ខ្លួន**” បានដល់ កកើតមានះ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។

បទថា **គតិ**[២] បានដល់ បដិបទាជាគ្រឿងប្រព្រឹត្តទៅឲ្យកើតផល ។ បទថា **និកេតោ** “**នៅដូចអ្នកលេង**” បានដល់ រស់នៅ (ដូចជាអ្នកលេង) ។ បទថា **តស្សា បុណ្ណំ** “**ដែលពេញទៅដោយទឹកប្រភេទនោះ**” សេចក្ដីថា លោកចូរទិញក្អមនេះដែលពេញទៅដោយសុរាបែបនោះ ។ បទថា **យត្ថ វិនាសយន្តិ** “**ណា... រមែងវិនាស**”

---

១.បិដក. សញ្ញា បឋវីតិ ។ ២. គតី ។

សេចក្តីថា ជនទាំងឡាយអាស្រ័យទឹកសុរាណា តម្កល់ខ្លួនទុកក្នុងការផឹកទឹកសុរាណា ទម្លាយសម្បត្តិមានទ្រព្យ និងស្រូវអង្ករជាដើមតែម្យ៉ាង ឬសូម្បីច្រើនយ៉ាងឲ្យវិនាស រហូតក្លាយជាជនកំព្រា ។ បទថា **ឥទ្ធានិ “ស្តុកស្តម្ភ”** បានដល់ ស្តុកស្តម្ភ ។ បទថា **ផីតានិ “សម្បូរ”** សេចក្តីថា ស្តុកស្តម្ភបរិបូណ៌ដោយវត្ថាលង្ការ និងគ្រឿងប្រើប្រាស់ទាំងឡាយ ។ បទថា **ឧច្ឆិន្នទាយជ្ជកតានិ “ធ្វើឲ្យដាច់នូវភាពជាទាយាទបាន”** សេចក្តីថា ទឹកសុរានេះរមែងធ្វើទាយាទឲ្យដាច់សូន្យ នាំទ្រព្យសម្បត្តិឲ្យវិនាស ។ បទថា **ទុជ្ជរូបោ**[១] **“អាក្រក់”** សេចក្តីថា ជាបុគ្គលរឹងត្អឹងអាក្រក់ ។ បទថា **គណ្ហេយ្យ “ចាប់ពាល់”** សេចក្តីថា ចាប់កាន់ដៃកូនប្រសារដោយអំណាចនៃកិលេស ដោយសម្គាល់ថាជាកិរិយាបាន ។ បទថា **ទាសំបិ**[២] **“ចាប់ពាល់ទាសៈ”** សេចក្តីថា ចាប់កាន់ដៃសូម្បីទាសៈ អ្នកបម្រើរបស់ខ្លួនដោយអំណាច

---

១.បិដក. ទិត្តរូបោវ ។ ២. ចាប់ពី គណ្ហេយ្យ ដល់ ទាសំបិ (សេចក្តីដូចខុសពីបិដក) ។

កិលេស ដោយសម្គាល់ថាជាស្វាមីរបស់ខ្លួន ។ បទថា **បិត្វាន** “ផឹក ទឹក” បានដល់ ផឹកហើយ ។

បទថា **ទុច្ចរិតំ ចរន្តិ** “ប្រព្រឹត្តទុច្ចរិត” សេចក្តីថា ធ្វើអកុ-សលកម្មបថ ១០ យ៉ាង ដោយត្រៃទ្វារយ៉ាងនេះ ។ បទថា **យាចមានា** “អង្វរ” សេចក្តីថា ជនទាំងឡាយសូម្បីនឹងលះបង់មាសប្រាក់ជាសំណូកទឹកចិត្តដ៏ច្រើន ពោលអង្វរបុរសណាដែលមិនធ្លាប់ផឹកសុរាអំពីមុនថា “លោកចូរកុហក” រមែងមិនបាន ។ បទថា **បិត្វា** “ផឹក” សេចក្តីថា អ្នកបម្រើផឹកទឹកណាហើយ ។ បទថា **នប្បជានាតិ វុត្តោ** “ត្រូវសាកសួរក៏និយាយមិនដឹងរឿង” សេចក្តីថា ត្រូវសាកសួរថា អ្នកមកដើម្បីត្រូវការអ្វី គេមិនដឹងសូម្បីរឿងនោះ ព្រោះខ្លួនទទួលបញ្ជូនដំណើងទៅមិនល្អ ។ បទថា **ហិរិមនាបិ**(១) “អៀនខ្មាស” សេចក្តីថា សូម្បីនឹងមានចិត្តប្រកបទៅដោយហិរិ ។ បទថា

---

១.បិដក. ហិរីមនាបិ ។

ឯកជូបា "ច្រើនដេកត្បុលក្បាលគ្នា" សេចក្តីថា ដេកត្រសុលក្បាលដូចកូនជ្រូក ដេកប្រគរគ្នាដោយជាតិកំណើតដែលថោកទាបដូច្នោះ ។ បទថា **អនាសកា** "អត់បាយក្រហាយទឹក" បានដល់ អត់អាហារ ។ បទថា **ថណ្ឌិលទុក្ខសេយ្យំ** "ដេកជាទុក្ខនៅលើផែនដី" បានដល់ ដេកជាទុក្ខនៅលើផែនដី ។ បទថា **អាយសក្យំ**(១) "ត្រូវតិះដៀល" បានដល់ ពាក្យនិន្ទា ។ បទថា **បត្តក្ខន្ធា** "ធ្លាក់ក" សេចក្តីថា ដេកធ្លាក់ក" ។ បទថា **កូដហាតារិវ** "ដូចគោដែលត្រូវក្រោះដែលចងទុកត្រង់កវាយ" សេចក្តីថា រមែងដេកប្រគរដូចជាគោ ដែលក្រោះចងជាប់នៅត្រង់កបៀតបៀន ។ អធិប្បាយថា រមែងដេកខ្សៀនដូចគោមិនស៊ីស្មៅ ផឹកទឹក ដូច្នោះ ។ បទថា **ឃោរសមិវ**(២) "ប្រៀបដូចពស់មានពិសកាច" បានដល់ ដែលប្រៀបដូចជាពស់មានពិសដ៏កាច ។ បទថា **វិសសមានំ** "ដូចជាថ្នាំពិស" បានដល់ ដែលដូច

---

១.ឋិដក. អាយសក្យញ្ចុបេន្តិ ។ ២. ឃោរវិសមិវ ។

គ្មានថ្នាំពិស ។ បទថា **អន្ធកវេណ្ហុបុត្តា** “ឱរសទាំងឡាយរបស់ស្តេចអន្ធកៈ និងវេណ្ហៈ” បានដល់ រាជាបងប្អូនគ្នា ១០ អង្គ ។ បទថា **ឧបក្កម្ម** “ប្រហារគ្នានឹងគ្នា” បានដល់ ប្រហារគ្នា (ដោយអង្រែ) ។ បទថា **បុព្វទេវា** “បុព្វទេព” បានដល់ អសុរទាំងឡាយ ។ បទថា **តិទិវា** “ត្រៃទិព្វ” សេចក្តីថា ចាកតាវត្តិង្សទេវលោក ។ បទថា **សស្សតិយា** “សម្គាល់ខ្លួនថាទៀង” សេចក្តីថា នៅសម្គាល់ខ្លួនថាទៀងដោយភាពជាអ្នកមានអាយុវែង ។ អធិប្បាយថា ចាកទេវលោកដែលសន្មតគ្នាថាទៀងជានិរន្តរ៍ ។ បទថា **សមាយា** “ដោយអសុរមាយា” សេចក្តីថា ប្រព្រឹត្តទៅជាមួយអសុរមាយា ។

បទថា **ជានំ** “ដឹង” សេចក្តីថា បុរសអ្នកឈ្លាសដូចជាព្រះអង្គកាលជ្រាបថា ទឹកផឹកប្រភេទនេះ ជាទឹករកប្រយោជន៍គ្មានដូច្នោះ នឹងគួរផឹកធ្វើអ្វី ។ បទថា **កុម្ភគតា មយា** “វត្ថុដែលនៅក្នុងក្អមនេះខ្ញុំ” សេចក្តីថា វត្ថុនៅក្នុងក្អមនេះដែលខ្ញុំប្រាប់ហើយ ។ ម្យ៉ាងទៀត

បាឋៈថា **កុម្ភគតំ មយា** ក៏មានន័យដូចគ្នា ។ បទថា **អក្ខាតរូបំ** “ប្រាប់” សេចក្តីថា ដែលខ្ញុំប្រាប់ហើយតាមសេចក្តីពិត ។

ព្រះបាទសព្វមិត្តទ្រង់ស្តាប់ដូច្នោះ ទ្រង់ក៏ជ្រាបទោសរបស់សុរា ពេញព្រះទ័យ កាលនឹងទ្រង់សរសើរសក្កទេវរាជ បានត្រាស់ ២ ព្រះគាថាថា

[៤២៣] ន មេ បិតា វា អថវាបិ មាតា
ឯតាទិសោ យាទិសកោ តុវំសិ
ហិតានុកម្បី បរមត្ថកាមោ
សោហំ ករិស្សំ វចនំ តវជ្ជ ។
ទទាមិ តេ គាមវរានិ បញ្ច
ទាសីសតំ សត្ត គវំសតានិ
អាជញ្ញយុត្តេ ច រថេ ទស ឥមេ
អាចរិយោ ហោសិ មមត្ថកាមោ ។

លោកមិនមែនជាបិតា ឬមាតារបស់ខ្ញុំ ជាបុគ្គលប្រភេទណាមួយ ដែលជាអ្នកមានបំណងអនុគ្រោះ ប្រាថ្នាប្រយោជន៍ដ៏យ៉ាងក្រៃលែងដល់ខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់លោកក្នុងថ្ងៃនេះ ។

ខ្ញុំនឹងឲ្យស្រុកសួយ ៥ ស្រុក ទាសី ១០០ នាក់ គោ ៧០០ ក្បាល និងរថទឹមដោយសេះអាជានេយ្យ ១០ ដល់លោក សូមលោកអ្នកប្រាថ្នាប្រយោជន៍ជាអាចារ្យរបស់ខ្ញុំចុះ ។

បណ្ដាបទទាំងនោះ បទថា **គាមវរានិ** "ស្រុកសួយ" សេចក្ដីថា ព្រះបាទសព្វមិត្តត្រាស់ថា "បពិត្រព្រាហ្មណ៍ អាចរិយភាគ (គឺចំណែកនៃអាចារ្យ) ដែលឈ្មោះថា បុគ្គលអ្នកជាអាចារ្យ រមែងគួរប្រាថ្នា ខ្ញុំសូមប្រគល់ស្រុកសួយ ៥ តំបន់ ដែលមានប្រាក់ចំណូលបានមួយឆ្នាំ ១០០.០០០ កហាបណៈដល់លោក" ។ បទថា **ទសា ឥមេ**[១] "១០ រថនេះ" សេចក្ដីថា និងកាលព្រះបាទសព្វមិត្តទ្រង់

---

១.បិដក. ទស ឥមេ ។

ចន្ទុលដល់រថដែលវិចិត្រដោយមាស ដែលចតទុកចំពោះព្រះភក្ត្រ ១០ រថនោះ ទើបត្រាស់យ៉ាងនេះ ។

សក្កទេវរាជទ្រង់ស្តាប់ដូច្នោះ កាលនឹងទ្រង់សម្តែងអត្តភាពរបស់ទេវតាឲ្យព្រះបាទសព្វមិត្តទ្រង់ស្គាល់ព្រះអង្គ ទើបប្រថាប់ឈរក្នុងអាកាស ត្រាស់ ២ ព្រះគាថាថា

[៤២៤] តវេវ ទាសីសតមត្ថុ រាជ

គាមា ច គាវោ ច តវេវ ហោន្តុ

អាជញ្ញយុត្តា ច រថា តវេវ

សក្កោហមស្មិ តិទសានមិន្ទោ ។

មំសោទនំ សប្បិបាយាសំ កុញ្ច

ខាទស្សុ ច ត្វំ មធុមាសបូវេ

ឯវំ តុវំ ធម្មរតោ ជនិន្ទ

អនិន្ទិតោ សគ្គមុបេហិ ឋានន្តិ ។

ព្រះរាជា ទាសី ស្រុកសួយ គោ និងរថទឹមដោយសេះ អាជានេយ្យ ចូរជារបស់ព្រះអង្គដូចដើមចុះ ខ្ញុំជាសក្កទេវរាជ ជាកំពូលនៃទេវតាជាន់ត្រៃទិព្វ ។

ព្រះអង្គចូរសោយព្រះក្រយាហារ ទឹកដោះថ្លា និងបាយ-បាយាស គប្បីសោយនំកុម្មាសដែលមានឱជារស ព្រះអង្គជាធំលើប្រជាជន ព្រះអង្គចូរត្រេកអរក្នុងធម៌ដែលនរណាៗ មិនតិះដៀលដោយអាការយ៉ាងនេះ នឹងចូលដល់លោកជាដែននៃសួគ៌ ។

បណ្តាបទទាំងនោះ បទថា ឯវំ តុវំ ធម្មរតោ "ព្រះអង្គចូរត្រេកអរក្នុងធម៌... យ៉ាងនេះ" សេចក្តីថា កាលព្រះអង្គសោយនូវភោជនដែលមានរសដ៏ប្រសើរផ្សេងៗ យ៉ាងនេះ និងវៀរការផឹកសុរា លះទុច្ចរិត ៣ ជាអ្នកត្រេកអរតែក្នុងសុចរិតធម៌ ៣ ប្រការដែលនរណាៗ មិនតិះដៀលហើយ ចូរចូលដល់លោកដែលជាដែន

នៃស្ថានសួគ៌ចុះ ។

សក្កទេវរាជកាលទ្រង់ប្រទានឱវាទដល់ព្រះបាទសព្វមិត្ត ដោយប្រការដូច្នេះហើយ ស្តេចក៏ទៅកាន់វិមានរបស់ព្រះអង្គក្នុងរំពេចនោះឯង ។ ចំណែកព្រះបាទសព្វមិត្តទ្រង់ក៏មិនផឹកសុរា ត្រាស់បង្គាប់ឲ្យបំបែកកាជនៈស្រានោះទាំងអស់ ហើយទ្រង់សមាទានសីល បរិច្ចាគទាន បានជាអ្នកមានស្ថានសួគ៌ជាទីទៅខាងមុខ ។ ការផឹកស្រាក៏កើតមានការនិយមទូលំទូលាយជាប់តគ្នាទូទាំងជម្ពូទ្វីប ។

ព្រះសាស្ដា គ្រាទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ប្រជុំជាតកថា "ព្រះរាជាក្នុងកាលនោះ បានមកជាអានន្ទ រីឯសក្កទេវរាជក្នុងគ្រានោះ គឺ **តថាគត** នេះឯង" ។

ចប់អដ្ឋកថា កុម្ភជាតកទី ២

# អដ្ឋកថា ជយទ្ទិសជាតកទី ៣

## (រឿងចៅវិសាខ និងព្រះបាទជ័យទ្ទិស)

*ព្រះសាស្ដាកាលស្ដេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បានប្រារព្ធភិក្ខុចិញ្ចឹមមាតាមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា* ***ចិរស្សំ វត មេ "អស់វេលាយូរណាស់ហើយ... ដែលឃើញ"*** *ដូច្នេះ ។*

*ក៏ក្នុងគ្រានោះ ព្រះសាស្ដាត្រាស់ថា "បុរាណកបណ្ឌិតទាំងឡាយ លះបង់ស្វេតឆត្រដែលប្រដាប់ដោយកាញ្ចនមាលា ហើយចិញ្ចឹមមាតាបិតា" ភិក្ខុនោះក៏ទូលអារាធនា ទើបទ្រង់នាំអតីតនិទានមកត្រាស់សម្ដែងដូចតទៅនេះ ។*

*ក្នុងអតីតកាល មានព្រះរាជាត្រង់ព្រះនាមថា ឧត្តរបញ្ចាលរាជ សោយរាជ្យសម្បត្តិនៅក្នុងកបិលរដ្ឋ ។ ព្រះអគ្គមហេសីរបស់ព្រះអង្គទ្រង់តាំងព្រះគភ៌ហើយប្រសូតព្រះឱរស ។ ក្នុងកពមុន ស្រ្តី*

ម្នាក់រួមស្វាមីជាមួយព្រះនាងបានក្រោធហើយ តាំងសេចក្តីប្រាថ្នាថា "សូមឲ្យយើងអាចទំពាស៊ីបុត្តរបស់នាងដែលប្រសូតហើយ" ដូច្នេះ ហើយបានមកកើតជានាងយក្ខិនី ។ គ្រានោះ នាងយក្ខិនីបានឱកាស ទាំងដែលព្រះនាងទេវីទតព្រះនេត្រឃើញហើយ ក៏ស្រវាចាប់ព្រះ កុមារដែលមានវណ្ណៈដូចជាដុំសាច់ស្រស់ ទំពាស៊ីឮសំឡេងគ្រួបៗ ហើយរត់គេចទៅ ។ សូម្បីក្នុងវារៈទី ២ ក៏ធ្វើយ៉ាងនោះ ។ តែក្នុង វារៈទី ៣ វេលាដែលព្រះនាងទេវីស្តេចចូលទៅកាន់ផ្ទះប្រសូតហើយ ពួករាជបុរសនាំគ្នាយាមជុំវិញដំណាក់ ចាត់ការថ្វាយអារក្ខាដ៏យ៉ាង តឹងរឹង ។ ក្នុងថ្ងៃដែលព្រះទេវីប្រសូត នាងយក្ខិនីក៏មកចាប់យក ទារកទៀត ។ ព្រះនាងទេវីទើបបញ្ចេញព្រះសូរសៀងស្រែកឡើង ថា "យក្ខិនីៗ" ។ រាជបុរសមានអាវុធគ្រប់ដៃ នាំគ្នាដេញជាប់តាម នាងយក្ខិនីតាមសញ្ញាដែលព្រះទេវីប្រាប់ ។ នាងយក្ខិនីមិនបានឱកាស ទំពាស៊ី ក៏គេចអំពីទីនោះចូលទៅកាន់បន្ទប់ទឹក ។ ចំណែកទារក

បើកមាត់សម្លឹងមើលដោះនាងយក្ខិនីដោយសម្គាល់ថាជាមាតា ។ ឯនាងយក្ខិនីក៏កើតសេចក្តីស្រឡាញ់ដូចជាបុត្តរបស់ខ្លួន គេចចេញអំពីបន្ទប់ទឹកបានហើយ ក៏ទៅកាន់សុសានប្បទេស ធ្វើការប្រៀងបំពេទារកនោះនៅក្នុងល្អាងសិលា ។ តមក កាលទារកនោះចម្រើនធំធាត់ឡើងដោយលំដាប់ នាងយក្ខិនីក៏នាំសាច់មនុស្សមកឲ្យស៊ីជាអាហារ ។ ទាំងពីរនាក់ក៏ស៊ីសាច់មនុស្សក្នុងទីនោះឯង ។ ទារកមិនដឹងខ្លួនថាជាមនុស្ស សម្គាល់ថា ជាបុត្តរបស់នាងយក្ខិនី តែក៏មិនអាចបំបាំងខ្លួនបាន ។ តមកនាងយក្ខិនីទើបឲ្យឫសឈើដល់ព្រះរាជកុមារ ដើម្បីត្រូវការបំបាំងខ្លួនបាន ។ ដោយអានុភាពនៃឫសឈើ ព្រះរាជកុមារក៏បំបាំងខ្លួនបាន បានត្រាច់ទៅស៊ីសាច់មនុស្ស ។ នាងយក្ខិនីទៅប្រណិប័តន៍ស្តេចវេស្សវ័ណមហារាជ ហើយបានធ្វើកាលកិរិយាក្នុងទីនោះឯង ។ ចំណែកព្រះនាងទេវីប្រសូព្រះឱរសជាទៅក្នុងវារៈទី ៤ ។ ព្រះរាជឱរសទើបផុតចាកភ័យ ។ ព្រោះផុត

ចាកអំពីនាងយក្ខិនី ព្រះជនកព្រះជននី និងព្រះញាតិបានតាំងព្រះនាមឲ្យព្រះឱរសនោះថា **ជយទ្ទិសកុមារ** ព្រោះកើតមកឈ្នះយក្ខិនីដែលជាបច្ចាមិត្ត ។ ព្រះជយទ្ទិសកុមារទ្រង់ចម្រើនវ័យហើយ ទ្រង់បានសិក្សាសិល្បវិជ្ជាចប់ ហើយទ្រង់បានឲ្យលើកស្វេតឆត្រសោយរាជ្យសម្បត្តិបន្តជាសន្តតិវង្ស ។

គ្រានោះ ព្រះពោធិសត្វបានកើតក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីរបស់ព្រះបាទជយទ្ទិសនោះ ។ ព្រះជនកព្រះជននី និងព្រះញាតិបានតាំងព្រះនាមថា **អលីនសត្តុកុមារ** ។ លុះអលីនសត្តុកុមារចម្រើនវ័យហើយ ទ្រង់សិក្សាសិល្បសាស្ត្រចប់ ក៏បានជាឧបរាជ ។ ក្នុងវេលាតមក កុមារដែលជាបុត្តនាងយក្ខិនីនោះ ធ្វើឲ្យឫសឈើបាត់ដោយសេចក្តីប្រមាទ មិនអាចបំបាំងខ្លួនបាន ទើបមានរូបរាងប្រាកដទំពាស៊ីសាច់មនុស្សនៅព្រៃខ្មោច ។ មនុស្សទាំងឡាយឃើញគេ ក៏នាំគ្នាភ័យខ្លាច ហើយចូលទៅសម្តែងសារទុក្ខចំពោះព្រះរាជា

ថា "ព្រះតេជះ ព្រះអង្គជាអ្នកទ្រទ្រង់នូវគុណដ៏ប្រសើរ មានយក្ខមួយប្រាកដខ្លួនទំពាស៊ីសាច់មនុស្សត្រង់ព្រៃស្មសាន វាតែងចូលមកក្នុងព្រះនគររឿយៗ នឹងសម្លាប់មនុស្សស៊ីជាអាហារ គួរត្រាស់ឲ្យចាប់វា ព្រះអង្គ" ព្រះរាជាទ្រង់ជ្រាបហើយ ទ្រង់មានព្រះរាជឱង្ការបង្គាប់ដល់ពលនិកាយថា "អ្នកទាំងឡាយចូរទៅចាប់យក្ខនោះ ពលនិកាយទាំងនោះនាំគ្នាទៅឈរឡោមព័ទ្ធសុសានប្បទេស ។ កុមារបុត្តនាងយក្ខិនីមានរូបរាងអាក្រាតគួរខ្លាច តក់ស្លុតដល់មរណភ័យ ក៏ស្រែកឡើងដោយសំឡេងខ្លាំងៗ ស្ទុះរត់ទម្លាយហ្វូងមនុស្សទៅ ។ មនុស្សទាំងឡាយភ័យខ្លាចក្នុងមរណភ័យក៏ស្រែកប្រាប់គ្នាថា យក្ខៗបានបែកខ្ញែកគ្នាជាពីរក្រុម ។ ចំណែកកុមារបុត្តរបស់នាងយក្ខិនីគេចអំពីទីនោះបានហើយ ក៏ចូលទៅកាន់ព្រៃ មិនត្រឡប់មកកាន់ដែនដីមនុស្សទៀតឡើយ ។ បានទៅអាស្រ័យនៅព្រៃក្រាស់ជិតផ្លូវធំមួយ ពួនចាំចាប់មនុស្សធ្វើដំណើរឆ្លងកាត់ផ្លូវម្តងមួយ ហើយចូល

ទៅកាន់ព្រៃសម្ងាប់ស៊ី ស្នាក់អាស្រ័យក្រោមដើមនិគ្រោធមួយដើម ។

លំដាប់នោះ ព្រាហ្មណ៍ឈ្មួញរទេះម្នាក់ ជួលអ្នករក្សាព្រៃជាតម្លៃ ១.០០០ កហាបណៈ ដើម្បីនាំជូនព្រៃព្រមដោយរទេះ ៥០០ ។ មនុស្សយក្ខឃើញហើយ ទើបបញ្ចេញសំឡេងលាន់ឡើងស្ទុះរត់ចូលមក មនុស្សទាំងឡាយក៏មានចិត្តភ័យតក់ស្លុត នាំគ្នាក្រាបអស់ ។ មនុស្សយក្ខចាប់ព្រាហ្មណ៍ជាឈ្មួញបានហើយក៏គេចទៅ ត្រូវជន្លត់ឈើបុកត្រង់ជើង និងកាលពួកអ្នករក្សាព្រៃរត់ដេញជាប់តាមមក ទើបលះបង់ព្រាហ្មណ៍ រត់គេចទៅដេកក្រោមដើមឈើជាទីនៅរបស់ខ្លួន ។ កាលមនុស្សយក្សនោះ ដេកក្នុងទីនោះអស់ ៧ ថ្ងៃ ព្រះបាទជ័យទ្ទិសស្ដេចចេញចាកព្រះនគរដើម្បីបរបាញ់សត្វ ។ ព្រាហ្មណ៍អ្នកចិញ្ចឹមមាតាបិតាម្នាក់ឈ្មោះ នន្ទៈ ជាអ្នកក្រុងតក្កសិលា បានរៀនសតារហៈ ៤ បាទ មកគាល់ព្រះបាទជ័យទ្ទិសដែលកំពុងស្ដេច ចេញចាកព្រះនគរ ។

ព្រះបាទជ័យទ្ទិសត្រាស់ថា "យើងត្រឡប់មកវិញនឹងស្លាប់" ទ្រង់ព្រះរាជាទានផ្ទះសម្នាក់ដល់ព្រាហ្មណ៍នោះហើយ ស្ដេចក៏ទៅបាញ់សត្វហើយត្រាស់ថា "ម្រឹគរត់គេចតាមផ្លូវអ្នកណា អ្នកនោះនឹងត្រូវមានទោស" ។

លំដាប់នោះ ឈ្លូសមួយក្បាលក្រោកឡើងស្ទុះរត់មានមុខឆ្ពោះព្រះរាជា ។ អាមាត្យទាំងឡាយក៏នាំគ្នាសើច ។ ព្រះរាជាទ្រង់កាន់ព្រះខ័នដេញជាប់តាមឈ្លូសនោះអស់ចម្ងាយផ្លូវ ៣ យោជន៍ទើបតាមទាន់ ហើយយកព្រះខ័នកាប់ឈ្លូសនោះដាច់ជាពីរកំណាត់ ទ្រង់ដាក់ក្នុងសង្រែករែក ស្ដេចមកដល់ស្ថានទីដែលមនុស្សយក្ខដេកក៏ ទ្រង់ប្រថាប់អង្គុយសម្រាកបន្តិចត្រង់វាលស្មៅ ហើយស្ដេចត្រៀមនឹងធ្វើដំណើរតទៅទៀត ។ លំដាប់នោះ មនុស្សយក្ខក្រោកឡើងពោលថា "ឈប់ អ្នកទៅណា អ្នកនឹងជាអាហាររបស់យើងហើយ" បានចាប់ព្រះហត្ថទុក ពោលគាថាទី ១ ថា

[៤២៥] ចិរស្សំ វត មេ ឧទបាទិ អជ្ជ

កក្ខោ មហា សត្តមិកត្តកាលេ

កុតោសិ កោ វាសិ តទិង្ឃ ព្រូហិ

អាចិក្ខ ជាតឹ វិទិតោ យថាសិ ។

អស់វេលាយូរណាស់ហើយ រាប់តាំងអំពីវេលាដែលយើងអត់អាហារមកគម្រប់ ៧ ថ្ងៃ អាហារយ៉ាងច្រើនគប្បីកើតឡើងដល់យើងថ្ងៃនេះ អ្នកជានរណា មកអំពីណា សូមលោកប្រាប់នូវជាតិត្រកូលតាមដែលដឹងមកចុះ ។

បណ្តាបទទាំងនោះ បទថា កក្ខោ មហា "អាហារយ៉ាងច្រើន" សេចក្តីថា អាហារជាច្រើន ។ បទថា សត្តមិកត្តកាលេ "រាប់តាំងពីវេលាដែលយើងអត់អាហារមកគម្រប់ ៧ ថ្ងៃ" សេចក្តីថា រាប់តាំងអំពីថ្ងៃបាដិបទមក ដល់កាលដែលយើងអត់អាហារគម្រប់ ៧ ថ្ងៃ ។ បទថា កុតោសិ "អ្នក... មកអំពីណា" សេចក្តីថា អ្នកមកអំពី

ទីណា ។

ព្រះរាជាទតព្រះនេត្រឃើញយក្ខហើយក៏តក់ស្លុត មានព្រះកាយរឹងដូចសសរ ទ្រង់មិនអាចនឹងរត់បាន ទើបតាំងព្រះសតិត្រាស់ព្រះគាថាទី ២ ថា

[៤២៦] បញ្ចាលរាជា មិគវំ បវិដ្ឋោ

ជយទ្ទិសោ នាម យទិ សុតោ តេ

ចរាមិ គច្ឆានិ វនានិ ចាហំ

បសទំ ឥមំ ខាទ មមជ្ជ មុញ្ច ។

យើង គឺ ព្រះបាទបញ្ចាលរាជមាននាមថា ជយទ្ទិស បើអ្នកបានឮឈ្មោះក៏គង់នឹងស្គាល់ យើងចេញមកបរបាញ់ម្រឹគ ដើរមកតាមជើងភ្នំ និងដងព្រៃ អ្នកចូរស៊ីសាច់ឈ្លូសនេះចុះ ថ្ងៃនេះចូរលែងយើងទៅ ។

បណ្ដាបទទាំងនោះ បទថា មិគវំ បវិដ្ឋោ "ចេញមកបរបាញ់

ម្រឹគ” សេចក្ដីថា ចេញចាកដែនចូលព្រៃដើម្បីបរបាញ់ម្រឹគ ។ បទថា កច្ឆានិ(១) “ជើងភ្នំ” សេចក្ដីថា ដើរកាត់មកតាមជើងភ្នំ និងដងព្រៃ ។ បទថា បសទំ “ឈ្លូសនេះ” សេចក្ដីថា (អ្នកចូរស៊ី) ឈ្លូសនេះ ។

យក្ខបានឮដូច្នោះ ទើបពោលគាថាទី ៣ ថា

[៤២៧] សោនេវ ត្វំ បណសិ សយ្ហមានោ(២)

មមេស កក្ខា បសទោ យំ វទេសិ

តំ ខាទិយាន បសទំ ជិឃញ្ញំ

ខាទិស្សំ បច្ឆា ន វិលាបកាលោ ។

ព្រះអង្គត្រូវខ្ញុំព្រះអង្គបៀតបៀន ត្រឡប់ជាយកខ្លួនដែលធ្លាក់ជារបស់ខ្ញុំព្រះអង្គនោះឯងមកដោះដូរ ឈ្លូសដែលព្រះអង្គត្រាស់នោះ ជាអាហាររបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គស៊ីព្រះអង្គហើយ

១.បិដក. គច្ឆានិ ។ ២.ឱ. បណសី សស្សមានោ ។

ប្រាថ្នានឹងស៊ីឈ្លួស ក៏នឹងស៊ីជាខាងក្រោយ វេលានេះមិនមែន

ជាវេលាខ្សឹកខ្សួលឡើយ ។

បណ្ដាបទទាំងនោះ បទថា **សោនេវ** "ជារបស់ខ្ញុំព្រះអង្គនោះ ឯង" សេចក្ដីថា ដែលជារបស់ខ្ញុំព្រះអង្គនោះឯង ។ បទថា **បណាសិ** "ដោះដូរ" សេចក្ដីថា ព្រះអង្គត្រាស់យករបស់ខ្ញុំព្រះអង្គមកដោះដូរ ខ្លួន ។ បទថា **សស្សមានោ** "ត្រូវខ្ញុំព្រះអង្គបៀតបៀន" បានដល់ ត្រូវខ្ញុំព្រះអង្គបៀតបៀនហើយ ។ បទថា **តំ ខាទិយាន** "ស៊ីព្រះ អង្គហើយ" សេចក្ដីថា ស៊ីព្រះអង្គមុន ។ បទថា **ជិឃញ្ញំ** "ប្រាថ្នា នឹងស៊ី" សេចក្ដីថា ព្រោះខ្ញុំព្រះអង្គនឹងស៊ីម្រឹគនោះក្នុងកាលជាខាង ក្រោយ ។ បទថា **ន វិលាបកាលោ** "មិនមែនវេលាខ្សឹកខ្សួល" សេចក្ដីថា យក្ខទូលថា "ព្រះអង្គកុំយំឡើយ វេលានេះមិនមែនជា វេលាដែលត្រូវយំឡើយ" ។

ព្រះរាជាទ្រង់ស្ដាប់ដូច្នោះហើយ ទ្រង់រលឹកដល់នន្ទព្រាហ្មណ៍

បាន ទើបត្រាស់ព្រះគាថាទី ៤ ថា

[៤២៨] ន ចត្ថិ មោក្ខោ មម និក្កយេន

គន្ត្វាន បច្ចាគមនាយ បណ្ហេ

តំ សង្គរំ ព្រាហ្មណសប្បទាយ

សច្ចានុរក្ខី បុនរាវជិស្សំ ។

បើសេចក្ដីរួចផុតរបស់យើងមិនមាន ដោយការលោះ សូម ឲ្យយើងបានត្រឡប់ទៅកាន់ព្រះនគរសិន យើងបានប្ដេជ្ញានឹង ព្រាហ្មណ៍ទុកថា នឹងឲ្យទ្រព្យ យើងនឹងរក្សាពាក្យសច្ចៈ នឹង ព្រមត្រឡប់មករកអ្នកម្ដងទៀត ។

បណ្ដាបទទាំងនោះ បទថា ន ចត្ថិ "បើ... មិនមាន" សេចក្ដី ថា ប្រសិនបើការរួចផុតរបស់យើងមិនមាន សូម្បីដោយការដោះដូរ នោះសោត ។ បទថា គន្ត្វាន "ទៅ" សេចក្ដីថា បើដូច្នេះ ថ្ងៃនេះ អ្នកចូរស៊ីសាច់ម្រឹគនេះ ឲ្យយើងបានត្រឡប់ទៅកាន់ព្រះនគរសិន

ចុះ ។ បទថា បណ្ហ "មុន" បានដល់ មុននោះឯង ។ អធិប្បាយ

ថា អ្នកចូរទទួលប្ដេជ្ញាដើម្បីត្រូវការឲ្យយើងត្រឡប់មកឲ្យទាន់វេលា

បរិភោគអាហារព្រឹកស្អែកនេះចុះ ។ បទថា តំ សង្គរំ "សន្យា"

សេចក្ដីថា ព្រោះយើងបានធ្វើការសន្យាជាមួយព្រាហ្មណ៍ថា នឹងឲ្យ

ទ្រព្យដល់គេ គ្រាយើងឲ្យទ្រព្យដល់គេហើយ នឹងតាមរក្សាពាក្យ

សច្ចៈដូចយើងបានពោលហើយ នឹងត្រឡប់មករកអ្នកវិញ ។ យក្ខ

បានស្ដាប់ដូច្នោះ ទើបពោលគាថាទី ៥ ថា

[៤២៩] កឹ កម្មជាតំ អនុតប្បតេ តំ

បត្តំ សមីបំ មរណស្ស រាជ

អាចិក្ខ មេ តំ អបិ សក្កុណេមុ

អនុជានិតុំ អាគមនាយ បណ្ហ ។

បពិត្រព្រះរាជា ព្រះអង្គជិតនឹងសុគតទៅហើយ ទ្រង់នៅក្ដៅ

ក្រហាយដល់កម្មអ្វី សូមចូរត្រាស់ប្រាប់កម្មនោះដល់ខ្ញុំព្រះអង្គ

ខ្ញុំព្រះអង្គនឹងអនុញ្ញាតឲ្យត្រឡប់ទៅវិញបាន ។

កម្មក្នុងគាថានេះ បានដល់ កម្មនោះ ។ បទថា **អនុតប្បតិ តំ**(១) "ក្តៅក្រហាយ" សេចក្តីថា នៅក្តៅក្រហាយចិត្តដល់ករណីយ-កិច្ចអ្វី ។ បទថា **បត្តុំ** "ដល់" ចូលដល់ ។ បទថា **អបិ សក្កុណេមុ** "នឹងអនុញ្ញាត" សេចក្តីថា អើ បើខ្ញុំព្រះអង្គបានស្តាប់ដល់ហេតុនៃសេចក្តីសៅហ្មងរបស់ព្រះអង្គហើយ អាចនឹងអនុញ្ញាតឲ្យព្រះអង្គមកក្នុងវេលាព្រឹកបាន ។

ព្រះរាជាកាលនឹងត្រាស់ប្រាប់ហេតុនោះ ទើបត្រាស់គាថាទី ៦ ថា

[៤៣០] កតា មយា ព្រាហ្មណស្ស ធនាសា
តំ សង្គរំ បដិមោក្ខំ ន មុត្តំ
តំ សង្គរំ ព្រាហ្មណសប្បទាយ

១.បិដក. អនុតប្បតេ តំ ។

សច្ចានុរក្ខី បុនរាវជិស្សំ ។

សេចក្តីប្រាថ្នាក្នុងទ្រព្យ យើងបានធ្វើទុកដល់ព្រាហ្មណ៍ សញ្ញានោះ ជាចំណងចងខ្លួននឹងរួចមិនបាន ព្រោះយើងប្តេជ្ញាទុកថា នឹងឲ្យទ្រព្យដល់ព្រាហ្មណ៍ យើងជាអ្នករក្សាពាក្យសច្ចៈ នឹងត្រឡប់មករកអ្នកវិញ ។

បណ្តាបទទាំងនោះ បទថា **បដិមោក្កំ ន មុត្តុំ** "សញ្ញានោះជាចំណងចងខ្លួនយើងមិនឲ្យរួចបាន" សេចក្តីថា យើងតាំងសេចក្តីប្តេជ្ញាជាសញ្ញាចងនូវខ្លួន ដោយប្តេជ្ញាដល់ព្រាហ្មណ៍ថា នឹងស្តាប់សតារហគាថា ៤ បាទហើយ នឹងឲ្យទ្រព្យដល់គេ ព្រោះយើងមិនទាន់បានឲ្យទ្រព្យដល់ព្រាហ្មណ៍ ទើបរួចផុតមិនបាន ។

យក្ខស្តាប់ដូច្នោះ ទើបពោលគាថាទី ៧ ថា

[៤៣១] យា តេ កតា ព្រាហ្មណស្ស ធនាសា

តំ សង្គរំ បដិមោក្ខំ ន មុត្តុំ

តំ សង្គរំ ព្រាហ្មណសប្បទាយ

សច្ចានុរក្ខី បុនរាវជស្សុ ។

សេចក្ដីបំណាំងក្នុងទ្រព្យ ក៏ព្រះអង្គបានធ្វើទុកដល់ព្រាហ្មណ៍

សញ្ញានោះជាចំណងចងនូវខ្លួនមិនឲ្យរួចបាន ព្រោះបានប្ដេជ្ញា

ទុកដល់ព្រាហ្មណ៍ថា នឹងព្រះរាជទានទ្រព្យ សូមព្រះអង្គទ្រង់

រក្សាពាក្យសច្ចៈដែលស្ដេចនឹងត្រឡប់មកវិញ ។

បណ្ដាបទទាំងនោះ បទថា បុនរាវត្តស្សុ[១] "ចូរស្ដេចត្រឡប់មកវិញ" សេចក្ដីថា ចូរស្ដេចត្រឡប់មកវិញ ។

ក៏គ្រាយក្ខពោលយ៉ាងនេះហើយ ក៏លែងព្រះរាជាទៅ ។ ព្រះរាជានោះដែលយក្ខលែងហើយ ទើបត្រាស់ថា "អ្នកកុំវិតក្កៈឡើយ ខ្ញុំនឹងមកអំពីព្រលឹមនោះឯង" ហើយទ្រង់សង្កេតគ្រឿងសម្គាល់តាមផ្លូវ ស្ដេចចូលទៅរកពលនិកាយ ស្ដេចចូលទៅកាន់ព្រះនគរ ត្រាស់

---

១.បិដក. បុនរាវជស្សុ ។

ឲ្យហៅនន្ទព្រាហ្មណ៍មកគាល់ អញ្ជើញឲ្យអង្គុយលើអាសនៈដែលមានតម្លៃច្រើន ទ្រង់ស្តាប់គាថាចប់ហើយ ក៏ទ្រង់ព្រះរាជទានទ្រព្យ ៤.០០០ កហាបណៈ អញ្ជើញព្រាហ្មណ៍ឲ្យឡើងយានពាហនៈ ទ្រង់ត្រាស់ថា "លោកចូរនាំទ្រព្យនេះទៅកាន់ក្រុងតក្កសិលាចុះ" ទ្រង់ប្រគល់មនុស្សឲ្យហើយក៏បញ្ជូនព្រាហ្មណ៍ទៅ ទ្រង់ព្រះបំណងនឹងស្តេចត្រឡប់ទៅរកយក្ខក្នុងថ្ងៃស្អែកឡើង ទើបត្រាស់ឲ្យរកព្រះឱរសមក ទ្រង់ទូន្មាន ។

ព្រះសាស្តាកាលនឹងទ្រង់ប្រកាសសេចក្តីនោះ ទើបបានត្រាស់ ២ ព្រះគាថាថា

[៤៣២] មុត្តោ ច សោ បោរិសាទស្ស ហត្ថា
គន្ត្វា សកំ មន្ទិរំ កាមកាមី
តំ សន្ធំ ព្រាហ្មណស្សប្បទាយ
អាមន្តយី បុត្តមលីនសត្តុំ ។

អជ្ជេវ រជ្ជំ អភិសេចយស្សុ
ធម្មញ្ច រដ្ឋេសុ ជនេសុ ចាបិ
អធម្មការោ ច តេ មាហុ រដ្ឋេ
គច្ឆាមហំ បោរិសាទស្ស ញាត្តេ[១] ។

ព្រះបាទជយទ្ទិសនោះ ទ្រង់រួចផុតពីកណ្តាប់ដៃយក្ខហើយ ស្តេចប្រញាប់ត្រឡប់ទៅកាន់ព្រះរាជមន្ទីររបស់ព្រះអង្គ ព្រោះទ្រង់បានបេ្តជ្ញាទុកដល់ព្រាហ្មណ៍ថា នឹងព្រះរាជទានទ្រព្យ បានត្រាស់ឲ្យរកព្រះរាជឱរសព្រះនាមថា អលីនសត្តុ ចូលមកគាល់ ត្រាស់ថា អ្នកចូរអភិសេកគ្រប់គ្រងរដ្ឋសីមាក្នុងថ្ងៃនេះ ចូរប្រព្រឹត្តធម៌ក្នុងរដ្ឋសីមា និងក្នុងប្រជាជនទាំងឡាយ បុគ្គលមិនប្រព្រឹត្តធម៌ ចូរកុំមានក្នុងដែនរបស់កូន យើងនឹងទៅក្នុងសម្នាក់របស់យក្ខ ។

បណ្តាបទទាំងនោះ បទថា អលីនសត្តុំ "ព្រះរាជឱរសព្រះ

---

១.ម. បោរិសាទស្ស បន្តេ , ឱ. បោរិសាទស្ស ញាត្តេ ។

នាមថា អលីនសត្តុ" បានដល់ ព្រះរាជកុមារអ្នកមានព្រះនាមយ៉ាងនេះ ។ តែក្នុងព្រះបាលីលោកសរសេរទុកថា "អលីនសត្តុ:" ។ បទថា អជ្ជេវ រជ្ជំ "គ្រប់គ្រងរជ្ជសីមាក្នុងថ្ងៃនេះ" សេចក្ដីថា កូនជាទីស្រឡាញ់ បិតានឹងប្រគល់រាជ្យសម្បត្តិឲ្យដល់អ្នក កូនចូរស្រង់ទឹកអភិសេកក្នុងថ្ងៃនេះឯង ។ បទថា ញាន្តេ "សម្នាក់" បានដល់ក្នុងសម្នាក់ ។

ព្រះរាជកុមារទ្រង់ស្ដាប់ដូច្នោះ បានត្រាស់គាថាទី ១០ ថា

[៤៣៣] កឹ កម្មកុព្វំ តវ ទេវ បាទេ(១)

នារាធយឹ តំ តទិច្ឆាមិ សោតុំ

យមជ្ជ រជ្ជម្ហិ ឧទស្សយេ តុវំ

រជ្ជំបិ និច្ឆេយ្យ តយា វិនាហំ ។

បពិត្រព្រះរាជបិតាអ្នកទ្រទ្រង់នូវគុណដ៏ប្រសើរ ខ្ញុំព្រះអង្គបាន

---

១.ម. ទេវ បាវ ។

ធ្វើសេចក្តីមិនពេញព្រះទ័យអ្វីទុកក្រោមបាតព្រះបាទ ខ្ញុំព្រះអង្គប្រាថ្នានឹងបានស្តាប់សេចក្តីដែលព្រះអង្គនឹងឲ្យឡើងគ្រងរាជ្យ-សម្បត្តិក្នុងថ្ងៃនេះ ព្រោះខ្ញុំព្រះអង្គមិនមានព្រះរាជបិតាហើយ មិនប្រាថ្នាសូម្បីរាជ្យសម្បត្តិឡើយ ។

បណ្តាបទទាំងឡាយ បទថា **កុព្វំ** "**បានធ្វើ**" បានដល់ ធ្វើហើយ ។ បទថា **យមជ្ជ** "**ក្នុងថ្ងៃនេះ**" សេចក្តីថា ព្រះរាជបិតាឲ្យខ្ញុំព្រះអង្គឡើងគ្រងរាជ្យសម្បត្តិក្នុងថ្ងៃនេះ ព្រោះធ្វើការដែលមិនពេញព្រះទ័យណា ។ បទថា **ឧទស្សយេ** "**នឹងឲ្យឡើង**" សេចក្តីថា ព្រះរាជបិតាទ្រង់លើកឡើង គឺ តែងតាំងឲ្យខ្ញុំព្រះអង្គតាំងនៅក្នុងរាជ្យសម្បត្តិ ព្រោះការធ្វើមិនពេញព្រះទ័យណា សូមព្រះអង្គត្រាស់ប្រាប់ការធ្វើនោះ ព្រោះខ្ញុំព្រះអង្គខ្វះព្រះអង្គហើយ រមែងមិនប្រាថ្នាសូម្បីរាជ្យសម្បត្តិ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទើបត្រាស់ព្រះគាថាតទៅថា

[៤៣៤] ន កម្មុនា វា វចសា ច តាត
អបរាធិតោហំ តុវិយំ សរាមិ
សន្ធិញ្ច កត្វា បុរិសាទកេន
សច្ចានុរក្ខី បុនហំ គមិស្សំ ។

កូនសម្លាញ់ បិតាមិនបានទឹកដល់កំហុសផ្លូវកាយកម្ម និងវចី-កម្មរបស់កូនឡើយ តែបិតាបានធ្វើសេចក្តីយល់ព្រមជាមួយយក្ខ បិតាត្រូវរក្សាពាក្យសច្ចៈ ទើបត្រូវត្រឡប់ទៅវិញ ។

បណ្តាបទទាំងនោះ បទថា **អបរាធិតោ**[១] "កំហុស" សេចក្តីថា យើងមិនទឹកដល់កំហុសផ្លូវត្រែទ្វាររបស់អ្នកឡើយ ។ បទថា **តុវិយំ** "របស់អ្នក" បានដល់ របស់កូន ។ មានពាក្យអធិប្បាយថា កូនសម្លាញ់ បិតាមិនបានរលឹកដល់កំហុសដែលមិនជាទីប្រោស-ប្រាណរបស់បិតាអ្វីៗ របស់កូនទាំងផ្លូវកាយ និងផ្លូវវាចាឡើយ ។

---

១.បិដក. អបរាធិតោហំ ។

បទថា *សន្ទិញ្ច កត្វា* “ធ្វើសេចក្ដីយល់ព្រមទុក” សេចក្ដីថា ព្រះរាជាត្រាស់ថា “តែព្រោះយក្ខមួយចាប់បិតាបាន គ្រាទៅព្រៃបរបាញ់សត្វ ដោយគិតថា នឹងស៊ីជាអាហារ” ដូច្នោះ ទើបបិតាឲ្យនូវពាក្យសច្ចៈនឹងយក្សនោះថា “កាលយើងបានស្ដាប់ធម្មកថារបស់ព្រាហ្មណ៍ធ្វើសក្ការៈដល់គេហើយ នឹងមកឲ្យទាន់វេលាអាហារព្រឹកថ្ងៃស្អែកនេះ ទើបត្រឡប់មកបាន” ព្រោះហេតុនោះ ដើម្បីនឹងតាមរក្សាពាក្យសច្ចៈ បិតានឹងត្រូវទៅកាន់ទីនោះវិញ ចូរកូនសោយរាជ្យសម្បត្តិចុះ” ។

អលីនសត្តុរាជកុមារ ស្ដាប់ព្រះរាជតម្រាស់របស់ព្រះរាជបិតាហើយ ក៏ត្រាស់គាថាថា

[៤៣៥] អហំ គមិស្សាមិ ឥធេវ ហោហិ
នត្ថិ តតោ ជីវតោ វិប្បមោក្ខោ
សចេ តុវំ គច្ឆសិយេវ រាជ

*អហំបិ គច្ឆាមិ ឧភោ ន ហោម ។*

*ខ្ញុំព្រះអង្គនឹងទៅជំនួស សូមព្រះរាជបិតាទ្រង់ប្រថាប់នៅទីនេះចុះ កាលបើផ្លូវដែលនឹងបានរួចជីវិតអំពីសម្នាក់នៃយក្សនោះមិនមាន បពិត្រព្រះរាជបិតា ប្រសិនបើព្រះអង្គមានព្រះបំណងនឹងស្តេចឲ្យបាន ខ្ញុំព្រះអង្គនឹងទៅតាមព្រះអង្គដែរ យើងទាំងពីរសុខចិត្តស្លាប់ ។*

បណ្តាបទទាំងនោះ បទថា **ឥធេវ** “នៅទីនេះ” សេចក្តីថា សូមព្រះអង្គទ្រង់ប្រថាប់នៅទីនេះចុះ ។ បទថា **តតោ** “នោះ” មានសេចក្តីថា ដែលឈ្មោះថា ការរួចជីវិតអំពីសម្នាក់របស់យក្សនោះមិនមានឡើយ ។ បទថា **ឧភោ** “ទាំងពីរ” សេចក្តីថា បើដូច្នេះក៏ជាការមិនត្រូវរស់នៅទាំងពីរនាក់ ។

ព្រះរាជាទ្រង់ស្តាប់ដូច្នោះ ទើបត្រាស់ព្រះគាថាថា

[៤៣៦] *អទ្ធា[១] ហិ តាត សតានេស ធម្មោ*

---

១ម. សទ្ធា ។

*មរណា ច មេ ទុក្ខតរំ តទស្ស*

*កម្មាសបាទោ តំ យទា បចិត្វា*

*បសយ្ហ ខាទេ ភិទារុក្ខមូលេ ។*

*កូនសម្លាញ់ នោះជាធម្មតារបស់សប្បុរសដោយពិត តែកាល*

*ណាយក្ខដែលមានជើងពពាលទម្លាយលោក ដុតអាំងអ្នកស៊ី*

*ត្រង់ក្រោមដើមឈើ ប្រការនេះឯង ទើបជាទុក្ខយ៉ាងក្រៃលែង*

*ជាងការស្លាប់របស់បិតាទៅទៀត ។*

ព្រះគាថានោះមានអធិប្បាយថា នោះជាធម៌ គឺ ធាតុពិតនៃ សប្បុរស គឺ បណ្ឌិតទាំងឡាយដោយពិត កូននិយាយពាក្យត្រឹមត្រូវ ហើយ ប៉ុន្តែថា នឹងជាសេចក្តីទុក្ខយ៉ាងក្រៃលែងជាងសេចក្តីស្លាប់ របស់បិតា ប្រការនោះជាមន្ទិល ជាទោសចងចំពោះបិតា ។

បទថា *ភិទារុក្ខមូលេ* “ទម្លាយ... ត្រង់គល់ឈើ” សេចក្តីថា កាលយក្សញាំញីទម្លាយដុតអាំងអ្នកស៊ីដោយពលការ ត្រង់ក្រោមដើម

ឈើយ៉ាងក្មៀវក្លា ។

ព្រះរាជកុមារទ្រង់ស្តាប់ដូច្នោះហើយ ទើបត្រាស់គាថាថា

[៤៣៧] បាណេន តេ បាណមហំ និមិស្សំ

មា ត្វំ អគា បោរិសាទស្ស ញាន្តេ

ឯតញ្ច តេ បាណមហំ និមិស្សំ

តស្មា មតំ ជីវិតស្ស វណ្ណេមិ ។

ខ្ញុំព្រះអង្គ សូមយកជីវិតរបស់ខ្ញុំព្រះអង្គប្តូរព្រះជន្មជីពរបស់ព្រះបិតា ព្រះរាជបិតាស្តេចកុំទៅក្នុងសម្នាក់របស់យក្សឡើយ ខ្ញុំព្រះអង្គ នឹងសូមយកជីវិតរបស់ខ្ញុំព្រះអង្គប្តូរព្រះជន្មជីពរបស់ព្រះរាជបិតានេះឯង ព្រោះដូច្នោះ ខ្ញុំព្រះអង្គសូមព្រមស្លាប់ជំនួសព្រះរាជបិតា ។

បណ្តាបទទាំងនោះ បទថា និមិស្សំ "ប្តូរ... ជំនួស" សេចក្តីថា ខ្ញុំព្រះអង្គនឹងប្តូរជីវិតរបស់ខ្លួនជាមួយព្រះជន្មរបស់ព្រះរាជបិតា

ក្នុងគ្រានេះឯង ។ បទថា **តស្មា** “ព្រោះដូច្នោះ” សេចក្តីថា ព្រោះខ្ញុំព្រះអង្គនឹងបួរព្រះជន្មរបស់ព្រះរាជបិតា ដូច្នោះ ទើបជ្រើសរើសយកសេចក្តីស្លាប់ដើម្បីត្រូវការឲ្យព្រះរាជបិតាមានព្រះជន្ម ខ្ញុំព្រះអង្គសរសើរសេចក្តីស្លាប់តែម្យ៉ាងប៉ុណ្ណោះ ទើបជ្រើសរើស គឺ ប្រាថ្នាសេចក្តីស្លាប់ ។

ព្រះបាទជ័យទ្ទិសទ្រង់បានស្តាប់ដូច្នោះ ទ្រង់ជ្រាបកម្លាំងរបស់ព្រះឱរស ទើបត្រាស់ថា “ប្រពៃហើយកូនសម្លាញ់ កូនចូរទៅចុះ” ។ អលីនសត្តុរាជកុមារថ្វាយបង្គំលាព្រះរាជមាតាព្រះរាជបិតាហើយ ក៏ស្តេចចេញចាកព្រះនគរ ។

ព្រះសាស្តាកាលនឹងប្រកាសនូវសេចក្តីនោះ ទើបត្រាស់កន្លះគាថាថា

[៤៣៨] តតោ ហវេ ធីតិមា រាជបុត្តោ
វន្ទិត្វា មាតុញ្ច បិតុញ្ច បាទេ ។

លំដាប់នោះ ព្រះរាជឱរសអ្នកមានប្រាជ្ញា ថ្វាយបង្គំព្រះយុ-
គលបាទព្រះជនកព្រះជននីហើយ ស្តេចចេញទៅ ។

បណ្តាបទទាំងនោះ បទថា **បាទេ** "ព្រះយុគលបាទ" សេចក្តី
ថា ថ្វាយបង្គំព្រះយុគលបាទព្រះជនកព្រះជននី ស្តេចបានយាងទៅ
ហើយ ។

លំដាប់នោះ ព្រះជនកព្រះជននីក្តី ព្រះភគនីក្តី ព្រះជាយាក្តី
របស់ព្រះកុមារនោះ ព្រមទាំងពួកអាមាត្យ និងរាជបរិវារ ក៏ស្តេច
ចេញទៅជាមួយ ។ គ្រាព្រះរាជកុមារនោះចេញចាកព្រះនគរហើយ
ក៏ទូលសួរផ្លូវចំពោះព្រះរាជបិតាកំណត់ចំណាំដោយល្អហើយ ថ្វាយ
បង្គំព្រះជនកព្រះជននី ប្រទានឱវាទដល់ជនដ៏សេស មិនមានព្រះ
ទ័យតក់ស្លុតអ្វីឡើយ ស្តេចយាងឡើងកាន់ផ្លូវធ្វើដំណើរទៅកាន់ទី
លំនៅរបស់យក្ស ប្រៀបដូចជាក្រៃសរសីហរាជ ។ ព្រះមាតាទត
ព្រះនេត្រឃើញព្រះកុមារកំពុងទ្រង់ដំណើរទៅ មិនអាចតាំងព្រះអង្គ

បាន ក៏ដួលចុះលើប្រឹថពី ។ ព្រះរាជបិតាទ្រង់ក៏ផ្គងព្រះពាហាខ្សឹក-ខ្សួលដោយសំឡេងដ៏ខ្លាំង ។

កាលព្រះសាស្តាទ្រង់នឹងប្រកាសសេចក្តីនោះ ទើបត្រាស់កន្លះគាថាថា

ទុក្ខិនិស្ស មាតា និបតី បឋព្យា
បិតស្ស បគ្គយ្ហ ភុជានិ កន្ទតិ ។

ព្រះជននីរបស់ព្រះរាជកុមារនោះ ទ្រង់មានទុក្ខទោមនស្សបាន ដួលចុះលើប្រឹថពី ព្រះជនកនាថក៏ទ្រង់ផ្គងព្រះពាហា ទ្រង់ខ្សឹក ខ្សួលដោយសំឡេងដ៏ខ្លាំង ។

គ្រាត្រាស់កន្លះគាថានេះហើយ កាលទ្រង់នឹងប្រកាសសច្ច-កិរិយា ដែលព្រះរាជបិតារបស់ព្រះរាជកុមារនោះទ្រង់ប្រកប និង ដែលព្រះរាជមាតា ព្រះភគនី និងព្រះជាយាធ្វើហើយ ទើបទ្រង់បាន ត្រាស់ព្រះគាថាបន្តទៀត ៤ ព្រះគាថាថា

[៤៣៩] តំ គច្ឆន្តំ តាវ បិតា វិទិត្វា

បរម្មុខោ វន្ទតិ បញ្ជលីកោ[១]

សោមោ ច រាជ វរុណោ ច រាជា

បជាបតី ចន្ទិមា សុរិយោ ច

ឯតេហិ គុត្តោ បុរិសាទកម្ហា

អនុញ្ញាតោ សោត្ថិ បច្ចេហិ[២] តាត ។

ព្រះរាជបិតាទ្រង់ជ្រាបច្បាស់ថា ព្រះឱរសកំពុងឆ្ពោះមុខស្ដេចទៅ ទ្រង់បែរព្រះភក្ត្រផ្គងអញ្ជលីក្រាបសំពះទេវតាទាំងឡាយ គឺ ព្រះសោមរាជា ព្រះវរុណរាជ ព្រះបជាបតី ព្រះចន្ទនិងព្រះអាទិត្យ សូមទេវតាទាំងនេះជួយឃុំគ្រងព្រះឱរសរបស់យើងពីអំណាចរបស់យក្ស អលីនសត្តកូនសម្លាញ់ សូមយក្សនោះចូរអនុញ្ញាតឲ្យកូនត្រឡប់មកដោយសួស្ដី ។

១.ឱ.ម. បញ្ចសី សោ ។ ម. មុញ្ចេហិ ។

[៤៤០] យំ ទណ្ឌកិរញ្ញោ គតស្ស មាតា
រាមស្ស កាសិ សោត្ថានំ សុគុត្តា
តន្តេ អហំ សោត្ថានំ ករោមិ
ឯតេន សច្ចេន សរន្តុ ទេវា
អនុញ្ញាតោ សោត្ថិ បច្ចេហិ បុត្ត ។

មាតារបស់រាជបុរសអ្នកទៅកាន់ដែនរបស់ស្តេចទណ្ឌកិ-រាជ បានឃុំគ្រងដោយល្អ បានធ្វើនូវសួស្តីដល់រាមៈដែលជាបុត្តយ៉ាងណា មាតាសូមធ្វើនូវសួស្តីយ៉ាងនោះដល់កូន ដោយពាក្យសច្ចនេះ សូមទេវតាជួយរក្សា សូមឲ្យកូនបានទទួលនូវអនុញ្ញាតត្រឡប់មកដោយសួស្តីចុះ កូនសម្លាញ់ ។

[៤៤១] អាវី រហោវាបិ មនោបទោសំ
នាហំ សរេ ជាតុមលីនសត្តេ
ឯតេន សច្ចេន សរន្តុ ទេវា

អនុញ្ញាតោ សោត្ថិ បចេ្ចហិ ភាតា ។

ប្អូនគិតមិនឃើញឡើយ សូម្បីការគិតនឹងប្រទូស្តក្នុងអ-លីនសត្តជាព្រះជេដ្ឋា ទាំងក្នុងវាល និងក្នុងទីកំបាំង ដោយពាក្យសច្ចៈនេះ សូមទេវតាប្រោសលើកដល់ព្រះជេដ្ឋាដែលជាទីគោរព សូមព្រះជេដ្ឋាចូរបាននូវការអនុញ្ញាតឲ្យត្រឡប់មកដោយសួស្តី ។

[៤៤២] យស្មា ច មេ អនធិមនោសិ សាមិ

ន ចាបិ មេ មនសា អប្បិយោសិ

ឯតេន សច្ចេន សរន្តុ ទេវា

អនុញ្ញាតោ សោត្ថិ បចេ្ចហិ សាមិ ។

បពិត្រព្រះស្វាមី ព្រះអង្គមិនធ្លាប់ប្រព្រឹត្តក្បត់ចិត្តខ្ញុំព្រះអង្គឡើយ ដូច្នោះ ទើបជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គដោយពិតដោយភាពសច្ចៈនេះ សូមទេវតាប្រោសលើកដល់ព្រះស្វាមី

ជាទីគោរព បពិត្រព្រះស្វាមី សូមព្រះអង្គចូរបានទទួលនូវការ

អនុញ្ញាតឲ្យត្រឡប់មកដោយសួស្តី ។

បណ្តាបទទាំងនោះ បទថា **បរម្មុខោ** **"ស្តេចផ្ទោះមុខទៅ"** សេចក្តីថា ព្រះរាជបិតាទ្រង់ជ្រាបច្បាស់ថា "ព្រះឱរសរបស់យើងនេះ កំពុងមានមុខផ្ទោះទៅ" ។ បទថា **បញ្ជលីកោ** **"ផ្គងអញ្ជលី"** សេចក្តីថា ទ្រង់បែរព្រះភក្ត្រប្រតិស្ឋានអញ្ជលីលើសីសៈ ក្នុងកាលនោះទ្រង់សំពះអង្វរ នមស្ការទេវតាទាំងឡាយ ។ បទថា **បោរិសាទកម្មា** **"ចាកអំណាចរបស់យក្ស"** សេចក្តីថា សូមទេវតាចូរជួយឃុំគ្រងឱរសរបស់យើងពីអំណាចរបស់យក្ស អលីនសត្តកូនសម្លាញ់យក្សនោះចូរអនុញ្ញាតឲ្យកូនត្រឡប់មកដោយសួស្តីចុះ ។

បទថា **រាមស្សកា**[១] **"មាតារបស់រាមបុត្ត"** សេចក្តីថា មាតារបស់រាមបុរសបានធ្វើសេចក្តីឃុំគ្រង ។ តំណាលមកថា មានបុរស

---

១.បិដក. រាមស្ស កាសិ ។

ម្នាក់ជាអ្នកក្រុងពារាណសីឈ្មោះរាមៈ ជាអ្នកចិញ្ចឹមមាតា បដិបត្តិមាតាបិតា គ្រាមួយទៅលក់ទំនិញដល់ក្រុងកុម្ភវតី ក្នុងដែនរបស់ព្រះបាទទណ្ឌកិរាជ កាលដែនទាំងមូលត្រូវវិនាសដោយភ្លៀង ៩ ប្រការគេបានរលឹកដល់គុណរបស់មាតាបិតា ។ គ្រានោះ ដោយផលមាតាបិតុឧបដ្ឋានធម៌ ទេវតាទាំងឡាយបាននាំគេមកប្រគល់ឲ្យដល់មាតាដោយសួស្តី ។ ព្រះជននីរបស់អលីនសត្តុរាជកុមារទ្រង់នាំហេតុការណ៍នោះមកត្រាស់យ៉ាងនេះ ព្រោះបានឮបានស្តាប់មក ។

បទថា *សោត្ថានំ “ដោយសួស្តី”* បានដល់ សេចក្តីសួស្តី ។ សូម្បីទេវតាទាំងឡាយនឹងធ្វើនូវសេចក្តីសួស្តីបានក៏ពិត តែលោកពោលថា មាតាបានធ្វើហើយ ព្រោះកើតហើយអាស្រ័យមាតាបិតុឧបដ្ឋានធម៌ ។ បទថា *តន្តេ អហំ “ម៉ែ... យ៉ាងនោះដល់កូន”* គឺ (មាតារបស់រាមបុរសធ្វើនូវសួស្តីដល់រាមៈជាបុត្ត យ៉ាងណា) សូម្បីម៉ែក៏ធ្វើនូវសួស្តីដល់កូនដូចគ្នា គឺ ព្រោះអាស្រ័យម៉ែ សូមសេចក្តី

សួស្តីចូរមានដល់កូនរបស់ម៉ែដូច្នោះដូចគ្នា ។ ន័យមួយទៀត បទថា **ករោមិ** “សូមធ្វើ” បានដល់ នឹងទៅ ។ បទថា **ឯតេន សច្ចេន** “**ដោយសច្ចៈនេះ**” សេចក្តីថា បើថាពាមបុរសនោះជាអ្នកដែលទេវតា នាំមកហើយដោយសួស្តីជាការពិតសោត ដោយអំណាចនៃសច្ចៈនោះ សូមទេវតាទាំងឡាយចូររលឹកដល់កូន ដើម្បីព្រះជនក ព្រះជននី គឺ សូមទេវតាចូរនាំកូនមកសម្តែងដល់មាតា ដូចជាពាមបុរសនោះចុះ ។

បទថា **អនុញ្ញាតោ** “**បានទទួលនូវអនុញ្ញាត**” សេចក្តីថា កូនសម្លាញ់ ដែលយកអនុញ្ញាតថាទៅបាន ។ គឺ ព្រះជននីត្រាស់ថា “កូនសម្លាញ់ សូមកូនចូរត្រឡប់មកដោយសួស្តីដោយទេវានុភាពចុះ” ។

បទថា **ជាតុមលីនសត្តេ** “**អលីនសត្តុជាព្រះជេដ្ឋា**” សេចក្តីថា ព្រះកនិដ្ឋកគិនីរបស់អលីនសត្តុរាជកុមារនោះ បានតាំងសត្យា-

ធិដ្ឋានយ៉ាងនេះថា “ប្អូនរលឹកមិនបានដល់ការគិតប្រទូស្តទាំងចំពោះមុខ ឬក្រោយខ្នង ចំពោះអលីនសត្តុជាព្រះជេដ្ឋាដោយចំណែកណាមួយទីមួយដោយពិត” ។ បទថា **យស្មា ច មេ អនធិមនោសិ សាមិ** **“បពិត្រព្រះស្វាមី ព្រះអង្គមិនធ្លាប់ប្រព្រឹត្តក្បត់ចិត្តខ្ញុំព្រះអង្គឡើយ”** សេចក្តីថា ព្រះអគ្គមហេសីរបស់អលីនសត្តុរាជកុមារនោះ បានតាំងសច្ចាធិដ្ឋានយ៉ាងនេះថា “បពិត្រព្រះអលីនសត្តុព្រះស្វាមី ព្រះអង្គមិនបានប្រព្រឹត្តក្បត់ចិត្តខ្ញុំម្ចាស់ឡើយ គឺ ព្រះអង្គមិនបានប្រព្រឹត្តកន្លងខ្ញុំម្ចាស់ មានតែការយកព្រះទ័យមិនប្រាថ្នាស្រីដទៃឡើយ” ។ បទថា **ន ចាបិ មេ មនសា អប្បិយោសិ “ទើបបានជាទីស្រឡាញ់ពេញចិត្តដោយពិត”** សេចក្តីថា ព្រះអង្គនឹងមិនជាទីស្រឡាញ់ដោយចិត្តពិតរបស់ខ្ញុំម្ចាស់ក៏មិនមែន យើងទាំងពីរនាក់នៅរួមគ្នាមកដោយសេចក្តីស្រឡាញ់តែម្យ៉ាង ។

ព្រះរាជកុមារស្តេចយាងទៅកាន់ផ្លូវជាទីនៅរបស់យក្ស តាម

ពាក្យណែនាំដែលព្រះរាជបិតាត្រាស់ប្រាប់ ។ ចំណែកយក្សគិតថា "ធម្មតាក្សត្រមានមាយាច្រើន នរណានឹងដឹងថា នឹងកើតអ្វីឡើង" ទើបឡើងដើមឈើអង្គ្រុយមើលផ្លូវដែលព្រះបាទជយទ្ទិសស្តេចនឹងមក ។ យក្សឃើញព្រះកុមារកំពុងធ្វើដំណើរមក គិតថា ប្រហែលព្រះឱរសឲ្យព្រះរាជបិតាត្រឡប់ ហើយខ្លួនមកជំនួស ភ័យគង់មិនមានដល់យើងទេ ទើបចុះអំពីដើមឈើអង្គ្រុយផ្អែកខ្នង ។ ព្រះរាជកុមារស្តេចមកដល់ហើយ ចូលទៅឈរចំពោះមុខយក្ស ។

លំដាប់នោះ យក្សពោលគាថាថា

[៤៤៣] ព្រហា ឧជូ ចារុមុខោ កុតោសិ
ន មំ បជានាសិ វនេ វសន្តំ
លុទ្ទំ មំ ញត្វា បុរិសាទកោតិ
កោ សោត្ថិមាជានមិធាវជេយ្យ ។

អ្នកមានរាងកាយខ្ពស់ធំ មានមុខស្រស់បស់ មកអំពីណា អ្នក

មិនដឹងទេថា យើងនៅក្នុងព្រៃ នរណាៗ រមែងស្គាល់យើង ដែលជាបុគ្គលកាចសាហាវជាយក្សស៊ីមនុស្ស អ្នកមិនដឹងដល់ការផុតភ័យរបស់ខ្លួនទេឬ ទើបមកក្នុងទីនេះ ។

បណ្ដាបទទាំងនោះ បទថា កោ សោត្ថិមាជានមិធាវជេយ្យ "អ្នកមិនដឹងការផុតភ័យរបស់ខ្លួន... ទើបមកក្នុងទីនេះ" សេចក្ដីថា នៃកុមារ បុរសណាហ្ន៎ដឹងការផុតភ័យរបស់ខ្លួន ដើរទៅដោយក្ខា-ហានមកក្នុងទីនេះ ប្រហែលជាអ្នកមិនដឹងហើយទើបមក ។

ព្រះរាជកុមារស្ដាប់ដូច្នោះ ទើបត្រាស់គាថាថា

[៤៤៤] ជានាមិ លុទ្ទ បុរិសាទកោ ត្វំ
ន តំ ន ជានាមិ វនេ វសន្តំ(១)
អហញ្ច បុត្តោស្មិ ជយទ្ទិសស្ស
មមជ្ជ ខាទ បិតុនោ បមោក្ខា ។

---

១.ម. វសន្តិ ។

យើងដឹងថា អ្នកជាបុគ្គលអាក្រក់ស៊ីមនុស្ស តែមិនដឹងថាអ្នក

នៅក្នុងព្រៃនេះទេ យើងគឺឱរសរបស់ស្តេចជយទិស ថ្ងៃនេះ

អ្នកចូរស៊ីយើងជំនួសព្រះជនក ចូរដោះលែងព្រះបិតារបស់

យើងចុះ ។

បណ្តាបទទាំងនោះ បទថា **បមោក្ខ**[១] "ចូរលែង" សេចក្តី

ថា ព្រោះហេតុដែលដោះនូវការៈចេញ យើងទើបព្រមប្រគល់ជីវិត

ជំនួសព្រះរាជបិតាមកក្នុងទីនេះ ព្រោះដូច្នោះ អ្នកចូរដោះលែងព្រះ

ជនករបស់យើង ហើយស៊ីយើងជំនួសព្រះអង្គចុះ ។

លំដាប់នោះ យក្សពោលគាថាថា

[៤៤៥] ជានាមិ បុត្តោសិ ជយទ្ទិសស្ស

តថាហិ វោ មុខវណ្ណោ ឧភិន្នំ

សុទុក្ករញ្ចេវ កតំ តវេទំ

១.បិដក. បមេក្ខា ។

យោ មត្តុមិច្ឆ បិតុនោ បមោក្ខា ។

យើងដឹងថា អ្នកជាឱរសរបស់ស្តេចជយទ្ទិស មើលព្រះភក្ត្រ និងពណ៌សម្បុររបស់អ្នកទាំងពីរស្រដៀងគ្នា ការដែលបុគ្គលព្រមស្លាប់ជំនួសដើម្បីលោះបិតាឲ្យរួចផុតទៅនេះ ជាកម្មដែលធ្វើបានលំបាក តែអ្នកក៏ធ្វើបាន ។

បណ្តាបទទាំងនោះ បទថា **តាទិសោ វោ**(១) "របស់អ្នកទាំងពីរស្រដៀងគ្នា" សេចក្តីថា ព្រះភក្ត្រ និងពណ៌សម្បុររបស់អ្នកទាំងពីរស្រដៀងៗ គ្នា គឺ ដូចគ្នា ។ បទថា **កតំ តវេទំ** "កម្មដែលធ្វើ" សេចក្តីថា កម្មរបស់អ្នកទាំងនេះ ជាកម្មដែលធ្វើបានដោយលំបាក ។

លំដាប់នោះ ព្រះរាជកុមារត្រាស់ព្រះគាថាថា

[៤៤៦] ន ទុក្ករំ កិញ្ចិមហេត្ថ មញ្ញេ

យោ មត្តុមិច្ឆេ បិតុនោ បមោក្ខា

១.បិដក. តថាហិ វោ មុខវណ្ណោ ឧភិន្នំ ។

មាតុ ច ហេតុ បរលោកគមា្យ[១]

សុខេន សគ្គេន ច សម្បយុត្តា ។

មិនមែនជារបស់ដែលធ្វើបានលំបាកឡើយ ក្នុងរឿងនេះ យើង មិនឃើញសំខាន់អ្វីឡើយ បុគ្គលណាព្រមស្លាប់ជំនួសដើម្បី លោះបិតា ឬព្រោះហេតុនៃមាតា បុគ្គលនោះទៅកាន់បរលោក ហើយ រមែងជាអ្នកសម្បូរដោយសុខ និងអារម្មណ៍ដ៏ប្រសើរ ។

បណ្តាបទទាំងនោះ បទថា កិញ្ចិមហេត្ថ មញ្ញេ "ក្នុងរឿង នេះយើងមិនឃើញសេចក្តីសំខាន់អ្វីឡើយ" សេចក្តីថា ម្នាលយក្ស ក្នុងប្រការនេះ យើងមិនឃើញសេចក្តីសំខាន់អ្វីឡើយ ។ លោក ពោលអធិប្បាយទុកថា "បុគ្គលណាប្រាថ្នានឹងស្លាប់ដើម្បីដោះបិតា ឬព្រោះហេតុនៃមាតា" ។ បទថា បរលោកគមា្យ "ទៅកាន់បរលោក" សេចក្តីថា ចូលទៅកាន់បរលោកហើយ ។ បទថា សុខេន សគ្គេន

១.ម. បរលោកំ គន្ត្វា ។

“ដោយសុខ និងអារម្មណ៍ដ៏ប្រសើរ” សេចក្តីថា រមែងជាអ្នកប្រកបដោយសុខដែលជាហេតុឲ្យកើតក្នុងសួគ៌ ។ បទថា **មត្តុមិច្ឆេ** “ព្រមស្លាប់ជំនួស” សេចក្តីថា ព្រោះដូច្នោះ ក្នុងការលះបង់ជីវិតដើម្បីប្រយោជន៍ដល់មាតាបិតានេះ យើងមិនសម្គាល់ថា ជាវត្ថុដែលធ្វើបានលំបាកអ្វីឡើយ ។

យក្សស្តាប់ដូច្នោះហើយទើបពោលថា “ម្នាលកុមារ ធម្មតាថាសត្វបុគ្គលដែលមិនខ្លាចស្លាប់មិនមានឡើយ ហេតុអ្វីអ្នកទើបមិនខ្លាចស្លាប់ហ្ន៎” ។ កាលព្រះរាជកុមារនឹងប្រាប់សេចក្តីដល់យក្ស បានពោល ២ គាថាថា

[៤៤៧] អហញ្ច ខោ អត្តនោ បាបក្រិយំ
អាវី រហោ វាបិ សរេ ន ជាតុ
សង្ខាតជាតីមរណោហមស្មិ
យថេវ មេ ឥធ តថា បរត្ថ ។

ខាទថ មំទានិ មហានុភាវ

ករស្សុ កិច្ចានិ ឥមំ សរីរំ

រុក្ខស្ស វា តេ បបតាមិ អគ្គា

ឆាទមានោ មយ្ហំ តវមទេសិ មំសំ ។

យើងរលឹកមិនបានឡើយថា យើងនឹងធ្វើសេចក្ដីអាក្រក់ដើម្បីខ្លួនឯង ទាំងក្នុងទីវាល និងទីកំបាំង ព្រោះថា យើងជាអ្នកមានជាតិ និងមរណៈដែលកំណត់ទុកហើយថា ក្នុងលោកនេះរបស់យើងយ៉ាងណា ឯលោកខាងមុខក៏ដូច្នោះដូចគ្នា ។

បពិត្រលោកអ្នកមានអានុភាពច្រើន សូមអ្នកស៊ីសាច់យើងក្នុងថ្ងៃនេះឥឡូវនេះចុះ យើងនឹងធ្វើជាភ្លាត់ធ្លាក់អំពីចុងឈើអ្នកពេញចិត្តចំណែកណាៗ ក៏សូមអ្នកស៊ីសាច់ចំណែកនោះៗរបស់យើងចុះ ។

បណ្ដាបទទាំងនោះ បទថា សរេ ន ជាតុ “រលឹកមិនបាន

ឡើយ” សេចក្តីថា យើងរលឹកមិនបានឡើយសូម្បីត្រឹមតែម្តង ។ បទថា **សន្និដ្ឋាតជាតិមរណោហមស្មិ** “ជាអ្នកមានជាតិ និងមរណៈដែលកំណត់ទុកហើយ” សេចក្តីថា យើងដឹងថា “សត្វដែលកើតមកហើយ មានការកើត និងការស្លាប់ដែលញាណកំណត់ហើយដោយល្អ ដែលឈ្មោះថា មានការមិនស្លាប់ជាធម្មតាមិនមាន” ។ បទថា **យថា ឥធ មេ តថ** “ក្នុងលោកនេះរបស់យើងយ៉ាងណា” សេចក្តីថា ប្រការនេះ ញាណរបស់យើងកំណត់ទុកហើយយ៉ាងល្អតែម្យ៉ាងថា “លោកនេះរបស់យើងយ៉ាងណា លោកខាងមុខក៏យ៉ាងនោះ លោកខាងមុខយ៉ាងណា សូម្បីលោកនេះក៏យ៉ាងនោះ ឈ្មោះថា ការផុតចាកសេចក្តីស្លាប់មិនមាន” ។ បទថា **ករស្សុ កិច្ចានិ** “សូមលោកធ្វើកិច្ចចុះ” សេចក្តីថា លោកចូរធ្វើកិច្ចដែលគួរធ្វើដោយសរីរៈនេះ សរីរៈនេះយើងលះបង់ដល់លោកហើយ ។ បទថា **ឆាទមានោ មយ្ហំ ត្វមទេសិ**[1] **មំសំ** “អ្នកពេញចិត្តសាច់ចំណែកណាៗ ក៏អ្នកស៊ីសាច់

១.បិដក. តវមទេសិ មំសំ ។

ចំណែកនោះៗ របស់យើងចុះ” សេចក្ដីថា កាលយើងធ្លាក់អំពីចុង ឈើស្លាប់ហើយ កាលអ្នកនឹងស៊ី ពេញចិត្តសាច់ចំណែកណាអំពី សរីរៈរបស់យើង ក៏គួរបរិភោគសាច់ចំណែកនោះចុះ ។

យក្សស្ដាប់ពាក្យរបស់ព្រះកុមារហើយក៏តក់ស្លុត បានគិតថា “យើងមិនអាចស៊ីសាច់ព្រះកុមារនេះបានទេ នឹងរកឧបាយបណ្ដេញ ឲ្យគេគេចចេញទៅ” ទើបពោលគាថានេះ

[៤៤៨] ឥទញ្ច តេ រុច្ចតិ រាជបុត្ត
ចជេសិ បាណំ បិតុ បមោក្ខា
តស្មាតិហ ត្វំ តរមានរូបោ
សម្ភញ្ជ[១] កដ្ឋានិ ជលេហិ អគ្គិំ ។

ព្រះរាជឱរស រឿងនេះអ្នកពេញចិត្តពិត ទើបលះបង់ជីវិត ដើម្បីដោះដូរព្រះជនកបាន ព្រោះហេតុនោះឯង អ្នកចូរប្រញាប់

១.ម. តំ តញ្ច ។

ទៅកាច់មែកឈើមកបង្កាត់ភ្លើងចុះ ។

បណ្តាបទទាំងនោះ បទថា ជលេហិ "បង្កាត់ភ្លើង" សេចក្តីថា ក៏យក្សណែនាំថា "អ្នកចូរចូលទៅកាន់ព្រៃ រកឧសឈើខ្ចីមមកបង្កាត់ភ្លើង ធ្វើឲ្យជាផ្សែងដែលប្រាសចាកផ្សែង យើងនឹងអាំងសាច់របស់អ្នកក្នុងភ្លើងផ្សែងនោះស៊ី" ។

អលីនសត្តុរាជកុមារ បានធ្វើតាមពាក្យដែលយក្សប្រាប់គ្រប់ប្រការ ស្រេចហើយក៏ទៅកាន់សម្នាក់របស់យក្ស ព្រះសាស្តាកាលនឹងទ្រង់ប្រកាសហេតុនោះ ទើបត្រាស់ព្រះគាថាក្រៅអំពីនេះថា

[៤៤៩] តតោ ហវេ ធីតិមា រាជបុត្តោ
ទារុំ សមាហត្វ មហន្តមគ្គឹ
សន្ទីបយិត្វា បដិវេទយិត្ថ
អាទីបិតោទានិ មហាយមគ្គិ ។

លំដាប់នោះឯង ព្រះរាជឱរសអ្នកមានបញ្ញា បានរកឧសមក

បង្កាត់ភ្លើងជាគំនរធំឡើងហើយ ដើម្បីបញ្ជាក់ឲ្យយក្សជ្រាបថា ឥឡូវនេះ បានដុតភ្លើងជាគំនរធំស្រេចហើយ ។

យក្សសម្លឹងមើលព្រះរាជកុមារដែលដុតភ្លើងស្រេចហើយដើរមករក កើតការព្រឺរោមព្រឺស្បែកថា "បុរសនេះដូចជារាជសីហ៍ មិនខ្លាចសេចក្ដីស្លាប់ឡើយ រហូតអស់កាលប្រមាណប៉ុណ្ណេះ យើងមិនធ្លាប់ឃើញបុគ្គលដែលមិនខ្លាចស្លាប់យ៉ាងនេះឡើយ" ទើបអង្គុយផ្ទៀងមើលព្រះកុមាររឿយៗ ។ ព្រះកុមារឃើញកិរិយារបស់យក្សហើយ ទើបត្រាស់គាថាថា

[៤៥០] ខាទជ្ជ មំទានិ បសយ្ហការី
កឹ មំ មុហុំ បេក្ខសិ ហដ្ឋលោមា
តថា តថា តុយ្ហមហំ ករោមិ
យថា យថា មំ ឆាទមានោ អទេសិ ។

ក្នុងគ្រានេះ អ្នកគំរាមកំហែងថានឹងស៊ីយើង ក្នុងថ្ងៃនេះហេតុអ្វី

ទើបខ្វាចក្រែងក្នុងយើង ឆ្ងៀងមើលរឿយៗ យើងបានធ្វើតាម

ពាក្យរបស់អ្នកស្រេចហើយ បើពេញចិត្តស៊ី ក៏ចូរស៊ីបាន ។

បណ្តាបទទាំងនោះ បទថា មុហុំ "រឿយៗ" បានដល់ សម្ទីង

រឿយៗ ។ បទថា តថា តថា តុយ្ហមហំ "យើងបានធ្វើតាមពាក្យ

របស់អ្នកស្រេចហើយ" សេចក្តីថា អ្នកពេញចិត្តនឹងបរិភោគទំពា

ស៊ីយើងដោយវិធីណា យើងធ្វើតាមពាក្យរបស់អ្នកដោយវិធីនោះ

ហើយ គ្រានេះនឹងឲ្យយើងធ្វើដូចម្តេច ព្រោះដូច្នោះ សូមអ្នកស៊ី

យើងក្នុងថ្ងៃនេះចុះ ។

យក្សស្តាប់ពាក្យរបស់ព្រះកុមារហើយ ពោលគាថាថា

[៤៥១] កោ តាទិសំ អាហរតិ[១] ខាទិតាយេ

ធម្មេ ឋិតំ សច្ចវាទី វទញ្ញុំ

មុទ្ធាបិ តស្ស វិផលេយ្យ សត្តធា

---

១.ឱ. នេតាទិសំ អរហតិ, ម. កោ តាទិសំ អរហតិ ។

យោ តាទិសំ សច្ចវាទី អទេយ្យ ។

អ្នកតាំងនៅក្នុងធម៌ មានវាចាសច្ចៈ ដឹងសេចក្តីបំណងរបស់
អ្នកសូមដូចជាអ្នក នរណានឹងនាំមកស៊ីជាភក្សាហារបាន បុគ្គល
ណាស៊ីអ្នកមានវាចាសច្ចៈដូចជាអ្នក សីសៈរបស់បុគ្គលនោះ
នឹងគប្បីបែកចេញជា ៧ ចម្រៀក ។

ព្រះរាជកុមារបានស្តាប់ដូច្នោះ ទើបនិយាយថា “បើអ្នកមិន
បំណងនឹងស៊ីយើង ហេតុអ្វីទើបប្រាប់ឲ្យយើងកាច់ឧសមកបង្កាត់
ភ្លើង” កាលយក្សប្រាប់ថា ដើម្បីត្រូវការសាកល្បងមើលថា អ្នក
នឹងរត់ឬទេ ទើបត្រាស់ថា “អ្នកនឹងដឹងយើងក្នុងវេលានេះយ៉ាងណា
គ្រាយើងកើតក្នុងកំណើតសត្វតិរច្ឆាន ក៏យើងមិនព្រមឲ្យសក្កទេវរាជ
មើលងាយបាន” ទើបត្រាស់គាថាថា

[៤៥២] ឥទំ ហិ សោ ព្រាហ្មណំ មញ្ញមានោ

សសោ អវាសេសិ សកសរីរេ

តេនេវ សោ ចន្ទិមា ទេវបុត្តោ

សសដ្ឋកោ[១] កាមទុហជ្ជ យក្ខ ។

ពិតណាស់ សសបណ្ឌិតនោះសម្គាល់សក្កទេវរាជនេះថា ជាព្រាហ្មណ៍ ទើបបានឲ្យវត្ថុក្នុងសរីរៈរបស់ខ្លួន យក្ស ព្រោះហេតុនោះឯង ចន្ទិមទេវបុត្តនោះទើបមានរូបទន្សាយប្រាកដសមតាមបំណងរបស់លោករហូតសព្វថ្ងៃនេះ ។

គាថានោះ មានអធិប្បាយថា សសបណ្ឌិតនោះ សម្គាល់នូវសក្កព្រាហ្មណ៍យ៉ាងនេះថា បុគ្គលនេះជាព្រាហ្មណ៍ ទើបនិយាយថា "ថ្ងៃនេះ សូមលោកទំពាស៊ីសរីរៈរបស់យើងក្នុងទីនេះចុះ" ហើយឲ្យអាស្រ័យ គឺ ឲ្យស្នាក់នៅដើម្បីឲ្យសរីរៈរបស់ខ្លួនជាទានដូច្នេះ និងដើម្បីឲ្យសរីរៈជាអាហារដល់សក្កព្រាហ្មណ៍នោះ ។ សក្កទេវ-រាជទើបប្រចាប់យករសដែលកើតអំពីបពិត មកគូសជារូបទន្សាយ

---

១.ឱ. សសត្ថោ, ម. សសត្ថកោ ។

ទុកក្នុងមណ្ឌលព្រះចន្ទ ។ តាំងអំពីនោះមក ព្រោះរូបទន្សាយនោះ ឯង ចន្ទិមទេវបុត្ត មនុស្សលោកទើបដឹងទូទៅថា "ទន្សាយ ទន្សាយ" ចន្ទិមទេវបុត្ត មានរូបទន្សាយប្រាកដច្បាស់ដូច្នេះ សមតាមបំណង គឺ ញ៉ាំងសេចក្តីពេញចិត្តរបស់លោកឲ្យចម្រើន រុងរឿងរហូតសព្វថ្ងៃនេះ រឿងនេះក៏ជារឿងអស្ចារ្យនៅរហូតកប្ប ។

យក្សស្តាប់ដូច្នោះ កាលនឹងលែងព្រះរាជកុមារ ទើបពោលគាថាថា

[៤៥៣] ចន្ទោ យថា រាហុមុខា បមុត្តោ
វិរោចតេ បណ្ណរសេវ ភាណុមា
ឯវំ តុវំ បោរិសាទា បមុត្តោ
វិរោច កបិលេ្វ មហានុភាវ
អាមោទយំ បិតរំ មាតរញ្ច
សព្វោ ច តេ នន្ទតុ ញាតិបក្ខោ ។

ព្រះចន្ទព្រះអាទិត្យរួចចាកមាត់រាហូហើយ រមែងរុងរោចន៍ក្នុងថ្ងៃពេញវង់យ៉ាងណា បពិត្រអ្នកមានអានុភាពច្រើន អ្នកក៏ដូច្នោះ រួចផុតអំពីយើងអ្នកស៊ីសាច់មនុស្សជាអាហារហើយញុំាងព្រះជនកព្រះជននីឲ្យសប្បាយព្រះទ័យ ចូររុងរឿងក្នុងកបិលរដ្ឋ មួយទៀត ព្រះញាតិរបស់អ្នកចូរត្រេកអរគ្រប់គ្នា ។

បណ្ដាបទទាំងនោះ បទថា ភាណុមា "ព្រះអាទិត្យ" បានដល់ព្រះអាទិត្យ លោកអធិប្បាយថា ព្រះចន្ទ ឬព្រះអាទិត្យរួចផុតចាកមាត់រាហូហើយ រមែងស្វាងស្វៃក្នុងតិថី ១៥ កើតយ៉ាងណា បពិត្រអ្នកមានអានុភាពច្រើន សូម្បីអ្នករួចផុតអំពីសម្នាក់របស់យើងហើយ ក៏រុងរោចន៍ក្នុងកបិលរដ្ឋដូច្នោះចុះ ។

យក្សពោលថា "បពិត្រមហាវីរៈ សូមអ្នកទៅចុះ" ហើយបញ្ជូនស្ដេចព្រះមហាសត្វ ចំណែកព្រះមហាសត្វគ្រាទ្រង់ធ្វើឲ្យយក្សអស់មានះហើយ ទ្រង់ឲ្យសីល ៥ កំណត់មើលថា បុគ្គលនេះនឹងមិនមែន

ជាយក្ស ទើបទ្រង់ព្រះតម្រិះថា “ធម្មតា យក្សរមែងមានភ្នែកក្រហម និងមិនព្រិច គេនេះក៏មិនប្រាកដជាបុគ្គលកាចសាហាវ បុគ្គលនេះ ប្រហែលជាមិនមែនជាយក្ស ប្រាកដជាមនុស្ស គេតំណាលថា ព្រះជេដ្ឋានៃព្រះរាជបិតារបស់យើង ត្រូវនាងយក្ខិនីចាប់ទៅអស់ ៣ អង្គ ក្នុងចំនួននោះ នាងយក្ខិនីស៊ីអស់ ២ អង្គ ចិញ្ចឹមបីបាច់ទុកដូចជាកូនជាទីស្រឡាញ់ ១ អង្គ ប្រហែលជាអង្គនេះហើយ យើងនឹងនាំទៅទូលបញ្ជាក់ចំពោះព្រះរាជបិតារបស់យើង ហើយឲ្យលោកគ្រងរាជ្យសម្បត្តិ” ទើបត្រាស់បបួលថា “មកចុះ លោកដ៏ចម្រើន លោកមិនមែនជាយក្សទេ លោកជាព្រះជេដ្ឋានៃព្រះបិតារបស់យើង សូមលោកទៅជាមួយយើង ហើយឲ្យលើកស្វេតឆត្រសោយរាជ្យសម្បត្តិបន្តវង្សចុះ” កាលយក្សគំរាមថា “យើងមិនមែនមនុស្ស” ទើបបាន ត្រាស់សួរថា “លោកមិនជឿយើង តែមានអ្នកដែលលោកល្មមជឿខ្លះទេ?” កាលយក្សតបថា “មាន គឺ តាបសអ្នកមានចក្ខុជាទិព្វនៅ

ទីឯណោះ” ទើបទ្រង់នាំយក្សនោះទៅសម្នាក់តាបសនោះ ។ តាបសឃើញអ្នកទាំងពីរហើយក៏ពោលឡើងថា “អ្នកទាំងពីរ គឺ អ៊ំ និងក្មួយដើរធ្វើអ្វីនៅក្នុងព្រៃ” ហើយប្រាប់រឿងរបស់ជនទាំងពីរនោះជាញាតិនឹងគ្នាឲ្យជ្រាប ។ យក្សជឿពាក្យតាបស ទើបពោលថា “ក្មួយប្រុសក្មួយចូរត្រឡប់ទៅចុះ អ៊ំកើតមកកំណើតតែមួយតែមានសភាពជាពីរ អ៊ំមិនត្រូវការរាជ្យសម្បត្តិទេ អ៊ំនឹងបួស” ហើយបួសជាឥសីនៅក្នុងសំណាក់តាបសនោះឯង ។ លំដាប់នោះ ព្រះអលីនសត្តកុមារថ្វាយបង្គំលាឥសីអ៊ំហើយ ស្តេចក៏ត្រឡប់ទៅកាន់ព្រះនគរ ។

ព្រះសាស្តាកាលនឹងប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថាថា

[៤៥៤] តតោ ហវេ ធីតិមា រាជបុត្តោ
កតញ្ជលី បត្តយ្ហ បោរិសាទំ
អនុញ្ញាតោ សោត្ថិ សុខី អរោគោ

បច្ចាគមា កបិល្លមលីនសត្តោ ។

លំដាប់នោះឯង ព្រះរាជឱរសអលីនសត្តអ្នកមានព្រះបញ្ញា ទ្រង់ផ្គងអញ្ជលីសំពះយក្សបោរិសាទ បានទទួលការអនុញ្ញាតហើយ មានសេចក្តីសុខសួស្តី មិនមានរោគ ស្តេចក៏ត្រឡប់មកកាន់កបិលរដ្ឋ ។

ព្រះសាស្តា គ្រាត្រាស់ព្រះគាថានេះហើយ កាលនឹងសម្តែងនូវករណីយកិច្ចដែលអ្នកព្រះនគរ និងអ្នកនិគមជាដើមត្រូវធ្វើ ទើបត្រាស់ឱសានគាថាថា

[៤៥៥] តំ នេគមា ជានបទា ច សព្វេ
ហត្ថារោហា រថិកា បត្តិកា ច
នមស្សមានា បញ្ជលិកា ឧបាគមុំ
នមត្ថុ តេ ទុក្ករការកោសីតិ ។

អ្នកនិគម អ្នកជនបទគ្រប់គ្នា ទាំងពលដំរី ពលរថ និងពលថ្មើរ

ជើង នាំគ្នាមកថ្វាយបង្គំព្រះរាជឱរសនោះ ផ្គងអញ្ជលីព្រមគ្នា ក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គទាំងឡាយសូមថ្វាយបង្គំចំពោះព្រះអង្គ ព្រះអង្គទ្រង់ជាអ្នកធ្វើនូវកិច្ចដែលធ្វើបានយ៉ាងលំបាក ។

ព្រះបាទជយទ្ទិសបានស្ដាប់ដំណឹងថា ព្រះរាជកុមារត្រឡប់មក ទើបទ្រង់បានចាត់ការសម្ពោធទទួល ។ ព្រះកុមារហែហមដោយមហាជន បានថ្វាយបង្គំព្រះរាជបិតា ។ លំដាប់នោះ ព្រះរាជាត្រាស់សួរព្រះឱរសថា "កូនសម្លាញ់ កូនរួចផុតអំពីយក្សនោះបានដូចម្ដេច?" ព្រះរាជកុមារទូលថា "បពិត្រ ព្រះរាជបិតា ជននោះមិនមែនជាយក្សទេ តែជាព្រះជេដ្ឋាធិរាជរបស់ព្រះបិតា អ្នកនោះជាព្រះបិតុលារបស់ខ្ញុំព្រះអង្គ" ហើយក្រាបទូលរឿងរ៉ាវឲ្យទ្រង់ជ្រាប បានក្រាបទូលថា "គួរព្រះរាជបិតាស្ដេចយាងទៅសួរសុខទុក្ខព្រះបិតុលារបស់ខ្ញុំព្រះអង្គផង" ភ្លាមនោះ ព្រះបាទជយទ្ទិសទើបត្រាស់ឲ្យគ្នាក់ងាររគេរីវាយ

ស្តារប្រកាសឲ្យដឹងទូទៅ ហើយស្តេចទៅកាន់សម្នាក់តាបសទាំងឡាយ ព្រមទាំងរាជបរិវារដ៏ច្រើន ។ មហាតាបសទើបស្តេចតំណាលរឿងនាងយក្ខិនីនាំព្រះអង្គទៅចិញ្ចឹមមិនស៊ី រឿងដែលព្រះអង្គមិនមែនជាយក្ស និងរឿងដែលព្រះអង្គជាព្រះញាតិរបស់រាជត្រកូលនោះ ដល់ព្រះបាទជយទ្ទិសគ្រប់យ៉ាងដោយពិស្តារ ។ ព្រះបាទជយទ្ទិសទ្រង់ជឿ ហើយទូលថា "បពិត្រព្រះជេដ្ឋាធិរាជ សូមយាងព្រះអង្គស្តេចសោយរាជ្យសម្បត្តិចុះ" មហាតាបសថ្វាយព្រះពរហាមថា "កុំឡើយមហារាជ" ព្រះបាទជយទ្ទិសត្រាស់បបួលថា "បើដូច្នោះ សូមព្រះជេដ្ឋាធិរាជទៅនៅក្នុងព្រះរាជឧទ្យានចុះ ខ្ញុំព្រះអង្គនឹងទំនុកបម្រុងដោយបច្ច័យ ៤" មហាតាបសថ្វាយព្រះពរថា "អាត្មាភាពមិនទៅទេ មហាបពិត្រ" ។ ព្រះបាទជយទ្ទិសត្រាស់ឲ្យជីកប្រឡាយជំវែងត្រង់ចន្លោះភ្នំមួយ មិនឆ្ងាយអំពីអាស្រមបទរបស់ពួកតាបស ហើយឲ្យកាប់ឆ្ការព្រៃធ្វើស្រែចម្ការ ប្រោសឲ្យមហាជន ១.០០០ ត្រកូលផ្លាស់ទីកន្លែងមកតាំងទីលំនៅជាគ្រួសារតំបន់ធំ តាំងទុកជាភិក្ខាចារ

របស់តាបសទាំងឡាយ ។ តំបន់នោះប្រាកដឈ្មោះថា ចុល្លកម្មា-សទម្មនិគម ។ ចំណែកស្ថានទីដែលព្រះមហាសត្វសុតសោមបណ្ឌិតទូន្មានយក្សបោរិសាទ គប្បីជ្រាបថា ឈ្មោះមហាកម្មាសទម្មនិគម ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងចប់ហើយ ទ្រង់ប្រកាសសច្ចធម៌ទាំងឡាយ ហើយទ្រង់ប្រជុំជាតក ។ ក្នុងវេលាចប់សច្ចៈ ព្រះថេរៈអ្នកចិញ្ចឹមមាតាក៏បានតាំងនៅក្នុងសោតាបត្តិ-ផល ។ ព្រះមាតាព្រះបិតាក្នុងគ្រានោះ បានមកជាត្រកូលព្រះមហា-រាជក្នុងគ្រានេះ, តាបសក្នុងគ្រានោះ បានមកជាព្រះសារីបុត្ត, យក្សក្នុងគ្រានោះ បានមកជាព្រះអង្គុលិមាល, ព្រះកនិដ្ឋកតិនីក្នុងកាលនោះ បានមកជារាហុលមាតា, ចំណែកអលីនសត្តុរាជកុមារក្នុងគ្រានោះ គឺ **តថាគត** នេះឯង ។

ចប់អដ្ឋកថា ជយទ្ទិសជាតកទី ៣

# អដ្ឋកថា ឆទ្ទន្តជាតកទី ៤

## (រឿងស្តេចដំរីឆទ្ទន្ត)

*ព្រះសាស្តាកាលស្តេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បាន ប្រារព្ធភិក្ខុនីក្រមុំមួយរូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើម ថា កឹ នុ សោចសិ “ហេតុអ្វីហ្ន៎ ព្រះនាងទើបសោយសោក” ។*

*តំណាលមកថា នាងភិក្ខុនីនោះជាធីតានៃត្រកូលមួយក្នុងព្រះ នគរសាវត្ថី ឃើញទោសក្នុងឃរាវាសក៏ចេញបួសក្នុងព្រះសាសនា ថ្ងៃមួយទៅដើម្បីនឹងស្តាប់ធម៌ព្រមជាមួយពួកនាងភិក្ខុនី ឃើញព្រះ រូបឆោមដែលកើតឡើងដោយបុញ្ញានុភាពរកប្រមាណមិនបាន ព្រម ដោយរូបសម្បត្តិដ៏ឧត្តមរបស់ព្រះទសពល ទ្រង់ប្រថាប់លើធម្មា- សនៈដែលប្រដាប់ហើយ ទ្រង់កំពុងសម្តែងព្រះធម្មទេសនា ទើប គិតថា កាលយើងត្រាច់រង្គាត់ហើយនៅក្នុងភព ធ្លាប់បានជាបាទ- បចារិការបស់មហាបុរសនេះឬទេហ្ន៎ ។ ក្នុងវេលានោះឯង នាងក៏*

កើតការរលឹកជាតិក្នុងខាងក្រោយបានថា "យើងធ្លាប់ជាបាទបចា-
រិការបស់មហាបុរសនេះ ក្នុងគ្រាដែលព្រះអង្គជាស្តេចដំរីឆទ្ទន្ត" ។
កាលនាងរលឹកបានដូច្នោះ ក៏កើតបីតិបាមោជ្ជៈដ៏ក្រៃលែង ដោយ
កម្លាំងនៃបីតិ នាងទើបសើចខ្លាំងៗ ហើយគិតទៀតថា ដែលឈ្មោះ
ថា បាទបចារិកាមានអធ្យាស្រ័យបំណងប្រយោជន៍ចំពោះស្វាមីមាន
តិច មិនបំណងប្រយោជន៍មានច្រើន យើងមានអធ្យាស្រ័យបំណង
ប្រយោជន៍ចំពោះបុរសនេះ ឬមិនហ្ន៎ ។ នាងរលឹកទៅក៏បានឃើញ
សេចក្តីពិតថា ដែលពិតយើងសាងកំហុសទុកក្នុងចិត្តមិនតិចឡើយ
តម្លៃដែលប្រើព្រានសោណុត្តរឲ្យយកកូនសរលាបដោយថ្នាំពិស បាញ់
ស្តេចដំរីឆទ្ទន្តកម្ពស់ប្រមាណ ១២០ ហត្ថឲ្យស្លាប់ ។ គ្រានោះឯង
សេចក្តីសោកក៏កើតដល់នាង ។ ហឫទ័យក៏ក្តៅក្រហាយ ។ នាង
មិនអាចទឹងអត់ទ្រាំនឹងសេចក្តីសោកបាន ទើបស្រែកយំដោយសំឡេង
ខ្លាំងៗ ។ ព្រះសាស្តាទតព្រះនេត្រឃើញដូច្នោះ ទ្រង់ក៏ធ្វើការញញឹម

ឲ្យប្រាកដ ភិក្ខុសង្ឃទូលសួរថា “បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុ ជាបច្ច័យនៃការធ្វើសេចក្ដីញញឹមឲ្យប្រាកដ” ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ នាងភិក្ខុនីក្រមុំរូបនេះ រលឹកដល់កំហុសដែលធ្លាប់ធ្វើដល់តថាគតក្នុងជាតិមុនទើបយំ” ហើយទ្រង់នាំអតីតនិទានមកត្រាស់ដូចតទៅនេះ ។

ក្នុងអតីតកាល មានដំរីប្រមាណ ៨.០០០ មានឫទ្ធិហោះទៅក្នុងអាកាសបាន អាស្រ័យនៅទីងស្រះឆទ្ទន្តក្នុងព្រៃហិមពាន្ត ។ គ្រានោះ ព្រះពោធិសត្វកើតជាកូនរបស់ដំរីមេហ្វូង មានសម្បុរកាយស មាត់ និងជើងពណ៌ក្រហម តមកកាលវ័យចម្រើនហើយមានកម្ពស់បាន ៨៨ ហត្ថ ប្រវែង ១២០ ហត្ថ ប្រកបដោយប្រមោយប្រៀបដូចជាកម្រងផ្កាប្រវែង ៥៨ ហត្ថ ។ ចំណែកភ្លុកទាំងពីរវាស់ដោយជុំវិញបាន ១៥ ហត្ថ មានប្រវែង ៣០ ហត្ថ ប្រកបដោយរស្មី ៦ ប្រការ ។ ព្រះពោធិសត្វនោះជាប្រមុខដំរី ៨.០០០ និង

ធ្វើការបូជាព្រះបច្ចេកពុទ្ធ ៥០០ អង្គ (ជានិច្ច) ។ អគ្គមហេសីព្រះពោធិសត្វនោះមាន ២ គឺ នាងចុល្លសុភទ្ទា ១ មហាសុភទ្ទា ១ ។ ស្តេចដំរីនោះមានដំរី ៨.០០០ ជាបរិវារនៅក្នុងល្អាងមាស ។ មួយទៀត ស្រះឆទ្ទន្តនោះ ទាំងចំណែកបណ្តោយ និងទទឹងប្រមាណ ៥២ យោជន៍ ។ ត្រង់កណ្តាលប្រមាណ ១២ យោជន៍ មិនមានសារាយចក ឬភក់ល្បាប់ឡើយ មានទឹកជាប្រចាំ មានពណ៌ដូចដុំកែវមណី បន្ទាប់ពីនោះមានគុម្ពចង្កុលណីដុះព័ទ្ធជុំវិញបានមួយយោជន៍ តពីគុម្ពចង្កុលណីនោះ មានគុម្ពឧប្បលខៀវដុះព័ទ្ធជុំវិញមួយយោជន៍ តពីនោះ ជាទីវាលមួយយោជន៍ មានគុម្ពឧប្បលក្រហម ឧប្បលខៀវ និងកុមុទ ដុះលោមព័ទ្ធជុំវិញ មួយទៀត ចន្លោះគុម្ពឈូក ៧ កន្លែងនេះ មានគុម្ពឈូកគ្រប់ប្រភេទ ជាដើមថា ចង្កុលណីដុះតគ្នាព័ទ្ធជុំវិញ មានបរិមណ្ឌលធំប្រមាណមួយយោជន៍ដូចគ្នា លាតសន្ធឹងមកដល់ទឹកជ្រៅត្រឹមពោះដំរី មានព្រៃស្រូវសាលីក្រហមដុះទៅបាន

មួយយោជន៍មកដល់មាត់ទឹក មានគុម្ពវល្លិទឹកដេរដាសដោយផ្កាពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម ពណ៌ស ក្លិនក្រអូបផ្សាយទៅ ព្រៃឈើទាំងជប់ប្រភេទនេះ មានផ្ទៃដីមួយយោជន៍ដូចគ្នា ដោយប្រការដូច្នេះ ។ តអំពីនោះទៅ មានព្រៃសណ្តែកបាជមាសខ្នាតតូច និងព្រៃសណ្តែកបាជមាសខ្នាតធំ ។ តអំពីនោះ មានព្រៃឪឡឹក ល្ពៅឃ្លោក និងត្រឡាចស្រូវ ។ តអំពីនោះ មានព្រៃអំពៅខ្នាតប៉ុនដើមស្លា ។ តអំពីនោះ មានព្រៃចេកផ្លែប៉ុនភ្លុកដំរី ។ តអំពីនោះ មានព្រៃរាំង ព្រៃខ្នុរផ្លែធំខ្នាតប៉ុនពាង ។ តអំពីនោះ មានព្រៃខ្នុរសម្ល មានផ្លែផ្អែម ។ តអំពីនោះ មានព្រៃខ្វិត ។ តអំពីនោះ មានព្រៃសណ្ឋះធំ មានពូជឈើលាយឡំគ្នា ។ តអំពីនោះ មានព្រៃឫស្សី ។ នេះជាភាពសម្បូរនៃស្រះឆទ្ទន្តក្នុងសម័យនោះ និងក្នុងអដ្ឋកថាសំ-យុត្តនិកាយ លោកក៏ពណ៌នាភាពសម្បូរដែលមានក្នុងបច្ចុប្បន្ននេះដូចគ្នា ។

មួយទៀត មានភ្នំឡោមព័ទ្ធជុំវិញព្រៃឫស្សីដល់ទៅ ៧ ជាន់ ។ រាប់តាំងអំពីជុំខាងក្រៅនៃភ្នំទាំងនោះទៅ ភ្នំទីមួយឈ្មោះ ចុល្លកាឡបព៌ត ភ្នំទីពីរឈ្មោះ មហាកាឡបព៌ត ភ្នំទីបីឈ្មោះ ឧទកបស្សបព៌ត ភ្នំទីបួនឈ្មោះ ចន្ទបស្សបព៌ត ភ្នំទីប្រាំឈ្មោះ សុរិយបព៌ត ភ្នំទីប្រាំមួយឈ្មោះ មណីបស្សបព៌ត ភ្នំទីប្រាំពីរឈ្មោះ សុវណ្ណបស្សបព៌ត ។

សុវណ្ណបស្សបព៌តនោះខ្ពស់ ៧ យោជន៍ តាំងឡោមព័ទ្ធស្រះឆទ្ទន្ត ដូចកណ្តាប់មាត់បាត្រ ផ្នែកខាងសុវណ្ណបស្សបព៌តមានពណ៌លឿងដូចមាស ព្រោះជះពន្លឺចេញអំពីសុវណ្ណបស្សបព៌តនោះ ស្រះឆទ្ទន្តនោះ មើលទៅប្រៀបដូចជាពន្លឺព្រះអាទិត្យដ៏ស្រទន់ ក្នុងវេលាឧទ័យ ។ មួយទៀត ឯភ្នំដែលតាំងជាបន្តបន្ទាប់ ភ្នំមួយកម្ពស់ ៦ យោជន៍, ៥ យោជន៍, ៤ យោជន៍, ៣ យោជន៍, ២ យោជន៍, ១ យោជន៍ ត្រង់ជ្រុងទិសឦសាននៃស្រះឆទ្ទន្តដែលមានភ្នំ ៧ ជាន់

ឡោមព័ទ្ធយ៉ាងនេះ ក៏មានដើមជ្រៃធំដុះត្រង់ឱកាសដែលទឹក និងខ្យល់បក់ត្រូវបាន ។ ដើមជ្រៃនោះវាស់ដោយជុំវិញបាន ៥ យោជន៍ មានកម្ពស់ ៧ យោជន៍ មានមែកប្រវែង ៦ យោជន៍ ដុះចេញទៅក្នុងទិសទាំងបួន សូម្បីមែកដែលដុះត្រង់ទៅលើ ក៏ប្រវែង ៦ យោជន៍ដូចគ្នា វាស់អំពីគល់នៃដើមឡើងទៅកម្ពស់បាន ១៣ យោជន៍ វាស់ដោយជុំវិញបរិមណ្ឌលមែកបាន ១២ យោជន៍ ប្រដាប់ដោយឫសជ្រៃ ៨.០០០ ឫស ខ្ពស់ត្រដឹម យ៉ាងសង្ហាស្រដៀងភ្នំមណី ។

មួយទៀត ក្នុងទិសបស្ចិមនៃស្រះឆទ្ទន្ត ភ្នំសុវណ្ណបស្សបព៌តមានល្អាងមាសធំប្រមាណ ១២ យោជន៍ ក្នុងរដូវភ្លៀង ស្តេចដំរីឆទ្ទន្ត មានដំរី ៨.០០០ ជាបរិវារនឹងស្នាក់នៅក្នុងល្អាងមាសនោះ ។ ក្នុងរដូវក្តៅក៏មកឈរទទួលខ្យល់ និងទឹកនៅចន្លោះឫសជ្រៃ ក្រោមដើមនិគ្រោធធំ ។ តមកថ្ងៃមួយ ដំរីទាំងឡាយមកប្រាប់ថា "ព្រៃរាំងធំមានផ្ការីកហើយ" ស្តេចឆទ្ទន្តគិតថា "យើងនឹងលេងកីឡាត្រង់

ផ្កាពាំង” ព្រមទាំងបរិវារក៏ទៅកាន់ព្រៃពាំងនោះ យកពោងត្រដុស ដើមពាំងមួយដើមដែលមានផ្ការីក ។ នាងចុល្លសុភទ្ទាឈរនៅខាង លើខ្យល់ ស្លឹកពាំងចាស់ៗ ជាប់ជាមួយមែកងាប់ៗ និងអង្រ្កងបាន ធ្លាក់មកលើសីសៈរបស់នាង ។ នាងមហាសុភទ្ទាឈរនៅក្រោម ខ្យល់ កេសរផ្កា និងស្លឹកស្រស់ៗ ក៏រោយរាយធ្លាក់ត្រូវសរីរៈរបស់ នាង ។ នាងចុល្លសុភទ្ទាគិតថា ស្តេចដំរីនេះជម្រុះកេសរផ្កា និង ស្លឹកស្រស់ៗ ឲ្យធ្លាក់លើសរីរៈភរិយាដែលខ្លួនស្រឡាញ់ ឯយើង ឲ្យស្លឹកឈើចាស់ជាប់នឹងមែកងាប់ៗ ទាំងអង្រ្កងមកធ្លាក់ ត្រូវយើង យើងនឹងដឹងនូវវត្ថុដែលគួរធ្វើ ទើបចងពៀរក្នុងព្រះមហាសត្វ ។

តមកថ្ងៃមួយ ស្តេចដំរីព្រមទាំងបរិវារចុះកាន់ស្រះឆទ្ទន្តដើម្បី ងូតទឹក ។ ខណៈនោះ ដំរីជំទង់ ២ ក្បាល យកប្រមោយបោច ស្លឹកជ្រៃមកឲ្យស្តេចដំរីជម្រះកាយ ប្រៀបដូចជាបោសសម្អាតកំពូល ភ្នំកៃលាសដូច្នោះ ។ គ្រាស្តេចដំរីងូតទឹកឡើងមកហើយ ទើបឲ្យ

នាងដំរីទាំងពីរចុះងូត លុះនាងដំរីទាំងពីរឡើងមកហើយ នាំគ្នាទៅឈរក្បែរព្រះមហាសត្វ តពីនោះ ដំរីទាំង ៨.០០០ ក៏ចុះក្នុងស្រះលេងកីឡាទឹកហើយនាំយកផ្កាឈើច្រើនប្រភេទអំពីស្រះ ប្រដាប់ចំពោះព្រះមហាសត្វ ប្រៀបដូចជាប្រដាប់ស្តូបប្រាក់ដូច្នោះ ស្រេចហើយក៏ប្រដាប់ដល់ដំរីទាំងពីរជាខាងក្រោយ ។ គ្រានោះមានដំរីមួយក្បាល ត្រាច់ទៅក្នុងស្រះបានផ្កាឈូកធំ មានត្របក ៧ ជាន់មួយទង ទើបនាំមកប្រគល់ឲ្យស្តេចដំរី ស្តេចដំរីឆទ្ទន្តយកប្រមោយទទួលផ្កាបទុមមក ហើយរាយកេសរត្រង់ពោង ហើយរោយដាក់នាងមហាសុភទ្ទាជាជេដ្ឋករិយា ។ នាងចុល្លសុភទ្ទាឃើញដូច្នោះទើបគិតតូចចិត្តថា ស្តេចដំរីនេះឲ្យផ្កាបទុមធំដែលមានត្របក ៧ ជាន់នេះ ដល់តែករិយាជាទីស្រឡាញ់ប្រោសប្រាណចំពោះខ្លួនប៉ុណ្ណោះ ចំណែកយើងមិនឲ្យ ទើបបានចងពៀរក្នុងព្រះមហាសត្វទៀត ។

តមកថ្ងៃមួយ កាលស្តេចដំរីពោធិសត្វចាត់ចែងផ្សំផ្លែស្រគំ

ត្រាវ ជំឡូងជាមួយទឹកឃ្មុំ ថ្វាយព្រះបច្ចេកពុទ្ធ ៥០០ អង្គនោះ ។ នាងចុល្លសុភទ្ទា បានថ្វាយផលាផលដែលខ្លួនបានចំពោះព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្ដីប្រាថ្នាថា "បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គឃ្លាតចាកអត្តភាពក្នុងជាតិនេះហើយ សូមឲ្យបានកើតក្នុងត្រកូលមទ្ទរាជ និងបាននាមថា សុភទ្ទារាជកញ្ញា លុះចម្រើនវ័យហើយ សូមឲ្យបានជាអគ្គមហេសីរបស់ព្រះបាទពារាណសី ជាទីប្រោសប្រាណរបស់ព្រះអង្គ រហូតអាចធ្វើអ្វីៗ បានតាមបំណង និងអាចទូលស្ដេចឲ្យទ្រង់ប្រើព្រានម្នាក់មកបាញ់ដំរីនេះ ដោយសរលាបដោយថ្នាំពិសរហូតដល់ស្លាប់ និងឲ្យនាំយកភ្លុកទាំងគូដែលចែងចាំងដោយរស្មី ៦ ប្រការមកបាន" ។ ចាប់តាំងអំពីថ្ងៃនោះមក នាងចុល្លសុភទ្ទាមិនបានទទួលស្មៅ ទឹក រាងកាយក៏ស្គមចុះ មិនយូរប៉ុន្មានក៏ស្លាប់ បានទៅកើតក្នុងព្រះគភ៌ព្រះអគ្គមហេសីរបស់ព្រះរាជាក្នុងដែនមទ្ទរដ្ឋ និងកាលប្រសូតមកហើយ ព្រះជនកព្រះជននីបានតាំងព្រះ

នាមថា សុភទ្ទា កាលព្រះនាងចម្រើនវ័យហើយ ទើបនាំទៅថ្វាយ
ចំពោះព្រះបាទពារាណសី ។ នាងជាទីស្រឡាញ់ប្រោសប្រាណរបស់
ព្រះបាទពារាណសី រហូតបានជាប្រមុខនៃនាងស្នំ ១៦.០០០ នាក់
ទាំងញាណជាគ្រឿងរលឹកជាតិខាងមុនបាន ។ ព្រះនាងសុភទ្ទានោះ
ត្រិះរិះថា សេចក្ដីប្រាថ្នារបស់យើងសម្រេចហើយ គ្រានេះនឹងឲ្យគេ
ទៅយកភ្លុកទាំងគូរបស់ស្ដេចដំរីនោះមក ។ តពីនោះ ព្រះនាងក៏
យកប្រេងមកលាបព្រះសរីរៈ ស្លៀកដណ្ដប់សំពត់សៅហ្មងសម្ដែង
នូវអាការឈឺ ស្ដេចចូលកាន់បន្ទប់សិរីសេយ្យាសន៍ផ្ទំលើព្រះទែន
តូច ។ ព្រះបាទពារាណសីត្រាស់សួរថា “ព្រះនាងសុភទ្ទាទៅណា?”
ទ្រង់ជ្រាបថា ព្រះនាងប្រឈួន ទើបស្ដេចយាងចូលទៅកាន់បន្ទប់ផ្ទំ
ប្រថាប់គង់លើព្រះទែន ទ្រង់ស្ទាបអង្អែលព្រះប្រឹស្ឋរបស់ព្រះនាង
ហើយត្រាស់ព្រះគាថាទី ១ ថា

[៤៥៦] កិន្នុ សោចសិនុច្ចគ្គី[(១)] បណ្ឌុសី វរវណ្ណិនី

---

១.ឱ. សោចសិនុជ្ជគ្គិ ។

មិលាយសិ វិសាលក្ខី មាលាវ បរិមទ្ទិតា ។

ព្រះនាងអូន អ្នកមានសរីរៈល្អដូចមាស មានសម្បុរល្មៀងខ្ចី រុងរឿង ព្រះនេត្រទាំងគូក្លីថ្លា ហេតុអ្វីហ្ន៎ ព្រះនាងទើបសោកស្រពោនដូចផ្កាដែលត្រូវប្រហាច់ដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា អនុច្ចង្គី "អ្នកមានសរីរៈល្អដូចមាស" សេចក្ដីថា អ្នកមានសរីរៈស្អាតដូចមាស ។ បទថា មាលាវ បរិមទ្ទិតា "ដូចផ្កាដែលត្រូវប្រហាច់ដូច្នោះ" សេចក្ដីថា ដូចជាផ្កាបទុមត្រូវប្រហាច់ដោយដៃដូច្នោះ ។

ព្រះនាងសុកន្ទាទ្រង់ស្ដាប់ដូច្នោះ ទើបត្រាស់គាថាតទៅថា

[៤៥៧] ទោហឡោ មេ មហារាជ សុបិនន្តេនុបច្ចគា

ន សោ សុលភរូបោវ យាទិសោ មម ទោហឡោ ។

បពិត្រមហារាជ នាងខ្ញុំម្ចាស់ចាញ់ព្រះគភ៌ ព្រោះការចាញ់ព្រះគភ៌ជាហេតុ ទើបនាងខ្ញុំម្ចាស់យល់សប្តិឃើញវត្ថុដែលរកមិន

បានឆាយ ។

បណ្ដាបទទាំងនោះ បទថា **ន សោ** "មិនបាន" សេចក្ដីថា ការបាញ់ព្រះគតិដែលនាងខ្ញុំម្ចាស់យល់សប្តិឃើញយ៉ាងនោះ ។ បទថា **សុបិនន្តេនុបច្ចគា** "ជាហេតុឲ្យ... យល់សប្តិឃើញវត្ថុដែលរកមិនបានឆាយ" សេចក្ដីថា ព្រះទេវីទូលថា "នាងខ្ញុំម្ចាស់យល់សប្តិឃើញជានិមិត្ត ក្នុងទីបំផុតនៃការយល់សប្តិទើបបាញ់ព្រះគតិ វត្ថុដែលបាញ់ព្រះគតិព្រោះយល់សប្តិឃើញនោះ គិតថាជាវត្ថុរកបានដោយឆាយក៏មិនមែន គឺ វត្ថុនោះរកបានដោយលំបាក តែកាលនាងខ្ញុំម្ចាស់មិនបានវត្ថុនោះ ប្រាកដជាមិនមានជីវិតឡើយ" ។

ព្រះរាជាទ្រង់ស្ដាប់ដូច្នោះ ទើបត្រាស់ព្រះគាថាថា

[៤៥៨] យេ កេចិ មានុសា កាមា ឥធលោកស្មិ នន្ទនេ

សព្វេ តេ បចុរា មយ្ហំ អហន្តេ ទម្មិ ទោហឡំ ។

កាមសម្បត្តិរបស់មនុស្សពួកណាមួយក្នុងលោកនេះ និងក្នុង

សួននន្ទនវ័ន កាមសម្បត្តិទាំងអស់នោះ ជារបស់យើងទាំងអស់ យើងនឹងរកឲ្យនាងបាន ។

បណ្ដាបទទាំងនោះ បទថា បច្ចុភ "កាមសម្បត្តិ" សេចក្ដីថា នាងសុភទ្ទាដ៏ចម្រើន កាមសម្បត្តិដែលជារបស់មនុស្ស ដែលពួកមនុស្សប្រាថ្នាក្នុងលោកនេះ និងរតនៈទាំង ៧ យ៉ាងណាមួយ ក្នុងនន្ទនវ័ន មានច្រើនរកបានងាយ គឺ កាមគុណ ៥ ណានីមួយ មានហើយក្នុងមនុស្សលោក យើងនឹងឲ្យវត្ថុកាម និងកិលេសកាមទាំងអស់នោះដល់នាង ។

ព្រះនាងទេវីបានស្ដាប់ដូច្នោះទើបទូលថា "បពិត្រមហារាជ ការចាញ់គភ៌របស់នាងខ្ញុំម្ចាស់កែបានលំបាក នាងខ្ញុំម្ចាស់នឹងមិនទូលឲ្យជ្រាបមុនក្នុងគ្រានេះទេ ក៏ក្នុងដែននាងខ្ញុំម្ចាស់ មានព្រានព្រៃចំនួនប៉ុន្មាន ទ្រង់ប្រោសឲ្យមកប្រជុំគ្នាទាំងអស់ចុះព្រះអង្គ នាងខ្ញុំម្ចាស់នឹងទូលឲ្យជ្រាបក្នុងកណ្ដាលពួកព្រានព្រៃទាំងនោះ" ហើយត្រាស់

គាថាក្នុងលំដាប់តទៅ

[៤៥៩] លុទ្ធា ទេវ សមាយន្តុ   យេ កេចិ វិជិតេ តវ
      ឯតេសំ  អហមក្ខិស្សំ   យាទិសោ មម ទោហឡោ ។

បពិត្រព្រះអង្គជាសម្មតិទេព  ព្រានព្រៃពួកណាមួយក្នុងដែន
របស់ព្រះអង្គ  ចូរមកប្រជុំព្រមគ្នា  នាងខ្ញុំនឹងប្រាប់ហេតុដែល
ចាញ់ព្រះគភ៌របស់នាងខ្ញុំម្ចាស់ឲ្យព្រានព្រៃទាំងនោះជ្រាប ។

ក្នុងគាថានោះ មានអធិប្បាយថា "បពិត្រមហារាជ មានព្រានជំពូកណាដែលជាអ្នកអាស្រ័យនៅក្នុងដែនរបស់នាងខ្ញុំម្ចាស់ ព្រានជំពូកនោះទាំងអស់ចូរប្រជុំគ្នា គឺ ប្រកាសហៅមក នាងខ្ញុំម្ចាស់នឹងប្រាប់ការចាញ់គភ៌របស់នាងខ្ញុំម្ចាស់ ដែលមានហើយដល់ព្រានពួកនោះ" ។

ព្រះចៅក្រុងពារាណសីត្រាស់ទទួលពាក្យហើយ ស្តេចត្រាស់បង្គាប់ក្នុងកាលិករដ្ឋ ដែលមានអាណាខេត្ត ៣០០ យោជន៍ សូមអ្នក

ចូរវាយស្គរប្រកាស ឲ្យព្រានព្រៃទាំងអស់នោះប្រជុំគ្នា” អាមាត្យទាំងនោះក៏ធ្វើតាមព្រះរាជឱង្ការ ។ មិនយូរប៉ុន្មានព្រានព្រៃអ្នកដែនកាលិករដ្ឋ ក៏កាន់យកគ្រឿងបណ្ណាការតាមកម្លាំង នាំគ្នាមកគាល់ក្រាបទូលការដែលខ្លួនមកដល់ឲ្យទ្រង់ជ្រាប ។ ព្រានព្រៃទាំងអស់មានប្រមាណ ៦០.០០០ នាក់ ។ ព្រះរាជាទ្រង់ជ្រាបថា ពួកព្រានមកហើយ ទើបប្រថាប់ឈរនៅត្រង់ព្រះបញ្ចរ កាលទឹងលើកព្រះហត្ថចង្អុលត្រាស់ប្រាប់ព្រះទេវីដល់ពួកព្រានមកហើយ ទើបត្រាស់ព្រះគាថាថា

[៤៦០] ឥមេ តេ លុទ្ទកា ទេវិ កតហត្ថា វិសារទា

វនញ្ញូ ច មិគញ្ញូ ច មមត្ថេ ចត្តជីវិតា ។

ទេវី ព្រានព្រៃទាំងនេះសុទ្ធតែមានថ្វីដៃ ជាអ្នកក្លៀវក្លាជំនាញព្រៃ ស្គាល់ប្រភេទម្រឹគ រមែងលះបង់ជីវិតដើម្បីប្រយោជន៍របស់យើងបាន ។

បណ្ដាបទទាំងនោះ បទថា **ឥមេ** “**ទាំងនេះ**” សេចក្ដីថា ព្រះទេវី នាងឲ្យព្រានពួកណាមកប្រជុំគ្នា ព្រានពួកនោះ គឺ ពួកនេះ ។ បទថា **កតហត្ថា** “**មានថ្វីដៃ**” សេចក្ដីថា សុទ្ធតែមានថ្វីដៃ គឺ ឆ្លាតបានទទួលការសិក្សារហូតជំនាញក្នុងក្បួនបាញ់ និងកាប់ជាដើម ។

បទថា **វិសារទា** “**ជាបុគ្គលក្លៀវក្លា**” សេចក្ដីថា ជាអ្នកផុតភ័យ ។ បទថា **វនញ្ញូ ច មិគញ្ញូ ច** “**ជំនាញព្រៃ ស្គាល់ប្រភេទម្រឹគ**” សេចក្ដីថា ជំនាញព្រៃ និងដឹងប្រភេទសត្វ ។ បទថា **មមត្ថេ** “**ប្រយោជន៍របស់យើង**” សេចក្ដីថា ពួកព្រានទាំងអស់នេះរមែងលះបង់ជីវិតក្នុងប្រយោជន៍របស់យើងបាន គឺ គេធ្វើតាមដែលយើងប្រាថ្នាបាន ។

ព្រះទេវីទ្រង់ស្ដាប់ដូច្នោះ ត្រាស់ហៅពួកព្រានមកហើយ បានត្រាស់តទៅថា

[៤៦១] លុទ្ទបុត្តា និសាមេថ យាវន្តេត្ថ សមាគតា

ឆព្វិសាណំ គជំ សេតំ    អទ្ទសំ សុបិនេ អហំ

តស្ស ទន្តេហិ មេ អត្ថោ    អលាភេ នត្ថិ ជីវិតំ ។

អ្នកទាំងឡាយជាខ្សែស្រឡាយព្រាន ដែលមកព្រមគ្នាក្នុងទីនេះ ចូរស្តាប់យើង យើងយល់សប្តិឃើញដំរីស ភ្លុកមានរស្មី ៦ ប្រការ ខ្ញុំត្រូវការគូនៃភ្លុកដំរីនោះ កាលមិនបាន ក៏នឹងមិនមានជីវិត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះ ដូចតទៅនេះ ព្រះនាងទេវីត្រាស់ថា "អ្នកទាំងឡាយជាខ្សែស្រឡាយព្រានព្រៃ ដែលមកព្រមគ្នាក្នុងទីនេះ ចូរតាំងចិត្តស្តាប់ពាក្យរបស់យើង" ។

បទថា ឆព្វិសាណំ "ភ្លុកមានរស្មី ៦ ប្រការ" បានដល់ ដំរីសមានរស្មីនៃភ្លុក ៦ ប្រការ ។ ព្រះទេវីត្រាស់ថា "យើងយល់សប្តិឃើញដំរីស មានភ្លុកមានរស្មី ៦ ប្រការ យើងយល់សប្តិឃើញគជសារបែបនេះ ទើបមានសេចក្តីត្រូវការភ្លុកទាំងពីររបស់ស្តេចដំរី

នោះ កាលមិនបាន ជីវិតយើងក៏នឹងមិនមាន" ។ ពួកបុត្តព្រានព្រៃ

ស្ដាប់ព្រះសវនីយ៍ដូច្នោះ នាំគ្នាក្រាបទូលថា

[៤៦២] ន នោ បិតូនំ ន បិតាមហានំ

ទិដ្ឋា សុតោ កុញ្ជរោ ឆព្វិសាណោ

យមទ្ទស សុបិនេ រាជបុត្តី

អក្ខាហិ នោ យាទិសោ ហត្ថិនាគោ ។

បិតា ឬជីតាទួតរបស់ខ្ញុំព្រះអង្គទាំងឡាយ ក៏មិនធ្លាប់បានឃើញ

ទាំងមិនធ្លាប់បានឮថា មានស្ដេចដំរីដែលមានរស្មីនៃភ្លុក ៦

ប្រការ ព្រះនាងទ្រង់និមិត្តឃើញស្ដេចដំរីមានលក្ខណៈយ៉ាង

ណា សូមទ្រង់ត្រាស់ប្រាប់នូវស្ដេចដំរីដែលមានលក្ខណៈយ៉ាង

នោះ ដល់ខ្ញុំព្រះអង្គទាំងឡាយចុះ ព្រះនាង ។

បណ្ដាបទទាំងនោះ បទថា បិតូនំ "បិតា" ជាឆដ្ឋីវិភត្តិចុះ

ក្នុងអត្ថនៃតតិយាវិភត្តិ ។ មានពាក្យអធិប្បាយថា "ពួកព្រានក្រាប

ទូលថា ព្រះតេជះ ស្វេតកុញ្ជរភ្ជុកមានរស្មី ៦ ប្រការ លក្ខណៈដូច្នេះ បិតា ឬជីតារបស់ពួកខ្ញុំព្រះអង្គក៏មិនធ្លាប់ឃើញ មិនធ្លាប់បានស្តាប់ មិនចាំបាច់និយាយដល់ពួកខ្ញុំព្រះអង្គឡើយ ព្រោះហេតុនោះ ព្រះនាងទ្រង់និមិត្តឃើញស្តេចដំរីដែលមានលក្ខណៈយ៉ាងណា សូមទ្រង់ប្រោសត្រាស់ប្រាប់លក្ខណៈអាការ ដែលទ្រង់និមិត្តឃើញយ៉ាងនោះដល់ពួកខ្ញុំព្រះអង្គចុះ” ។

ពួកបុត្តព្រានព្រៃពោលសួមប្បីគាថាតទៅថា

[៤៦៣] ទិសា ចតស្សោ វិទិសា ចតស្សោ
ឧទ្ធំ អធោ ទស ទិសា ឥមាយោ
កតមំ ទិសំ តិដ្ឋតិ នាគរាជា
យមទ្ទស សុបិនេ ឆព្វិសាណំ ។

ទិសធំ ៤ ទិសតូច ៤ ទិសខាងលើ ១ ទិសខាងក្រោម ១ ទិសទាំង ១០ នេះ ព្រះនាងទ្រង់និមិត្តឃើញស្តេចដំរីដែល

មានភក្កមានរស្មី ៦ ប្រការនៅទិសណា ។

បណ្តាបទទាំងនោះ បទថា **ទិសា** "ទិសធំ" បានដល់ ក្នុងទិសទាំងឡាយ ។ បទថា **កតមំ** "ទិសណា" សេចក្តីថា ក្នុងបណ្តាទិសទាំងឡាយនេះ ស្តេចជំរីនៅទិសណា ព្រះនាង ។

កាលពួកព្រានទូលសួរយ៉ាងនេះហើយ ព្រះនាងសុភទ្ទារាជទេវី ទើបទ្រង់ពិចារណាមើលព្រានព្រៃទាំងអស់ក្នុងចំនួននោះ ទ្រង់ ឃើញព្រានព្រៃម្នាក់ឈ្មោះ សោណុតរៈធ្លាប់ជាគូពៀរជាមួយព្រះមហាសត្វ ប្រាកដជាកំពូលលើសព្រានគ្រប់គ្នា រូបរាងសណ្ឋានយ៉ាងអាក្រក់ ដូចជាមានជើងធំ កំភួនជើងដូចជាដុំកត្ត ជង្គង់ធំ ថ្លាមធំ ពុកមាត់ធ្លាក់ ពុកចង្កាក្រហម ភ្នែកលឿង ទើបទ្រង់ត្រិះរិះថា ព្រាននេះអាចធ្វើតាមពាក្យរបស់យើងបាន ហើយក្រាបទូលសូមព្រះបរមរាជានុញ្ញាត ទ្រង់នាំព្រានសោណុតរៈឡើងទៅកាន់ផ្ទៃប្រាសាទជាន់ទី ៧ ទ្រង់បើកសីហបញ្ជរខាងទិសឧត្តរ ហើយលាព្រះហត្ថ

ចន្ទុលត្រង់ទៅកាន់ព្រៃហិមពាន្តខាងទិសឧត្តរ បានត្រាស់ ៤ គាថា

ថា

[៤៦៤] ឥតោ ឧជុំ ឧត្តរាយំ ទិសាយំ

អតិក្កម្ម សោ សត្ត គិរី ព្រហន្តេ

សុវណ្ណបស្សោ នាម គិរិ ឧឡារោ

សំបុប្ផិតោ កិំបុរិសានុចិណ្ណោ ។

អារុយ្ហ សេលំ ភវនំ កិន្នរានំ

ឱលោកយ បព្វតបាទមូលំ

អថ ទក្ខសី មេឃសមានវណ្ណំ

និគ្រោធរាជំ អដ្ឋសហស្ស បាទំ(១) ។

តត្ថច្ឆតិ កុញ្ជរោ ឆព្វិសាណោ

សព្វសេតោ ទុប្បសហោ បរេភិ

១.ម. អដ្ឋសហស្សបោរំ ។

រក្ខន្តិ នំ អដ្ឋសហស្សនាគា
ឦសាទន្តា វាតជវប្បហារិនោ ។
តិដ្ឋន្តិ តេ តុមូលមស្សសន្តា
កុប្បន្តិ វាតស្សបិ ឯរិតស្ស
មនុស្សភូតំ បន តត្ថ ទិស្វា
ភស្មំ ករេយ្យុំ នាស្ស រជោបិ តស្ស ។

អំពីទីនេះត្រង់ទៅទិសឧត្តរ ឆ្លងភ្នំខ្ពស់ ៧ ជាន់ ភ្នំដែលខ្ពស់បំផុតឈ្មោះសុវណ្ណបស្សគិរី មានដើមឈើចេញផ្ការីកព្រោងព្រាត មានហ្វូងកិន្នរត្រាច់សញ្ចរទៅមកមិនដាច់ ។

អ្នកចូរឡើងទៅលើភ្នំដែលជាទីនៅនៃពួកកិន្នរ ហើយសម្លឹងមើលចុះមកតាមជើងភ្នំ រំពេចនោះ នឹងបានឃើញដើមជ្រៃធំពណ៌ដូចជាពណ៌ផ្ទៃមេឃ មានពួរ ៨.០០០ ពួរ សំយុងចុះ ។

ខាងក្រោមដើមជ្រៃនោះ ស្តេចស្វេតកុញ្ជរដែលមានភ្លុក

មានរស្មី ៦ ប្រការនៅអាស្រ័យ លំបាកនឹងនរណាបៀតបៀន ចាប់បាន ដំរីប្រមាណ ៨.០០០ មានភ្លុកប៉ុនដងនង្គ័ល ស្ទុះទៅលឿនរហ័សដូចខ្យល់ នាំគ្នាចោមរោមរក្សាស្តេចស្វេតកុញ្ជរ នោះ ។

ដំរីទាំងនោះរមែងបន្ទឹសំឡេងគួរឲ្យតក់ស្លុត ក្រោធសូម្បីតែខ្យល់បក់ត្រូវខ្លួន បើឃើញមនុស្សត្រង់ទីនោះ ប្រាកដជាត្រូវជាន់ឲ្យទៅជាផង់ធូលី សូម្បីតែល្អងធូលី ក៏មិនឲ្យពាល់ត្រូវស្តេចដំរីនោះបានឡើយ ។

បណ្តាបទទាំងនោះ បទថា **ឥតោ** “អំពីទីនេះ” សេចក្តីថា ម្នាលព្រានដ៏ចម្រើន អ្នកចេញអំពីទីនេះទៅហើយ ។ បទថា **ឧត្ត-រាយំ** “ទិសឧត្តរ” សេចក្តីថា អ្នកចូរទៅត្រង់ខាងទិសឧត្តរ ដើរឆ្លងភ្នំខ្ពស់ ៧ ជាន់ កាលអ្នកឆ្លងទៅហួស ៦ ភ្នំ នឹងដល់ភ្នំឈ្មោះសុវណ្ណ-បស្សគិរីពាសពេញដោយមាស ។ បទថា **ឧឡារោ** “ធំខ្ពស់” គឺ

ខ្ពស់ធំជាងភ្នំទាំង ៦ ក្រៅពីនោះ ។ បទថា **ឱរោហយ** **“សម្លឹង ចុះមក”** សេចក្ដីថា អ្នកចូរសម្លឹងចុះត្រួតមើល ។ បទថា **តត្ថច្ឆតិ** **“ក្រោមដើមជ្រៃនោះ... អាស្រ័យនៅ”** សេចក្ដីថា ក្នុងរដូវក្ដៅ ស្ដេចស្វេតកុញ្ជរនោះ ឈរទទួលទឹក និងខ្យល់នៅក្រោមដើមជ្រៃនោះ ។

បទថា **ទុប្បសហោ** **“លំបាកនឹងនរណាសង្កត់សង្កិនចាប់បាន”** សេចក្ដីថា បុគ្គលដទៃដែលឈ្មោះថាអាចនឹងចូលទៅញាំញី ចាប់យកស្ដេចស្វេតកុញ្ជរនោះមិនមានឡើយ ដូច្នោះ ទើបឈ្មោះថា អ្នកដទៃណាញាំញីបានលំបាក លុះដល់រដូវក្ដៅស្វេតកុញ្ជរបែបនេះ ក៏ឈរទទួលទឹក និងខ្យល់នៅត្រង់ក្រោមដើមជ្រៃនោះក្នុងទីនោះ នៃព្រាន ដំរី ៨.០០០ ក៏យ៉ាងនោះ ។ បទថា **ឦសាទន្តា** **“មានភ្លុក ប៉ុនដងនង្គ័ល”** បានដល់ មានភ្លុកប៉ុនចន្ទោលរថ ។ បទថា **វាត-ជវប្បហារិនោ** **“មានសន្ទុះលឿនដូចខ្យល់”** សេចក្ដីថា ដំរីទាំងនោះ មានប្រក្រតីស្ទុះទៅប្រហារបច្ចាមិត្តបានរហ័សដូចខ្យល់ ដំរី ៨.០០០

ក្បាលនេះ ចាំរក្សាស្តេចដំរីនោះ ។

បទថា **តុមូលំ**[១] **“គួរតក់ស្លុត”** សេចក្តីថា ដំរីទាំងនោះឈរបញ្ចេញខ្យល់ដង្ហើមគួរខ្លាច គឺ មានសំឡេងខ្លាំងជាប់តគ្នាជាលំដាប់រៀងទៅ ។ បទថា **ឯរិតស្ស “ខ្យល់ដែលបក់”** សេចក្តីថា ដំរីទាំងនោះរមែងក្រោធសូម្បីតែខ្យល់ដែលបក់ប៉ះ ជាប់តាមសំឡេង និងបញ្ចេញនូវសំឡេងឲ្យញ័ររន្ធត់ ឃើញមនុស្សមកក្នុងទីនោះៗ ហើយមានអាការកោចយ៉ាងនេះ ។ បទថា **នាស្ស “មិន... ដំរីនោះ”** គឺកាលមនុស្សត្រូវខ្យល់ដង្ហើមនោះកម្ចាត់ រមែងធ្វើឲ្យជាផង់ធូលីហើយក៏មិនឲ្យសូម្បីតែលម្អងធូលីធ្លាក់ត្រូវស្តេចដំរីនោះ ។

ព្រានសោណុត្តរៈស្តាប់ព្រះសវនីយ៍ហើយ ភ័យខ្លាចដល់មរណៈ ក៏ក្រាបទូលជាគាថាថា

[៤៦៥] ពហូ ហិ មេ រាជកុលម្ហិ សន្តិ

---

១.បិដក. តុមូលមស្សសន្តា ។

បិលន្ធនា ជាតរូបស្ស ទេវិ
មុត្តា មណី វេឡុរិយាមយា ច
កឹ ការណា ទន្តបិលន្ធនេន
មារេតុកាមា កុញ្ជរំ ឆព្វិសាណំ
ឧទាហុ ឃាតេស្សសិ លុទ្ទបុត្តេ ។

បពិត្រព្រះរាជទេវី គ្រឿងអាភរណៈដែលសម្រេចហើយដោយប្រាក់ កែវមុក្តា កែវមណី និងកែវពៃទូរ្យ មានហើយនៅក្នុងរាជត្រកូលយ៉ាងច្រើន ហេតុអ្វីព្រះនាងទើបទ្រង់បំណងយកភ្លុកដំរីធ្វើជាគ្រឿងប្រដាប់ហ្ន៎ ព្រះនាងម្ចាស់ទ្រង់ប្រាថ្នានឹងឲ្យសម្លាប់ដំរីដែលមានភ្លុកមានរស្មី ៦ ប្រការ ឬថា នឹងឲ្យស្តេចដំរីសម្លាប់ពួកវង្សរបស់ព្រាន ។

បណ្តាបទទាំងនោះ បទថា បិលន្ធនា "គ្រឿងអាភរណៈ" គឺ គ្រឿងអាភរណៈទាំងឡាយ ។ បទថា វេឡុរិយាមយា "កែវពៃទូរ្យ"

បានដល់ គ្រឿងកែវពៃទូរ្យ ។ បទថា ឃាតេស្សតិ(១) "សម្លាប់" គឺ ព្រានសោណុតរៈទូលសួរថា "ឬថា ព្រះនាងម្ចាស់មានព្រះបំណង នឹងឲ្យស្តេចជំរឹសម្លាប់នូវវង្សនៃពួកព្រាន ដោយលើកយកគ្រឿង ប្រដាប់ជាលេស" ។

លំដាប់នោះ ព្រះនាងទេវីត្រាស់គាថាថា

[៤៦៦] សា ឥស្សិតា ទុក្ខិតា ចស្មិ លុទ្ទ
ឧទ្ធញ្ច សុស្សាមិ អនុស្សរន្តី
ករោហិ មេ លុទ្ទក ឯតមត្ថំ
ទស្សាមិ តេ គាមវរានិ បញ្ច ។

ម្នាលព្រាន យើងនោះមានទាំងឥស្សា ទាំងសេចក្តីតូចចិត្ត ព្រោះនឹកដល់កាលខាងក្រោយក៏ឈឺចិត្ត សូមអ្នកចូរធ្វើតាម សេចក្តីបំណងរបស់យើង យើងនឹងឲ្យស្រុកសួយដល់អ្នក ៥ ស្រុក ។

---

១.បិដក. ឃាតេស្សសិ ។

បទថា **សា** "យើងនោះ" បានដល់ ខ្ញុំនេះឯង ។ បទថា **អនុស្សរន្តី** "នឹងដល់" សេចក្តីថា យើងរលឹកដល់ពៀរដែលស្តេចដំរីនោះធ្វើជាមួយយើងក្នុងកាលមុន ក៏ឈឺចិត្ត ។ បទថា **ទស្សាមិ តេ** "នឹងឲ្យ... ដល់អ្នក" សេចក្តីថា កាលសេចក្តីត្រូវការរបស់យើងនេះសម្រេច យើងនឹងឲ្យស្រុកសួយ ៥ តំបន់ ដែលមានតម្លៃបាន ១០០.០០០ កហាបណៈរាល់ៗ ឆ្នាំ ជារង្វាន់ដល់អ្នក ។

គ្រាព្រះនាងទេវីត្រាស់យ៉ាងនេះហើយ ក៏ត្រាស់លួងលោមថា "ម្នាលព្រានសម្លាញ់ ក្នុងជាតិមុនយើងបានថ្វាយនូវទានចំពោះព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្តីប្រាថ្នាថា សូមឲ្យយើងជាមនុស្សអាចនឹងឲ្យសម្លាប់ស្តេចដំរីឆទ្ទន្តនេះ យកភ្លុកទាំងគូមកឲ្យបាន នឹងថាខ្ញុំយល់សប្តិឃើញក៏មិនមែន មួយទៀត សេចក្តីប្រាថ្នាដែលខ្ញុំតាំងទុកត្រូវសម្រេច អ្នកទៅចុះ កុំខ្លាចឡើយ" ព្រានសោណុត្តរៈទទួលបដិបត្តិតាមព្រះសវនីយ៍របស់ព្រះនាងទេវីថា "យល់ព្រមព្រះនាង

ម្ចាស់” ហើយទូលថា “បើដូច្នោះ ព្រះនាងម្ចាស់ប្រោសចង្អុលបង្ហាញទីនៅរបស់ស្ដេចដំរីឆទ្ទន្តនោះឲ្យប្រាកដចុះ” កាលនឹងទូលសួរតទៅ ទើបពោលគាថាថា

[៤៦៧] កត្ថច្ឆតិ កត្ថមុបេតិ ឋានំ

វីថិស្ស កា ន្ហានគតស្ស ហោតិ

កថញ្ហិ សោ ន្ហាយតិ នាគរាជា

កថំ វិជានេមុ គតិ គជស្ស ។

ស្ដេចដំរីនោះនៅត្រង់ទីណា ចូលទៅឈរនៅទីណា ផ្លូវណាជាផ្លូវដែលស្ដេចដំរីទៅងូតទឹក មួយទៀត ស្ដេចដំរីនោះងូតទឹកយ៉ាងណា ធ្វើដូចម្ដេចខ្ញុំព្រះអង្គទើបនឹងដឹងនូវការប្រព្រឹត្តទៅរបស់ស្ដេចដំរីបាន ។

បណ្ដាបទទាំងនោះ បទថា កត្ថច្ឆតិ “នៅត្រង់ទីណា” សេចក្ដីថា ស្ដេចដំរីនៅត្រង់ទីណា ។ បទថា កត្ថមុបេតិ “ឈរនៅត្រង់

ណា” សេចក្តីថា ចូលទៅក្នុងទីណា អធិប្បាយថា ឈរទីណា ។ បទថា **វីថិស្ស កា** “ផ្លូវណា” សេចក្តីថា ផ្លូវណាជាផ្លូវដែលស្តេចដំរីទៅផ្ចូតទឹក គឺ ស្តេចដំរីទៅផ្ចូតទឹកផ្លូវណា ។ បទថា **កថំ វិជានេមុ គតី**[១] “ធ្វើដូចម្តេចខ្ញុំព្រះអង្គទើបនឹងដឹងការប្រព្រឹត្តទៅ” គឺ កាលព្រះនាងម្ចាស់មិនចង្អុលបង្ហាញ ខ្ញុំព្រះអង្គនឹងជ្រាបកន្លែងទៅមករបស់ស្តេចដំរីនោះបានយ៉ាងណា ព្រោះហេតុនោះ សូមព្រះនាងម្ចាស់ប្រោសត្រាស់ប្រាប់ខ្ញុំព្រះអង្គចុះ ។

កាលព្រះនាងទេវីនឹងត្រាស់ប្រាប់ស្ថានទីដែលទ្រង់ឃើញដោយប្រច័ក្ស ដោយញាណជាគ្រឿងរលឹកជាតិបានដល់ព្រានសោណុត្តរៈ ទើបបានត្រាស់ ២ គាថាថា

[៤៦៨] តត្ថេវ សា បោក្ខរណី អវិទូរេ

រម្មា សុតិត្ថា ច មហោទកា ច

១.បិដក. កថំ វិជា នេមុ គតិ គជស្ស ។

សំបុប្ផិតា ភមរគណានុចិណ្ណា
ឯត្ថ ហិ សោ ន្ហាយតិ នាគរាជា ។
សីសំ នហាតោ ឧប្បលមាលធារី
សព្វសេតោ បុណ្ឌរីកត្តចង្គី
អាមោទមានោ គច្ឆតិ សន្និកេតំ
បុរក្ខត្វា មហេសី សព្វភទ្ទំ ។

ក្នុងទីដែលស្តេចដំរីអាស្រ័យនៅនោះ មានស្រះនៅជិតៗ គួររីករាយ មានកំពង់រាបស្មើ ទាំងទឹកក៏ច្រើន ដេរដាសទៅដោយវណ្ណៈ ឈើផ្កា មានពួកភមរហើរក្រឡឹង ស្តេចដំរីចុះងូតទឹកក្នុងស្រះនេះឯង ។

ស្តេចដំរីសជម្រះសីសៈហើយ ប្រដាប់កម្រងឧប្បលមានពណ៌សផូរផង់ស្រដៀងផ្កាបុណ្ឌរិកយ៉ាងសប្បាយ ឲ្យមហេសីឈ្មោះសព្វភទ្ទាដើរមុខ ធ្វើដំណើរទៅកាន់ទីនៅរបស់ខ្លួន ។

បណ្ដាបទទាំងនោះ បទថា **តត្ថ** "នោះ" សេចក្ដីថា ក្នុងស្ថានទីនៅរបស់ស្ដេចដំរីនោះឯង ។ បទថា **បោក្ខរណី** "ស្រះ" នេះ ព្រះនាងទេវីទ្រង់ត្រាស់សំដៅដល់ស្រះឆទ្ទន្ត ។ បទថា **សំបុប្ផិតា** "ដេរដាសទៅដោយវណ្ណៈនៃផ្កាឈើ" សេចក្ដីថា មានផ្កាកុមុទ ២ ប្រភេទ ផ្កាឧប្បល ៣ ប្រភេទ ផ្កាបទុម ៥ ប្រភេទ មានផ្ការីកព្រោងព្រាត ។ បទថា **ឯត្ថ ហិ សោ** "ស្ដេចដំរី... ក្នុងស្រះនេះឯង" សេចក្ដីថា ស្ដេចដំរីនោះចុះងូតទឹកក្នុងស្រះឆទ្ទន្តនេះ ។ បទថា **ឧប្បលមាលធារី** "ប្រដាប់នូវកម្រងឧប្បល" សេចក្ដីថា ទ្រទ្រង់នូវកម្រងបុប្ផជាតិដែលកើតក្នុងទឹក និងលើគោក មានឧប្បលជាដើម ។ បទថា **បុណ្ឌរីកតចង្គី** "ដូចជាផ្កាបុណ្ឌរិក" សេចក្ដីថា ប្រកបដោយអវយវៈសសុទ្ធ មានសម្បុរស្រដៀងផ្កាបុណ្ឌរិក ។

បទថា **អាមោទនានោ**[១] "សប្បាយចិត្ត" សេចក្ដីថា ទាំងសប្បាយរីករាយ ។ បទថា **សនិកេតំ**[២] "កាន់ទីនៅ" សេចក្ដីថា

---

១.បិដក. អាមោទមានោ , ២. សន្និកេតំ ។

ទៅកាន់ទីនៅរបស់ខ្លួន ។ បទថា បុរក្ខត្វា "ដើរមុខ" សេចក្ដីថា ព្រះនាងទេវីត្រាស់ថា ស្ដេចដំរីធ្វើមហេសីឈ្មោះសព្វកទ្ទាទុកខាងមុខ ហែហមដោយដំរី ៨.០០០ ជាបរិវារ ទៅកាន់ទីនៅរបស់ខ្លួន ។

ព្រានសោណុត្តរៈស្ដាប់ព្រះសវនីយ៍ហើយ បានទូលទទួលថា "ករុណាព្រះនាងម្ចាស់ ខ្ញុំព្រះអង្គនឹងសម្លាប់ដំរីនោះនាំយកភ្លុកមកថ្វាយ" គ្រានោះ ព្រះនាងទេវីទ្រង់រីករាយព្រះទ័យ ប្រទានទ្រព្យដល់គេ ១.០០០ កហាបណៈ ត្រាស់ថា "អ្នកត្រឡប់ទៅផ្ទះសិនចុះ ៧ ថ្ងៃទៀតសឹមទៅទីនោះ" គ្រាបញ្ជូនគេទៅហើយ ទ្រង់ត្រាស់ឲ្យជាងដែកមកគាល់ ទ្រង់បញ្ជាថា "នែបា ខ្ញុំត្រូវការកាំបិតបត់ ពូថៅ ចបពន្លាក ញញួរ កាំបិតភ្ជារគុម្ពឫស្សី កណ្ដៀវប្រួតស្មៅ ដាវ ដំបងលោហៈ លំពែង រណារ និងបង្គោលដែក សម បាចូរប្រញាប់ធ្វើរបស់ទាំងអស់នោះមកឲ្យខ្ញុំ" ហើយត្រាស់ឲ្យជាងស្បែកមកគាល់ទ្រង់បញ្ជាថា "ម្នាលបា អ្នកគប្បីចាត់ចែងធ្វើការុងស្បែក សម្រាប់

ដាក់សម្ភារៈធ្ងន់ប្រមាណមួយកុម្ភៈឲ្យយើង យើងត្រូវការខ្សែស្បែក ខ្សែចង ស្រោមដៃ ទ្រនាប់ជើង និងធុងស្បែក បាចូរជួយធ្វើរបស់ទាំងអស់នេះឲ្យយើងផង” តាំងអំពីនោះ ជាងទាំងពីរក៏ប្រញាប់ធ្វើរបស់ទាំងអស់នោះ នាំមកថ្វាយព្រះទេវី ។ ព្រះនាងទើបទ្រង់ត្រៀមស្បៀងឲ្យសោណុត្តរព្រាន តាំងអំពីឈើស្ងួនជាដើម ដាក់គ្រឿងឧបករណ៍គ្រប់យ៉ាង និងស្បៀងមានសដូវដុំជាដើម ដាក់ក្នុងការុងស្បែក គ្រឿងឧបករណ៍ និងស្បៀងទាំងអស់នោះ ធ្ងន់ប្រមាណ ១ កុម្ភៈ ។ ចំណែកសោណុត្តរព្រាននោះ ត្រៀមខ្លួនជាស្រេច លុះដល់ថ្ងៃទី ៧ ក៏មកគាល់ថ្វាយបង្គំព្រះរាជទេវី ។ លំដាប់នោះ ព្រះនាងទេវីត្រាស់នឹងគេថា “គ្រឿងឧបករណ៍គ្រប់យ៉ាងរបស់អ្នកសម្រេចហើយ អ្នកចូរល្បងលើកការុងនេះចុះ” ក៏សោណុត្តរព្រាននោះជាមនុស្សមានកម្លាំងច្រើន ទ្រទ្រង់នូវកម្លាំងប្រមាណ ៥ ដំរីសារ ។ ព្រោះដូច្នោះ ទើបលើកការុងឡើងប្រហែលនឹងលើកកន្ត្រកម្លូ ហើយ

ស្តាយទីងស្នាឈរព្រងើយដូចជាឈរដែទទេ ។ ព្រះនាងសុភទ្ទាទើប ប្រទានបាយដល់ពួកកូនៗ របស់ព្រាន ហើយក្រាបទូលថ្វាយព្រះ រាជាទ្រង់ជ្រាប ចាត់បញ្ជូនសោណុត្តរព្រានទៅ ។

ចំណែកសោណុត្តរព្រាននោះ គ្រាថ្វាយបង្គំព្រះរាជា និងព្រះ ទេវីហើយ ក៏ចុះចាកព្រះរាជនិវេសន៍ ឡើងរថចេញពីព្រះនគរដោយ បរិវារដ៏ច្រើន កន្លងគាមនិគម និងជនបទតាមលំដាប់ ដល់ចុងព្រះ រាជាណាខេត្តហើយ ទើបឲ្យអ្នកជនបទត្រឡប់ ធ្វើដំណើរចូលព្រៃ អ្នកស្រុកជាយដែនរហូតផុតដែនដីមនុស្ស ទើបឲ្យអ្នកស្រុកជាយដែន ត្រឡប់ទាំងអស់ ហើយដើរទៅតែម្នាក់ឯងអស់រយៈផ្លូវ ៣០ យោជន៍ ដល់ព្រៃក្រាស់ ១៨ កន្លែងដោយលំដាប់ គឺ ដំបូងព្រៃស្បូវក្លាំង ព្រៃត្រែង ព្រៃស្មៅ ព្រៃឈើមានខ្លឹម ព្រៃឈើមិនមានខ្លឹម ព្រៃ ឈើមិនមានសំបក ព្រៃស្តៅ ព្រៃសសិត ព្រៃឈើមានពណ៌ផ្សេងៗ ព្រៃបបុស ព្រៃអញ្ចាញ ព្រៃស្តុកក្រាស់សូម្បីពស់ក៏លូនទៅបាន

លំបាក ព្រៃឈើសាមញ្ញ ព្រៃឫស្សី ព្រៃគុម្ពឫស្សី ព្រៃភក់ ព្រៃទឹក ព្រៃភ្នំ លុះចូលទៅហើយ ក៏យកកណ្ដៀវប្រូតស្បូវ យកកាំបិតសម្រាប់កាប់ភ្លារគុម្ពឫស្សីជាដើម យកពូថៅកាប់គល់ដើមឈើ ប្រើពន្លាកជំរោះធ្វើផ្លូវដើរ ត្រង់ព្រៃឫស្សីក៏ធ្វើជណ្ដើរឡើងកាប់ឫស្សីឲ្យធ្លាក់គ្របលើគុម្ពឫស្សីដទៃ ហើយដើរទៅតាមខាងលើដើមឫស្សីដល់ទីដែលមានភក់ស្ងួ ក៏បោះឈើជាបង្គោលដើទៅតាមនោះ និងបោះកំណាត់ឈើដទៃតទៅទៀត ដកកំណាត់ឈើក្រៅអំពីនេះ បោះតទៅខាងមុខ ឆ្លងព្រៃដែលមានភក់ទៅបាន ដល់ព្រៃដែលមានទឹកស្ងួ ក៏ធ្វើទូកកំពោលឆ្លងទៅឈរនៅត្រង់ជើងភ្នំ យកខ្សែចងដែកសម គ្រវែងឡើងទៅឲ្យជាប់នឹងភ្នំ ហើយតោងឡើងទៅតាមខ្សែស្បែករហូតដល់ឈរនៅលើភ្នំបាន ទើបទម្លាក់ខ្សែស្បែកនោះចុះទៅកាន់ខ្សែស្បែកចុះមកចងត្រង់បង្គោលខាងក្រោម ហើយតោងឡើងតាមខ្សែ យកដំបងដែកដែលមានចុងស្រួចមុតដូចពេជ្រ ចោះភ្នំបោះ

បង្គោលដែកស្រេចហើយ ក៏ឈរនៅទីនោះ ទើបស្រាយដែកសម្រេច ហើយគ្រវែងទៅខាងលើទៀត ។ ឈរនៅត្រង់នោះ ហើយទម្លាក់ខ្សែស្បែកចុះទៅចងទុកត្រង់បង្គោលខាងក្រោម តោងឡើងទៅតាមខ្សែ ដៃឆ្វេងកាន់ខ្សែ ដៃស្តាំកាន់ញញួរ ស្រាយខ្សែហើយដកបង្គោលដែកឡើងតទៅទៀត ដោយទំនងនេះរហូតឡើងទៅដល់កំពូលភ្នំ កាលនឹងចុះអំពីខាងនោះ ក៏ដំបង្គោលដែកត្រង់កំពូលភ្នំទី ១ ដោយទំនងនោះឯង ទើបបានយកខ្សែចងការុងស្បែកភ្ជាប់នឹងបង្គោល ខ្លួនឯងអង្គុយក្នុងការុងស្បែក ស្រាយខ្សែឲ្យធ្លាក់ចុះមកស្រដៀងនឹងអាការសត្វពីងពាង អាចារ្យខ្លះពោលថា "សោណុត្តរព្រានចុះអំពីភ្នំដោយឆត្រស្បែក ដូចបក្សីត្រដាងស្លាបចុះដូច្នោះ" ។

ព្រះសាស្តា កាលនឹងទ្រង់ធ្វើឲ្យច្បាស់ដល់ប្រការដែលព្រានសោណុត្តរៈ ទទួលយកព្រះសវនីយ៍របស់ព្រះនាងសុភទ្ទាយ៉ាងនោះហើយ ចេញចាកព្រះនគរកន្លងព្រៃ ១៧ កន្លែង រហូតដល់ជួរជង

ភ្នំ ធ្វងភ្នំ ៦ ក្នុងទីនោះបាន ហើយឡើងកាន់កំពូលភ្នំសុវណ្ណបស្ស-
បព៌ត ទើបត្រាស់ព្រះគាថាថា

[៤៦៩] តតោ សោ ឧគ្គហេត្វាន វាក្យំ
អាទាយ តូណិញ្ច[១] ធនុញ្ច លុទ្ទោ
វិតុរិយតិ សត្ត គិរី ព្រហន្តេ
សុវណ្ណបស្សន្នាម គិរី ឧឡារំ ។
អារុយ្ហ សេលំ ភវនំ កិន្នរានំ
ឱលោកយិ បព្វតបាទមូលំ
តត្ថទ្ទសា មេឃសមានវណ្ណំ
និគ្រោធរាជំ អដ្ឋសហស្សបាទំ ។
តត្ថទ្ទសា កុញ្ជរំ ឆព្វិសាណំ
សព្វសេតំ ទុប្បសហំ បរេភិ
រក្ខន្តិ នំ អដ្ឋសហស្សនាគា

ឦ្សាទន្តា វាតជវប្បហារិនោ ។

តត្ថុស្សា បោក្ខរណី អវិទូរេ
រម្មំ សុតិត្ថញ្ច មហោទកញ្ច
សំបុប្ផិតំ ភមរគណានុចិណ្ណំ
យត្ថ ហិ សោ ន្ហាយតិ នាគរាជា ។

ទិស្វាន នាគស្ស គតឹ ឋិតញ្ច
វីថិស្ស យា ន្ហានគតស្ស ហោតិ
ឱបាតមាគច្ឆិ អនរិយរូបោ
បយោជិតោ ចិត្តវសានុគាយ ។

ព្រានទោះ កាន់យកព្រះសវនីយ៍របស់ព្រះនាងសុភទ្ទារាជ-ទេវី ដែលប្រថាប់ឈរនៅត្រង់ទីនោះឯង ហើយកាន់យកបំពង់ធ្នូ ចូងភ្នំធំទាំង ៧ ទៅរហូតដល់គិរីបព៌តឈ្មោះថា សុវណ្ណ-បស្សបព៌ត ។

គេឡើងទៅកាន់បពិតដែលជាទីនៅរបស់កិន្នរហើយ បានសម្លឹងមើលចុះមកជើងភ្នំ បានឃើញដើមជ្រៃធំពណ៌ខៀវដូចជាផ្ទៃមេឃ មានឫស ៨.០០០ ធ្លាក់រយោងត្រង់ជើងភ្នំនោះ ។

វេលានោះឯង គេក៏បានឃើញស្តេចដំរីស ដែលមានភ្លុកមានរស្មី ៦ ពណ៌ លំបាកនឹងមានបុគ្គលដទៃចាប់បាន មានដំរីប្រមាណ ៨.០០០ សុទ្ធតែមានភ្លុក.ងស្អាតខ្នាតប៉ុនជង្គន់ល មានសន្ទុះលឿនរហ័សដូចខ្យល់ រក្សាស្តេចដំរីនោះឯង ។

ម្យ៉ាងទៀត គេបានឃើញស្រះបោក្ខរណីដែលគួរមនោរម្យនៅជិតទីនៅរបស់ស្តេចដំរីនោះ ទាំងកំពង់ទឹកក៏រាបស្មើ ទឹកក៏មានច្រើន មានវណ្ណឈើផ្ការីកពាសពេញ មានពួកភមរជាតិត្រាច់ឆ្វេលឆ្វាត់ជាអាចិណ្ណ ។

គ្រាឃើញស្តេចដំរីចុះងូតទឹក ទាំងទីដែលស្តេចដំរីដើរ ទីឈរ និងផ្លូវដែលស្តេចដំរីចុះងូតទឹក ក៏នាយព្រានអ្នកមានចិត្ត

អាក្រក់ លុះក្នុងអំណាចព្រះនាងសុកទ្វាទ្រង់ប្រើមក ក៏បាន
ចាត់ចែងត្រៀមរណ្តៅ ។

បណ្តាបទទាំងនោះ បទថា **សោ** “**នោះ**” សេចក្តីថា ម្នាល
ភិក្ខុទាំងឡាយ ព្រាននោះ កាន់យកព្រះតម្រាស់របស់ព្រះទេវីដែល
ប្រថាប់ឈរត្រង់ផ្លែប្រាសាទជាន់ទី ៧ នោះ ហើយកាន់យកបំពង់
សរ និងធ្នូធំទៅកាន់ដងព្រៃនៃបព៌ត គិតថា ភ្នំណាហ្ន៎ ឈ្មោះសុ-
វណ្ណបស្សបព៌ត ទើបធ្វូងមហាបព៌តទាំង ៧ ។ បទថា **វិតុរិយា**[១]
“**ធ្វូង**” សេចក្តីថា គិត គឺ ពិចារណាក្នុងគ្រានោះ ។ កាលកំពុង
ពិចារណានោះឯង គេក៏ឃើញភ្នំដែលឈ្មោះថា សុវណ្ណបស្សគិរី
ធំខ្ពស់ ទើបគិតថា ប្រហែលជាភ្នំនេះហើយ ។

បទថា **ឱលោកយិ** “**សម្លឹងចុះមក**” សេចក្តីថា គេឡើងទៅ
កាន់បព៌តដែលជាទីនៅរបស់ពួកកិន្នរហើយ ក៏សម្លឹងមើលតាមការ

---
១.បិដក. វិតុរិយតិ ។

កំណត់ដែលព្រះនាងសុភទ្ទាប្រទាន ។ បទថា **តត្ថ** **"គេនោះ"** គឺគេទើបឃើញដើមនិគ្រោធនៅក្បែរជើងភ្នំនោះឯង ។ បទថា **តត្ថ** **"ដើមជ្រៃនោះ"** សេចក្តីថា ឈរនៅត្រង់គល់ដើមជ្រៃនោះ ។ បទថា **តត្ថ** **"នោះ"** សេចក្តីថា ខាងក្នុងភ្នំ មិនឆ្ងាយអំពីដើមជ្រៃនោះ ស្តេចដំរីផ្ញុំ(ងូត)ទឹកត្រង់ស្រះធម្មជាតិណា គេបានឃើញស្រះធម្មជាតិនោះ ។ បទថា **ទិស្វាន** **"ឃើញ"** សេចក្តីថា ក្នុងវេលាដែលដំរីទាំងឡាយទៅហើយ ព្រាននោះក៏ចុះចាកសុវណ្ណបព្វតបព៌ត ពាក់ស្រោមដៃនិងទ្រនាប់ជើង ហើយត្រួតមើលទីដែលស្តេចដំរីនោះទៅ និងទីដែលស្តេចដំរីនៅជាប្រចាំ ដោយសព្វគ្រប់ថា ស្តេចដំរីដើរផ្លូវនេះ ងូតទឹកត្រង់នេះ គ្រាងូតទឹកហើយឡើងទៅឈរត្រង់ទីនេះ ព្រោះជាអ្នកមិនមានហិរិ គឺ មានចិត្តលាមក ត្រូវព្រះនាងសុភទ្ទាដែលលុះក្នុងអំណាចចិត្តប្រើមក ព្រោះដូច្នោះ ទើបមកត្រៀមរណ្តៅ គឺ ជីករណ្តៅទុក ។

ក្នុងរឿងនោះ មានសេចក្ដីរៀងលំដាប់ដូចតទៅនេះ តំណាល មកថា សោណុតរព្រាននោះ មកដល់ទីនៅរបស់ព្រះមហាសត្វក៏ កំណត់បាន ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ កំណត់មើលស្ថានទីនៅរបស់ ព្រះមហាសត្វ ដោយន័យដូចពោលហើយនោះ កំណត់ទុកក្នុងចិត្ត ថា "យើងនឹងត្រូវជីករណ្ដៅត្រង់ទីនេះ ឈរអែបក្នុងរណ្ដៅនោះបាញ់ ស្ដេចដំរីឲ្យស្លាប់" ដូច្នេះហើយ ទើបចូលព្រៃកាប់ដើមឈើដើម្បី ធ្វើសសរជាដើម ត្រៀមទព្វសម្ភារៈទុក កាលដំរីទាំងឡាយទៅងូត ទឹកហើយ ទើបយកចបជំជីករណ្ដៅចតុរស្ស (បួនជ្រុង) ត្រង់ទីនៅ របស់ស្ដេចដំរី ហើយយកទឹកស្រោច ធ្វើដូចជាកូនឈើដែលទើប នឹងដុះឡើង កប់សសរចុះលើថ្មដែលមានសណ្ឋានស្រដៀងត្បាល់ ក្រាលក្ដារពីលើ ចោះរន្ធតូចល្មមមើលឃើញ ហើយរោយធូលី និង បោសសំរាម លាមកដំរីក្រៀមអំពីលើ ធ្វើផ្លូវចេញចូលរបស់ខ្លួន កាលរណ្ដៅសម្រេចហើយ ក្នុងវេលាជិតភ្លឺ ទើបគ្របសីសៈ ដណ្ដប់

សំពត់កាសាវពស្ត្រ កាន់ធ្នូព្រមដោយកូនសរលាបថ្នាំពិស ចុះទៅឈរនៅក្នុងរណ្តៅ ។

ព្រះសាស្តាកាលនឹងទ្រង់ប្រកាសនូវសេចក្តីនោះ ក៏ទ្រង់បានត្រាស់គាថាថា

[៤៧០] ខណិត្វាន កាសុំ ផលកេហិ ឆាទយិ
អត្តានមោធាយ ធនុញ្ច លុទ្ទោ
បស្សាគតំ បុថុសល្លេន នាគំ
សមប្បយិ ទុក្កដកម្មការី ។
វិទ្ធោ ច នាគោ កោញ្ចមនាទិ ឃោរំ
សព្វេ នាគា និន្នាទុំ ឃោររូបំ
តិណញ្ច កដ្ឋញ្ច រណំ ករោន្តា
ធាវីសុ តេ អដ្ឋ ទិសា សមន្តតោ ។
វធិស្សមេនន្តិ បរាមសន្តោ

កាសាវមុទ្ទិ ធជំ ឥសីនំ

ទុក្ខេន ផុដ្ឋស្សុទបាទិ សញ្ញា

អរហទ្ធជោ សព្ភិ អវជ្ឈរូបោ ។

ព្រានអ្នកមាននិស្ស័យធ្វើកម្មដ៏អាក្រក់ ជីករណ្ដៅយកក្ដារបិទស្រេចហើយ បិទបាំងខ្លួន យកកូនសរធំដាក់ក្នុងធ្នូបាញ់ស្ដេចដំរីដែលមកឈរនៅខាងលើរណ្ដៅរបស់ខ្លួន ។

ស្ដេចដំរីត្រូវបាញ់ហើយ ក៏បន្លឺនូវសំរែកកោញ្ចនាទ ដំរីទាំងឡាយនាំគ្នាបន្លឺសំឡេងអឺងកង នាំគ្នារត់មកព័ទ្ធជុំវិញទាំង ៨ ទិស ធ្វើស្មៅ និងឈើឲ្យខ្ទេចខ្ទីជាផង់ ។

ស្ដេចដំរីចាប់ព្រាននោះ ដោយគិតថា យើងនឹងសម្លាប់ព្រាននេះ តែបានឃើញសំពត់កាសាវពស្ត្រដែលជាទង់ជ័យរបស់ឥសី ខណៈនោះ ការរលឹកបានកើតឡើងដល់ព្រះមហា-សត្វកំពុងទទួលនូវទុក្ខវេទនាថា ទង់ជ័យរបស់ព្រះអរហន្តដែល

សប្បុរសមិនគួរទម្លាយ ។

បណ្ដាបទទាំងនោះ បទថា ឱធាយ[១] "បញ្ចូល" បញ្ចូលកូនសរ ។ បទថា បស្សាគតំ "មកឈរនៅក្នុងរណ្ដៅ" សេចក្ដីថា ខ្លួនមកឈរនៅខាងក្នុងរណ្ដៅរបស់ខ្លួន ។

បានឮថា ក្នុងថ្ងៃទី ២ ស្ដេចដំរីនោះមកងូតទឹក ហើយឡើងមកឈរនៅត្រង់ទីលានធំនោះ លំដាប់នោះ ទឹកអំពីសរីរៈស្ដេចដំរីនោះ ក៏ហូរស្រក់តាមផ្ចិត ធ្លាក់ត្រូវខ្លួនរបស់ព្រានតាមប្រហោងនោះ តាមការសង្កេតនោះ ព្រានក៏ដឹងថា ព្រះមហាសត្វមកឈរហើយ ទើបយកកូនសរជំបាញ់ស្ដេចដំរី ដែលមកឈរនៅអំពីខាងលើរណ្ដៅរបស់ខ្លួន ។

បទថា ទុក្កដកម្មការី "អ្នកមាននិស្ស័យធ្វើកម្មដ៏អាក្រក់" គឺឈ្មោះថា អ្នកបង្កនូវកម្មដ៏អាក្រក់ ព្រោះបង្កនូវទុក្ខឲ្យកើតដល់ព្រះម-

១.បិដក. អត្តាមនោធាយ... ។

ហាសត្វទាំងកាយ និងចិត្ត ។ បទថា **កោញ្ចនមនាទិ**[១] "បន្លឺសម្រែក

**កោញ្ចនាទ**" សេចក្តីថា បន្លឺនូវកោញ្ចនាទកងរំពង ន័យថា កូនសរ

នោះទម្លុះត្រង់ផ្ចិតរបស់ស្តេចដំរី ទម្លាយអវយវៈដូចជាស្នូតជាដើម

ឲ្យបែក ផ្តាច់ពោះវៀនតូចជាដើមវៀនទៅរហូតធ្លាយចេញតាមខ្នង

ស្តេចដំរី ហើយស្ទុះទៅក្នុងអាកាស ។ មុខរបួសស្រដៀងនឹងត្រូវ

មុតពូថៅដូច្នោះ ឈាមហូរចេញតាមមុខរបួសដូចទឹកល័ក្ខហូរចេញ

អំពីក្អមបែក ញ៉ាំងនូវទុក្ខវេទនាដ៏ខ្លាំង ស្តេចដំរីមិនអាចអត់ទ្រាំនឹង

ទុក្ខវេទនាបាន ក៏ស្រែកឡើងឮកងរំពងទូទៅសកលបពិត បន្លឺនូវ

កោញ្ចនាទរហូត ៣ ដង ។ បទថា **សព្វេ** "**ទាំងអស់**" សេចក្តី

ថា ដំរី ៨.០០០ ក្បាលទាំងអស់បានឮសំឡេងនោះខ្វះក៏ភ័យតក់ស្លុត

ដល់មរណៈ ក៏បន្លឺសំឡេងដ៏ចម្លែកគួរភ័យខ្លាច ។ បទថា **រណំ**

**ករោន្តា** "**ធ្វើ... ឲ្យបែកជាផង់ធូលី**" សេចក្តីថា ដំរីទាំង ៨.០០០

បញ្ចេញសំឡេងគឹកកងគួរឲ្យខ្លាច ស្ទុះមកតាមសំឡេងនោះ ឃើញ

---

១.បិដក. កោញ្ចមនាទិ ។

ស្តេចដំរីឆទ្ទន្តត្រូវទទួលនូវទុក្ខវេទនា គិតថា ពួកយើងនឹងចាប់នូវបច្ចាមិត្រឲ្យបាន ហើយក៏ស្ទុះជាន់ស្មៅ និងឈើឲ្យបែកខ្ទេចខ្ទីជាផង់ធូលី ។ បទថា **វេធិស្សាមេតំ**[១] **“យើងនឹងសម្លាប់ព្រាននេះ”** សេចក្តីថា ម្នាលភិក្ខុទាំងឡាយ គ្រាដំរីទាំងឡាយគេចចេញទៅក្នុងទិសានុទិសហើយ កាលមេដំរីមហាសុភទ្ទាចូលទៅឈរក្បែរស្តេចដំរីលួងលោម ស្តេចដំរីឆទ្ទន្តក៏អត់ទ្រាំនឹងវេទនាបាន ហើយកំណត់ផ្លូវដែលកូនសរស្ទុះចេញមក ពិចារណាមើលថា បើកូនសរនេះមកអំពីបុរត្ថិមទិសជាដើមហើយ កូនសរនឹងត្រូវទម្លុះពោងជាដើមមុនហើយនឹងចេញទៅតាមផ្លូវនេះជាដើម តែនេះត្រូវត្រង់នាភី ធ្លុះចេញទៅកាន់អាកាស ព្រោះដូច្នោះ កូនសរនេះនឹងមានមនុស្សឈរនៅក្នុងដីបាញ់ចេញមក បំណងនឹងត្រួតមើលទីដែលមនុស្សឈរតទៅទើបគិតថា នរណានឹងដឹងថា នឹងមានអ្វីកើតឡើង គួរយើងឲ្យនាង

១.បិដក. វេធិស្សាមេនន្តិ ។

មហាសុភទ្ទាចេញទៅសិន ហើយពោលថា "ប្អូនសម្លាញ់ ដំរីទាំង ៨.០០០ ស្វែងរកបច្ចាមិត្ររបស់បង បាននាំគ្នារត់ទៅកាន់ទិសានុទិស ប្អូនរវល់ធ្វើអ្វីនៅទីនេះ" កាលនាងមហាសុភទ្ទាតបថា "បពិត្រអ្នកជាស្វាមី ខ្ញុំឈររង់ចាំព្យាបាលលួងលោមលោក សូមលោកអត់នូវទោសដល់ខ្ញុំផងចុះ" ហើយធ្វើប្រទក្សិណ ៣ ជុំ ធ្វើសេចក្តីគោរពក្នុងឋានៈទាំង ៤ ហើយក៏ហោះទៅកាន់អាកាស ចំណែកស្តេចដំរីក៏យកក្រចកជើងឈូសផែនដី បន្ទះក្តារក៏ផ្ងាត់ឡើង ស្តេចដំរីសម្លឹងមើលតាមប្រហោងនោះ ឃើញសោណុត្តរព្រាន ក៏កើតទោសចិត្តគិតថា យើងនឹងសម្លាប់វា ទើបសឹកប្រមោយដែលដូចជាកម្រងប្រាក់ចុះទៅស្ទាបមើល បានសម្លឹងឃើញសំពត់កាសាវៈដែលជាទង់ជ័យរបស់ព្រះអរហន្តមានព្រះពុទ្ធជាដើម ៗ ស្តេចដំរីទើបលើកនាយព្រានឡើងមកដាក់អំពីខាងមុខ ។ លំដាប់នោះ សញ្ញា គឺ ការរលឹកខុសត្រូវបានកើតឡើងដល់ព្រះមហាសត្វដែលកំពុងទទួលទុក្ខវេទនា

ដ៏ខ្វាំង ដូច្នេះថា ដែលឈ្មោះថា ទង់ជ័យរបស់ព្រះអរហន្តបណ្ឌិត មិនគួរទម្លាយឡើយ គួរធ្វើសក្ការៈគោរពតែម្យ៉ាងដោយពិត កាលព្រះមហាសត្វសន្ទនាជាមួយព្រាន ទើបពោល ២ គាថាថា

[៤៧១] អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហិស្សតិ
អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ ។
យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ
ឧបេតោ ទមសច្ចេន សវេ កាសាវមរហតិ ។

បុគ្គលណាមិនទាន់អស់កិលេស ប្រាសចាកទមៈ និងសច្ចៈ បុគ្គលនោះមិនគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈឡើយ ។

ចំណែកបុគ្គលណាប្រាសចាកកិលេសហើយ តាំងនៅក្នុងសីល ប្រកបដោយទមៈ និងសច្ចៈ បុគ្គលនោះគួរស្លៀកដណ្តប់នូវសំពត់កាសាវៈ ។

គាថានោះមានអធិប្បាយដូច្នេះ ព្រានសម្លាញ់ ជនណាប្រើ

បុគ្គលអ្នកមានកិលេសដូចទឹកចត់មានរាគៈជាដើម ប្រាសចាកការទូន្មានឥន្ទ្រិយ ទាំងវចីសច្ចៈ គឺ មិនចូលដល់គុណទាំងនោះ ស្លៀកដណ្តប់សំពត់កាសាវៈដែលជ្រលក់ហើយដោយទឹកចត់ បុគ្គលនោះមិនគួរស្លៀកដណ្តប់សំពត់កាសាវៈនោះឡើយ គឺ មិនសមគួរជាមួយនឹងសំពត់នោះ ចំណែកបុគ្គលណាឈ្មោះថា ជាអ្នកជម្រះកិលេសបាន ព្រោះខ្ជាក់នូវកិលេសដូចទឹកចត់ទាំងនោះចេញបាន ។ បទថា **សីលេសុ សុសមាហិតោ "តាំងនៅក្នុងសីល"** សេចក្តីថា បុគ្គលណាជាអ្នកមានសីល និងអាចារៈតម្កល់មាំដោយល្អបរិបូណ៌ បុគ្គលនោះឈ្មោះថា គួរស្លៀកដណ្តប់សំពត់កាសាវៈនេះ ។

ព្រះមហាសត្វលុះពោលយ៉ាងនេះហើយ ក៏រម្ងាប់ការគិតនឹងសម្លាប់ព្រាននោះ សួរថា "សម្លាញ់ អ្នកបាញ់យើងដើម្បីត្រូវការអ្វី ដើម្បីប្រយោជន៍ខ្លួនឯង ឬអ្នកដទៃប្រើមក ។

ព្រះសាស្តាកាលនឹងប្រកាសសេចក្តីនោះ ទើបត្រាស់នូវព្រះ

គាថាថា

[៤៧២] សមប្បិតោ បុថុសល្លេន នាគោ
អទុដ្ឋចិត្តោ លុទ្ទកំ អជ្ឈភាសិ
កិមត្ថិយំ(១) កិស្ស វា សម្ម ហេតុ
មមំ វធី កស្ស វាយំ បយោគោ ។

ស្តេចដំរីត្រូវកូនសរធំមុតចូលហើយ មិនមានចិត្តគិតប្រទូស្ត បានសួរព្រានថា សម្លាញ់អើយ អ្នកបំណងអ្វី ព្រោះហេតុអ្វី ឬថា នរណាប្រើអ្នកឲ្យមកសម្លាប់យើង ។

បណ្តាបទទាំងនោះ បទថា **កិមត្ថិយំ** "បំណងអ្វី" សេចក្តីថា អ្នកប្រាថ្នាអ្វីក្នុងអនាគត ។ បទថា **កិស្ស វា** "ព្រោះហេតុអ្វី" បានដល់ ព្រោះហេតុណា ។ អធិប្បាយថា ដោយហេតុណា គឺ អ្នកចងពៀរអ្វីជាមួយយើង ។ បទថា **កស្ស វា**(២) "ឬថានរណា" គឺ

---

១.ម. កឹ បត្ថយំ ។ ២.បិដក. កស្ស វាយំ ។

ឬថា នេះជាសេចក្តីបំណងរបស់អ្នកដទៃ គឺ នរណាប្រើអ្នកឲ្យមក សម្លាប់យើង ។ កាលសោណុត្តរព្រានទឹងប្រាប់សេចក្តីនោះចំពោះស្តេចដំរី ទើបពោលគាថាថា

[៤៧៣] កាសិស្ស រញ្ញោ មហេសី ភទន្តេ

សា បូជិតា រាជកុលេ សុភទ្ទា

សា តំ អទ្ទស សា ច មមំ អសំសិ

ទន្តេហិ អត្ថោតិ មមំ អវោច ។

ស្តេចដំរីដ៏ចម្រើន នាងសុភទ្ទាព្រះមហេសីរបស់ព្រះបាទកាសិករាជ ដែលប្រជាជនសក្ការៈបូជានៅក្នុងរាជត្រកូល ព្រះនាងទ្រង់បាននិមិត្តឃើញលោក និងបានប្រោសឲ្យធ្វើសក្ការៈដល់ខ្ញុំហើយ ត្រាស់ប្រាប់ខ្ញុំថា មានព្រះបំណងក្នុងភ្លុកទាំងគូរបស់លោក ។

បណ្តាបទទាំងនោះ បទថា បូជិតា "សក្ការៈបូជា" សេចក្តី

ថា ដែលប្រជាជនបូជាហើយដោយឋានៈជាព្រះអគ្គមហេសី ។ បទ ថា **អទ្ទសា**[១] **"ទ្រង់បានទិមិត្តឃើញ"** សេចក្តីថា ន័យថា ព្រះនាង ទ្រង់ព្រះសុបិនទិមិត្តឃើញលោក ។ បទថា **អសំសិ "ត្រាស់ប្រាប់"** សេចក្តីថា ទាំងព្រះនាងក៏ប្រោសឲ្យធ្វើសក្ការៈដល់ខ្ញុំ ហើយត្រាស់ ប្រាប់ខ្ញុំថា "ក្នុងព្រៃហិមពាន្ត មានស្តេចដំរីរូបរាងយ៉ាងនេះ នៅទី កន្លែងឯណោះ" ។ បទថា **ទន្តេហិ "ភ្លុក"** សេចក្តីថា ព្រះនាងទេវី បានត្រាស់ប្រាប់ខ្ញុំថា "ភ្លុកទាំងពីររបស់ស្តេចដំរីនោះ មានរស្មី ៦ ប្រការរុងរឿង យើងត្រូវការភ្លុកទាំងនោះ បំណងនឹងធ្វើជាគ្រឿង ប្រដាប់ អ្នកចូរទៅនាំយកភ្លុកដំរីនោះមកឲ្យយើង" ។

ព្រះមហាសត្វទ្រង់ស្តាប់ដូច្នោះ ក៏បានជ្រាបថា "នេះជាការធ្វើ របស់នាងចុល្លសុភទ្ទា" ស៊ូអត់ទ្រាំនូវទុក្ខវេទនា ពោលថា "ព្រះ នាងសុភទ្ទានោះ ត្រូវការភ្លុកទាំងគូរបស់យើងក៏មិនមែន តែព្រោះ

---

១.បិដក. អទ្ទស សា ។

បំណងនឹងឲ្យអ្នកមកសម្លាប់យើង ទើបបានបញ្ជូនមក” កាលនឹងសម្តែងសេចក្តីតទៅ ទើបត្រាស់ ២ គាថាថា

[៤៧៤] ពហូ ហិ មេ ទន្តយុគា ឧឡារា

យេ មេ បិតូនញ្ច បិតាមហានំ

ជានាតិ សា កោធនា រាជបុត្តី

វធត្ថិកា វេរមកាសិ ពាលា ។

ឧដ្ឋេហិ ត្វំ លុទ្ទ ខរំ គហេត្វា

ទន្តេ ឥមេ ឆិន្ទ បុរា មរាមិ

វជ្ជាសិ តំ កោធនំ រាជបុត្តី

នាគោ ហតោ ហន្ទ ឥមស្ស ទន្តា ។

ពិតហើយ ព្រះនាងសុភទ្ទាទ្រង់ជ្រាបថា ភ្លុកស្អាតៗ នៃបិតា និងជីតារបស់យើងមានយ៉ាងច្រើន តែព្រះនាងជាបុគ្គលពាល ក្រោធខឹង ចង់ពៀរត្រូវការនឹងសម្លាប់យើង ។

ម្នាលព្រាន អ្នកចូរក្រោកឡើង ចូរយករណារមក កាត់នូវភ្លុកគូនេះចុះ មុននឹងយើងស្លាប់ អ្នកចូរក្រាបទូលព្រះនាងសុភទ្ទាអ្នកចងសេចក្តីក្រោធថា ស្តេចដំរីស្លាប់ហើយ សូមព្រះនាងទទួលភ្លុកគូនេះទុកចុះ ។

បណ្តាបទទាំងនោះ បទថា **ឥមេ "ទាំងនេះ"** សេចក្តីថា បានឮថា ភ្លុកទាំងឡាយគ្រាបិតា និងជីតារបស់ស្តេចដំរីនោះ បានរក្សាទុកក្នុងទីកំបាំង ដោយបំណងថា កុំបានវិនាស ស្តេចដំរីឆទ្ទន្តសំដៅយកភ្លុកដំរីទាំងនោះ ទើបពោលយ៉ាងនេះ ។ បទថា **ជានាតិ "ដឹង"** សេចក្តីថា ព្រះនាងសុភទ្ទានោះដឹងហើយថា ភ្លុកដំរីចំនួនដ៏ច្រើនរក្សាទុកក្នុងទីនេះ ។ បទថា **វធត្ថិកា "ត្រូវការនឹងសម្លាប់"** ន័យថា តែព្រះនាងសុភទ្ទានោះបំណងនឹងឲ្យអ្នកមកសម្លាប់យើងឲ្យស្លាប់តែម្យ៉ាង បានចងពៀរទុក ព្រោះចងសេចក្តីក្រោធសូម្បីតិចតួចទុកក្នុងចិត្ត គឺ ព្រះនាងនឹងឲ្យយើងដល់នូវទីបំផុត ដោយការធ្វើយ៉ាង

អាក្រក់បែបនេះ ។ បទថា **ខរំ** "រណារ" គឺ រណារអារឈើ ។ បទថា **ហុរាមហាមិ**[១] "មុននឹងស្លាប់" សេចក្តីថា ឥឡូវនេះយើងមិនទាន់ស្លាប់ ។ បទថា **វជ្ជាសិ** "ក្រាបទូល" សេចក្តីថា អ្នកគប្បីក្រាបទូល ។ បទថា **ហន្ទ ឥមស្ស ទន្តា** "សូមព្រះនាងទទួលនូវភ្លុកគូនេះទុកចុះ" សេចក្តីថា អ្នកគប្បីទូលព្រះនាងសុភទ្ទានោះថា ស្តេចដំរីនោះត្រូវអ្នកសម្លាប់ឲ្យស្លាប់ហើយ មនោរថរបស់ព្រះនាងដល់ទីបំផុតហើយ សូមទទួលភ្លុកទាំងនេះរបស់ស្តេចដំរីនោះចុះ ។

ព្រានសោណុត្តរៈបានស្តាប់ពាក្យរបស់ស្តេចដំរីហើយ ក្រោកឡើងអំពីទីអង្គុយកាន់រណារចូលមកជិតស្តេចដំរី គិតថា "យើងនឹងកាត់យកភ្លុកទៅ" ឯស្តេចដំរីនោះកម្ពស់ប្រមាណ ៨០ ហត្ថ ឈរស្រដៀងនឹងភ្នំប្រាក់ ព្រោះហេតុនោះ ព្រានសោណុត្តរទើបឈោងរណារអារមិនដល់ ។ លំដាប់នោះ ព្រះមហាសត្វទើបបន្ទន់កាយដេកទម្លាក់សីសៈចុះឲ្យទាប ។ ខណៈនោះនាយព្រានទើបលើកនូវ

---

១.បិដក. ហុរា មហាមិ ។

ប្រមោយដែលដូចជាកម្រងប្រាក់របស់ព្រះមហាសត្វ ហើយឡើងទៅខាងលើពោងដូចជាឡើងឈរលើភ្នំកៃលាស ហើយយកជង្គង់រុញសាច់ដែលធ្លាក់ត្រង់មាត់រុញចូលទៅខាងក្នុង ចុះអំពីពោងហើយស៊ិករណារចូលទៅក្នុងមាត់ ។ ព្រានយកដៃទាំងពីរចាប់រណារអារចុះឡើងយ៉ាងរហ័ស ។ ទុក្ខវេទនាកើតឡើងដល់ព្រះមហាសត្វយ៉ាងខ្លាំង មាត់ពេញទៅដោយលោហិត កាលព្រានកំពុងអារទៅមកនោះក៏មិនអាចយករណារអារឲ្យដាច់បាន គ្រានោះព្រះមហាសត្វទើបខ្ជាក់លោហិតចេញអំពីមាត់ អត់ទ្រាំនូវទុក្ខវេទនា សួរព្រានថា "សម្លាញ់អ្នកមិនអាចនឹងកាត់ភ្លុកឲ្យដាច់បានទេឬ?" ព្រានសោណុតរតបថា "ប្រើហើយលោក" ព្រះមហាសត្វតាំងសតិ ពោលថា "បើដូច្នោះអ្នកចូរលើកប្រមោយរបស់យើងឡើងឲ្យចាប់រណារខាងលើ យើងមិនមានកម្លាំងនឹងលើកប្រមោយរបស់ខ្លួនបាន" ព្រានក៏បដិបត្តិតាមនោះ ព្រះមហាសត្វយកប្រមោយចាប់រណារ ហើយក៏អារចុះឡើង

ចំណែកក្អកទាំងពីរក៏ជាច់ ប្រៀបដូចជាកាត់នូវដង្កត់ឈើដូច្នោះ គ្រា នោះ ស្តេចដំរីទើបឲ្យព្រាននាំក្អកទាំងនោះមក ហើយពោលថា “នែ សម្លាញ់ យើងឲ្យក្អកទាំងនេះដល់អ្នក មិនមែនថាយើងមិនស្រឡាញ់ នោះទេ ទាំងយើងមិនបានប្រាថ្នាភាពជាសក្កទេវរាជ ជាមារ ជាព្រហ្ម ឡើយ តែព្រោះក្អក គឺ ព្រះសព្វញ្ញុតញ្ញាណនោះ យើងស្រឡាញ់ ជាងក្អកទាំងគូនេះទាំងរយដងពាន់ដង សូមបុណ្យនេះចូរជាបច្ច័យ នៃការបានសម្រេចនូវព្រះសព្វញ្ញុតញ្ញាណចុះ” ដូច្នេះហើយ ទើប ប្រគល់ក្អកទៅ ហើយសួរទៀតថា “សម្លាញ់ ជាងអ្នកមកដល់ទី នេះ អស់វេលាប៉ុន្មាន?” កាលព្រានតបថា “៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ” ទើបពោលថា សូមទៅចុះ ដោយអានុភាពនៃក្អកគូនេះ អ្នកនឹងទៅ ដល់ព្រះនគរពារាណសីក្នុងរយៈ ៧ ថ្ងៃប៉ុណ្ណោះ ដូច្នេះហើយទើប ធ្វើការការពារដល់ព្រាននោះ បញ្ជូនគេដោយតាំងសត្យាធិដ្ឋានថា

យើងជាអ្នកត្រូវសរបាញ់ធ្លុះហើយ សូម្បីនឹងត្រូវវេទនាគ្រប-

សង្កត់ ក៏មិនគិតប្រទូស្តក្នុងបុគ្គល អ្នកស្លៀកដណ្តប់សំពត់
កាសាវៈ ប្រសិនបើសេចក្តីនេះជាការពិត ដែលយើងជាស្តេច
ដំរីតាំងទុក សូមពាលម្រឹគក្នុងព្រៃសណ្ឋៈកុំបានបៀតបៀននូវ
ព្រាននេះឡើយ[១] ។

ក៏គ្រាព្រះមហាសត្វបញ្ជូនព្រាននោះទៅហើយ ក៏បានធ្វើកាលៈ
ដូលចុះក្នុងកាលពួកដំរី និងនាងមហាសុភទ្ទាមកមិនទាន់ដល់ នោះ
ឯង ។

ព្រះសាស្តាកាលនឹងប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថា
មានសេចក្តីថា

[៤៧៥] ឧដ្ឋាយ សោ លុទ្ទោ ខរំ គហេត្វា
ឆេត្វាន ទន្តានិ គជុត្តមស្ស
វគ្គូ សុភេ អប្បដិមេ បឋព្យា

---

១. សេចក្តីនៃគាថានេះ មិនឃើញមានព្រះបាលីទេ ។

អាទាយ បក្កាមិ តតោ ហិ ខិប្បំ ។

ព្រាននោះប្រញាប់ក្រោកឡើងចាប់រណារ អារភ្លុកស្តេចដំរីទាំង
គូដែលល្អស្អាតវិលាស រកអ្វីប្រៀបស្មើមិនបានក្នុងផែនប្រឹថពី
ហើយក៏ប្រញាប់កាន់ចៀសចេញអំពីទីនោះទៅដោយរហ័ស ។

បណ្តាបទទាំងនោះ បទថា វគ្គូ "វិលាស" សេចក្តីថា ស្អាត វិលាស ។ បទថា សុភេ "ដ៏ល្អស្អាត" បានដល់ ដែលល្អស្អាត ។ បទថា អប្បដិមេ "រកអ្វីប្រៀបស្មើមិនបាន" សេចក្តីថា ល្អស្អាត រកភ្លុកដទៃក្នុងផែនដីនេះប្រៀបមិនបាន ។

កាលព្រាននោះគេចចេញទៅហើយ ដំរីទាំងឡាយក៏មកដល់ ទាំងមិនបានឃើញបច្ចាមិត្រ ។

ព្រះសាស្តាកាលនឹងប្រកាសខ្លឹមសារនោះ ទ្រង់ទើបត្រាស់ ព្រះគាថាថា

[៤៧៦] ភយដ្ដិតា នាគវធេន អដ្ដា

*យេ តេ នាគា អដ្ឋ ទិសា វិធាវុំ*

*អទិស្វាន បោសំ គជបច្ចមិត្តំ*

*បច្ចាគមុំ យេន សោ នាគរាជា ។*

*ដំរីទាំងនោះស្លុតចិត្ត បានទទួលនូវសេចក្តីទុក្ខ ព្រោះស្តេចដំរីត្រូវសម្លាប់ ដំរីដែលនាំគ្នារត់មកអំពីទិសទាំង ៨ កាលមិនឃើញបច្ចាមិត្ររបស់ស្តេចដំរី ក៏នាំគ្នាត្រឡប់មកកាន់ទីនៅរបស់ស្តេចដំរី ។*

បណ្តាបទទាំងនោះ បទថា **ភយដ្ដិតា** “**តក់ស្លុត**” សេចក្តីថា ដែលសេចក្តីភ័យខ្លាចដល់មរណៈចូលទៅគំរាមហើយ ។ បទថា **អដ្ដា** “**បានទទួលសេចក្តីទុក្ខ**” បានដល់ ដល់នូវសេចក្តីទុក្ខ ។ បទថា **គជបច្ចាមិត្តំ**[(១)] “**បច្ចាមិត្ររបស់ស្តេចដំរី**” បានដល់ បុគ្គលដែលជាសត្រូវរបស់ស្តេចដំរី ។ បទថា **យេន សោ** “**ទីនៅរបស់ស្តេច**

---

១.បិដក. គជបច្ចមិត្តំ ។

ដំរី” សេចក្តីថា ស្តេចដំរីនោះធ្វើកាលកិរិយាដួលចុះត្រង់ទីលានដ៏ធំដូចជាភ្នំកៃលាស ដំរីទាំងឡាយនាំគ្នាមកកាន់ស្ថានទីនោះ ។

ចំណែកនាងមហាសុភទ្ទាដែលមកជាមួយដំរីទាំងនោះក្តី ដំរីទាំង ៨.០០០ ក្តី បានយំរៀបរាប់នៅត្រង់ទីនោះ ហើយនាំគ្នាទៅកាន់សម្នាក់របស់ព្រះបច្ចេកពុទ្ធជាកុលុបកៈព្រះមហាសត្វ ប្រាប់ថា “បពិត្រលោកម្ចាស់ដ៏ចម្រើន បច្ច័យទាយករបស់លោកម្ចាស់ទាំងឡាយ ត្រូវបាញ់ដោយកូនសរលាបថ្នាំពិស ធ្វើកាលៈហើយ និមន្តលោកម្ចាស់ទាំងឡាយ ទៅមើលសាកសពរបស់បច្ច័យទាយកនោះក្នុងប៉ាឆាចុះ” ។ ព្រះបច្ចេកពុទ្ធទាំង ៥០០ អង្គ ក៏ហោះមកតាមផ្លូវអាកាសចុះត្រង់ទីលានធំ ។ ខណៈនោះ ដំរីជំទង់ ២ ក្បាល ជួយគ្នាយកភ្លុកលើកសរីរៈរបស់ស្តេចដំរី ឲ្យឋិតត្រង់ចំពោះព្រះបច្ចេកពុទ្ធ ហើយលើកឡើងកាន់ជើងថ្ករធ្វើឈាបនកិច្ច ។ ព្រះបច្ចេកពុទ្ធទាំងឡាយធ្វើការស្វាធ្យាយធម៌នៅត្រង់ប៉ាឆាអស់មួយយប់ទល់ភ្លឺ ។

ដំរីទាំង ៨.០០០ គ្រារំលត់ជាតុនិងលាងសម្អាតហើយ ក៏អញ្ជើញនាងមហាសុភទ្ទាឲ្យជាប្រធាន ដង្ហែមកកាន់ទីនៅរបស់ខ្លួន ។

ព្រះសាស្ដាកាលនឹងប្រកាសសេចក្ដីនោះ បានត្រាស់ព្រះគាថានេះថា

[៤៧៧] តេ តត្ថ កន្ទិត្វា រោទិត្វាន នាគា
សីសេ សកេ បំសុកំ ឱកិរិត្វា
អាគមឹសុ តេ សព្វេ សកំ និកេតំ
បុរក្ខត្វា មហេសី សព្វភទ្ទំ ។

ដំរីទាំងនោះនាំគ្នាយំខ្សឹកខ្សួលនៅត្រង់ទីនោះ នាំគ្នារោយធូលីដាក់លើសីសៈខ្លួនរៀងៗ ខ្លួន ហើយលើកនាងសព្វភទ្ទាដែលជាមហេសីឲ្យជាប្រធាន នាំគ្នាត្រឡប់ទៅកាន់ទីនៅរបស់ខ្លួនវិញ ។

បណ្ដាបទទាំងនោះ បទថា បំសុកំ "ធូលី" បានដល់ កំទេច

សរីរន្តាត្រង់ប៉ុផា ។

ចំណែកសោណុត្តរព្រាន យកភ្លុកទាំងគូមកមិនដល់ ៧ ថ្ងៃផង ក៏មកដល់ព្រះនគរពារាណសី ។

ព្រះសាស្តាកាលនឹងប្រកាសសេចក្តីនោះ ទើបត្រាស់នូវព្រះគាថាថា

[៤៧៨] អាទាយ ទន្តានិ គជុត្តមស្ស
វគ្គូ សុភេ អប្បដិមេ បឋព្យា
សុវណ្ណរាជីហិ សមន្តមោទរេ
សោ លុទ្ទកោ កាសិបុរំ ឧបាគមិ
ឧបនេសិ សោ រាជកញ្ញាយ ទន្តេ
នាគោ ហតោ ហន្ទ ឥមស្ស ទន្តា ។

ព្រានដោះនាំភ្លុកទាំងគូរបស់ស្តេចគជសារ ដ៏ឧត្តមពិសាលល្អស្អាត មិនមានភ្លុកដទៃក្នុងផែនប្រឹថពីប្រៀបស្មើបាន បញ្ចេញ

រស្មីដូចពណ៌មាស រុងរឿងទូទៅក្នុងព្រៃសណ្ឌ មកដល់ព្រះនគរកាសីហើយ បង្អោនក្អុកទាំងគូថ្វាយចំពោះព្រះនាងសុភទ្ទា ក្រាបទូលថា ស្តេចដំរីដួលហើយ សូមព្រះនាងទតព្រះនេត្រ ក្អុកទាំងគូនេះចុះ ។

បណ្តាបទទាំងនោះ បទថា **សុវណ្ណរាជីហិ** "បញ្ចេញរស្មីដូចពណ៌មាស" សេចក្តីថា មានរស្មីដូចមាស ។ បទថា **សមន្តមោទរេ** "រុងរឿងទូទៅទាំងព្រៃសណ្ឌ" សេចក្តីថា មានរស្មីជះចេញដូចមាសទៅជុំវិញទូទាំងព្រៃសណ្ឌ ។ បទថា **ឧបនេសិ** "បង្អោនថ្វាយ" សេចក្តីថា ចំណែកសោណុត្តរព្រាន បញ្ជូនដំណឹងទៅទូលព្រះនាងទេវីថា "ខ្ញុំព្រះអង្គនឹងនាំក្អុកទាំងគូដែលរុងរឿងដោយរស្មី ៦ ប្រការ របស់ស្តេចដំរីឆទ្ទន្តចូលមកថ្វាយ សូមព្រះនាងប្រោសឲ្យប្រជាប់តាក់តែងព្រះនគរ" កាលព្រះនាងក្រាបទូលថ្វាយព្រះរាជាទ្រង់ជ្រាប ឲ្យប្រជាប់តាក់តែងព្រះនគរ ដូចទេវនគរហើយ ក៏ចូល

កាន់ព្រះនគរ ឡើងទៅកាន់ប្រាសាទបង្អោនភ្លុកទាំងគូចូលទៅ ។ គ្រាបង្អោនចូលទៅហើយ បានក្រាបទូលថា “បពិត្រព្រះនាងម្ចាស់ បានជ្រាបថា ព្រះនាងម្ចាស់ចងគំនុំដោយហេតុតិចតួច ទុកក្នុងព្រះទ័យចំពោះស្តេចដំរីណា ខ្ញុំព្រះអង្គបានសម្លាប់ស្តេចដំរីនោះហើយ ប្រោសទ្រង់ជ្រាបថា ស្តេចដំរីដួលហើយ សូមព្រះនាងម្ចាស់ទតព្រះនេត្រមើលភ្លុកទាំងគូរបស់ស្តេចដំរីនោះចុះ” ហើយបានថ្វាយភ្លុកនោះទៅ ។ ព្រះនាងសុភទ្ទាទើបយកវីជនីដែលធ្វើដោយកែវមណីទទួលនូវគូនៃភ្លុកដ៏វិចិត្រ មានរស្មី ៦ ប្រការរបស់ព្រះមហាសត្វមកផ្ទប់ត្រង់ព្រះឱរៈ ទតព្រះនេត្រមើលភ្លុករបស់ស្វាមីជាទីស្រឡាញ់របស់ព្រះនាងក្នុងបុរិមកព ទ្រង់រលឹកថា “សោណុតរព្រានសម្លាប់ស្តេចដំរីដែលដល់នូវចំណែកនៃសេចក្តីល្អស្អាតបែបនេះ ឲ្យដល់ការអស់ជីវិត ព្រោះកូនសរលោបថ្នាំពិស កាត់យកភ្លុកទាំងគូមក” ។ កាលទ្រង់អនុស្សរណៈដល់ព្រះមហាសត្វ ទ្រង់ក៏ដល់នូវសេចក្តីសោក

មិនអាចនឹងអត់ទ្រាំបាន ។ រំពេចនោះ ដួងហឫទ័យរបស់ព្រះនាង ក៏បែក ហើយបានសុគតក្នុងថ្ងៃនោះឯង ។

ព្រះសាស្តាកាលនឹងទ្រង់ប្រកាសសេចក្តីនោះ ទើបត្រាស់ព្រះគាថាថា

[៤៧៩] ទិស្វាន ទន្តានិ គជុត្តមស្ស

កត្តុ បិយស្ស បុរិមាយ ជាតិយា

តត្ថេវ តស្សា ហទយំ អផាសិ

តេនេវ សា កាលមកាសិ ពាលា ។

ព្រះនាងសុភទ្ទាជាពាល គ្រាទតព្រះនេត្រឃើញភ្លុកទាំងពីររបស់ស្តេចគជសារដ៏ឧត្តម ដែលជាបិយកស្តារបស់ខ្លួនក្នុងជាតិមុនហើយ ហឫទ័យរបស់ព្រះនាងក៏បែកត្រង់ទីនោះឯង ព្រះនាងទើបសុគតព្រោះហេតុនោះឯង ។

លំដាប់នោះ កាលព្រះធម្មសង្គាហកត្ថេរៈទាំងឡាយសរសើរ

ព្រះគុណរបស់ព្រះទសពល ទើបពោលពាក្យជាគាថាយ៉ាងនេះថា

[៤៨០] សម្ពោធិបត្តោ ច មហានុភាវោ

សិតំ អកាសី បរិសាយ មជ្ឈេ

បុច្ឆីសុ ភិក្ខូ សុវិមុត្តចិត្តា

នាការណេ បាតុករោន្តិ ពុទ្ធា ។

យមទ្ទសាថ ទហរឹ កុមារឹ

កាសាវវត្ថំ អនគារិយំ ចរន្តឹ

សា ខោ តទា រាជកញ្ញា អហោសិ

អហំ តទា នាគរាជា អហោសឹ ។

អាទាយ ទន្តានិ គជុត្តមស្ស

វគ្គូ សុភេ អប្បដិមេ បឋព្យា

យោ លុទ្ទកោ កាសិបុរំ ឧបាគមិ

សោ ខោ តទា ទេវទត្តោ អហោសិ ។

អនាវសូរំ ចិររត្តសំសិតំ
ឧច្ចាវចំ ចរិតមិទំ បុរាណំ
វីតទ្ទរោ វីតសោកោ វិសល្លោ[1]
សយំ អភិញ្ញាយ អភាសិ ពុទ្ធោ ។

អហំ វោ តេន កាលេន អហោសឹ តត្ថ ភិក្ខវោ
នាគរាជា តទាហោសឹ ឯវំ ធារេថ ជាតកន្តិ ។

ព្រះសាស្តាបានសម្រេចសម្ពោធិញ្ញាណហើយ មានព្រះអានុភាពច្រើន ទ្រង់គ្រងជាក់ក្នុងកណ្តាលបរិស័ទ ភិក្ខុទាំងឡាយអ្នកមានចិត្តរួចផុតល្អហើយ នាំគ្នាក្រាបទូលសួរថា ព្រះពុទ្ធទាំងឡាយ ទ្រង់មិនបានធ្វើការញញឹមឲ្យប្រាកដ ដោយមិនមានហេតុផលឡើយ ។

ព្រះមានព្រះភាគត្រាស់ថា អ្នកទាំងឡាយចូរមើលកុមារី

---
១.ម. វីតសល្លោ ។

ក្រមុំស្លៀកដណ្ដប់សំពត់កាសាវៈនោះ ប្រព្រឹត្តអនាគារិយវត្ត នាងកុមារីម្នាក់នោះឯងជានាងសុភទ្ទាក្នុងកាលនោះ ឯតថាគត ជាស្ដេចដំរីក្នុងកាលនោះ ។

នាយព្រានកាន់យកភ្លុកទាំងគូរបស់ស្ដេចគជសារដ៏ឧត្តម រកភ្លុកដទៃប្រៀបស្មើមិនបានក្នុងប្រឹថពី ត្រឡប់មកកាន់ព្រះនគរកាសីក្នុងកាលនោះ ជាទេវទត្ត ។

ព្រះពុទ្ធអង្គទ្រង់ប្រាសចាកសេចក្ដីក្រវល់ក្រវាយ សេចក្ដីសោក និងកិលេសដូចកូនសរ ត្រាស់ដឹងដ៏ក្រៃលែងដោយព្រះអង្គឯងហើយ បានត្រាស់ឆទ្ទន្តជាតកនេះដែលជារបស់ចាស់មិនប្រាកដច្បាស់ដែលព្រះអង្គត្រាច់រង្គាត់អស់កាលដ៏យូរ ជាបុព្វចរិយាទាំងខ្ពស់ និងទាបថា ម្នាលភិក្ខុទាំងឡាយ គ្រានោះតថាគតជាស្ដេចដំរីឆទ្ទន្តអាស្រ័យនៅត្រង់ស្រះឆទ្ទន្តនោះ អ្នកទាំងឡាយចូរចងចាំជាតកនេះទុក ដោយប្រកាដូច្នេះ ។

គាថាទាំងនេះ ព្រះធម្មសង្គាហកត្ថេរៈទាំងឡាយសរសើរនូវព្រះគុណរបស់ព្រះទសពល រចនាឲ្យប្រាកដទុក ។ បណ្ដាបទទាំងនោះ បទថា **សិតំ អកាសិ**[1] **"បានទ្រង់ញញឹម"** ន័យថា អាវុសោទាំងឡាយ ព្រះសាស្ដាទ្រង់សម្រេចព្រះសម្ពោធិញ្ញាណហើយ មានព្រះអានុភាពច្រើន ថ្ងៃមួយប្រថាប់គង់លើធម្មាសនៈដែលប្រដាប់ល្អហើយ កណ្ដាលបរិស័ទ ក្នុងធម្មសភាដែលតាក់តែងហើយ ទ្រង់បានធ្វើការញញឹម ។ បទថា **នាការណេ "ឥតហេតុផលទេ"** សេចក្ដីថា ភិក្ខុទាំងឡាយជាមហាខីណាស្រពក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មិនធ្វើការញញឹមដោយឥតហេតុផលឡើយ ក៏ការញញឹមរបស់ព្រះអង្គទ្រង់ធ្វើហើយ អ្វីហ្ន៎ជាហេតុឲ្យព្រះអង្គទ្រង់ធ្វើការញញឹម" ។

បទថា **យមទ្ទសាថ "ចូរមើល... ណា"** សេចក្ដីថា អាវុសោ

---

១.បិដក. សេតំ អកាសី ។

ទាំងឡាយ ព្រះសាស្តាត្រូវទូលសួរយ៉ាងនេះហើយ កាលនឹងត្រាស់ប្រាប់នូវហេតុដែលព្រះអង្គទ្រង់ធ្វើការញញឹម ទ្រង់ចង្អុលភិក្ខុនីក្រមុំមួយរូបត្រាស់យ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកជួប ឬក៏ឃើញនាងកុមារិកានេះ ដែលកំពុងពេញវ័យ គ្រងសំពត់កាសាវៈចូលដល់ គឺ ប្រព្រឹត្តអនាគារិយវត្តក្នុងព្រះសាសនានេះ នាងកុមារិកានោះ គឺ ព្រះនាងសុភទ្ទារាជកញ្ញាក្នុងគ្រានោះ ដែលប្រើព្រានសោ-ណុត្តរថា អ្នកចូរយកនូវកូនសរលាបដោយថ្នាំពិសទៅបាញ់សម្លាប់ស្តេចដំរីចុះ គ្រានោះ តថាគតជាស្តេចដំរីដែលព្រានសោណុត្តរទៅបាញ់ឲ្យដល់នូវការអស់ជីវិត ។

បទថា ***ទេវទត្តោ*** ***"ជាទេវទត្ត"*** សេចក្តីថា ម្នាលភិក្ខុទាំងឡាយសោណុត្តរព្រានក្នុងគ្រានោះ បានមកជាទេវទត្តក្នុងកាលនេះ ។ បទថា ***អនាវសូរំ*** កាត់បទជា ***ន អវសូរំ*** ប្រែថា គ្រាព្រះអាទិត្យមិនទាន់អស្តង្គត ។ បទថា ***ចិររត្តសំសិតំ*** ***"ត្រាច់ទៅអស់កាលយូរ"***

សេចក្តីថា រាប់តាំងអំពីកាលដ៏វែងឆ្ងាយនេះ ទ្រង់ត្រាច់ទៅហើយ គឺ ទ្រង់ស្ទុះទៅហើយ បានដល់ ទ្រង់ប្រព្រឹត្តមកហើយដោយលំដាប់ ក្នុងទីបំផុតនៃកោដិកប្បមិនមែនតិច ។ លោកពោលអធិប្បាយទុកថា "អាវុសោទាំងឡាយ ព្រះពុទ្ធ ឈ្មោះថា ទ្រង់ប្រាសចាកសេចក្តីក្រវល់ក្រវាយ ព្រោះទ្រង់ប្រាសចាកកិលេសមានរាគៈជាដើម ឈ្មោះថា ទ្រង់ប្រាសចាកសេចក្តីសោក ព្រោះមិនមានសេចក្តីសោក ដែលកើតអំពីញាតិ និងទ្រព្យជាដើម ឈ្មោះថា ប្រាសចាកកូនសរ ព្រោះប្រាសចាកកូនសរ មានកូនសរ គឺ រាគៈជាដើម ទ្រង់ដឹងច្បាស់ដោយព្រះអង្គឯងហើយ បានត្រាស់រឿងនេះដែលជារបស់ចាស់ រាប់តាំងអំពីកាលដ៏យូរនេះ សូម្បីទ្រង់ត្រាច់វង្គាត់ទៅក្នុងទីបំផុតនៃកោដិកប្បមិនមែនតិច ដែលឈ្មោះថា ជាព្រះចរិយាទាំងខ្ពស់ទាំងទាប ព្រោះទ្រង់ខ្ពស់ដោយអំណាចនៃបុញ្ញចរិយារបស់ព្រះអង្គ និងព្រោះទាបដោយអំណាចនៃចរិយារបស់ព្រះនាងសុភទ្ទារាជធីតា និងព្រានសោណុត្តរៈ ដូចទ្រង់រលឹកបានដល់វត្ថុដែលធ្វើដោយសេចក្តីវង្វេង

ព្រោះប្រាសចាកសេចក្តីវង្វេង វត្ថុដែលធ្វើក្នុងវេលាព្រឹកបាន ក្នុងវេលាល្ងាចនៃថ្ងៃនោះឯង” ។

បទថា **វោ** ក្នុងពាក្យថា **អហំ វោ** នេះ ត្រឹមតែជានិបាត ។ សេចក្តីថា ម្នាលភិក្ខុទាំងឡាយ កាលនោះ តថាគតបានជាស្តេចដំរីអាស្រ័យនៅត្រង់ស្រះឆទ្ទន្តនោះ ។ បទថា **នាគរាជា “ស្តេចដំរី”** សេចក្តីថា ក្នុងគ្រានោះនឹងថាជាបុគ្គលដទៃណាក៏មិនមែន ការពិត ក៏គឺ **តថាគត** នេះឯងជាស្តេចដំរីឆទ្ទន្ត ។ បទថា **ឯវំ ធារេថ “ចូរចងចាំ... ដោយប្រការដូច្នេះ”** សេចក្តីថា អ្នកទាំងឡាយចូរចាំទុក គឺ ចងចាំ បានដល់ រៀនជាតកនេះទុកដោយប្រការដូច្នេះ ។

មនុស្សដ៏ច្រើនស្តាប់ព្រះធម្មទេសនានេះហើយ ក៏បានសម្រេចជាព្រះសោតាបន្នជាដើម (ចំណែក) នាងភិក្ខុនីនោះ ចម្រើនវិបស្សនាហើយ ក្រោយមកក៏លុះព្រះអរហត្តផលដូច្នេះឯង ។

ចប់អដ្ឋកថា ឆទ្ទន្តជាតកទី ៤

# អដ្ឋកថា សម្ពុទ្ធជាតកទី ៥

## (រឿងអ្នករុងរឿងចានព្រោះបញ្ញា)

*ព្រះសាស្តាកាលស្តេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បាន ប្រារព្ធព្រះបញ្ញាបារមី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា* ***វដ្ឌញ្ច បដិបជ្ជន្នស្មា “យើងទាំងឡាយបានរាជ្យសម្បត្តិ”*** *។*

*រឿងបច្ចុប្បន្នក៏មានច្បាស់ក្នុងឧម្មង្គជាតកហើយ ចំណែករឿង ក្នុងអតីតមានសេចក្តីថា ព្រះរាជាទ្រង់ព្រះនាមថា* ***ធនញ្ជយកោរព្យៈ*** *សោយរាជ្យសម្បត្តិក្នុងឥន្ទបត្តនគរ ដែនកុរុ ។ ព្រាហ្មណ៍បុរោហិត នាមថា* ***សុចីរតៈ*** *បានជាអ្នកប្រាប់នូវអត្ថ និងធម៌របស់ព្រះអង្គ ។ ព្រះរាជាទ្រង់បំពេញបុណ្យកុសលមានទានជាដើម ទ្រង់គ្រងរាជ្យ-សម្បត្តិដោយទសពិធរាជធម៌ ។ ក្នុងថ្ងៃមួយ ទ្រង់លើកនូវបញ្ហា ឈ្មោះ* ***ធម្មយាគៈ*** *ទើបអញ្ជើញសុចីរតព្រាហ្មណ៍ឲ្យអង្គុយនៅលើ អាសនៈ ទ្រង់ធ្វើសក្ការៈហើយ កាលនឹងត្រាស់សួរបញ្ហា បានត្រាស់*

៤ គាថាថា

[៤៨១] រជ្ជញ្ច បដិបន្នស្មា អាធិបច្ចំ សុចីរត
មហន្តំ[១] បត្តុមិច្ឆាមិ វិជេតុំ បឋវី ឥមំ ។

លោកអាចារ្យសុចីរតៈ យើងទាំងឡាយបានរាជ្យសម្បត្តិ និងភាពជាធំហើយ នៅប្រាថ្នាចង់បានភាពជាធំក្រៃលែងឡើង ដើម្បីអភិសេកគ្រប់គ្រងផែនប្រឹថពីនេះ ។

ធម្មេន នោ អធម្មេន អធម្មោ មេ ន រុច្ចតិ
កិច្ចោវ ធម្មោ ចរិតោ រញ្ញោ ហោតិ សុចីរត ។

ដោយធម៌ មិនមែនដោយអធម៌ យើងមិនពេញចិត្តក្នុងអធម៌ទេ លោកអាចារ្យសុចីរតៈ ការប្រព្រឹត្តធម៌ជាកិច្ចរបស់ព្រះរាជាដោយពិត ។

ឥធ ចេវានិន្ទិតា យេន បេច្ច យេន អនិន្ទិតា
យសំ ទេវមនុស្សេសុ យេន បប្បោមុ ព្រាហ្មណ ។

---

១.បាលីឆដ្ឋ. មហត្តំ ។

ម្នាលព្រាហ្មណ៍ យើងទាំងឡាយនឹងមិនត្រូវនិន្ទាទាំងក្នុងលោកនេះ និងលោកខាងមុខដោយហេតុណា និងនឹងបានទទួលកិត្តិយសក្នុងទេវតា និងមនុស្សព្រោះហេតុណា (សូមលោកចូរប្រាប់ហេតុនោះៗ ដល់យើង) ។

យោហំ អត្ថញ្ច ធម្មញ្ច    កត្តុមិច្ឆាមិ ព្រាហ្មណ
តំ ត្វំ អត្ថញ្ច ធម្មញ្ច    ព្រាហ្មណក្ខាហិ បុច្ឆិតោ ។

ម្នាលព្រាហ្មណ៍ យើងប្រាថ្នានឹងធ្វើតាមអត្ថ និងធម៌ យើងសួរលោកហើយ សូមចូរប្រាប់អត្ថ និងធម៌នោះផងចុះ ។

បណ្ដាបទទាំងនោះ បទថា រជ្ជំ "រាជ្យសម្បត្តិ" សេចក្ដីថា លោកអាចារ្យយើងទាំងឡាយ បានរាជ្យសម្បត្តិក្នុងឥន្ទបត្តនគរដែលមានបរិមណ្ឌលដល់ ៧ យោជន៍នេះ និងទទួលភាពជាធំ ពោលគឺឥស្សរភាពក្នុងកុរុរដ្ឋ ដែលមានបរិមណ្ឌលដល់ ៣០០ យោជន៍ ។

បទថា បដិប្បន្នា "បាន" បានដល់ ប្រសព្វហើយ ។ បទថា

**មហន្តំ** *"ភាពជាធំ"* សេចក្ដីថា គ្រានេះយើងក៏នៅប្រាថ្នាភាពជាធំក្រៃលែងឡើង ។ បទថា **វិជេតុំ** *"គ្រប់គ្រង"* សេចក្ដីថា យើងនៅប្រាថ្នាភាពជាធំដើម្បីអភិសេកគ្រប់គ្រងផែនដីនេះដោយធម៌ ។ បទថា **កិច្ចាវ** *"ជាកិច្ចរបស់ព្រះរាជាដោយពិត"* ន័យថា ការប្រព្រឹត្តធម៌ជាកិច្ច គឺ ជាព្រះរាជករណីយដែលសំខាន់ជាងជនដ៏សេស ។ អធិប្បាយថា លោកបណ្ដោយតាមព្រះរាជា កាលព្រះរាជាប្រព្រឹត្តធម៌ មនុស្សលោកទាំងអស់ក៏ជាអ្នកប្រព្រឹត្តធម៌ ព្រោះដូច្នោះ ដែលឈ្មោះថា ធម៌នេះជាកិច្ចរបស់ព្រះរាជាតែម្យ៉ាង ។

បទថា **ឥធ ចេវានន្ទិតា** *"នឹងមិនត្រូវនិន្ទាទាំងក្នុងលោកនេះនិងលោកខាងមុខ"* សេចក្ដីថា យើងទាំងឡាយនឹងមិនត្រូវនិន្ទាក្នុងលោកនេះ និងលោកខាងមុខព្រោះហេតុណា ។ បទថា **យេន បប្បោមុ** *"នឹងបានទទួល... ព្រោះហេតុណា"* សេចក្ដីថា យើងទាំងឡាយនឹងមិនកើតក្នុងនរកជាដើម គប្បីដល់នូវយស គឺ ភាពជាធំ បានដល់

កាលជាអ្នកដ៏ប្រសើរដោយសេចក្ដីស្អាតក្នុងទេវលោក និងមនុស្ស-លោកព្រោះហេតុណា លោកចូរប្រាប់ហេតុនោះដល់យើង ។

បទថា **យោហំ** “**យើង**” សេចក្ដីថា ព្រាហ្មណ៍ យើងប្រាថ្នានឹងធ្វើផង សមាទានហើយប្រព្រឹត្តផង នូវអត្ថ គឺ ផលវិបាក និងធម៌ គឺ ហេតុនៃផលនោះ និងញុំាងនូវអត្ថនៃធម៌នោះឲ្យកើតឡើងផង ។ បទថា **តំ ត្វំ** “**លោក... នោះ**” សេចក្ដីថា ព្រះរាជាទ្រង់ត្រាស់សួរធម្មយាគបញ្ហានឹងព្រាហ្មណ៍បុរោហិតថា “កាលយើងប្រាថ្នានឹងឡើងកាន់ផ្លូវដែលញុំាងសត្វឲ្យដល់ព្រះនិព្វាន ដោយសួស្ដីហើយជាអ្នករកបដិសន្ធិមិនបាន កាលលោកត្រូវសួរដល់អត្ថ និងធម៌នោះចូរប្រាប់ គឺ ពោលឲ្យប្រាកដចុះ” ។

ក៏បញ្ហាជ្រាលជ្រៅជាពុទ្ធវិស័យ គួរនឹងទូលសួរចំពោះព្រះសព្វញ្ញុពុទ្ធប៉ុណ្ណោះ កាលព្រះសព្វញ្ញុពុទ្ធមិនមាន គួរសួរចំពោះព្រះពោធិសត្វអ្នកស្វែងរកព្រះសព្វញ្ញុតញ្ញាណ ព្រោះសុចីរតបុរោហិត

មិនមែនជាព្រះពោធិសត្វ ទើបមិនអាចដោះស្រាយបញ្ហាថ្វាយបាន និងកាលមិនអាច ក៏មិនធ្វើការប្រកាន់ខ្លួនថាជាបណ្ឌិត កាលនឹងក្រាបទូលសេចក្តីដែលខ្លួនមិនអាច ទើបពោលគាថាថា

[៤៨២] នាញ្ញត្រ វិធុរា រាជា តទក្ខាតុមរហតិ(១)
យំ ត្វំ អត្ថញ្ច ធម្មញ្ច កត្តុមិច្ឆសិ ខត្តិយ ។

សូមតេជះព្រះខត្តិយរាជ ព្រះអង្គទ្រង់ប្រាថ្នានឹងបដិបត្តិតាមអត្ថ និងធម៌ណា ក្រៅអំពីវិធុរព្រាហ្មណ៍ហើយ មិនមាននរណាដទៃ ដែលនឹងសមគួរបង្ហាញអត្ថ និងធម៌នោះបានឡើយ ។

គាថានោះមានអធិប្បាយដូច្នេះ បពិត្រមហារាជ បញ្ហានេះ មិនជាវិស័យរបស់បុគ្គលដូចជាខ្ញុំព្រះអង្គឡើយ ខ្ញុំព្រះអង្គមិនឃើញខាងដើមខាងចុងនៃបញ្ហានោះឡើយ ប្រៀបដូចចូលទៅកាន់ទីងងឹត តែរាជបុរោហិតរបស់ព្រះបាទពារាណសី ឈ្មោះថា វិធុរព្រាហ្មណ៍ គេគប្បីឆ្លើយបញ្ហានោះបាន វៀរគេចេញហើយនរណាដទៃ មិនអាច

១.បាលីឆដ្ឋ. ឯតទក្ខាតុមហរតិ ។

នឹងសម្តែងអត្ថ និងធម៌ដែលព្រះអង្គទ្រង់ប្រាថ្នានឹងធ្វើបានទេ ។

ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់សុចីរតព្រាហ្មណ៍ហើយ ត្រាស់ថា "ម្នាលព្រាហ្មណ៍ បើដូច្នោះ លោកចូរទៅកាន់សម្នាក់របស់វិធូរ-ព្រាហ្មណ៍ចុះ" មានព្រះបំណាងនឹងគ្រឿងបណ្ណាការទៅព្រះរាជទាន ទើបត្រាស់ព្រះគាថាថា

[៤៨៣] ឯហិ ខោ បហិតោ គច្ឆ វិធូរស្ស ឧបន្តិកំ

និក្ខញ្ចិមំ សុវណ្ណស្ស ហរំ គច្ឆ សុចីរត

អភិហារំ ឥមំ ទជ្ជ អត្ថធម្មានុសិដ្ឋិយា ។

លោកអាចារ្យសុចីរតៈ មកចុះ យើងនឹងបញ្ជូនលោកទៅកាន់

សម្នាក់របស់វិធូរព្រាហ្មណ៍ លោកចូរនាំយកដុំមាសនេះទៅ

ប្រគល់ឲ្យ ដើម្បីទទួលពាក្យអធិប្បាយនូវអត្ថ និងធម៌ ។

បណ្តាបទទាំងនោះ បទថា ឧបន្តិកំ "កាន់សម្នាក់" បានដល់ទៅកាន់សម្នាក់ ។ បទថា និក្ខំ "ដុំ" សេចក្តីថា មាសទម្ងន់ ៥ តម្លឹង

ជាមួយនិក្ខៈ តែព្រះរាជាធនញ្ជ័យកោរព្យៈអង្គនេះ ព្រះរាជទានមាស ១.០០០ ដុំ ទើបទ្រង់ត្រាស់យ៉ាងនេះ ៗ បទថា **ឥមំ ទជ្ជា** “នេះទៅប្រគល់ឲ្យ” សេចក្តីថា កាលវិធុរព្រាហ្មណ៍នោះពោលធម្មយាគ-បញ្ហានេះហើយ លោកគប្បីនាំទៅធ្វើការបូជាប្រគល់មាស ១.០០០ ដុំនេះដល់វិធុរព្រាហ្មណ៍នោះ ដើម្បីសូមទទួលពាក្យអធិប្បាយអត្ថនិងធម៌ ៗ

ព្រះបាទធនញ្ជ័យកោរព្យៈ គ្រាត្រាស់បញ្ជូនយ៉ាងនេះហើយ ទើបត្រាស់ឲ្យយកដុំនៃមាសមានតម្លៃ ១០០.០០០ កហាបណៈមកធ្វើជាផែន ដើម្បីបានចារឹកពាក្យវិសជ្ជនាបញ្ហា ឲ្យចាត់ចែងយានពាហនៈសម្រាប់ដើរផ្លូវ ចាត់ចែងពលនិកាយសម្រាប់ជាបរិវារ ចាត់ចែងគ្រឿងរាជបណ្ណាការស្រេចហើយ ក៏ទ្រង់បញ្ជូនទៅក្នុងខណៈនោះឯង ៗ ចំណែកសុចិរតព្រាហ្មណ៍ចេញចាកព្រះនគរឥន្ទបត្តហើយមិនបានធ្វើដំណើរត្រង់ទៅកាន់ព្រះនគរពារាណសីឡើយ ពួកបណ្ឌិត

នៅក្នុងទីណាៗ ក៏ចូលទៅកាន់ទីនោះៗ សព្វទូទៅ មិនបានទទួលផលពោល គឺ ការពោលដោះស្រាយនូវបញ្ហាក្នុងជម្ពូទ្វីបទាំងមូលរហូតដល់នគរពារាណសីដោយលំដាប់ កាន់យកទីស្នាក់ត្រង់កន្លែងមួយ ទៅកាន់និវេសន៍របស់វិធុរព្រាហ្មណ៍ព្រមជាមួយអ្នកបម្រើ ២-៣ នាក់ក្នុងវេលាអាហារព្រឹក តំណាលប្រាប់នូវធុរៈដែលខ្លួនមកឲ្យបានជ្រាប កាលវិធុរព្រាហ្មណ៍នោះអញ្ជើញឲ្យចូលទៅ បានឃើញវិធុរព្រាហ្មណ៍កំពុងទទួលទានអាហារនៅក្នុងផ្ទះរបស់ខ្លួន ។

កាលព្រះសាស្តាទ្រង់នឹងប្រកាស ធ្វើនូវសេចក្តីនោះឲ្យជាក់ច្បាស់ឡើង ទើបត្រាស់ព្រះគាថាទី ៧ ថា

[៤៨៤] ស្វាធិប្បាគា ភារទ្វាជោ វិធុរស្ស ឧបន្តិកំ

តមទ្ទស មហាព្រហ្មា អសមានំ សកេ ឃរេ ។

មហាព្រាហ្មណ៍ជាទ្វារភាជៈគោត្រនោះ បានទៅដល់សម្នាក់របស់វិធុរព្រាហ្មណ៍ហើយ ឃើញព្រាហ្មណ៍កំពុងបរិភោគនូវ

អាហារក្នុងផ្ទះរបស់ខ្លួន ។

បណ្ដាបទទាំងនោះ បទថា **ស្វាធិប្បាគា** "នោះ បានទៅដល់" សេចក្ដីថា សុចីរតព្រាហ្មណ៍ការទ្វាជគោត្រនោះបំណាងទៅ គឺ សម្រេច ដល់ហើយ ។ បទថា **មហាព្រហ្មា** "មហាព្រាហ្មណ៍" គឺ ព្រាហ្មណ៍ ដែលជាធំ ។ បទថា **អសមានំ** "កំពុងបរិភោគ" បានដល់ កំពុង បរិភោគ ។

សុចីរតព្រាហ្មណ៍នោះ កាលនៅក្មេងជាសម្លាញ់ជាមួយវិធុរ-ព្រាហ្មណ៍ រៀនសិល្បវិជ្ជាក្នុងសម្នាក់អាចារ្យជាមួយគ្នា ព្រោះដូច្នោះ ទើបរួមទទួលទានអាហារជាមួយវិធុរព្រាហ្មណ៍នោះឯង ក្នុងវេលា ទទួលទានស្រេចហើយ អង្គុយជាសប្បាយទើបសាកសួរថា "សម្លាញ់ លោកមកធុរៈអ្វី?" កាលនឹងប្រាប់ហេតុដែលមក ទើបពោលគាថាទី ៨ ថា

[៤៨៥] រញ្ញោហំ បហិតោ ទូតោ កោរព្យស្ស យសស្សិនោ

អត្ថំ ធម្មញ្ច បុច្ឆសិ ឥច្ចព្រវិ យុធិដ្ឋិលោ
តំ ត្វំ អត្ថញ្ច ធម្មញ្ច វិធុរក្ខាហិ បុច្ឆិតោ ។

ព្រះបាទកោរព្យរាជរុងរឿងដោយព្រះយស ទ្រង់បញ្ជូនយើង
មកជាទូត ព្រះអង្គទ្រង់ជាយុធិដ្ឋិលគោត្រត្រាស់សួរដល់អត្ថ
និងធម៌ បានត្រាស់ហើយយ៉ាងនេះថា វិធុរៈសម្លាញ់ លោក
ត្រូវសួរដល់អត្ថ និងធម៌នោះហើយ ករុណាប្រាប់យើងផង ។

បណ្ដាបទទាំងនោះ បទថា រញ្ញោហំ "ព្រះបាទកោរព្យៈ... យើង" សេចក្ដីថា យើងជាទូតរបស់ព្រះបាទកោរព្យៈទ្រង់ក្រៃលែងដោយយស ។ បទថា បហិតោ "ទ្រង់បញ្ជូនមក" សេចក្ដីថា យើងត្រូវព្រះអង្គបញ្ជូនឲ្យជាទូត ទើបមកទីនេះ ។ បទថា បុច្ឆសិ "ទ្រង់ត្រាស់សួរ" សេចក្ដីថា ព្រះបាទធនញ្ជ័យរាជជាយុធិដ្ឋិលគោត្រនោះត្រាស់សួរបញ្ហាឈ្មោះធម្មយាគៈ យើងមិនអាចនឹងដោះស្រាយបាន យើងដឹងថា លោកនឹងអាច ទើបក្រាបទូលព្រះអង្គអំពីលោកបាន

ទ្រង់ជ្រាប ព្រះអង្គទ្រង់ព្រះរាជទានគ្រឿងបណ្ណាការ នឹងទ្រង់បញ្ជូន យើងមកកាន់សម្នាក់របស់លោកដើម្បីសួរបញ្ហា បានត្រាស់ថា "អ្នកចូរទៅកាន់សម្នាក់របស់វិធុរព្រាហ្មណ៍ សួរដល់លំនាំអត្ថ និងធម៌នៃបញ្ហានេះ" ឥឡូវនេះខ្ញុំសួរលោកហើយ លោកចូរប្រាប់នូវអត្ថ និងធម៌នោះចុះ ។

ក៏ក្នុងគ្រានោះ វិធុរព្រាហ្មណ៍គិតថា យើងនឹងកំណត់ចិត្តរបស់មហាជនដែលជ្រួលច្របល់ជាមួយការវិនិច្ឆ័យសេចក្តី ប្រៀបដូចជាបិទនូវទន្លេគង្គា មិនមានឱកាសនឹងដោះស្រាយបញ្ហានោះបាន កាលនឹងប្រាប់សេចក្តីនោះ ទើបពោលគាថាទី ៩ ថា

[៤៨៦] គង្គំ មេ បិទហិស្សន្តិ ន តំ សក្កោមិ ព្រាហ្មណ

អបិធេតុំ មហាសិន្ធុំ តំ កថំ សោ ភវិស្សតិ

ន តេ សក្កោមិ អក្ខាតុំ អត្ថំ ធម្មញ្ច បុច្ឆិតោ ។

ម្នាលព្រាហ្មណ៍ យើងគិតថានឹងបិទទន្លេគង្គា តែមិនអាចនឹង

បិទទន្លេដ៏ធំនោះបាន ព្រោះហេតុនោះ ឱកាសនោះ នឹងមាន

យ៉ាងណា កាលលោកសួរដល់អត្ថ និងធម៌ យើងទើបមិនអាច

ប្រាប់បាន ។

គាថានោះមានអត្ថាធិប្បាយដូច្នេះ ព្រាហ្មណ៍សម្លាញ់ យើង

កើតសេចក្តីកង្វល់ថា “នឹងបិទទន្លេគង្គា គឺ គតិចិត្តផ្សេងៗ របស់

មហាជន ក៏មិនអាចបិទបាន ព្រោះដូច្នោះ ទើបមិនមានឱកាស កាល

ឱកាសមិនមាន យើងក៏វិសជ្ជនាប្រាប់ដល់លោកមិនបាន កាលមិន

បាននូវសេចក្តីដោយចិត្តស្មោះត្រង់ និងមិនមានឱកាស សូម្បីនឹង

ត្រូវលោកសួរ ក៏មិនអាចប្រាប់អត្ថ និងធម៌ដល់លោកបាន” ។

គ្រាវិធុរព្រាហ្មណ៍ពោលយ៉ាងនេះហើយ ទើបប្រាប់ថា “បុត្ត

របស់យើងជាមនុស្សឆ្លាត មានប្រាជ្ញាវាងវៃជាងយើង គេនឹងព្យា-

ករណ៍ដល់លោកបាន លោកចូរទៅកាន់សម្នាក់របស់បុត្តយើងចុះ”

ដូច្នេះហើយ ទើបពោលគាថាទី ១០ ថា

ភទ្រការោ ច មេ បុត្តោ ឱរសោ មម អត្រជោ
តំ ត្វំ អត្ថញ្ច ធម្មញ្ច គន្ត្វា បុច្ឆស្សុ ព្រាហ្មណ ។

បពិត្រភទ្រការៈ អ្នកជាបុត្តកើតអំពីទ្រូងរបស់យើងមាន សូមលោកទៅសួរអត្ថ និងធម៌នឹងគេមើលចុះ ព្រាហ្មណ៍ ។

បណ្តាបទទាំងនោះ បទថា ឱរសោ "បុត្តកើតអំពីទ្រូង" បានដល់ អ្នកចម្រើនហើយអំពីទ្រូង ។ បទថា អត្រជោ "បុត្ត" បានដល់ បុត្តកើតព្រោះខ្លួន ។

សុចីរតព្រាហ្មណ៍ស្តាប់ដូច្នោះ ទើបចេញចាកផ្ទះរបស់វិធុរព្រាហ្មណ៍ ទៅកាន់និវេសន៍របស់ភទ្រការមាណព ក្នុងវេលាដែលគេទទួលទានអាហារស្រេចហើយ អង្គុយត្រង់កណ្តាលបរិស័ទរបស់ខ្លួន ។

ព្រះសាស្តា កាលនឹងទ្រង់ប្រកាសនូវសេចក្តីនោះ ទើបត្រាស់

ព្រះគាថាទី ១១ ថា

[៤៨៧] ស្វាធិប្បាគា ភារទ្វាជោ   ភគ្គការស្ស   សន្តិកំ

តមទ្ទស   មហាព្រហ្មា   និសិន្នំ សម្ហិ វេស្មនិ ។

មហាព្រាហ្មណ៍ជាភារទ្វាជគោត្រនោះ  ក៏បានទៅដល់សម្នាក់

របស់ភគ្គការមាណព   បានឃើញគេកំពុងអង្គុយនៅក្នុងផ្ទះ

របស់ខ្លួន ។

បណ្តាបទទាំងនោះ បទថា វេស្មនិ "ក្នុងផ្ទះ" បានដល់ ក្នុងផ្ទះ ។

សុចីរតព្រាហ្មណ៍ទៅកាន់ទីនោះហើយ  ភគ្គការមាណពបានចាត់ចែងការទទួល និងធ្វើសក្ការៈគោរព អង្គុយហើយត្រូវសួរដល់ការដែលមក ទើបពោលគាថាទី ១២ ថា

[៤៨៨] រញ្ញោហំ បហិតោ ទូតោ   កោរព្យស្ស យសស្សិនោ

អត្ថំ ធម្មញ្ច បុច្ឆេសិ   ឥច្ចព្រវិ   យុធិដ្ឋិលោ

តំ ត្វំ អត្ថញ្ច ធម្មញ្ច    ភទ្រការ បព្រូហិ មេ ។

យើងជារាជទូតរបស់ព្រះបាទកោរព្យរាជ អ្នកទ្រទ្រង់នូវយស បញ្ជូនមក ព្រះអង្គទ្រង់ជាយុធិដ្ឋិលគោត្រត្រាស់សួរដល់អត្ថ និងធម៌ បានត្រាស់យ៉ាងនេះថា ភទ្រការមាណព អ្នកចូរប្រាប់ នូវអត្ថ និងធម៌នោះដល់យើងផង ។

លំដាប់នោះ ភទ្រការមាណពទើបពោលនឹងសុចីរតព្រាហ្មណ៍ ដូច្នេះថា "បពិត្រលោកពុក ខ្ញុំកំពុងតែភ្លើតភ្លើនក្នុងបរទារិកកម្ម (កម្ម គឺ ធ្វើសហាយនឹងភរិយាអ្នកដទៃ) សព្វថ្ងៃនេះ ចិត្តរបស់ខ្ញុំមួហ្មង ព្រោះហេតុនោះ ទើបមិនអាចវិសជ្ជនាដល់លោកបាន តែប្អូនប្រុស របស់ខ្ញុំឈ្មោះ សញ្ជ័យកុមារ មានបញ្ញាប្រសើរក្រៃលែងជាងខ្ញុំ សូមលោកចូរសួរគេចុះ គេនឹងដោះស្រាយបញ្ហារបស់លោកបាន" កាលនឹងបញ្ជូនទៅកាន់សម្នាក់ប្អូនប្រុស បានពោល ២ គាថាថា

[៤៨៩] មំសកាជំ អវហាយ    គោធំ អនុបតាមហំ

ន តេ សក្កោមិ អក្ខាតុំ អត្ថំ ធម្មញ្ច បុច្ឆិតោ ។
សញ្ជយោ នាម មេ ភាតា កនិដ្ឋោ មេ សុចីរត
តំ ត្វំ អត្ថញ្ច ធម្មញ្ច គន្ត្វា បុច្ឆស្សុ ព្រាហ្មណ ។

ខ្ញុំដូចជាបុគ្គលទម្លាក់នូវសង្រែកសាច់ ហើយរត់ទៅតាមសត្វទន្សង សូម្បីនឹងត្រូវសួរអត្ថ និងធម៌ ក៏មិនអាចនឹងប្រាប់ដល់លោកបាន ។

បពិត្រសុចីរតព្រាហ្មណ៍ ប្អូនប្រុសរបស់ខ្ញុំឈ្មោះសញ្ជ័យមានហើយ សូមលោកទៅសួរអត្ថ និងធម៌នឹងគេចុះ ។

បណ្ដាបទទាំងនោះ បទថា មំសកាជំ "សង្រែកសាច់" ន័យថា បុរសរែកដុំសាច់ធ្វើដំណើរទៅ ឃើញកូនទន្សងក្នុងរវាងផ្លូវ ក៏ទម្លាក់នូវសង្រែកសាច់ដេញតាមកូនទន្សងនោះយ៉ាងណា ខ្ញុំក៏ដូច្នោះដូចគ្នា លះបង់កិរិយាដែលនៅក្នុងអំណាចក្នុងផ្ទះរបស់ខ្លួន រវល់តែជាប់ពាក់ព័ន្ធនឹងស្រីរបស់អ្នកដទៃរក្សាឃុំគ្រង កាលកទ្រការមោណព

សម្តេងដូច្នេះ ទើបពោលយ៉ាងនោះ ។

ក្នុងគ្រានោះឯង សុចីរតព្រាហ្មណ៍ទើបទៅកាន់និវេសន៍របស់សញ្ជ័យកុមារ ដែលសញ្ជ័យកុមារធ្វើសក្ការៈគោរពហើយ ត្រូវសួរដល់ហេតុដែលមក ទើបប្រាប់ឲ្យជ្រាប ។

ព្រះសាស្តាកាលនឹងទ្រង់ប្រកាសសេចក្តីនោះ បានត្រាស់ព្រះគាថា ២ គាថាថា

[៤៩០] ស្វាធិប្បាគា ភារទ្វាជោ សញ្ជយស្ស ឧបន្តិកំ
តមទ្ទស មហាព្រហ្មា និសិន្នំ សម្ហិ បរិសតិ ។

មហាព្រាហ្មណ៍អ្នកជាភារទ្វាជគោត្រនោះ បានទៅដល់សម្នាក់សញ្ជយកុមារហើយ បានឃើញសញ្ជយកុមារអង្គុយនៅក្នុងនិវេសន៍របស់ខ្លួន ទើបនិយាយថា

[៤៩១] រញ្ញោហំ បហិតោ ទូតោ កោរព្យស្ស យសស្សិនោ
អត្ថំ ធម្មញ្ច បុច្ឆេសិ ឥច្ចព្រវិ យុធិដ្ឋិលោ

*តំ ត្វំ អត្ថញ្ច ធម្មញ្ច   សញ្ជយក្ខាហិ បុច្ឆិតោ ។*

*យើងជារាជទូតរបស់ព្រះបាទកោរព្យរាជ ដែលទ្រទ្រង់នូវយស បញ្ជូនមក ព្រះអង្គជាយុធិដ្ឋិលគោត្រត្រាស់សួរអត្ថ និងធម៌ បានត្រាស់យ៉ាងនេះថា សញ្ជយកុមារ អ្នកត្រូវសួរហើយចូរ ប្រាប់អត្ថ និងធម៌នោះចុះ ។*

*ក៏ក្នុងគ្រានោះ សញ្ជយកុមារកំពុងគប់រកកិរិយាអ្នកដទៃនោះ ឯង លំដាប់នោះ គេទើបប្រាប់សុចិរតព្រាហ្មណ៍ថា "លោកពុក ខ្ញុំ កំពុងគប់រកកិរិយាអ្នកដទៃ និងកាលគប់រកក៏ត្រូវឆ្លងទន្លេទៅកាន់ ត្រើយនាយ មច្ចុ គឺ សេចក្ដីស្លាប់រមែងទំពាស៊ីខ្ញុំ ដែលកំពុងឆ្លង ទន្លេទាំងព្រឹកទាំងល្ងាច ព្រោះហេតុនោះ ចិត្តរបស់ខ្ញុំទើបកន្លល់ មិន អាចប្រាប់អត្ថ និងធម៌ដល់លោកបាន តែខ្ញុំមានប្អូនប្រុសម្នាក់ឈ្មោះ ថា សម្ភវកុមារ តែកើតមកមានអាយុបានត្រឹម ៧ ឆ្នាំ មានបញ្ញា ដឹងលើសខ្ញុំទាំងរយដង ពាន់ដង សែនដង គេនឹងប្រាប់ដល់លោក*

បាន សូមលោកទៅសួរគេចុះ” កាលនឹងប្រកាសសេចក្ដីនោះ បាន ពោល ២ គាថាថា

[៤៩២] សទា មំ គិលតេ មច្ចុ  សាយំ បាតោ សុចីរត
ន តេ សក្កោមិ អក្ខាតុំ  អត្ថំ ធម្មញ្ច បុច្ឆិតោ ។
សម្ភវោ នាម មេ ភាតា  កនិដ្ឋោ មេ សុចីរត
តំ ត្វំ អត្ថញ្ច ធម្មញ្ច  គន្ត្វា បុច្ឆស្សុ ព្រាហ្មណ ។

បពិត្រសុចីរតព្រាហ្មណ៍ មច្ចុរាជកំពុងទំពាស៊ីខ្ញុំសព្វកាល គឺ ទាំងព្រឹកទាំងល្ងាច សូម្បីត្រូវលោកសួរក៏មិនអាចនឹងប្រាប់ អត្ថ និងធម៌ដល់លោកបាន ។

បពិត្រសុចីរតព្រាហ្មណ៍ ប្អូនប្រុសរបស់ខ្ញុំឈ្មោះថា សម្ភវកុមារមានហើយ អញ្ជើញលោកទៅសួរអត្ថ និងធម៌នឹងគេចុះ ។

សុចីរតព្រាហ្មណ៍បានស្ដាប់ដូច្នោះ ទើបគិតថា បញ្ហានេះនឹង

ជារបស់ដ៏អស្ចារ្យក្នុងលោកនេះ ប្រហែលជាមិនមាននរណាដែល ឈ្មោះថា អាចនឹងវិសជ្ជនាបញ្ហានេះបានឡើយ ទើបបានពោល ២ គាថាថា

[៤៩៣] អព្ភុតោ វត ភោ ធម្មោ នាយំ អស្មាក រុច្ចតិ
តយោ ជនា បិតាបុត្តា តេ សុ បញ្ញាយ នោ វិទូ ។
ន តំ សក្កោថ អក្ខាតុំ អត្ថំ ធម្មញ្ច បុច្ឆិតា
កថំ នុ ទហរោ ជញ្ញា អត្ថំ ធម្មញ្ច បុច្ឆិតោ ។

អ្នកទាំងឡាយយើងអើយ បញ្ហានេះជាធម៌គួរអស្ចារ្យដោយពិត យើងមិនធ្លាប់ជួបឡើយ ជនទាំង ៣ នាក់ គឺ បិតា និងបុត្តទាំងពីរនាក់ គង់មិនមានបញ្ញាដឹងនូវធម៌នេះ ។

អ្នកទាំងឡាយត្រូវសួរហើយ គង់មិនអាចប្រាប់អត្ថ និងធម៌នោះបាន ក្មេង ៧ ខួបត្រូវសួរដល់អត្ថ និងធម៌ នឹងដឹងបានយ៉ាងណា ។

បណ្ដាបទទាំងនោះ បទថា **នាយំ "បញ្ហានេះ... មិន"** សេចក្ដីថា នេះជាបញ្ហាកម្មដែលគួរអស្ចារ្យ ឈ្មោះថា អ្នកដែលអាចប្រាប់បញ្ហាធម៌នេះបាន មិនមានឡើយ ព្រោះហេតុនោះ ក្មេងដែលអ្នកនិយាយថា នឹងប្រាប់បាននេះ យើងមិនពេញចិត្តឡើយ ។ **សុ** អក្សរក្នុងបទថា **តេ សុ** ត្រឹមតែជានិបាត ។ អធិប្បាយថា វិធុរព្រាហ្មណ៍ដែលជាបណ្ឌិតក្ដី ភទ្រការមាណពក្ដី និងសញ្ជយកុមារបុត្តក្ដី រួមជា ៣ នាក់ ទាំងបិតា និងបុត្ត គង់មិនដឹង គឺ មិនជ្រាបច្បាស់ នូវធម៌នេះដោយបញ្ញាបាន អ្នកដទៃណាហ្ន៎នឹងដឹង ។ បទថា **ន នំ**[១] **"មិន... អត្ថ និងធម៌នោះ"** សេចក្ដីថា លោកទាំង ៣ នាក់ត្រូវសួរហើយ នៅមិនអាចប្រាប់បាន ក្មេងអាយុ ៧ ខួបត្រូវសួរហើយនឹងដឹងបានដូចម្ដេច គឺ នឹងដឹងបានដោយហេតុយ៉ាងណា ។

សញ្ជយកុមារបានស្ដាប់ដូច្នោះ ទើបប្រាប់ថា "លោកកុំយល់ថា សម្ពុវកុមារជាក្មេង បើលោកមានសេចក្ដីត្រូវការដោយការវិស-

ជូនបញ្ហា លោកចូរទៅសួរគេចុះ” កាលនឹងប្រកាសកិត្តិគុណរបស់
កុមារជាប្អូនប្រុស ដោយលើកឧទាហរណ៍មកប្រៀបធៀបឲ្យយល់
ទើបបានពោល ១២ គាថាថា

[៤៩៤] មា នំ ទហរោតិ មញ្ញសិ អបុច្ឆិត្វាន សម្ភវំ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មញ្ច ព្រាហ្មណ ។

ម្នាលព្រាហ្មណ៍ លោកមិនទាន់បានសួរសម្ភវកុមារ កុំយល់
ថាគេក្មេង លោកសួរសម្ភវកុមារហើយ នឹងដឹងអត្ថ និងធម៌
បាន ។

យថាបិ ចន្ទោ វិមលោ គច្ឆំ អាកាសធាតុយា
សព្វេ តារគណេ លោកេ អាភាយ អតិរោចតិ
ឯវម្បិ ទហរូបេតោ បញ្ញាយោគេន សម្ភវោ
មា នំ ទហរោតិ មញ្ញសិ អបុច្ឆិត្វាន សម្ភវំ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មញ្ច ព្រាហ្មណ ។

ព្រះចន្ទប្រាសចាកមន្ទិល គោចរទៅក្នុងអាកាស រមែងរុងរឿង កន្លងពួកផ្កាយទាំងឡាយក្នុងលោកនេះដោយរស្មី យ៉ាងណា សម្ភវកុមារសូម្បីនៅក្មេង ក៏យ៉ាងនោះ (រមែងរុងរឿងកន្លងបណ្ឌិតទាំងឡាយ) ព្រោះប្រកបដោយបញ្ញា ម្នាលព្រាហ្មណ៍ លោកមិនទាន់បានសួរសម្ភវកុមារកុំយល់ថា គេក្មេង លោកសួរសម្ភវកុមារហើយ នឹងគប្បីដឹងអត្ថ និងធម៌បាន ។

យថាបិ រម្មកោ មាសោ គិម្ហានំ ហោតិ ព្រាហ្មណ
អតេវញ្ញេហិ មាសេហិ ទុមបុប្ផេហិ សោភតិ ។
ឯវម្បិ ទហរូបេតោ បញ្ញាយោគេន សម្ភវោ
មា នំ ទហរោតិ មញ្ញាសិ អបុច្ឆិត្វាន សម្ភវំ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មញ្ច ព្រាហ្មណ ។

ម្នាលព្រាហ្មណ៍ ខែ ៥ ក្នុងគិម្ហន្តរដូវ រមែងល្អស្អាតក្រៃលែងជាងខែដទៃៗ ដោយដើមឈើ និងផ្កា យ៉ាងណា សម្ភវកុមារ

សូម្បីនៅក្មេងក៏ដូច្នោះ (រមែងរុងរឿងកន្លងបណ្ឌិតទាំងឡាយ) ព្រោះប្រកបដោយបញ្ញា ម្នាលព្រាហ្មណ៍ លោកមិនទាន់បាន សួរសម្ភវកុមារ កុំយល់ថាគេនៅក្មេង លោកសួរសម្ភវកុមារ ហើយ នឹងគប្បីដឹងអត្ថ និងធម៌បាន ។

យថាបិ ហិមវា ព្រហ្ម បព្វតោ គន្ធមាទនោ
នានារុក្ខេហិ សញ្ឆន្នោ មហាភូតគណាលយោ
ឱសធេហិ ច ទិព្វេហិ ទិសា ភាតិ បវាតិ ច ។
ឯវម្បិ ទហរូបេតោ បញ្ញាយោគេន សម្ភវោ
មា នំ ទហរោតិ មញ្ញាសិ អបុច្ឆិត្វាន សម្ភវំ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មញ្ច ព្រាហ្មណ ។

ម្នាលព្រាហ្មណ៍ ហិមវន្តបព៌តឈ្មោះថា គន្ធមាទន៍ ដេរដាស ទៅដោយដើមឈើផ្សេងៗ ដែលជាទីអាស្រ័យនៅនៃពួកទេវតា រមែងល្អស្អាត និងក្លិនក្រអូបបក់ទៅទូទាំងទិសដោយទិព្វឱសថ

យ៉ាងណា សម្ភវកុមារសូម្បីនៅក្មេងក៏យ៉ាងនោះ (រមែងរុងរឿងកន្លងបណ្ឌិតទាំងឡាយ) ព្រោះប្រកបដោយបញ្ញា ម្នាលព្រាហ្មណ៍ លោកមិនទាន់សួរសម្ភវកុមារ កុំទាន់យល់ថា គេនៅក្មេង លោកសួរសម្ភវកុមារហើយ នឹងគប្បីដឹងអត្ថ និងធម៌បាន ។

យថាបិ បាវកោ ព្រហ្មេ អច្ចិមាលី យសស្សិមា
ជលមានោ វនេ គច្ឆេ អនលោ កណ្ហវត្តនី
ឃតាសនោ ធូមកេតុ ឧត្តមាហេវនន្ទហោ
និសិ្សវេ[១] បព្វតគ្គស្មឹ ពហុតេជោ វិរោចតិ ។
ឯវម្បិ ទហរូបេតោ បញ្ញាយោគេន សម្ភវោ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មញ្ច ព្រាហ្មណ ។

ម្នាលព្រាហ្មណ៍ ភ្លើងព្រៃមានអណ្តាតរុងរឿង ឆេះរាល

១.ឱ. និសិ្សត្ថេ ។

មិនឆ្អែត មានជានខ្មៅរៀងទៅ មានប្រេងជាអាហារ មានផ្សែងជាទង់ ឆេះដងព្រៃខ្ពស់ៗ ក្នុងវេលាកណ្តាលយប់ ភ្លឺរុងរឿងនៅលើកំពូលភ្នំ យ៉ាងណា សម្ភវកុមារសូម្បីនៅក្មេងក៏ដូច្នោះ (រមែងភ្លឺរុងរឿងកន្លងបណ្ឌិតទាំងឡាយ) ព្រោះប្រកបដោយបញ្ញា ម្នាលព្រាហ្មណ៍ លោកមិនទាន់បានសួរសម្ភវកុមារ កុំយល់ថា គេនៅក្មេង លោកសួរសម្ភវកុមារហើយ នឹងដឹងអត្ថនិងធម៌បាន ។

ជវេន កទ្រំ ជានន្តិ ពលិពទ្ទញ្ច វាហិយេ[1]
ទោហេន ធេនុំ ជានន្តិ ភាសមានញ្ច បណ្ឌិតំ ។
ឯវម្បិ ទហរូបេតោ បញ្ញាយោគេន សម្ភវោ
មា នំ ទហរោតិ មញ្ញាសិ អបុច្ឆិត្វាន សម្ភវំ
បុច្ឆិត្វា សម្ភវំ ជញ្ញា អត្ថំ ធម្មញ្ច ព្រាហ្មណ ។

---

១.ម. វាហានេ ។

សេះល្អនឹងដឹងបានទូវថ្មីជើង គោពលិព័ទ្ធនឹងដឹងបានព្រោះនាំ

ភារៈទៅ មេគោទឹកដោះនឹងដឹងបានព្រោះទឹកដោះល្អ ឯបណ្ឌិត

នឹងដឹងបានព្រោះការចរចា យ៉ាងណា សម្ពុវកុមារសូម្បីនៅ

ក្មេងក៏យ៉ាងនោះ ព្រោះប្រកបដោយបញ្ញា ម្នាលព្រាហ្មណ៍

លោកមិនទាន់បានសួរសម្ពុវកុមារ កុំទាន់យល់ថា គេនៅក្មេង

លោកសួរសម្ពុវកុមារហើយនឹងដឹងអត្ថ និងធម៌បាន ។

បណ្ដាបទទាំងនោះ បទថា ជញ្ញា "នឹងគប្បីដឹង" បានដល់

នឹងបានដឹង ។ បទថា ចន្ទោ "ព្រះចន្ទ" បានដល់ ព្រះចន្ទក្នុងថ្ងៃ

ពេញបូរមី ។ បទថា វិមលោ "ប្រាសចាកមន្ទិល" គឺ ប្រាសចាក

មន្ទិល គឺ ពពកជាដើម ។ បទថា ឯវម្បិ ទហរូបេតោ "សូម្បីគេ

នៅក្មេងក៏ដូច្នោះ" សេចក្ដីថា សម្ពុវកុមារសូម្បីចូលដល់កាលជាក្មេង

ក៏ដូច្នោះ រមែងស្អាតវិសេស គឺ រុងរឿងកន្លង បានដល់ ស្វាងស្វៃ

កន្លងបណ្ឌិតដ៏សេសក្នុងផ្ទៃជម្ពូទ្វីបទាំងមូល ព្រោះប្រកបទៅដោយ

បញ្ញា ។

បទថា **រម្មកោ** “ខែប្រាំ” បានដល់ ខែ ៥ ។ បទថា **អតេ-វញ្ញហិ** “ក្រៃលែងជាងខែដទៃៗ” សេចក្តីថា ស្អាតក្រៃលែងណាស់ជាងខែទាំង ១១ ដទៃៗ ។ បទថា **ឯវំ** “ដូច្នោះ” សេចក្តីថា សូម្បីសម្ភវកុមារក៏ដូច្នោះ រមែងល្អស្អាត ព្រោះប្រកបដោយបញ្ញា ។ បទថា **ហិមវា** “ហិមវន្ត” សេចក្តីថា ភ្នំឈ្មោះថា ហិមៈ ព្រោះប្រកបទៅដោយហិមៈ (ទឹកកក) ក្នុងសម័យហិមៈធ្លាក់ មួយទៀត ឈ្មោះថា ខ្វាក់នូវហិមៈព្រោះខ្វាក់នូវហិមៈក្នុងគិម្ហរដូវ ភ្នំឈ្មោះថា គន្ធ-មាទន៍ ព្រោះញ៉ាំញី (គ្របដណ្តប់) ជនដែលមកដោយរបស់ក្រអូប ។ បទថា **ហាភូតគណាលយោ**[1] “ជាទីនៅអាស្រ័យរបស់ពួកទេវតា” បានដល់ ជាទីនៅរបស់ពួកទេវតា ។ បទថា **ទិសា ភាតិ** “រមែងស្រស់សង្ហា... ទូទាំងទិស” សេចក្តីថា ភ្នំគន្ធមាទន៍នោះរមែងធ្វើ

---

១.បិដក. មហាភូតគណាលយោ ។

ទិសទាំងពួងឲ្យរុងរឿងទៅតែមួយដូចគ្នា ។ បទថា **បភាតិ** "ក្រអូបបក់" សេចក្តីថា រមែងផ្សាយទៅទូទាំងទិសដោយក្លិនក្រអូប ។

បទថា **ឯវំ** "ដូច្នោះ" សេចក្តីថា សម្ពវកុមារសូម្បីនៅក្មេងក៏ដូច្នោះ រមែងរុងរឿង និងមានក្លិនក្រអូបផ្សាយទៅទូទាំងទិស ព្រោះប្រកបដោយបញ្ញា ។ បទថា **យសស្សិមា** "រុងរឿង" សេចក្តីថា ភ្លើងព្រៃឈ្មោះថា **យសស្សិមា** មានអណ្តាតរុងរឿង ព្រោះដល់ព្រមដោយតេជះ ។ បទថា **អច្ចិមាលី**[១] "មានអណ្តាត" សេចក្តីថា ភ្លើងព្រៃប្រកបទៅដោយអណ្តាត ។ បទថា **ជលមានោ វនេ គច្ឆេ** "ឆេះរាលទៅក្នុងព្រៃ" សេចក្តីថា រមែងឆេះរាលទៅក្នុងព្រៃធំ ពោលគឺ គុម្ពឈើ ។ បទថា **អនលោ** "មិនឆ្អែត" បានដល់មិនល្មម ។ ឈ្មោះថា **កណ្ហវត្តនី** "មានដានខ្មៅ" ព្រោះផ្លូវដែលភ្លើងឆេះហើយមានពណ៌ខ្មៅ ។ បទថា **ឃតាសនោ** "មានប្រេងជា

១.បិដក. អច្ចិមាលី ។

អាហារ” ព្រោះស៊ីប្រេងដោយអំណាចនៃគ្រឿងបូជាក្នុងយញ្ញពិធី ។ បទថា **ធូមកេតុ** “មានផ្សែងជាទង់” ព្រោះផ្សែងភ្លើងជាគ្រឿងសម្គាល់ដូចជាទង់ ។ បទថា **ឧត្តមាហេវនទ្ធហោ** “ឆេះដងព្រៃខ្ពស់ៗ” គឺភ្លើងព្រៃរមែងឆេះព្រៃសណ្ឋះខ្ពស់ៗ ដែលគេហៅថា ព្រៃក្រាស់ ។ បទថា **និស្សិវេ** “ក្នុងវេលាកណ្តាលយប់” បានដល់ វេលាអធ្រាត្រ ។ បទថា **បព្វតគ្គស្មឹ** “នៅលើកំពូលភ្នំ” បានដល់ លើកំពូលភ្នំ ។ បទថា **ពហុតេជោ** “ឆេះសន្ធោសន្ធៅ” បានដល់ មានឫទ្ធិតេជះដ៏ខ្លាំង ។ បទថា **វិរោចតិ** “ភ្លឺ” សេចក្តីថា រមែងភ្លឺស្វាងស្វែទូទាំងទិស ។ បទថា **ឯវំ** “ដូច្នោះ” សេចក្តីថា សម្ភវកុមារប្អូនប្រុសខ្ញុំសូម្បីនៅក្មេងក៏ដូច្នោះ រមែងភ្លឺរុងរឿងកន្លងបណ្ឌិតទាំងឡាយ ព្រោះប្រកបដោយបញ្ញា ។ បទថា **ភទ្រំ** “ល្អ” សេចក្តីថា ជនទាំងឡាយដឹងសេះអាជានេយ្យដ៏ចម្រើន ព្រោះប្រកបទៅដោយថ្វីជើង មិនមែនព្រោះរូបរាង មុខមាត់ឡើយ ។ បទថា **វាហិយេ** “នាំភារៈទៅ”

សេចក្ដីថា ជនទាំងឡាយដឹងគោពលិព័ទ្ទថា គោនេះប្រសើរ ព្រោះនាំភារៈទៅបាន ក្នុងកាលមានភារៈដែលនឹងគប្បីនាំទៅ ។ បទថា **ទោហេន** “**ព្រោះទឹកដោះល្អ**” សេចក្ដីថា ដឹងមេគោទឹកដោះថា មានទឹកដោះល្អ ព្រោះដល់ព្រមដោយទឹកដោះ ។ ក្នុងបទថា **ភាសមានំ**[១] “**កាលចរចា**” នេះ សេចក្ដីថា ដឹងថាជាបណ្ឌិត កាលនិយាយរឿងរ៉ាវផ្សេងៗ ។ អ្នកប្រាជ្ញគប្បីនាំពាលបណ្ឌិតសូត្រមកសម្ដែងប្រកប ។

កាលសញ្ជយកុមារសរសើរសម្ភវកុមារយ៉ាងនេះ សុចីរតព្រាហ្មណ៍គិតថា “យើងសួរបញ្ហាហើយ នឹងដឹង” ដូច្នេះហើយទើបសួរថា “នែកុមារ ប្អូនប្រុសរបស់អ្នកនៅទីណាហ្ន៎?” លំដាប់នោះសញ្ជយកុមារទើបបើកបង្អួចលើកដៃចង្អុលប្រាប់សុចីរតព្រាហ្មណ៍ថា “នុ៎ះ សម្ភវកុមារ អ្នកដែលមានសម្បុរផូរផង់ដូចមាស កំពុងលេងជាមួយសម្លាញ់ក្មេង ៗ ចន្លោះផ្លូវជិតមាត់ទ្វារប្រាសាទនោះឯង គឺ

១.បិដក. ភាសមានញ្ច ។

ប្អូនប្រុសរបស់ខ្ញុំ អញ្ជើញលោកទៅហើយសាកសួរគេមើល គេនឹង ប្រាប់បញ្ហាដល់លោកបាន ដោយលីលានៃព្រះពុទ្ធជាម្ចាស់” ។ សុ-ចីរតព្រាហ្មណ៍ស្ដាប់ពាក្យរបស់សញ្ជយកុមារហើយ ក៏បានចុះចាក ប្រាសាទទៅកាន់សម្នាក់របស់សម្ភវកុមារ ។ មានពាក្យសួរថា “ទៅ វេលាណា?” ឆ្លើយថា “ទៅក្នុងវេលាដែលសម្ភវកុមារឈរដោះនូវ សម្ពត់ដណ្ដប់ចេញក្រវាត់ត្រង់ក យកដៃទាំងពីរកើបធូលីលេង” ។

កាលព្រះសាស្ដា ទ្រង់នឹងធ្វើសេចក្ដីនោះឲ្យជាក់ច្បាស់ ទើប ត្រាស់ព្រះគាថាថា

[៤៩៥] ស្វាធិប្បាគា ភារទ្វាជោ សម្ភវស្ស ឧបន្តិកំ

តមទ្ទស មហាព្រហ្មា កីឡមានំ ពហីបុរេ ។

មហាព្រាហ្មណ៍ភារទ្វាជគោត្រនោះ បានទៅកាន់សម្នាក់របស់ សម្ភវកុមារ ឃើញគេកំពុងលេងនៅខាងក្រៅផ្ទះ ។

បណ្ដាបទទាំងនោះ បទថា ពហីបុរេ “នៅក្រៅផ្ទះ” បានដល់

ចំណែកខាងក្រៅផ្ទះ ។

ចំណែកព្រះមហាសត្វ ឃើញព្រាហ្មណ៍មកឈរនៅចំពោះមុខ ទើបសួរថា "បពិត្រលោកពុក លោកមកដោយបំណងនូវវត្ថុអ្វី?" កាលសុចីរតព្រាហ្មណ៍ប្រាប់ថា "ម្នាលកុមារ យើងបានត្រាច់ទៅក្នុងជម្ពូទ្វីប ក៏មិនបានជួបអ្នកដែលអាចដោះស្រាយបញ្ហាដែលយើងសួរ ទើបបានមកកាន់សម្នាក់របស់អ្នក" ដូច្នេះហើយទើបគិតថា "ជ្រាបថា បញ្ហាដែលនរណាៗ វិនិច្ឆ័យមិនបានក្នុងសកលជម្ពូទ្វីប ធ្លាក់មកដល់សម្នាក់របស់យើង យើងជាមនុស្សប្រាស់ដោយការដឹង" ដូច្នេះ ក៏នឹកអៀនខ្មាសខ្លួន ទើបទម្លាក់ធូលីដែលនៅនឹងបាតដៃចេញ ទាញសំពត់ត្រង់កមកដណ្ដប់ ហើយក៏បវារណាដោយសព្វញ្ញុតញ្ញាណថា "អញ្ជើញសួរចុះព្រាហ្មណ៍ ខ្ញុំនឹងប្រាប់លោកដោយលីលានៃព្រះសម្ពុទ្ធជាម្ចាស់" ។

លំដាប់នោះ សុចីរតព្រាហ្មណ៍សួរបញ្ហាដោយគាថាថា

[៤៩៦] រញ្ញោហំ បហិតោ ទូតោ    កោរព្យស្ស យសស្សិនោ
អត្ថំ ធម្មញ្ច បុច្ឆេសិ    ឥច្ចព្រវិ យុធិដ្ឋិលោ
តំ ត្វំ អត្ថញ្ច ធម្មញ្ច    សម្ភវក្ខាហិ បុច្ឆិតោ ។

យើងជារាជទូតរបស់ព្រះបាទកោរព្យរាជ អ្នកទ្រទ្រង់នូវយស ទ្រង់បញ្ជូនមក ព្រះអង្គទ្រង់ជាយុធិដ្ឋិលគោត្រ ត្រាស់សួរដល់អត្ថ និងធម៌ បានត្រាស់យ៉ាងនេះថា សម្ភវកុមារ អ្នកត្រូវសួរហើយ សូមចូរប្រាប់អត្ថ និងធម៌នោះចុះ ។

ខ្លឹមសារនៃបញ្ហានោះថា កិត្តិគុណរបស់សម្ភវបណ្ឌិត បានប្រាកដដូចជាព្រះចន្ទក្នុងថ្ងៃពេញបូរមីកណ្ដាលនៃដួងតារា ដូច្នោះ ។

លំដាប់នោះ សម្ភវកុមារទើបពោលថា "បើដូច្នោះលោកចូរផ្ចាំស្ដាប់" កាលនឹងវិសជ្ជនា ធម្មយាគបញ្ហា ទើបពោលគាថាថា

[៤៩៧] តគ្ឃ តេ អហមក្ខិស្សំ    យថាបិ កុសលោ តថា

*រាជា ច ខោ តំ ជានាតិ យទិ កាហតិ វា ន វា ។*

*អញ្ជើញស្តាប់ ខ្ញុំនឹងដោះស្រាយបញ្ហាដល់លោកដោយភាព*

*ជាអ្នកប្រាជ្ញ មួយទៀត ព្រះរាជាទ្រង់រមែងជ្រាបអត្ថ និងធម៌*

*នោះបាន តែថាទ្រង់ធ្វើតាម ឬមិនធ្វើតាម មិនដឹងទេ ។*

គ្រាសម្ភវកុមារឈរសម្តែងធម៌នៅត្រង់ចន្លោះផ្លូវដោយសំឡេងដ៏ពីរោះ សំឡេងគឹកកងក៏ផ្សាយទូទៅក្នុងនគរពារាណសីប្រមាណ ១២ យោជន៍ ។ លំដាប់នោះ ព្រះរាជា និងឧបរាជជាដើមក៏មកប្រជុំគ្នាទាំងអស់ ។ ព្រះមហាសត្វទើបផ្តើមសម្តែងធម៌ទេសនាក្នុងកណ្តាលមហាជន ។

បណ្តាបទទាំងនោះ បទថា **តគ្ឃ "អញ្ជើញស្តាប់"** ជាពាក្យអញ្ជើញឲ្យស្តាប់ការព្យាករណ៍បញ្ហានោះឯង ។ បទថា **យថាបិ កុសលោ "ដោយភាពជាអ្នកប្រាជ្ញ"** សេចក្តីថា ព្រះមហាសត្វសម្តែងធម៌ដល់សុចីរតព្រាហ្មណ៍ថា "ព្រះសព្វញ្ញូទ្រង់ឈ្លាសវៃដ៏ក្រៃលែង

ត្រាស់ប្រាប់យ៉ាងណា ខ្ញុំក៏នឹងប្រាប់ដល់លោកដោយចំណែកមួយដូចគ្នានោះឯង” ។ បទថា រាជា ច ខោ តំ “ព្រះរាជា... នោះបាន” សេចក្តីថា សម្ភវកុមារបានសម្តែងថា “ខ្ញុំនឹងប្រាប់បញ្ហានោះ ដោយប្រការដែលព្រះរាជារបស់លោកនឹងទ្រង់ជ្រាបបាន ក្រៃលែងជាងនោះ ព្រះរាជារមែងទ្រង់ជ្រាបនូវអត្ថធម៌នោះបានយ៉ាងនេះ ព្រះអង្គទ្រង់ធ្វើតាម ឬទ្រង់មិនធ្វើតាមក្តី បញ្ហានោះនឹងកើតមានដល់ព្រះអង្គដែលទ្រង់ធ្វើតាម ឬមិនធ្វើតាមនោះឯង តែទោសកំហុសរបស់យើងមិនមាន” ។

គ្រាសម្ភវកុមារបេ្តជ្ញាពោលដោះស្រាយបញ្ហាដោយគាថាយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងពោលធម្មយាគប្បញ្ញាតទៅ ទើបពោលគាថាថា

[៤៩៨] អជ្ជ សុវេតិ សំសេយ្យ រញ្ញា បុដ្ឋោ សុចីរត
មាកត្វា អវសី រាជា អត្ថេ ជាតេ យុធិដ្ឋិលោ

បពិត្រសុចីរតព្រាហ្មណ៍ បុគ្គលដែលត្រូវព្រះរាជាត្រាស់សួរហើយ គប្បីទូលកិច្ចដែលគួរធ្វើក្នុងថ្ងៃនេះ ឲ្យធ្វើក្នុងថ្ងៃស្អែក ព្រះបាទយុធិដ្ឋិលៈទ្រង់កុំធ្វើតាម ក្នុងកាលប្រយោជន៍ត្រូវកើតឡើង ។

អជ្ឈត្តញ្ចេវ សំសេយ្យ    រញ្ញោ បុដ្ឋោ សុចីរត
កុម្មគ្គំ ន និវេសេយ្យ    យថា មុឡ្ហោ អចេតសោ ។

បពិត្រសុចីរតៈ បុគ្គលដែលត្រូវព្រះរាជាត្រាស់សួរហើយ គប្បីក្រាបទូលធម៌ខាងក្នុងប៉ុណ្ណោះ មិនគប្បីឲ្យស្តេចទៅកាន់ផ្លូវខុស ដូចបុគ្គលល្ងង់រកការគិតមិនបាន ដូច្នោះ ។

អត្តានំ នាតិវត្តេយ្យ    អធម្មំ ន សមាចរេ
អតិត្ថេ នប្បតារេយ្យ    អនត្ថេ ន យុតោ សិយា ។

ក្សត្រមិនគួរកន្លងព្រះអង្គ មិនគួរប្រព្រឹត្តអធម៌ មិនគួរឆ្លងទៅក្នុងទីមិនមែនកំពង់ ទ្រង់មិនគប្បីខ្វល់ខ្វាយក្នុងវត្ថុ ដែលមិនជា

ប្រយោជន៍ ។

យោ ច ឯតានិ ឋានានិ    កត្តុំ ជានាតិ ខត្តិយោ

សទា សោ វឌ្ឍតេ រាជា    សុក្កបក្ខេវ ចន្ទិមា ។

មយ៉ាងទៀត ក្សត្រអង្គណាទ្រង់ជ្រាបថា គួរធ្វើឋានៈទាំងនេះ ក្សត្រអង្គនោះទ្រង់រមែងចម្រើនសព្វកាល ដូចព្រះចន្ទក្នុងសុ-ក្កបក្ខដូច្នោះ ។

ញាតីនញ្ច បិយោ ហោតិ    មិត្តេសុ ច វិរោចតិ

កាយស្ស ភេទា សប្បញ្ញោ    សគ្គំ សោ ឧបបជ្ជតីតិ ។

ក្សត្រអង្គនោះ រមែងជាទីស្រឡាញ់ពេញព្រះទ័យរបស់ព្រះញាតិទាំងឡាយផង ទ្រង់រមែងរុងរឿងក្នុងពួកមិត្រផង ស្ដេចទ្រង់មានព្រះប្រាជ្ញា កាលសោយទិវង្គតហើយរមែងចូលដល់លោកសួគ៌ ។

បណ្ដាបទទាំងនោះ បទថា សំសេយ្យ "គប្បីទូល" បានដល់

គប្បីក្រាបទូល ។ លោកពោលអធិប្បាយទុកដូច្នេះថា "បពិត្រសុ-

ចីរតៈ ប្រសិនបើនរណាត្រូវព្រះរាជារបស់គេត្រាស់សួរថា ថ្ងៃនេះ

យើងនឹងឲ្យទាន រក្សាសីល ធ្វើឧបោសថ ដូច្នេះសោត គប្បីក្រាប

ទូលថា ព្រះតេជះ បពិត្រមហារាជ ថ្ងៃនេះពួកខ្ញុំព្រះអង្គនឹងសម្លាប់

សត្វ នឹងបរិភោគកាម នឹងផឹកសុរាសិន ចាំថ្ងៃស្អែកសឹមធ្វើបុណ្យ

ធ្វើកុសល ព្រះរាជាជាយុធិដ្ឋិលគោត្ររបស់លោក សូម្បីទ្រង់នឹង

ធ្វើតាមពាក្យរបស់អាមាត្យដែលជាធំនោះហើយ ក៏កុំបណ្តោយថ្ងៃ

នោះឲ្យកន្លងទៅដោយសេចក្តីប្រមាទ ក្នុងកាលប្រយោជន៍នោះឯង

កើតឡើង ទ្រង់កុំធ្វើតាមពាក្យរបស់គេ រក្សាកុសលចិត្តដែលកើត

ឡើងហើយកុំឲ្យវិនាស ទ្រង់ចូរបំពេញកម្មដែលបដិសំយុត្តដោយ

កុសលតែម្យ៉ាង លោកគួរក្រាបទូលពាក្យនេះចំពោះព្រះរាជារបស់

លោក" ។

ដោយគាថានេះ ព្រះមហាសត្វសម្តែងកទ្វេករត្តិសូត្រថា អ-

**ជ្ជេវ កិច្ចមាតប្បំ កោ ជញ្ញា មរណំ សុវេ** ជាអាទិ (គួរធ្វើសេចក្ដីព្យាយាមក្នុងថ្ងៃនេះ នរណាហ្ន៎នឹងដឹងសេចក្ដីស្លាប់ថា នឹងមានក្នុងថ្ងៃស្អែក) និងគប្បីសម្ដែងឱវាទទាក់ទងជាមួយសេចក្ដីមិនប្រមាទថា **អប្បមាទោ អមតំ បទំ បមាទោ មច្ចុនោ បទំ** ជាអាទិ (សេចក្ដីមិនប្រមាទជាផ្លូវមិនស្លាប់ សេចក្ដីប្រមាទជាផ្លូវនៃសេចក្ដីស្លាប់) ដោយប្រការដូច្នេះ ។ បទថា **អជ្ឈត្តញ្ញេវ**[(១)] **"ខាងក្នុងប៉ុណ្ណោះ"** សេចក្ដីថា បពិត្រសុចីរតៈ លោកត្រូវព្រះរាជាត្រាស់សួរថា "សម្កវ-បណ្ឌិតត្រូវលោកសួរក្នុងធម្មយាគបញ្ហាហើយ ដោះស្រាយដូចម្ដេច?" គប្បីក្រាបទូលអជ្ឈត្តធម៌ (ធម៌ដែលជាខាងក្នុង) តែម្យ៉ាងចំពោះព្រះរាជារបស់លោក គឺ គប្បីក្រាបទូលដល់បញ្ចក្ខន្ធដែលជានិយកជ្ឈ-ត្តធម៌ ធម៌ដែលនៅក្នុងខ្លួនឯងថា ជារបស់មិនទៀង ព្រោះជារបស់មានហើយត្រឡប់ជាមិនមាន ។

---

១.បិដក. អជ្ឈត្តញ្ញេវ ។

ដោយពាក្យប្រមាណត្រឹមប៉ុណ្ណេះ ព្រះមហាសត្វទ្រង់សម្តែងអនិច្ចតាធម៌ បញ្ជាក់ដោយគាថាយ៉ាងនេះថា

សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ(១)

អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ "តិ"(២)

កាលណាបណ្ឌិតពិចារណាឃើញដោយបញ្ញាថា សង្ខារទាំងឡាយមិនទៀង ក្នុងកាលនោះ រមែងនឿយណាយក្នុងទុក្ខ សង្ខារទាំងឡាយមិនទៀងហ្ន៎ មានការកើតឡើង និងវិនាសទៅជាធម្មតា លុះកើតឡើងហើយ រមែងរលត់ទៅ ការចូលទៅរម្ងាប់សង្ខារទាំងនោះ ទើបជាសុខ ។

បទថា កុម្មគ្គំ "ផ្លូវដែលខុស" សេចក្តីថា បពិត្រព្រាហ្មណ៍ អន្ធពាលបុថុជ្ជនដែលវង្វេងមិនមានការគិត រមែងសេពផ្លូវខុស គឺទិដ្ឋិ ៦២ ប្រការយ៉ាងណា ព្រះរាជារបស់លោកមិនគប្បីសេពផ្លូវ

---

១.ធម្មបទ មគ្គវគ្គ, ២.ទីឃ.និ., (តាមបាលីអដ្ឋកថា) ។

ខុសនោះ ចូរសេពចំពោះកុសលកម្មបថ ១០ ដែលជានិយ្យានិកធម៌ លោកគួរក្រាបទូលព្រះអង្គដូច្នេះ ។ បទថា **អត្តានំ** **"ព្រះអង្គ"** គឺ ក្សត្រមិនគប្បីលះបង់អត្តភាពនេះដែលតាំងនៅក្នុងសុគតិ ជនទាំងឡាយលះបង់កុសលសម្បត្តិ ៣ ប្រការក្នុងកាមភពទាំងពួង ហើយកើតក្នុងអបាយព្រោះកម្មណា ក្សត្រមិនគួរធ្វើកម្មនោះឡើយ ។ បទថា **អធម្មំ** **"អធម៌"** សេចក្តីថា មិនគប្បីប្រព្រឹត្តអធម៌ ពោលគឺ ទុច្ចរិត ៣ យ៉ាង ។ បទថា **អតិត្ថេ** **"មិនមែនកំពង់"** សេចក្តីថា មិនគួរឆ្លង គឺ មិនគួរចុះកាន់ក្នុងទីមិនមែនកំពង់ ពោលគឺ ទិដ្ឋិ ៦២ ប្រការ បាឋៈថា **ន តារយេ** ដូច្នេះក៏មាន ។ សេចក្តីថា មិនគួរញ៉ាំងជនអ្នកដល់នូវទិដ្ឋានុគតិរបស់ខ្លួនឲ្យចុះកាន់ ។ បទថា **អនត្ថេ** **"មិនជាប្រយោជន៍"** បានដល់ ក្នុងវត្ថុដែលមិនមែនហេតុ ។ បទថា **ន យុតោ** **"មិនខ្វល់ខ្វាយ"** សេចក្តីថា មិនគួរខ្វល់ខ្វាយ (ក្នុងវត្ថុឥតហេតុផល) ។ ក្នុងបទនេះមានអធិប្បាយថា បើព្រះរាជារបស់

លោកទ្រង់បំណង នឹងប្រព្រឹត្តក្នុងធម្មយាគបញ្ហា ចូរទ្រង់ប្រព្រឹត្ត ក្នុងឱវាទនេះ លោកគួរក្រាបទូលស្តេចដោយប្រការដូច្នេះ ។

បទថា **សទា** **"សព្វកាល"** បានដល់ ប្រព្រឹត្តជាប់តទៅអស់ កាល ។ លោកពោលអធិប្បាយទុកដូច្នេះថា ព្រះខត្តិយរាជអង្គណា ទ្រង់ជ្រាបហើយធ្វើនូវហេតុទាំងនេះ ព្រះខត្តិយរាជអង្គនោះក៏ទ្រង់ រមែងចម្រើនសព្វកាល ដូចព្រះចន្ទក្នុងចំណែករះឡើង ដូច្នោះ ។ បទថា **វិរោចតិ** **"រុងរឿង"** សេចក្តីថា ទ្រង់រមែងល្អរុងរោចន៍ក្នុង កណ្តាលមិត្ត និងអាមាត្យរបស់ព្រះអង្គដោយគុណទាំងឡាយមាន សីល មារយាទ និងញាណជាដើម ។

ព្រះមហាសត្វពោលដោះស្រាយបញ្ហាដល់ព្រាហ្មណ៍ ដោយ ពុទ្ធលីលា ដូចញុំាងព្រះចន្ទឲ្យប្រាកដក្នុងផ្ទៃអាកាស ដោយប្រការ ដូច្នេះ ។ មហាជនទាំងឡាយក៏បន្លឺសំឡេងស្រែកហ៊ោ ទះដៃ ធ្វើ សាធុការ ១.០០០ ដង ខ្លះនាំគ្នាគ្រវីទង់ និងធ្វើការទះដៃ ទាំងនាំ

ទៅនូវវត្ថុមានគ្រឿងប្រដាប់ដៃជាដើម ។ ទ្រព្យរបស់ដែលមហាជន នាំទៅហើយយ៉ាងនេះរាប់បានដល់កោដិ សូម្បីព្រះរាជាក៏ទ្រង់ប្រោស ប្រាណ ព្រះរាជទានយសធំដល់សម្ភវកុមារនោះ ។ ចំណែកសុចី- រតព្រាហ្មណ៍ធ្វើការបូជាដោយដុំមាសពាន់ដុំហើយ បានចារឹកពាក្យ វិសជ្ជនាបញ្ហាចុះក្នុងផែនមាសដោយហិង្គុល និងហរតាល ហើយ ធ្វើដំណើរត្រឡប់ទៅកាន់ឥន្ទបត្តនគរ ក្រាបទូលធម្មយាគបញ្ហាចំពោះ ព្រះរាជា ។ ព្រះរាជាទ្រង់ប្រព្រឹត្តក្នុងធម៌នោះ ហើយធ្វើសួគ៌បុរី ឲ្យពេញបរិបូណ៌ ។

ព្រះសាស្ដាទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងពេលនេះប៉ុណ្ណោះ ទេ សូម្បីក្នុងកាលមុន តថាគតក៏មានបញ្ញាច្រើនដូចគ្នា" ដូច្នេះ ទើបទ្រង់ប្រជុំជាតកថា "ព្រះបាទធនញ្ជយកោរព្យរាជក្នុងគ្រានោះ បានមកជាព្រះអានន្ទ, សុចីរតព្រាហ្មណ៍ក្នុងគ្រានោះ បានមកជាព្រះ

អនុរុទ្ធ, វិធុរព្រាហ្មណ៍ក្នុងកាលនោះ ក៏បានមកជាអរិយកស្សបៈ, កុទ្រការកុមារក្នុងគ្រានោះ បានមកជាព្រះមោគ្គល្លាន, សញ្ជយមាណព ក្នុងគ្រានោះ បានមកជាព្រះសារីបុត្ត ចំណែកសម្ភវបណ្ឌិតក្នុងគ្រា នោះ គឺ **តថាគត** នេះឯង” ។

ចប់អដ្ឋកថា សម្ភវជាតកទី ៥

# អដ្ឋកថា មហាកបិជាតកទី ៦

(រឿងផលកម្មរបស់ជនធ្វើអាក្រក់ដល់អ្នកមានគុណ)

*ព្រះសាស្តាកាលស្តេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បាន ប្រារព្ធការប្រមៀលថ្មរបស់ព្រះទេវទត្ត ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា ពារាណស្យំ អហុ រាជា "ព្រះរាជា... ក្នុងនគរ ពារាណសី"* ។

*សេចក្តីសង្ខេបថា កាលភិក្ខុទាំងឡាយនាំគ្នាពោលតិះដៀល ព្រះទេវទត្ត ព្រោះប្រើខ្មាន់ធ្នូ ព្រោះប្រមៀលថ្មក្នុងវេលាតមក ព្រះ សាស្តាទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងគ្រានេះ ទេ សូម្បីក្នុងជាតិមុន ទេវទត្តក៏ប្រមៀលថ្មដើម្បីសម្លាប់តថាគតដូច គ្នា" ហើយទ្រង់នាំអតីតនិទានមកត្រាស់ ដូចតទៅនេះ* ។

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជ្យសម្បត្តិក្នុង ព្រះនគរពារាណសី ក្នុងកាសិកគ្រាម ព្រាហ្មណ៍អ្នកស្រែម្នាក់ ភ្ជួរ*

ស្រែរួចហើយក៏លែងគោទៅ ផ្តើមធ្វើការងារជីកស្មៅបំផុសដីដោយ
ចប ។ ហ្វូងគោដើរស៊ីស្លឹកឈើត្រង់គុម្ពឈើមួយកន្លែង បណ្តើរៗ
ក៏ចូលទៅក្នុងព្រៃជ្រៅដោយលំដាប់ ។ ព្រាហ្មណ៍នោះគិតថា ដល់
វេលាហើយ ក៏ទុកចបងើបរកមើលហ្វូងគោមិនឃើញ ក៏កើតទោ-
មនស្ស ទើបដើរស្វែងរកក្នុងព្រៃ ចូលរហូតទៅដល់ព្រៃហិមពាន្ត
ព្រាហ្មណ៍នោះវង្វេងផ្លូវក្នុងព្រៃហិមពាន្ត អត់អាហារអស់ ៧ ថ្ងៃ
ទៅជួបដើមទន្លាប់មួយដើម ទើបឡើងទៅបេះផ្លែបរិភោគ ភ្លាត់ធ្លាក់
ចុះមកអំពីដើមទន្លាប់ ហើយធ្លាក់ចុះទៅក្នុងជ្រោះ ដូចរណ្តៅនរក
ជ្រៅប្រមាណ ៦០ ហត្ថ ។ ព្រាហ្មណ៍ធ្លាក់ចុះទៅក្នុងជ្រោះកន្លងបាន
១០ ថ្ងៃ ។ គ្រានោះ ព្រះពោធិសត្វកើតក្នុងកំណើតពានរ កំពុងស៊ីនូវ
ផលាផល ក្រឡេកឃើញបុរសនោះ ទើបចងខ្សែត្រង់ថ្ម ជួយបុរស
នោះឡើងមកបាន ។ កាលពានរពោធិសត្វកំពុងដេក ព្រាហ្មណ៍បាន
យកដុំថ្មមកគប់លើសីសៈ ។ ព្រះមហាសត្វបានដឹងការធ្វើរបស់គេ

ហើយ ទើបលោតឡើងទៅលើមែកឈើ ពោលថា "បុរសដ៏ចម្រើន អ្នកចូរដើរទៅតាមផែនដី ឯយើងនឹងដើរប្រាប់ផ្លូវដល់អ្នកតាមមែកឈើ" ។ ហើយនាំបុរសនោះចេញអំពីព្រៃរហូតដល់ផ្លូវ ទើបចូលទៅកាន់បព៌តតាមដើម ។ បុរសនោះទៅផុតអំពីព្រះពោធិសត្វហើយ ក៏កើតរោគឃ្លង់ ក្លាយជាមនុស្សប្រេតក្នុងបច្ចុប្បន្នទាន់ភ្នែក ។ គេត្រូវសេចក្ដីទុក្ខបៀតបៀនអស់ ៧ ឆ្នាំ ត្រាច់ទៅដល់មិគាជិនឧទ្យានខេត្តមួយនៃព្រះនគរពារាណសី ក្រាលស្លឹកខាងក្រោមកំពែងដេកសោយទុក្ខវេទនា គ្រានោះ ព្រះបាទពារាណសីស្ដេចទ្រង់ប្រពាសព្រះរាជឧទ្យាន ស្ដេចយាងទៅឃើញគេត្រង់ទីនោះ ហើយក៏ត្រាស់សួរថា អ្នកជានរណា ធ្វើកម្មអ្វី ទើបត្រូវមកទទួលទុក្ខដូច្នេះ រីឯប្រេតនោះបានក្រាបទូលរឿងរ៉ាវទាំងអស់ដោយពិស្ដារ ។

ព្រះសាស្ដាកាលនឹងទ្រង់ប្រកាសនូវសេចក្ដីនោះ ទើបត្រាស់គាថាថា

[៤៩៩] ពារាណស្យំ អហុ រាជា កាសីនំ រដ្ឋវឌ្ឍនោ
មិត្តាមច្ចបរិព្យុឡ្ហោ អគមាសិ មិគាជិនំ ។

ព្រះរាជានៃអ្នកដែនកាសី ទ្រង់ញុំាងរដ្ឋសីមាមណ្ឌលឲ្យចម្រើន ក្នុងព្រះនគរពារាណសី ទ្រង់ហែហមទៅដោយមិត្ត និងអាមាត្យ អ្នកមានកក្តីមុតមាំ ស្តេចទៅកាន់មិគាជិនឧទ្យាន ។

តត្ថ ព្រាហ្មណមទ្ទក្ខិ សេតំ ចិត្រំ កិលាសិនំ
វិទ្ធស្តំ កោវិឡារំវ កីសំ ធមនិសន្ថតំ ។

នៅទីនោះ ព្រះអង្គបានទតព្រះនេត្រឃើញព្រាហ្មណ៍ដែលកើតរោគឃ្លង់ ឃ្លង់ស ពពាលៗ ខ្ទួនពេញទៅដោយស្រែង កើតកម្រមានសាច់លៀនចេញអំពីមាត់ដំបៅ ដូចផ្កាចារដែលរីក រាងកាយគ្រប់កន្លែងមានត្រឹមតែឆ្អឹង ស្គមស្គាំង រវាមទៅដោយសរសៃ ។

បរមការុញ្ញតំ បត្តំ ទិស្វា កិច្ឆគតំ នរំ

អវច ព្យម្ហិតោ រាជា យក្ខានំ កតមោនុសិ ។

គ្រាទតព្រះនេត្រឃើញបុគ្គលគោកយ៉ាក ដល់នូវសេចក្ដីលំបាក គួរឲ្យអាណិតក្រៃលែង ទ្រង់ញាប់ញ័រព្រះទ័យ ទើបត្រាស់សួរថា អ្នកជាយក្ខប្រភេទណាក្នុងចំណោមយក្ខទាំងឡាយ ។

ហត្ថបាទា ច តេសេតា[១] តតោ សេតតរំ សិរោ

គត្តំ កម្មាសវណ្ណន្តេ កិលាសពហុលោចសិ ។

មួយទៀត ដៃ និងជើងរបស់អ្នកស សីសៈក៏កាន់តែសខ្លួន របស់អ្នកក៏ពពាលច្រើនទៅដោយស្រែង និងក្លឹ ។

វដ្តនាវលិសង្កាសា បិដ្ឋិ តេ និន្នតុន្នតា

កាឡបព្វា ច តេ អង្គា នាញ្ញំ បស្សាមិ ឯទិសំ ។

ខ្នងរបស់អ្នកក៏កើតពករជិបរដុប ដូចវល្លិដែលវេញ អវយវៈរបស់អ្នកខ្លះក៏ខ្មៅ ខ្លះក៏ក្ងិចក្ងក់ ដូចវល្លិដែលមានថ្នាំង មើលមិនដូចជនដទៃៗ ឡើយ ។

---

១.អដ្ឋ.បាលី និងឆដ្ឋ. ច តេ សេតា ។

ឧគ្ឃដ្ដបាទោ(១) តសិតោ កីសោ ធមនិសន្ថតោ

ឆា តោ អតិត្តរូបោសិ កុតោសិ កត្ថ គច្ឆសិ ។

ជើងប្រឡាក់ដោយធូលី គួរតក់ស្លុត ស្គាំងស្គម រវាមទៅដោយសរសៃ ស្រេកឃ្លាន រាងកាយស្គម អ្នកមកអំពីណា និងនឹងទៅទីណា ។

ទុទ្ទសី អប្បការោសិ ទុព្វណ្ណោ ភីមទស្សនោ

ជនេត្តិ យាបិ តេ មាតា ន តំ ឥច្ឆេយ្យ បស្សិតុំ ។

មើលគួរឲ្យខ្ពើម រូបរាងក៏អបលក្ខណ៍ ពណ៌សម្បុរគួរខ្ពើមមើលគួរខ្លាច សូម្បីមាតាបិតាបង្កើតរបស់អ្នកក៏មិនប្រាថ្នានឹងមើលអ្នកឡើយ ។

កឹ កម្មមករា បុព្វេ កឹ អវជ្ឈំ អឃាតយិ

កិព្ពិសំ យំ ករិត្វាន ឥទំ ទុក្ខំ ឧបាគមិ ។

ក្នុងជាតិមុនអ្នកធ្វើកម្មអ្វី បានបៀតបៀនអ្នកដែលមិនគួរបៀត-

---

១. អដ្ឋ.បាលី និងឆដ្ឋ. ឧគ្ឃដ្ដបាទោ ។

បៀនយ៉ាងណា ទើបចូលដល់ទុក្ខនេះ ព្រោះបានធ្វើកម្មដែល អាក្រក់យ៉ាងណា ។

បណ្ដាបទទាំងនោះ បទថា **ពារាណស្យំ** “**ក្នុងនគរពារាណសី**” បានដល់ ក្នុងព្រះនគរពារាណសី ។ បទថា **មិត្តាមច្ចបរិព្យុឡ្ហោ**[១] “**ទ្រង់ហែហមទៅដោយមិត្ត និងអាមាត្យដែលមានកក្ដីភាពមុតមាំ**” សេចក្ដីថា ទ្រង់ហែហមទៅដោយមិត្ត និងអាមាត្យអ្នកមានកក្ដីភាព មុតមាំ ។ បទថា **មិគាជិនំ** “**មិគាជិនឧទ្យាន**” គឺ ព្រះឧទ្យានដែល មាននាមយ៉ាងនេះ ។ បទថា **សេតំ** “**ស**” សេចក្ដីថា បានទតព្រះ នេត្រឃើញព្រាហ្មណ៍ដេកនៅលើស្លឹកចេក ឈ្មោះថា ស ព្រោះ កើតរោគឃ្លង់ស ឈ្មោះថា កើតក្លឹពពាលៗ ព្រោះកើតរោគស្រែង ឈ្មោះថា កើតរមាស់ ព្រោះកើតរមាស់បែក សោយនូវទុក្ខវេទនា ។

បទថា **វិទ្ធស្តំ កោវិឡារំវ** “**លៀនចេញ... ដូចផ្កាចារ**” គឺ

---

១.បិដក. មិត្តាមច្ចបរិព្យូឡ្ហោ ។

មានសាច់លៀនចេញអំពីមាត់ជំពៅ ដូចជាផ្កាចារដែលរីកហើយ ។ បទថា **កីសំ** “ស្គមស្គាំង” សេចក្តីថា ក្នុងចំណែកខ្លះនឹងមានសល់តែស្បែកជណ្តប់ឆ្អឹង ស្គមរវាមទៅដោយសរសៃ ។ បទថា **ព្យម្ភិ-តោ** “ទ្រង់ញាប់ញ័រ” សេចក្តីថា ព្រះរាជាទ្រង់ស្ញើប ឬទ្រង់ញ័រព្រះទ័យ ។ បទថា **យក្ខានំ** “យក្ស” សេចក្តីថា ព្រះរាជាបានត្រាស់សួរថា “ក្នុងចំណោមពួកយក្សទាំងឡាយ អ្នកជាយក្សប្រភេទណា?” បទថា **វដ្តនាវលិសង្កាសា** “រដិបរដុប” សេចក្តីថា ក្នុងចំណែកត្រង់ខ្នងរបស់អ្នកជាដុំរដិបរដុប ដូចជាវល្លិដែលវេញ ។ បទថា **អដ្ឋិ** “អវយវៈ” សេចក្តីថា អវយវៈទាំងឡាយរបស់អ្នកខ្មៅ ក្ងិចក្ងក់ដូចវល្លិដែលមានថ្នាំង ។ បទថា **នាញ្ញំ** “មិនដូចមនុស្សដទៃ” គឺយើងមិនឃើញជនដទៃៗ មានលក្ខណៈដូច្នេះឡើយ ។ បទថា **ឧ-គ្ឃដ្ឋបាទោ** “ជើងប្រឡាក់ធូលី” បានដល់ មានជើងប្រឡាក់ទៅដោយធូលី ។

បទថា **អាទិត្តរូបោ**[១] "ជើងប្រឡាក់" បានដល់ មានជើងប្រឡាក់ទៅដោយធូលី ។ បទថា **ទុទ្ទសី** "មើលគួរខ្ពើម" សេចក្តីថា មើលគួរខ្ពើម ។ បទថា **អប្បការោសិ** "រូបរាងក៏អបលក្ខណ៍" សេចក្តីថា មានរូបរាងមិនមានសិរី គឺ មានរូបរាងអាក្រក់ ។ បទថា **កឹ កម្មមករា** "ធ្វើកម្មអ្វីទុក" សេចក្តីថា ក្នុងជាតិមុនអំពីជាតិនេះ អ្នកបានធ្វើ គឺ បានធ្វើហើយនូវកម្មអ្វី ។ បទថា **កិព្វិសំ** "អាក្រក់" បានដល់ កម្មដែលអាក្រក់ ។

តអំពីនោះ ព្រាហ្មណ៍ទើបពោលគាថាក្រាបទូលថា

[៥០០] តគ្ឃ តេ អហមក្ខិស្សំ យថាបិ កុសលោ តថា
សច្ចវាទី ហិ លោកស្មិំ បសំសន្តីធ បណ្ឌិតា ។

មហាបពិត្រ សូមព្រះអង្គទ្រង់ស្តាប់ ខ្ញុំព្រះអង្គនឹងក្រាបទូលចំពោះព្រះអង្គបែបបុគ្គលជាអ្នកប្រាជ្ញ ព្រោះថា បណ្ឌិតទាំង

---

១.បិដក. អតិត្តរូបោសិ ។

ឡាយក្នុងលោកនេះ រមែងសរសើរបុគ្គលនិយាយពិត ។

ឯកោ ចរំ គោគវេសោ    មុឡ្ហោ អចូសរឹ វនេ
អរញ្ញេ ឥរិណេ វិវនេ    នានាកុញ្ជរសេវិតេ ។

កាលខ្ញុំព្រះអង្គត្រាច់តាមរកគោដែលបាត់ទៅតែម្នាក់ឯង បាន វង្វេងផ្លូវចូលទៅក្នុងព្រៃហិមពាន្ត ដាច់ស្រយាល ជាព្រៃកន្តារ ស្ងប់ស្ងាត់ ដែលពួកកុញ្ជរជាតិត្រាច់ទៅមក ។

វាឡមិគានុចរិតេ    វិប្បនដ្ឋោស្មិ កាននេ
អចរឹ តត្ថ សត្តាហំ    ខុប្បិបាសសមប្បិតោ ។

ខ្ញុំព្រះអង្គវង្វេងផ្លូវចូលទៅក្នុងព្រៃជ្រៅ ដែលពួកម្រឹគកាចៗ ត្រាច់ទៅមក ត្រូវអត់ទ្រាំនឹងសេចក្តីស្រេកឃ្លាន ត្រាច់ទៅ ក្នុងព្រៃរហូត ៧ ថ្ងៃ ។

តត្ថ តិណ្ឌុកមទ្ទក្ខឹ    វិសមដ្ឋំ ពុភុក្ខិតោ
បបាតមភិលម្ពន្តំ    សម្បន្នផលធារិនំ ។

នៅក្នុងព្រៃនោះ ខ្ញុំព្រះអង្គកំពុងឃ្វាន បានឃើញដើមទន្ទាប់មួយដើម ដុះនៅជិតមាត់ជ្រោះ ទេរទៅរកមាត់ជ្រោះ មានផ្លែដ៏ច្រើន ។

វាតស្សិតានិ ភក្ខេសឹ តានិ រុច្ចិសុ មេ កុសំ
អតិត្តោ រុក្ខមារុយ្ហ តត្ថ ហេស្សាមិ អស្សិតោ ។

ជាដំបូង ខ្ញុំព្រះអង្គរើសផ្លែដែលខ្យល់បក់ធ្លាក់មកស៊ី កាលខ្ញុំព្រះអង្គស៊ីផ្លែដែលជ្រុះទាំងនោះក៏មានការពេញចិត្ត តែនៅមិនទាន់ឆ្អែត ទើបឡើងទៅលើដើមបំណងថា នឹងស៊ីឲ្យសប្បាយលើដើមនោះ ។

ឯកំ មេ ភក្ខិតំ អាសិ ទុតិយំ អភិបត្ថិតំ
តតោ សា ភញ្ជថ សាខា ឆិន្នា ផរសុនា វិយ ។

ខ្ញុំព្រះអង្គស៊ីផ្លែមួយហើយ ប្រាថ្នានឹងស៊ីផ្លែទីពីរទៀត កាលខ្ញុំព្រះអង្គឈោងដៃស្រវាចាប់ផ្លែដែលត្រូវការ រំពេចនោះ មែក

ឈើត្រង់កន្ទែងជាន់ឈរនោះក៏បាក់ ដូចត្រូវកាប់ដោយពូថៅដូច្នោះ ។

សោហំ សាហាវ សាខាហិ ឧទ្ធំបាទោ អវំសិរោ
អប្បតិដ្ឋេ អនាលម្ពេ គិរិទុគ្គស្មិ បាបតំ[១] ។

ខ្ញុំព្រះអង្គព្រមជាមួយមែកឈើនោះ មានជើងឡើងលើ ក្បាលចុះក្រោមធ្លាក់ចុះទៅក្នុងជ្រោះភ្នំដែលរដិបរដុប ដែលមិនមានទីឈរ មិនមានទីតោងឡើយ ។

យស្មា ច វារិ គម្ភីរំ តស្មា ន សមបជ្ជិសំ
តត្ថ សេសឹ និរានន្ទោ អនូនា ទសរត្តិយោ ។

ខ្ញុំព្រះអង្គនៅមិនទាន់ធ្លាក់ដល់ ព្រោះទឹកជ្រៅ ត្រូវដេក មិនមានសេចក្តីត្រេកអរ គ្មានទីពឹងនៅក្នុងជ្រោះនោះ ១០ រាត្រីគត់ ។

១.ម. គិរិទុគ្គស្មិំ បបាតំ ។

អថេត្ថ កបិ មាគច្ឆិ គោនង្គុលោ ទរីចរោ
សាខាហិ សាខំ វិចរន្តោ ខាទមានោ ទុមប្ផលំ
សោ មំ ទិស្វា កីសំ បណ្ឌុំ ការុញ្ញមករំ មយិ ។

ក្រោយមក មានស្វាមួយមានកន្ទុយដូចជាកន្ទុយគោ ត្រាច់ទៅតាមញកភ្នំ ត្រាច់តោងតាមមែកឈើ រកផ្លែឈើស៊ី បានទៅដល់ទីនោះ ស្វាឃើញខ្ញុំព្រះអង្គស្គមលឿង បានធ្វើសេចក្ដីអាណិតករុណាក្នុងខ្ញុំព្រះអង្គ ។

អម្ភោ កោ នាម សោ ឯត្ថ ឯវំ ទុក្ខេន អដ្ដិតោ
មនុស្សោ អមនុស្សោ វា អត្តានម្មេ បវេទយ ។

ទើបសួរថា អ្នកដ៏ចម្រើន អ្នកឈ្មោះអ្វី ហេតុអ្វីទើបមកទទួលទុក្ខនៅទីនេះដូច្នេះ ជាមនុស្ស ឬជាអមនុស្ស សូមណែនាំខ្លួនឲ្យខ្ញុំបានជ្រាបផង ។

តស្សញ្ជលឹ បណាមេត្វា ឥទំ វចនមព្រវឹ

មនុស្សោហំ វិសម្បត្តោ សា មេ នត្ថិ ឥតោ គតិ
តំ វោ វទាមិ ភទន្តេ ត្វញ្ច មេ សរណំ ភវ ។

ខ្ញុំព្រះអង្គទើបបានប្រណមអញ្ជលីសំពះស្វានោះ ហើយពោលពាក្យនេះថា យើងជាមនុស្សដល់ហើយនូវហាយនៈ យើងមិនមានផ្លូវដែលនឹងទៅអំពីទីនេះបាន ព្រោះហេតុនោះ យើងទើបប្រាប់ឲ្យអ្នកជ្រាប សូមអ្នកចូរមានសេចក្តីចម្រើន មួយទៀតសូមអ្នកប្រោសជាទីពំនាក់របស់ខ្ញុំផង ។

គរុំ សិលំ គហេត្វាន វិចរី បព្វតេ កបិ
សិលាយ យោត្តំ កត្វាន និសភោ ឯតទព្រវិ ។
ឯហិ មេ បិដ្ឋិមារុយ្ហ គីវំ គណ្ហាហិ ពាហុហិ
អហន្តំ ឧទ្ធរិស្សាមិ គិរិទុគ្គត វេគសា ។

ស្វាដ៏អង់អាច ត្រាច់ទៅរកដុំថ្មធំៗ ឯភ្នំមក ហើយចងខ្សែទុកត្រង់ដុំថ្ម ស្រែកប្រាប់ខ្ញុំព្រះអង្គថា មកចុះលោក ចូរឡើង

មកគោងខ្នងខ្ញុំ យកដៃទាំងពីរឱប.ក យើងនឹងនាំអ្នកលោត
ឡើងអំពីជ្រោះដោយកម្លាំង ។

តស្ស តំ វចនំ សុត្វា វានរិន្ទស្ស សិរីមតោ
បច្ឆិមាយុយ្ហ ធីរស្ស គីវំ ពាហាហិ អគ្គហឹ ។

ខ្ញុំព្រះអង្គបានស្តាប់នូវពាក្យរបស់ស្តេចវានរិន្ទ ដ៏មានសិរី
នោះហើយ ទើបឡើងជិះលើខ្នងស្តេចស្វា យកដៃទាំងពីរឱបក ។

សោ មំ តតោ សមុដ្ឋាសិ តេជសី ពលវា កបិ
វិហញ្ញមានោ កិច្ឆេន គិរិទុគ្គត វេគសា ។

លំដាប់នោះ ស្តេចពានរដែលមានតេជះ មានកម្លាំង ក៏នាំខ្ញុំ
ព្រះអង្គលោតឡើងអំពីជ្រោះ ដោយយ៉ាងលំបាកនោះឯង ។

ឧទ្ធរិត្វាន មំ សន្តោ និសភោ ឯតទព្រវិ
ឥង្ឃំ មំ សម្ម រក្ខស្សុ បសុប្បិស្សំ មុហុត្តកំ ។

គ្រាឡើងមកបានហើយ ស្តេចពានរដ៏អង់អាចបានសូមខ្ញុំព្រះ

អន្តថា នៃសម្លាញ់ សូមអ្នកចូរក្សាខ្ញុំផង ខ្ញុំនឹងដេកបន្តិច ។

សីហា ព្យគ្ឃា ច ទីបិ ច អច្ឆកោកតរច្ឆយោ
តេ មំ បមត្តំ ហឹសេយ្យុំ តេ ត្វំ ទិស្វា និវារយ ។

រាជសីហ៍ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ និងខ្លារខិន សត្វទាំងនោះគប្បី បៀតបៀនខ្ញុំដែលដេកលក់ហើយ អ្នកឃើញពួកវា ចូរការពារខ្ញុំផង ។

ឯវំ មេ បរិត្តាតូន បសុប្បិ សោ មុហុត្តកំ
តទាហំ បាបិកំ ទិដ្ឋឹ បដិលច្ចឹ[១] អយោនិសោ ។

ព្រោះខ្ញុំជួយការពារឲ្យយ៉ាងនោះ ស្តេចពានរទើបដេកលក់ទៅមួយរំពេច គ្រានោះព្រោះខ្ញុំព្រះអង្គខ្វះគំនិត ត្រឡប់បានការឃើញនូវសេចក្តីលាមកថា ។

ភក្ខោ អយំ មនុស្សានំ យថា ចញ្ញេ វនេ មិគា
យន្នូនិមំ វធិត្វាន ឆាតោ ខាទេយ្យ វានរំ ។

---

១.អដ្ឋ.បាលី និងឆដ្ឋ. បដិលច្ឆឹ ។

ស្វានេះក៏ជាអាហាររបស់មនុស្សទាំងឡាយ ដូចជាម្រឹគដទៃៗ ក្នុងព្រៃនេះដូចគ្នា បើដូច្នោះ យើងគួរសម្លាប់ពានរនេះស៊ីដោះស្រាយសេចក្ដីស្រេកឃ្លានចុះ ។

អសិតោ ច គមិស្សាមិ មំសមាទាយ សម្ពលំ
កន្តារំ និត្ថរិស្សាមិ បាថេយ្យំ មេ ភវិស្សតិ ។

មួយទៀត យើងឆ្អែតហើយនឹងកាន់យកសាច់ធ្វើជាស្បៀងដើរផ្លូវបន្ត ព្រោះយើងត្រូវឆ្លងនូវផ្លូវកន្តារនេះ សាច់ក៏នឹងបានជាស្បៀងរបស់យើង ។

តតោ សិលំ គហេត្វាន មត្ថកំ សន្និតាឡយឹ
មម កត្តកិលន្តស្ស បហារោ ទុព្វលោ អហុ ។

រំពេចនោះ ខ្ញុំព្រះអង្គទើបចាប់ដុំថ្មមកគប់សីសៈស្វា ការប្រហាររបស់ខ្ញុំព្រះអង្គដែលជាអ្នកលំបាក ព្រោះអត់អាហារទើបមានកម្លាំងតិច ។

សោ ច វេគេនុទព្បត្តោ កបិ រុហិរមក្ខិតោ
អស្សុបុណ្ណេហិ នេត្តេហិ រោទន្តោ មំ ឧទិក្ខតិ ។
មាយ្យោ មំ ករិ ភទ្ទន្តេ ត្វញ្ច នាមេទិសំ ករិ
ត្វញ្ច ខោ នាម ទីឃាវុ អញ្ញេ វារេតុមរហសិ ។

ដោយកម្លាំងដុំថ្មដែលខ្ញុំព្រះអង្គគប់ចុះ ស្វានោះក៏ស្ទុះក្រោកឡើង ទាំងដែលខ្លួនប្រឡាក់ទៅដោយឈាម យំសម្លឹងមើលមកខ្ញុំព្រះអង្គ មានភ្នែកពេញទៅដោយទឹកភ្នែក បានពោលថា អ្នកកុំធ្វើដូច្នេះនឹងខ្ញុំឡើយ សូមអ្នកចូរមានសេចក្តីចម្រើន តែអ្នកបានធ្វើកម្មដ៏អាក្រក់ដូច្នេះ និងអ្នករួចអំពីស្លាប់ មានអាយុវែងមកបាន សមគួរនឹងហាមប្រាមជនដទៃ ។

អហោ វត រេ បុរិស តាវ ទុក្ករការក
ឯទិសា វិសមា ទុគ្គា បបាតា ឧទ្ធតោ មយា ។

អើហ្ន៎ អ្នកនូវធ្វើកម្មដ៏លំបាកដែលបុគ្គលមិនគប្បីនឹងធ្វើទៅបាន

គួរអាសូរពិតៗ ខ្ញុំជួយឲ្យអ្នកឡើងអំពីជ្រោះជ្រៅដែលលំបាក នឹងឡើងមកបានដូច្នេះ ។

អានីតោ បរលោកាវ ទុព្ពេយ្យំ មំ អមញ្ញថ
តន្តេន បាបធម្មេន បាបំ បាបេន ចិន្តិតំ ។

អ្នកដូចជាខ្ញុំនាំមកអំពីបរលោក នៅសម្គាល់ខ្លួនខ្ញុំថា គួរនឹងសម្លាប់ឬ ដោយចិត្តដែលជាបាបធម៌ ដែលជាហេតុឲ្យអ្នកគិតអាក្រក់ ។

មា ហេវ ត្វំ អធម្មដ្ឋ វេទនំ កដុកំ ផុសិ
មា ហេវ បាបកម្មន្តំ ផលំ វេឡុវ តំ វធិ ។

សូម្បីអ្នកគ្មានធម៌ វេទនាដ៏ក្តៅផ្សាកុំពាល់ត្រូវអ្នកឡើយ និងបាបកម្មក៏កុំបានតាមសម្លាប់ អ្នកដូចផ្លែឫស្សីសម្លាប់ដើមឡើយ ។

តយិ មេ នត្ថិ វិស្សាសោ បាបធម្ម អសញ្ញត

ឯហិ មេ បិដ្ឋិតោ គច្ឆ  ទិស្វា មាហាវ សន្តិកេ ។
មុត្តោសិ ហត្ថា វាឡានំ[១]  បត្តោសិ មានុសឹ បទំ
ឯស មគ្គោ អធម្មដ្ឋ  តេន គច្ឆ យថាសុខំ ។

នែអ្នកមានធម៌អាក្រក់ មិនមានសេចក្តីសង្រួម សេចក្តីស្និទ្ធ-
ស្នាលរបស់ខ្ញុំនឹងមិនមានទៅក្នុងអ្នកឡើយ មកចុះ អ្នកចូរដើរ
ឲ្យឆ្ងាយៗ អំពីយើង ល្មមមើលឃើញខ្នងគ្នាប៉ុណ្ណោះចុះ ។

ឥទំ វត្វា គិរិចរោ  រុហិរំ បក្ខលិយ មត្ថកំ
អស្សូនិ សម្បមជ្ជិត្វា  តតោ បព្វតមារុហិ ។

ស្តេចពានរនោះ លុះពោលយ៉ាងនេះហើយ ក៏លាងឈាមត្រង់
សីសៈ ជូតទឹកភ្នែកស្រេចហើយ ក៏លោតឡើងទៅកាន់ភ្នំ ។

សោហំ តេនាភិសត្តោស្មិ  បរិឡាហេន អដ្ដិតោ
ឌយ្ហមានេន គត្តេន  វារឹ បាតុំ ឧបាគមឹ ។

ខ្ញុំព្រះអង្គដែលពានរនោះអនុគ្រោះហើយ ត្រូវសេចក្តីក្រវល់

---

១.អដ្ឋ.បាលី និងឆដ្ឋ. មុត្តាសិ ។

ក្រវាយបៀតបៀនក្តៅពេញខ្លួន បានចុះទៅកាន់អន្លង់ទឹកមួយ ដើម្បីនឹងផឹកទឹក ។

អគ្គិនា វិយ សន្តត្តោ រហទោ រុហិរមក្ខិតោ
បុព្វលោហិតសង្កាសោ សព្វោ មេ សមបជ្ជថ ។

អន្លង់ទឹកក្តៅសព្វដូចត្រូវដាំដោយភ្លើង ជោរជន់ទៅដោយឈាម ប្រៀបដូចជាទឹកឈាម និងទឹកខ្ទុះដូច្នោះ វត្ថុគ្រប់យ៉ាងប្រាកដដល់ខ្ញុំព្រះអង្គយ៉ាងច្បាស់ ។

យាវន្តោ ឧទពិន្ទូនិ កាយស្មឹ និបតឹសុ មេ
តាវន្តោ គណ្ឌ ជាយេថ អឌ្ឍវេលុវសាទិសា ។

តំណក់ទឹកធ្លាក់ត្រូវខ្ញុំព្រះអង្គមានប្រមាណប៉ុន្មាន បូសក៏ផុសឡើងប៉ុណ្ណោះ មានសណ្ឋានដូចជាចំហៀងផ្លែព្នៅ ។

បភិន្នា បគ្ឃរឹសុ មេ កុណបា បុព្វលោហិតា
យេន យេនេវ គច្ឆាមិ គាមេសុ និគមេសុ ច ។

បូសក៏បែកក្នុងថ្ងៃនោះឯង ឈាម ខ្ទុះរបស់ខ្ញុំព្រះអង្គក៏ហូរចេញមក មានក្លិនស្អុយដូចសាកសព មួយទៀត ខ្ញុំព្រះអង្គដើរទៅផ្លូវណា ក្នុងស្រុក ឬនិគមទាំងឡាយ ។

ទណ្ឌហត្ថា និវារេន្តិ ឥត្ថិយោ បុរិសា ច មំ
ឱក្កិតា បូតិគន្ធេន មាស្សុ ឱរេន អាគមា ។

ពួកមនុស្សទាំងស្រីទាំងប្រុសនាំគ្នាកាន់ដំបង ហាម រាំងខ្ញុំព្រះអង្គដែលផ្សាយទៅដោយក្លិនស្អុយថា កុំចូលមកខាងនេះ ។

ឯតាទិសំ ឥទំ ទុក្ខំ សត្តវស្សានិទានិ មេ[១]
អនុភោមិ សកំ កម្មំ បុព្វេ ទុក្កដមត្តនោ ។

ឥឡូវនេះ ខ្ញុំព្រះអង្គបានសោយនូវទុក្ខវេទនាបែបនេះអស់ ៧ ឆ្នាំហើយ ដែលជាផលនៃកម្មអាក្រក់របស់ខ្លួនជាមុន ។

តំ វោ វទាមិ ភទ្ទន្តេ យាវន្តេត្ថ សមាគតា
មាស្សុ មិត្តាន ទុព្ភិត្ថោ មិត្តទុព្ភោ ហិ បាបកោ ។

---

១.បាលីអដ្ឋ. និងឆដ្ឋ. សត្ត វស្សានិ ទានិ មេ ។

ព្រោះហេតុនោះ ខ្ញុំព្រះអង្គទើបក្រាបទូលថ្វាយព្រះអង្គជ្រាប សូមសេចក្តីចម្រើនចូរមានដល់លោកទាំងឡាយ ដែលមកប្រជុំគ្នាក្នុងទីនេះ សូមព្រះអង្គកុំបានប្រទូស្តមិត្ត ព្រោះថា បុគ្គលប្រទូស្តមិត្ត ជាបុគ្គលថោកទាបដោយពិត ។

កុដ្ឋី កិលាសី ភវតិ យោ មិត្តានីធ ទុព្ភតិ
កាយស្ស ភេទា មិត្តទុព្ភី និរយំ សោ ឧបបជ្ជតីតិ ។

ក្នុងលោកនេះ អ្នកដែលប្រទូស្តមិត្តរមែងកើតរោគឃ្លង់ រោគស្រែង កាលស្លាប់ទៅហើយ រមែងចូលដល់នរក ។

បណ្តាបទទាំងនោះ បទថា កុសលោ "បុគ្គលឆ្លាត" សេចក្តីថា មហាបពិត្រ ខ្ញុំព្រះអង្គនឹងក្រាបទូលចំពោះព្រះអង្គ តាមបែបអ្នកប្រាជ្ញនិយាយគ្នា ។ បទថា គោគវេសោ "ដើរតាមរកគោដែលបាត់ទៅ" សេចក្តីថា កាលខ្ញុំព្រះអង្គដើរតាមរកគោដែលបាត់ទៅ ។ បទថា អចូសរឹ "ចូលទៅ" សេចក្តីថា វង្វេងផ្លូវកន្ទង់ដែនដីមនុស្ស

ចូលទៅកាន់ព្រៃហិមពាន្ត ។

បទថា **អរញ្ញេ** "**ក្នុងព្រៃ**" បានដល់ ក្នុងព្រៃជ្រៅមិនមានព្រះរាជាគ្រប់គ្រង ។ បទថា **ព្យីរិនេ**[១] "**កន្ទារ**" សេចក្តីថា ស្ងួតហែង មិនមានទឹក ។ បទថា **វិវនេ** "**ស្មៀមស្ងាត់**" គឺ ស្ងាត់ឈឹង ។ បទថា **វិប្បន្នដ្ឋោ**[២] "**វង្វេងផ្លូវចូលទៅ**" បានដល់ វង្វេងផ្លូវ ។ បទថា **ពុភុក្ខិតោ** "**ស្រេកឃ្លាន**" សេចក្តីថា កើតសេចក្តីស្រេកឃ្លាន គឺ ត្រូវសេចក្តីស្រេកឃ្លានជុតពេលហើយ ។ បទថា **បបាតមភិលម្ពន្តំ**[៣] "**ទេរទៅរកមាត់ជ្រោះ**" សេចក្តីថា មានដើមទេរទៅរកមាត់ជ្រោះ ។ បទថា **សម្បន្នផលធារិនំ** "**មានផ្លែធ្លាក់រយោង**" សេចក្តីថា ដេរដាសទៅដោយចង្កោមផ្លែដែលមានរសផ្អែម ។ បទថា **វាតស្សិតានិ** "**ផ្លែដែលខ្យល់បក់ធ្លាក់មក**" សេចក្តីថា ជាដំបូងខ្ញុំព្រះអង្គក៏រើសផ្លែដែលខ្យល់បក់ធ្លាក់មក (ស៊ី) ជាមុន ។ បទថា **តត្ថ**

---

បិដក. ១.ព្យីរិណេ ។ ២. វិប្បនដ្ឋោស្មិ ។ ៣. បបាតមភិលម្ពន្តំ ។

ហេស្សាមិ “នឹងស៊ីឲ្យសប្បាយលើដើមនោះ” សេចក្ដីថា ខ្ញុំព្រះអង្គ ទើបប្រឹងឡើងទៅលើដើមទន្ទាប់នោះ ដោយគិតថា នឹងស៊ីនៅលើ ដើមឲ្យសប្បាយ ។

បទថា **តតោ សា** “**រំពេចនោះ**” សេចក្ដីថា កាលខ្ញុំព្រះអង្គ ឈោងដៃស្រវាចាប់ផ្លែដែលត្រូវការ មែកឈើដែលឈរជាន់នោះ ក៏បាក់ធ្លាក់ចុះ ដូចត្រូវកាប់ដោយពូថៅដូច្នោះ ។ បទថា **អនាលម្ពេ** “**មិនមានទីតោង**” សេចក្ដីថា មិនមានទីដែលនឹងគប្បីពឹងតោង បានឡើយ ។ បទថា **គិរិទុគ្គស្មិ** “**ភ្នំដែលរដិបរដុប**” បានដល់ ភ្នំ ដែលរដិបរដុប ។ បទថា **សេសឹ** “**ដេក**” សេចក្ដីថា ខ្ញុំព្រះអង្គចាំ បាច់ត្រូវដេក ។ បទថា **កបិ មាគញ្ឆិ**[១] “**ស្វា... មក**” សេចក្ដីថា មានពានរមកដល់ទីនោះ ។ បទថា **គោនង្គុដ្ឋោ**[២] “**មានកន្ទុយដូច កន្ទុយគោ**” សេចក្ដីថា មានកន្ទុយស្រដៀងកន្ទុយគោទាំងឡាយ ។

---

បិដក. ១. កបិ មាគច្ឆិ ។ ២. គោនង្គុលោ ។

បាឋៈថា **នន្ទុជ្ជា** ដូច្នេះក៏មាន ។ អាចារ្យខ្លះពោលថា **គោនន្ទលិ** ។ បទថា **អករម្ហយិ**[១] "បានធ្វើ... ក្នុងខ្ញុំព្រះអង្គ" សេចក្តីថា បានធ្វើសេចក្តីអាណិតក្នុងខ្ញុំព្រះអង្គ ។ បទថា **អម្ភោ** "អ្នកដ៏ចម្រើន" សេចក្តីថា បពិត្រមហារាជ ស្តេចពានរនោះ បានឮសំឡេងខ្ញុំព្រះអង្គ ដែលហែលទឹកនៅក្នុងជ្រោះជ្រៅនោះ ទើបស្រែកហៅខ្ញុំព្រះអង្គថា "នែអ្នកដ៏ចម្រើន" ហើយសួរថា "អ្នកជានរណា" ។ បទថា **ព្យសម្បបត្តោ**[២] "ដល់ហើយនូវហាយនៈ" បានដល់ ដល់ហើយនូវសេចក្តីវិនាស ។ បាឋៈថា **បបាតស្ស វសំ បត្តោ** ដូច្នេះក៏មាន ។

បទថា **ភទ្ទំ វោ** "សូមលោកចូរមានសេចក្តីចម្រើន" សេចក្តីថា ព្រោះដូច្នោះ ខ្ញុំទើបពោលអង្វរលោក សូមសេចក្តីចម្រើនចូរមានដល់លោក ។ បទថា **គរុសិលំ** "ថ្មដុំធំ" សេចក្តីថា បពិត្រមហារាជ កាលខ្ញុំព្រះអង្គពោលយ៉ាងនេះហើយ ស្តេចពានរនោះក៏

---

បិដក. ១. ការុញ្ញមករំ មយិ ។ ២. វសម្បត្តោ ។

ប្រាប់ខ្ញុំព្រះអង្គថា "កុំខ្លាចឡើយ" ហើយត្រាច់ទៅក្នុងភ្នំ ចងខ្សែ ភ្ជាប់នឹងដុំថ្មដ៏ធ្ងន់ទុកខាងដើម ។ បទថា **និសភោ** **"ជាអ្នកអង់អាច"** សេចក្តីថា កំពូលពានរដ៏អង់អាច ចងខ្សែត្រង់សិលាហើយ ឈរ នៅត្រង់ញកភ្នំ បានពោលពាក្យនេះនឹងខ្ញុំព្រះអង្គ ។ បទថា **ពាហុហិ**[១] **"យកដៃទាំងពីរ"** សេចក្តីថា (អ្នកចូរឡើងជិះខ្នងខ្ញុំ) យកដៃទាំងពីរ តោងកខ្ញុំឲ្យល្អ ។ បទថា **វេគសា** **"ដោយពេញកម្លាំង"** សេចក្តីថា ដោយពេញកម្លាំង ។ បទថា **សិរិមតោ** **"មានសិរី"** បានដល់ អ្នក មានបុណ្យ ។ បទថា **អគ្គហឹ** **"ឱបក"** សេចក្តីថា កាលស្តេចពានរ លោតចុះមកកាន់ជ្រោះនរកជម្រៅ ៦០ ហត្ថ ដោយរហ័សដូចខ្យល់ ខ្ញុំព្រះអង្គលោតជិះខ្នងដោយរហ័ស យកដៃទាំងពីរឱប.កជាប់ ។

បទថា **វិហញ្ញមានោ** **"លំបាក"** បានដល់ លំបាក ។ បទថា **កិច្ឆេន** **"ដោយសេចក្តីលំបាក"** ដោយសេចក្តីលំបាក ម្យ៉ាងទៀត

---

បិដក. ១. ពាហាហិ ។

ន័យថា បណ្ឌិតជាសប្បុរស កាលរកឱកាសជួយ ក៏ត្រូវខ្វល់ខ្វាយ ។ បទថា **វេក្ខស្សុ** "**ចូរឃុំគ្រង**" សេចក្តីថា ខ្ញុំជួយដល់អ្នករហូតនឿយ-ហត់ នឹងដេកសម្រាកមួយស្របក់ ដូច្នោះ អ្នកចូររក្សាការផុតភ័យឲ្យខ្ញុំផង ។ បទថា **យថា ចញ្ញេ វនេ មិគា** "**ស្មើនឹងម្រឹគដទៃៗ ក្នុងព្រៃនេះដូចគ្នា**" សេចក្តីថា (ពានរនេះក៏ជាអាហារគួរស៊ីបានរបស់មនុស្ស) ស្មើនឹងពួកពាលម្រឹគក្នុងព្រៃនេះ ក្រៅអំពីសត្វកាចមានរាជសីហ៍ជាដើម ។ តែក្នុងព្រះបាលី លោកសរសេរទុកថា **អច្ឆ-កោ កតរច្ឆយោ**[១] ។

បទថា **បរិត្តាតូន** "**ជួយការពារ**" សេចក្តីថា បពិត្រមហារាជ ព្រោះស្តេចពានរនោះធ្វើខ្ញុំព្រះអង្គជាគ្រឿងការពារខ្លួនយ៉ាងនេះ ខ្ញុំះ យោនិសោមនសិការ ទើបដេកលក់មួយស្របក់ ។ បទថា **ភក្ខោ** "**ជាអាហារ**" សេចក្តីថា គួរដល់ការទំពាស៊ី ។ បទថា **អាសិតោ**

១.បិដក. អច្ឆកោកតរច្ឆយោ ។

*“ឆ្អែតហើយ” សេចក្ដីថា ស៊ីរហូតឆ្អែតហើយ ។ បទថា* ***សម្ពលំ*** *“ជាស្បៀង” បានដល់ ស្បៀង ។*

*បទថា* ***មត្ថកំ សន្និតាឡយំ*** *“គប់សីសៈស្វា” សេចក្ដីថា គប់សីសៈស្ដេចពានរនោះ ។ បាឋៈថា* ***សន្និតាឡយំ*** *ដូច្នេះក៏មាន ។ បទថា* ***ទុព្វលោ អហុ*** *“មានកម្លាំងតិច” សេចក្ដីថា ខ្ញុំព្រះអង្គមិនរង់ចាំមានកម្លាំង ទើបគប់មិនបានខ្លាំងសមតាមបំណង ។ បទថា* ***វេគេន*** *“ដោយកម្លាំង” សេចក្ដីថា ដោយកម្លាំងនៃដុំថ្មដែលខ្ញុំព្រះអង្គគប់ទៅហើយ ។ បទថា* ***ឧទប្បត្តោ*** *“ស្ទុះក្រោកឡើងមក” គឺស្ទុះក្រោកឡើង ។ បទថា* ***មាយ្យោ*** *“នែនាយ... កុំ” សេចក្ដីថា ដុំថ្មដែលបុរសអ្នកប្រទូស្តមិត្តគប់ទៅ បានកាត់ស្បែកក្រៅមុតចុះទៅឈាមក៏ហូរចេញ ។ ព្រះមហាសត្វសោយទុក្ខវេទនា គិតថា ក្នុងទីនេះមិនមានមនុស្សដទៃឡើយ ភ័យនេះត្រូវកើតឡើងព្រោះអាស្រ័យបុរសនេះ ទើបភ័យដល់មរណភ័យ យកដៃទាញស្បែកដែលដាច់នោះ*

លោតឡើងមែកឈើ កាលនឹងចរចាជាមួយបុរសលាមកនោះ ទើបពោលគាថាមានជាអាទិថា **នាយកុំបានធ្វើដូច្នេះឡើយ** ។

បណ្ដាបទទាំងនោះ បទថា **មាយ្យោ មំ ភទ្ទន្តេ**[១] **“កុំធ្វើដល់ខ្ញុំឡើយ សូមអ្នកចូរមានសេចក្ដីចម្រើន”** សេចក្ដីថា ស្ដេចពានរហាមព្រាហ្មណ៍នោះថា “អ្នកដ៏ចម្រើន កុំធ្វើយ៉ាងនេះដល់ខ្ញុំឡើយ” ។ បទថា **តវញ្ច នាម**[២] **“តែអ្នក”** សេចក្ដីថា អ្នកដែលខ្ញុំជួយឲ្យឡើងមកអំពីជ្រោះដូច្នេះហើយ នៅធ្វើកម្មអាក្រក់ចំពោះខ្ញុំបែបនេះ គួរអាសូរណាស់ អ្នកធ្វើកម្មមិនសមគួរឡើយ ។ បទថា **អហោ វត “គួរឲ្យអាសូរ”** សេចក្ដីថា ស្ដេចពានរកាលនឹងតិះដៀលព្រាហ្មណ៍នោះ ទើបពោលយ៉ាងនេះ ។ បទថា **តាវ ទុក្ករការកា**[៣] **“អើហ្ន៎ នៃបុរសចង្រៃ អ្នកធ្វើកម្មដ៏អាក្រក់ដល់ម្ល៉េះបាន”** សេចក្ដីថា នែបុរសអធម៌ អ្នកធ្វើកម្មដ៏អាក្រក់ទៅបាន ព្រោះធ្វើខុសក្នុងយើង ។

---

បិដក. ១. មាយ្យោ មំ ករិ ភទ្ទន្តេ ។ ២. ត្វញ្ច នាមេទិសំ ។ ៣. តាវ ទុក្ករការក ។

បទថា **បរលោកាវ** “ចាកបរលោក” សេចក្ដីថា អ្នកដូចដែលយើងនាំមកអំពីបរលោក ។ បទថា **ទុព្ភេយ្យំ** “គួរនឹងសម្លាប់” (គួរយល់ខ្លួនយើងថា) គួរប្រទូស្ត គឺ គួរសម្លាប់ ។

បទថា **វេទនំ កដុកំ** “វេទនាដ៏ក្ដៅផ្សា” សេចក្ដីថា សូម្បីដូច្នេះអ្នកជាបុគ្គលមិនមានធម៌ យើងត្រូវជួបនឹងទុក្ខវេទនាយ៉ាងណា វេទនាដ៏ក្ដៅផ្សាដូច្នេះ ចូរកុំប៉ះពាល់អ្នក បាបកម្មនោះកុំសម្លាប់អ្នកដូចផ្លែឫស្សីសម្លាប់ដើមឡើយ ។ បពិត្រមហារាជ ស្ដេចពានរនោះអាណិតខ្ញុំព្រះអង្គដូចបុត្តពៅជាទីស្រឡាញ់ ដោយប្រការដូច្នេះ ។ គ្រានោះ ខ្ញុំព្រះអង្គពោលពាក្យនេះនឹងស្ដេចពានរថា “បពិត្រនាយ អ្នកកុំធ្វើវត្ថុដែលខ្ញុំធ្វើឡើយ អ្នកកុំធ្វើឲ្យខ្ញុំជាអសប្បុរសបានវិនាសនៅក្នុងព្រៃបែបនេះឡើយ ខ្ញុំវង្វេងទិសមិនដឹងផ្លូវ សូមកុំញ៉ាំងកុសលកម្មដែលខ្លួនធ្វើហើយឲ្យវិនាស ប្រោសឲ្យជីវិតជាទានដល់ខ្ញុំចុះ ជួយនាំខ្ញុំចេញចាកព្រៃទៅកាន់ដែនដីមនុស្សផង” ។ កាលខ្ញុំព្រះអង្គ

ពោលយ៉ាងនេះហើយ ស្តេចពានរនោះកាលនឹងចរចាប្រាស្រ័យជាមួយខ្ញុំ ទើបពោលគាថាមានពាក្យថា **តយិ មេ នត្ថិ វិសាសោ**[១] "**សេចក្តីស្និទ្ធស្នាលរបស់ខ្ញុំមិនមានក្នុងអ្នកឡើយ**" ដូច្នេះជាដើម ។ បទថា **តត្ថ តយិ** "**ក្នុងអ្នក**" សេចក្តីថា រាប់តាំងអំពីថ្ងៃនេះ យើងនិងអ្នកមិនមានសេចក្តីស្និទ្ធស្នាលគ្នាទេ ។ បទថា **ឯហិ** "**មកចុះ**" សេចក្តីថា នែបុរសដ៏ចម្រើន យើងមិនដើរផ្លូវទៅជាមួយអ្នក តែអ្នកចូរមកចុះ អ្នកចូរដើរទៅល្មមនឹងឃើញខ្នងរបស់យើង យើងនឹងដើរទៅតាមចុងឈើប៉ុណ្ណោះ ។ បទថា **មុត្តោសិ** "**អ្នកចេញផុត**" សេចក្តីថា បពិត្រមហារាជ លំដាប់នោះ ស្តេចពានរបាននាំខ្ញុំព្រះអង្គចេញចាកព្រៃ ហើយពោលថា "នែបុរសដ៏ចម្រើន អ្នកផុតអំពីកណ្តាប់ដៃសត្វសាហាវហើយ" ។

បទថា **មានុសី បទំ** "**ផ្លូវដើររបស់មនុស្ស**" សេចក្តីថា ស្តេច

---

១.បិដក. តយិ មេ នត្ថិ វិស្សាសោ ។

ពានរពោលថា “អ្នកបានដល់ គឺ មកដល់ដែនដីដែលជាឧបចារៈរបស់មនុស្សហើយ អ្នកចូរទៅតាមផ្លូវនេះចុះ” ។ បទថា **គិរិចរោ** “**ស្តេចពានរ**” បានដល់ ពានរមានប្រក្រតីត្រាច់ទៅតាមញកភ្នំ ។ បទថា **បក្ខន្ទយ**(១) “**ជួត**” បានដល់ លាងហើយ ។ បទថា **តេ-នាភិសត្តោស្មិ** “**ជាអ្នកដែលពានរនោះអនុគ្រោះហើយ**” សេចក្តីថា បពិត្រមហារាជ ខ្ញុំព្រះអង្គនោះជាអ្នកដែលស្តេចពានរនោះសង្គ្រោះហើយ កាលបាបកម្មនោះទុំជោរហើយ ក៏សម្គាល់ថា “យើងដែលស្តេចពានរអនុគ្រោះហើយ ទើបពោលយ៉ាងនេះ” ។ បទថា **អទ្ទិ-តោ**(២) “**បៀតបៀន**” សេចក្តីថា ត្រូវសេចក្តីខ្វល់ខ្វាយបៀតបៀនហើយ ។ បទថា **ឧបាគមឹ** “**បានចុះទៅ**” សេចក្តីថា ខ្ញុំព្រះអង្គចូលទៅកាន់អន្លង់ទឹកមួយកន្លែង ។ បទថា **សមបជ្ជថ** “**ប្រាកដ**” មានន័យថា វត្ថុគ្រប់យ៉ាងកើតប្រាកដដល់ខ្ញុំព្រះអង្គបែបនេះ ។ បទថា

---

បិដក. ១. បក្ខល្យ ។ ២. អដ្ដិតោ ។

**យាវន្តោ** “មានប្រមាណប៉ុនណា” សេចក្តីថា មានប្រមាណប៉ុនណា ។

បទថា **គណ្ឌុ ជាយេថ** “បូសក៏ផុសឡើង” សេចក្តីថា បូសក៏ផុសឡើង (មានប្រមាណប៉ុណ្ណោះ) ។ បានឮថា មនុស្សប្រេតនោះ កាលមិនអាចនឹងអត់ទ្រាំសេចក្តីស្រេកឃ្លានបាន ទើបយកដៃក្បង់ទឹកផឹកបន្តិច ហើយស្រោចទឹកដាក់ក្បាល ។ រំពេចនោះឯងបូសខ្នាតប៉ុនចំហៀងផ្លែព្នៅទុំ ក៏ផុសឡើងតាមចំនួនតំណក់ទឹក ព្រោះហេតុនោះ គេទើបពោលយ៉ាងនោះ ។ បទថា **បភិន្នា** “បែក” គឺបូសទាំងនោះក៏បែកក្នុងថ្ងៃនោះឯង ខ្ទុះ និងឈាម ក៏ហូរចេញមកមានក្លិនស្អុយដូចសាកសព ។ បទថា **យេន** “ណា” សេចក្តីថា (ខ្ញុំព្រះអង្គ នឹងដើរទៅ) ផ្លូវណាៗ ។ បទថា **ឧកិត្តា**[១] “**ផ្សាយទៅ**” សេចក្តីថា ផ្សាយទៅដោយក្លិនស្អុយ គឺ មានក្លិនស្អុយផ្សាយជុំវិញខ្លួន ។ បទថា **មាស្សុ ឱរេន អាគមា** “កុំចូលមកខាងនេះ” សេចក្តី

---

១.បិដក. ឧក្កិតា ។

ថា ពួកមនុស្សទាំងឡាយ ខ្ញុំះកាន់ដំបងរារាំងខ្ញុំព្រះអង្គថា នែសត្វ ស្មោកគ្រោក ចេញទៅឲ្យឆ្ងាយ កុំចូលជិតយើង គឺ កុំចូលមកជិត ពួកយើង ។ បទថា **សត្តវស្សានិ ទានិ មេ** “ឥឡូវនេះខ្ញុំព្រះអង្គ... **នៅអស់ ៧ ឆ្នាំ**” សេចក្តីថា ព្រាហ្មណ៍ក្រាបទូលថា “មហាបពិត្រ រាប់តាំងអំពីថ្ងៃនោះមកដល់ឥឡូវនេះ ជាវេលា ៧ ឆ្នាំ ខ្ញុំព្រះអង្គ ត្រូវសោយកម្មរបស់ខ្លួនអស់កាលមានប្រមាណប៉ុណ្ណេះ គ្រាមនុស្ស ប្រេតនោះពណ៌នានូវកម្ម គឺ ការប្រទូស្តមិត្តរបស់ខ្លួនដោយពិស្តារ ហើយ ទើបទូលថា “បពិត្រមហារាជ នរណាៗ ឃើញខ្ញុំព្រះអង្គជា ឧទាហរណ៍ហើយ មិនគួរធ្វើកម្មបែបនេះឡើយ” ហើយពោលគាថា មានជាអាទិថា **តំ វោ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **តំ** ស្មើនឹង **តស្មា** ប្រែថា ព្រោះហេតុនោះ ។ អធិប្បាយថា ព្រោះ ហេតុនៃកម្មបែបនេះ មានទុក្ខជាវិបាកយ៉ាងនេះ ។

ព្រះសាស្តាត្រាស់អភិសម្ពុទ្ធគាថានេះទុកថា

កុដ្ឋី កិលាសី ភវតិ យោ មិត្តានីធ ទុព្ភតិ
កាយស្ស ភេទា មិត្តទុព្ភី និរយំ សោ ឧបបជ្ជតីតិ ។

ក្នុងលោកនេះ អ្នកប្រទូស្តមិត្តរមែងកើតរោគឃ្លង់ រោគស្រែង
កាលស្លាប់ទៅ រមែងចូលដល់នរក ។

អធិប្បាយថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលណាប្រទូសរ៉ាយ បៀតបៀនមិត្តក្នុងលោកនេះ បុគ្គលនោះរមែងមានសភាពបែបនេះ" ។

កាលបុរសនោះកំពុងក្រាបទូលព្រះរាជា ផែនដីក៏បានបើកនូវចន្លោះ ។ គេក៏ចុតិទៅកើតក្នុងអវិចីនរកក្នុងខណៈនោះឯង ។ កាលបុរសនោះត្រូវផែនដីស្រូបហើយ ព្រះរាជាក៏ចេញចាកព្រះរាជឧទ្យាន ស្តេចយាងទៅកាន់ព្រះនគរ ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងពេលនេះប៉ុណ្ណោះទេ សូម្បីក្នុងជាតិមុន ទេវទត្តក៏ប្រមៀលថ្មប្រទូស្តជាមួយតថាគត

ដូចគ្នា" ហើយទ្រង់ប្រជុំជាតកថា "បុរសដែលប្រទូស្តមិត្តក្នុងកាល

នោះ បានមកជាទេវទត្ត ស្តេចពានរក្នុងកាលនោះ គឺ **តថាគត** នេះ

ឯង" ។

## ចប់អដ្ឋកថា មហាកបិជាតកទី ៦

# អដ្ឋកថា ឧករក្ខសជាតកទី ៧

## (រឿងអារក្សទឹក)

[៥០១-៥១៥]

*សចេ វោ វុឃ្ឍមានានំ សត្តន្នំ ឧទកណ្ណវេ...*

*ទករក្ខសជាតក មានពាក្យផ្ដើមថា សចេ វោ វុឃ្ឍមានំ[១] "ប្រសិនបើ... សូមព្រះអង្គ... ទូករសាត់ទៅ (ក្នុងសមុទ្រ)" ដូច្នេះ ទាំងអស់នេះនឹងមានច្បាស់ក្នុងមហាឧម្មគ្គជាតកហើយ ។*

ចប់អដ្ឋកថា ឧករក្ខសជាតកទី ៧

---

១.បិដក. *វុឃ្ឍមានានំ ។*

# អដ្ឋកថា បណ្ណកជាតកទី ៨

## (រឿងមិនគួរប្រាប់សេចក្តីកំចាំងដល់អ្នកដទៃ)

*ព្រះសាស្តាកាលស្តេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់ប្រារព្ធកាលព្រះទេវទត្តធ្វើមុសាវាទ ហើយត្រូវផែនដីស្រូប ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **វិកិណ្ណវាចំ "សម្ពិល្លហាច"** ដូច្នេះ ។*

*សេចក្តីសង្ខេបថា កាលភិក្ខុនាំគ្នាពោលនូវទោសព្រះទេវទត្តក្នុងគ្រានោះព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនតែក្នុងកាលនេះទេ សូម្បីក្នុងជាតិមុនទេវទត្តក៏ធ្វើមុសាវាទ ត្រូវផែនដីស្រូបដូចគ្នា" ហើយទ្រង់ក៏នាំអតីតនិទានមកត្រាស់ ដូចតទៅនេះ ។*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជ្យសម្បត្តិក្នុងព្រះនគរពារាណសី ឈ្មួញ ៥០០ នាក់ បើកសំពៅទៅកាន់មហាសមុទ្ទ ក្នុងថ្ងៃគម្រប់ ៧ សំពៅដែលនៅក្នុងទីមិនឃើញកោះត្រើយ*

បានបែកក្នុងកណ្ដាលមហាសមុទ្ទ ពួកមនុស្សក៏បានជាចំណីត្រី និង អណ្ដើក សល់តែមនុស្សម្នាក់ ។ ក៏បុរសដែលសល់ម្នាក់នោះ ត្រូវកម្លាំងខ្យល់បក់អណ្ដែតទៅដល់កំពង់ទឹកឈ្មោះ **កទម្ពិយៈ** ។ គេឡើងអំពីសមុទ្ទបានហើយ មានកាយអាក្រាតដើរសូមទានតាមកំពង់ទឹកនោះ ។ មនុស្សទាំងឡាយឃើញគេ ក៏នាំគ្នាសរសើរថា "លោកនេះជាសមណៈ ប្រាថ្នាតិច សន្ដោស" ហើយធ្វើសក្ការៈបូជា ។ គេគិតថា យើងបានផ្លូវចិញ្ចឹមជីវិតហើយ ។ សូម្បីកាលជនទាំងនោះឲ្យសំពត់ស្លៀកដណ្ដប់ ក៏មិនប្រាថ្នា ។ ជនទាំងនោះទើបយល់ថា "សមណៈអ្នកប្រាថ្នាតិចក្រៃលែងជាងបុគ្គលនេះ មិនមាន" ទើបនាំគ្នាជ្រះថ្លាក្រៃលែងឡើង ជួយគ្នាសាងអាស្រមបទឲ្យជនអាក្រាតនោះស្នាក់អាស្រ័យនៅទីនោះ ។ គេមានឈ្មោះប្រាកដថា "**កទម្ពិយអចេលក**" កាលគេនៅក្នុងទីនោះ លាភសក្ការៈកើតឡើងយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

ស្តេចនាគរាជមួយ និងស្តេចគ្រុឌមួយ នាំគ្នាមកកាន់ទីបម្រើរបស់ជីអាក្រាតនោះ ក្នុងស្តេចសត្វទាំងពីរនោះ ស្តេចនាគឈ្មោះថា បណ្ឌរកនាគរាជ ។ តមកថ្ងៃមួយ ស្តេចគ្រុឌទៅកាន់សម្នាក់អចេលកៈនោះ សំពះហើយបានទំនៅត្រង់ទីមួយ ពោលយ៉ាងនេះថា "លោកម្ចាស់ ញាតិរបស់ខ្ញុំ កាលចាប់ពួកនាគក៏វិនាសទៅច្រើនណាស់ ព្រោះពួកខ្ញុំមិនដឹងវិធីចាប់នាគទាំងនោះ ។ បានឮថា ហេតុលាក់ខ្លួនរបស់ពួកនាគទាំងនោះមាន តើលោកនឹងអាចឬហ្ន៎ ដើម្បីលួងលោមសួរហេតុនោះនឹងពួកនាគ" ។ ជីអាក្រាតនោះទទួលពាក្យគ្រាស្តេចគ្រុឌសំពះហើយលាត្រឡប់ទៅ ស្តេចនាគក៏បានមក ទើបសួរស្តេចនាគដែលសំពះហើយអង្គុយនោះថា "ស្តេចនាគអើយ គេថា កាលពួកគ្រុឌចាប់ពួកអ្នកក៏ត្រូវវិនាសច្រើនណាស់ ហេតុអ្វីកាលពួកគ្រុឌចាប់ពួកអ្នក ទើបមិនអាចចាប់បាន" ស្តេចនាគបានតបថា "លោកម្ចាស់ ប្រការនេះ ជាសេចក្តីកំបាំងដែលត្រូវលាក់របស់ពួក

ខ្ញុំ កាលខ្ញុំប្រាប់ហេតុនេះហើយ រមែងបានឈ្មោះថា នាំសេចក្តីស្លាប់មកឲ្យដល់ញាតិ” ។ អចេលកៈទើបនិយាយថា “អាវុសោ ក៏អ្នកយល់ថា មនុស្សដូចជាយើងនេះ នឹងប្រាប់ដល់អ្នកដទៃយ៉ាងនេះឬ យើងនឹងមិនប្រាប់ដល់ជនដទៃឡើយ ក៏យើងសួរដោយខ្លួនចង់ដឹងប៉ុណ្ណោះ អ្នកជឿយើងហើយក៏នឹងរួចចាកភ័យ ចូរប្រាប់ចុះ” ។ ឯស្តេចនាគតបថា “លោកម្ចាស់ ខ្ញុំប្រាប់មិនបាន” សំពះហើយក៏លាចេញទៅ ។ លុះរាត្រីកន្លងទៅ ថ្ងៃស្អែកឡើងអចេលកៈក៏សួរទៀត ។ សួរយ៉ាងនោះ ស្តេចនាគក៏មិនព្រមប្រាប់ដូចដើម ។ ក្រោយមកថ្ងៃទី ៣ ជីអាក្រាតទើបសួរស្តេចនាគដែលមកអង្គុយថា “នេះជាថ្ងៃទី ៣ កាលយើងសួរហេតុអ្វីទើបអ្នកមិនប្រាប់” ។ ស្តេចនាគតបថា “លោកម្ចាស់ ព្រោះថាខ្ញុំខ្លាច “លោកប្រាប់ដល់អ្នកដទៃ” ។ ជីអាក្រាតក៏ពោលដដែលថា “យើងមិនប្រាប់នរណាទេ អ្នកនឹងរួចចាកភ័យដោយពិត ចូរប្រាប់មកចុះ” ។ ស្តេចនាគទើបពោលថា “លោកម្ចាស់ បើ

ដូច្នោះ លោកកុំប្រាប់អ្នកដទៃឡើយ" ។ ទទួលបណ្ដាហើយ ទើបប្រាប់ថា "លោកម្ចាស់ ពួកខ្ញុំលេបដុំថ្មធំៗ ចូល ធ្វើខ្លួនឲ្យធ្ងន់ហើយដេក ក្នុងវេលាពួកគ្រុឌមក ក៏ងើបក្បាលបញ្ចេញចង្កូមវង់ចាំត្របាក់គ្រុឌ ពួកគ្រុឌសូម្បីនឹងចាប់សីសៈរបស់ពួកខ្ញុំ កាលពួកវាព្យាយាមនឹងឆាបយកពួកខ្ញុំដែលមានខ្លួនដ៏ធ្ងន់ឡើង ទឹកក៏លិចវា ពួកគ្រុឌក៏ស្លាប់ក្នុងទឹកនោះឯង ព្រោះហេតុនេះ ពួកគ្រុឌទើបវិនាសទៅអស់ចំនួនច្រើន កាលពួកគ្រុឌនឹងចាប់ពួកខ្ញុំ ហេតុអ្វីត្រូវចាប់ត្រង់សីសៈ ពួកគ្រុឌល្ងង់ៗ នឹងត្រូវចាប់ត្រង់កន្ទុយ ធ្វើឲ្យពួកខ្ញុំមានសីសៈចុះក្រោម ឲ្យខ្ជាក់អាហារដែលលេបចេញតាមមាត់ ធ្វើខ្លួនឲ្យស្រាលហើយទើបអាចចាប់បាន" ។ ស្ដេចនាគប្រាប់ហេតុសម្ងាត់របស់ខ្លួនដល់អចេលកៈអ្នកទ្រុស្តសីល ដោយប្រការដូច្នេះ ។

គ្រាស្ដេចនាគលាត្រឡប់ទៅហើយ តមកស្ដេចគ្រុឌក៏មកសំពះកទម្ពិយអចេលកៈ ហើយសួរថា "លោកម្ចាស់ លោកសួរនូវហេតុ

សម្ងាត់របស់ស្តេចនាគហើយឬ” ។ អចេលកៈតបថា “អើអារុសោ” ហើយប្រាប់តាមសេចក្តីដែលស្តេចនាគបានប្រាប់ដល់ស្តេចគ្រុឌ គ្រប់ប្រការ ស្តេចគ្រុឌបានស្តាប់ដូច្នោះទើបគិតថា ស្តេចនាគធ្វើកម្មដែលមិនសមគួរហើយ ធម្មតាផ្លូវដែលនឹងឲ្យពួកញាតិវិនាស មិនគួរប្រាប់ដល់អ្នកដទៃឡើយ ថ្ងៃនេះគួរយើងនឹងធ្វើខ្យល់ឲ្យគួចវិលដោយកម្លាំងនៃគ្រុឌ ចាប់បណ្ឌរកនាគរាជនេះជាមុន ។ ស្តេចគ្រុឌនោះក៏ធ្វើខ្យល់ឲ្យគួចវិលដោយកម្លាំងគ្រុឌ ចាប់បណ្ឌរកនាគរាជត្រង់កន្ទុយ ធ្វើឲ្យមានសីសៈសំយុងចុះក្រោម ធ្វើឲ្យខ្ជាក់អាហារដែលលេបចូលទៅហើយស្ទុះហើរឡើងទៅក្នុងអាកាស ។ បណ្ឌរកនាគរាជកាលត្រូវសំយុងក្បាលចុះក្នុងអាកាស ក៏បរិទេវនាការថា “យើងនាំទុក្ខឲ្យដល់ខ្លួនឯងពិតៗ” ហើយបានពោលនូវគាថាថា

[៥១៦] វិកិណ្ណវាចំ អនិគុយ្ហមន្តំ
អសញ្ញាតំ អបរិចក្ខិតារំ[១]

១.ម. អបរិរក្ខិតារំ ។

ភយន្តមេន្វេតិ សយំ អពោធំ

នាគំ យថា បណ្ណរកំ សុបណ្ណា ។

ភ័យកើតអំពីខ្លួនឯង រមែងតាមជាប់បុគ្គលដែលគ្មានបញ្ញា និយាយពេយពាយ មិនបិទបាំងការដឹង ខ្វះការប្រយ័ត្ន ខ្វះការពិនិត្យពិចារណា ដូចគ្រុឌតាមជាប់យើងជាបណ្ណរកនាគ-រាជ ដូច្នោះ ។

យោ គុយ្ហមន្តំ បរិរក្ខនេយ្យំ

មោហោ នរោ សំសតិ ហាសមានោ

តំ ភិន្នមន្តំ ភយមន្វេតិ ខិប្បំ

នាគំ យថា បណ្ណរកំ សុបណ្ណា ។

នរជនណាត្រេកអរប្រាប់មន្តកំបាំងដែលខ្លួនគួររក្សា ដល់បុគ្គលអាក្រក់ ព្រោះសេចក្តីវង្វេង ភ័យរមែងជាប់តាមនរជនដែលបង្ហើបប្រាប់នូវមន្តនោះឯងដោយឆាប់ ដូចគ្រុឌជាប់តាមយើង

ជាបណ្ឌរកនាគរាជ ដូច្នោះ ។

នានុមិត្តោ  គរុំ  អត្ថំ   គុយ្ហំ  វេទិតុមរហតិ

សុមិត្តោ  ច  អសម្ពុទ្ធំ   សម្ពុទ្ធំ  វា  អនត្ថវា  ។

មិត្តប្រមមិនគួរនឹងឲ្យដឹងនូវហេតុសំខាន់ដែលកំបាំង សូម្បីមិត្ត

ពិតតែជាបុគ្គលល្ងង់ ឬមានបញ្ញាតែប្រព្រឹត្តនូវវត្ថុមិនមែនជា

ប្រយោជន៍ ក៏មិនគួរឲ្យដឹងសេចក្តីកំបាំងដូចគ្នា ។

វិស្សាសមាបជ្ជិមហំ   អចេលំ

សមណោ អយំ សម្មតោ ភាវិតត្តោ

តស្សាហមក្ខឹ  វិវរិំ  គុយ្ហមត្ថំ

អតីតមត្ថោ  កបណំ  រុទាមិ  ។

យើងបានស្និទ្ធស្នាលជាមួយជីអាក្រាត ដោយយល់ថាសមណៈ

នេះគេរាប់អាន មានខ្លួនអប់រំល្អហើយ បានបង្ហើបប្រាប់ការ

សម្ងាត់ដល់វា ទើបបានកន្លងនូវប្រយោជន៍ ស្រែកយំដូចជា

ជនកំព្រា ដូច្នោះ ។

តស្សាហំ បរមំ ព្រហ្ម គុយ្ហំ
វាចញ្ហិមំ នាសក្ខឹ សំយមេតុំ
តប្បក្ខតោ ហិ ភយមាគតំ មម
អតីតមត្ថោ កបណំ រុទាមិ ។

ស្តេចគ្រុឌដ៏ប្រសើរ កាលមុនយើងមានវាចាកំបាំង មិនប្រាប់សេចក្តីកំបាំងដល់វា តែក៏មិនបានប្រយ័ត្ន ពិតហើយ ភ័យបានមកដល់យើងអំពីផ្លូវនោះ យើងទើបបានកន្លងនូវប្រយោជន៍ ស្រែកយំដូចជនកំព្រាដូច្នោះ ។

យោ វេ នរោ សុហទំ មញ្ញមានោ
គុយ្ហមត្ថំ សំសតិ ទុក្កុលីនេ
ទោសា ភយា អថវា រាគរត្តោ
បល្លត្ថិតោ ពាលោ អសំសយំ សោ ។

នរជនណាសម្គាល់ថា ជននេះចិត្តល្អ ប្រាប់សេចក្ដីកំបាំងនឹងជនត្រកូលថោកទាប នរជននោះជាបុគ្គលល្ងង់ខ្លៅទ្រុឌទ្រោមចុះដោយឥតសង្ស័យ ព្រោះទោសាគតិ ភយាគតិ ឬព្រោះឆន្ទាគតិ ។

តិរោក្ខវាចោ អសតំ បវិដ្ឋោ
យោ សង្គតីសុ មុទិរេតិ វាក្យំ
អាសីវិសោ ទុម្មុខោត្យាហុ តំ នរំ
អារា អារា សំយមេ តាទិសម្ហា ។

ជនណាមាត់របិញរបុញរាប់ចូលក្នុងអសប្បុរស ពេញចិត្តពោលពាក្យក្នុងទីប្រជុំជន អ្នកប្រាជ្ញទាំងឡាយហៅជននោះថា អ្នកមានមាត់អាក្រក់ស្រដៀងអសិរពិស (យើង) គួរប្រយ័ត្នក្នុងបុគ្គលដូច្នោះ គេចចេញឲ្យឆ្ងាយ ។

អន្នំ បានំ កាសិកចន្ទនញ្ច

មនាបិត្ថិយោ មាលមុច្ឆាទនញ្ច

ឱហាយ គច្ឆាមសេ សព្វកាមេ

សុបណ្ណ បាណូបគតាវ ត្យាម្ហា ។

យើងបានលះបង់បាយទឹក សំពត់ដែនកាសី និងលម្អិតខ្លឹម-
ចន្ទន៍ ស្ត្រីដែលចម្រើនចិត្ត ផ្កាកម្រង និងគ្រឿងប្រោះព្រំ
ដែលជាចំណែកកាមារម្មណ៍ទាំងពួងទៅអស់ហើយ ស្តេចគ្រុឌ
យើងសូមដល់លោកជាសរណៈដោយជីវិត ។

បណ្តាបទទាំងនោះ បទថា វិកិណ្ណវាចំ "វាចាល្ហល្ហាច" បាន
ដល់ អ្នកមានវាចាផ្សាយទៅហើយ ។ បទថា អនិគ្គយ្ហមន្តំ "មិន
បិទបាំងការដឹង" បានដល់ អ្នកមានការដឹងមិនលាក់បាំង ។ បទថា
អសញ្ញតំ[១] "ខ្វះការប្រុងប្រយ័ត្ន" បានដល់ អ្នកមិនអាចនឹងរក្សា
កាយទ្វារជាដើមបាន ។ បទថា អបរិចក្ខិតារំ "ខ្វះការពិនិត្យពិចា-

---

១.បិដក. អសញ្ញាតំ ។

វណា" សេចក្ដីថា អ្នកមិនអាចនឹងត្រួតត្រាពិចារណាមើលថា ជននេះនឹងអាច ឬនឹងមិនអាចនឹងរក្សាមន្តដែលយើងប្រាប់ហើយ ។ បទថា **ភយំ តមន្វេតិ** "**ភ័យរមែងជាប់តាម... នោះ**" សេចក្ដីថា ជនអ្នកប្រកបដោយអង្គ ៤ នេះ ។ បទថា **អពោធំ** "**គ្មានបញ្ញា**" គឺភ័យដែលខ្លួនឯងនោះឯងធ្វើ រមែងតាមជាប់ជនដែលឥតបញ្ញា ដូចស្ដេចគ្រុឌតាមជាប់យើងដែលឈ្មោះថា បណ្ឌរកនាគរាជដូច្នោះ ។ បទថា **សំសតិ ហាសមានោ** "**ប្រាប់មន្តដែលកំបាំង**" សេចក្ដីថា ជនណាត្រេកអរប្រាប់នូវមន្តដ៏កំបាំងដែលខ្លួនគួររក្សា ដល់មនុស្សអាក្រក់ដែលមិនអាចរក្សាបាន ។ បទថា **នានុមិត្តោ** "**មិត្តប្ងម**" គឺស្ដេចបណ្ឌរកនាគរាជបរិទេវនាការថា "ជនណាជាមិត្តប្ងម រង់ចាំតែបណ្ដោយតាម មិនមែនជាមិត្តស្មើចិត្ត ជននោះមិនគួរប្រាប់នូវរឿងដែលកំបាំងឡើយ ។

បទថា **អសម្ពុទ្ធំ** "**ជាបុគ្គលល្ងង់**" សេចក្ដីថា ជាមនុស្សល្ងង់

គឺ មិនចេះដឹង អធិប្បាយថា មិនមានបញ្ញា ។ បទថា **សម្ពុទ្ធំ** "មានបញ្ញា" សេចក្តីថា ជាមនុស្សឈ្លាសវៃ គឺ ចេះដឹង អធិប្បាយថា មានបញ្ញា ។ មានពាក្យអធិប្បាយដូច្នេះ សូម្បីជនណាជាមិត្ត មានចិត្តល្អ តែមិនមានបញ្ញាក្តី និងជនណាសូម្បីមានបញ្ញា តែមានការប្រព្រឹត្តក្នុងវត្ថុមិនជាប្រយោជន៍ក្តី គឺ មានការប្រព្រឹត្តក្នុងទីឯណោះជាអនត្ថៈ ជនសូម្បីទាំងនោះរមែងមិនគួរឲ្យដឹងសេចក្តីកំបាំងឡើយ ។ បទថា **សមណោ អយំ** "សមណៈនេះ" សេចក្តីថា ស្តេចនាគនោះបរិទេវនាការថា យើងសម្គាល់ថា "បុគ្គលនេះជាសមណៈ ដោយគេលើកសរសើររាប់អានផង មានខ្លួនដែលអប់រំហើយផង ទើបដល់នូវសេចក្តីស្និទ្ធស្នាលជាមួយវា" ។ បទថា **អក្ខឺ** "បានប្រាប់" បានដល់ ប្រាប់ហើយ ។ បទថា **អតីតមត្ថោ** "កន្លងនូវប្រយោជន៍" សេចក្តីថា ឥឡូវនេះ យើងខាតប្រយោជន៍ហើយ គឺ ជាអ្នកកន្លងនូវប្រយោជន៍ហើយ ត្រូវស្រែកយំ ដូចជនកំព្រា ។ បទថា **តស្ស**

**“ដល់វា”** សេចក្តីថា ដល់អចេលក៍នោះ ។

ស្តេចនាគហៅស្តេចគ្រុឌថា “ព្រហ្ម” ស្តេចគ្រុឌដ៏ប្រសើរ ។

បទថា ***សំយមេតុំ*** “ប្រយ័ត្ន” សេចក្តីថា យើងមិនអាចនឹងរក្សាវាចាដែលកំបាំង គឺ ហេតុជាសម្ងាត់នេះបាន ។ បទថា ***តប្ប-ក្ខតោ ហិ*** “ដែលពិត... **ពីផ្លូវអចេលក៍នោះ**” សេចក្តីថា ស្តេចនាគបរិទេវនាការថា “ពេលនេះ ភ័យមកដល់យើងហើយ អំពីផ្លូវ គឺ អំពីសម្នាក់របស់អចេលក៍នោះ យើងខូចប្រយោជន៍ហើយ ត្រូវយំដូចមនុស្សកំព្រាដូច្នេះ” ។ បទថា ***សុហទំ*** **“មានចិត្តល្អ”** សេចក្តីថា ជនណាសម្គាល់ថា បុគ្គលនេះមានបំណងល្អដល់យើង ។ បទថា ***ទុក្កុលីនេ*** **“ត្រកូលថោកទាប”** បានដល់ អ្នកកើតក្នុងត្រកូលអាក្រក់ គឺ ត្រកូលថោកទាប ។ បទថា ***ទោសា*** **“ទោសគតិ”** សេចក្តីថា ជនណាប្រាប់សេចក្តីកំបាំងបែបនេះ ព្រោះហេតុទោសាគតិជាដើម នេះ ជននោះជាបុគ្គលល្ងង់ ថោកទាប ធ្លាក់ទៅក្នុងសភាពថោកទាប

ឈ្មោះថា វិនាសហើយដោយពិតដោយឥតសង្ស័យ ។ បទថា **តិ-រោក្ខវាចោ** "វាចាចេញក្រៅ" ជនណាឈ្មោះថា មានវាចាមិនបិទបាំង ព្រោះធ្វើពាក្យដែលខ្លួនបំណងនឹងនិយាយទុកខាងក្រៅ បទថា **អសតំ បវិដ្ឋោ** "រាប់ចូលក្នុងពួកអសប្បុរស" សេចក្ដីថា រាប់ចូលក្នុងចំនួនអសប្បុរស គឺ រាប់បញ្ចូលក្នុងពួកអសប្បុរស ។

បទថា **សង្គតីសុ មុទិរេតិ** "ពេញចិត្តនិយាយក្នុងទីប្រជុំជន" សេចក្ដីថា ជនណាមានលក្ខណៈយ៉ាងនេះ គឺ បានឮសេចក្ដីកំបាំងរបស់ជនដទៃហើយ ក៏ផ្សព្វផ្សាយក្នុងកណ្ដាលប្រជុំជនថា "វត្ថុឯណោះជនឯណោះធ្វើ ពាក្យនេះជនឯណោះនិយាយ" អ្នកប្រាជ្ញហៅបុគ្គលដូច្នោះថា "មានមាត់អាក្រក់ មានមាត់ស្អុយដូចអសិរពិស គួរប្រុងប្រយ័ត្នអំពីចម្ងាយ គឺ គួរវៀរ គួរគេចពីជននោះចេញអំពីចម្ងាយនោះឯង" ។ បទថា **មាលុច្ឆាទនញ្ច**[1] "ផ្កាកម្រង និងគ្រឿងប្រោះ

---

១.បិដក. មាលមុច្ឆាទនញ្ច ។

ព្រំ” សេចក្តីថា យើងលះបង់ទិព្វមាលា ចតុគន្ធជាតិ និងគ្រឿងប្រោះព្រំ ។ បទថា **ឱហាយ** “លះបង់” សេចក្តីថា ថ្ងៃនេះយើងលះបង់ គឺ លះបង់កាមារម្មណ៍ទាំងអស់ មានបាយទិព្វជាដើមទាំងនេះទៅហើយ ។ បទថា **សុបណ្ណ បាណូបគតាវ ត្យម្ហា** “**ស្តេចគ្រុឌយើងសូមដល់លោកជាសរណៈដោយជីវិត**” សេចក្តីថា ម្នាលស្តេចគ្រុឌដ៏ចម្រើន យើងសូមដល់លោកដោយជីវិត សូមជាទីពឹងដល់ពួកយើងចុះ ។

បណ្ឌរកនាគរាជ មានសីសៈសំយុងចុះក្នុងអាកាស បរិទេវនាការដោយ ៨ គាថាយ៉ាងនេះឯង ។ ស្តេចគ្រុឌបានឮសំឡេងបរិទេវនាការរបស់ស្តេចនាគនោះ ទើបតិះដៀលនាគរាជនោះថា “នែស្តេចនាគ អ្នកប្រាប់សេចក្តីកំបាំងរបស់ខ្លួនដល់អចេលកហើយ ហេតុអ្វីពេលនេះទើបបរិទេវនាការហ្ន៎” ហើយពោលគាថាថា

[៥១៧] នោនីធ តិណ្ណំ គរហំ ឧបេតិ

អស្មិំធ លោកេ បាណភូ នាគរាជ

សមណោ សុបណ្ណោ អថវា ត្វមេវ

កិំការណា បណ្ឌរក គហិតោ ។

បណ្ឌរកនាគរាជ បណ្តាសត្វទាំង ៣ ជំពូក គឺ សមណៈ គ្រុឌ និងនាគ នរណាហ្ន៎គួរនឹងបានទទួលពាក្យតិះដៀលក្នុងលោកនេះ ដែលពិត ខ្លួនអ្នកនោះឯងគួរនឹងបានទទួល អ្នកត្រូវគ្រុឌចាប់ព្រោះហេតុអ្វី ។

បណ្តាបទទាំងនោះ បទថា កោនីធ "នរណា... ក្នុងលោកនេះ" សេចក្តីថា ក្នុងពួកយើងទាំង ៣ មាននៅក្នុងទីនេះ នរណាហ្ន៎ ។ បទថា ឥធ ក្នុងបទថា អស្មិំធ[២] នេះ ជានិបាត សេចក្តីថា ក្នុងលោកនេះ ។ បទថា បាណភូ "សត្វ" បានដល់ សត្វមានជីវិត ។ បទថា អថវា តវេវ[១] "ដែលពិតខ្លួនលោកនោះឯង" សេចក្តីថា ឬលោក

១.បិដក. ត្វមេវ , ២. អស្មិំធ ។

នោះឯង ។

ក្នុងគាថានោះមានអធិប្បាយដូច្នោះ ក្នុងពួកយើងទាំង ៣ កុំទាន់តិះដៀលអចេលក៍ ព្រោះអចេលក៍នោះសួរសេចក្ដីកំបាំងដោយឧបាយ អ្នកកុំតិះដៀលគ្រុឌ ព្រោះយើងជាសត្រូវរបស់អ្នកដោយត្រង់ ។

បទថា **បណ្ឌរក គរហិតោ** "បណ្ឌរកនាគរាជ... ត្រូវគ្រុឌចាប់ព្រោះហេតុអ្វី" សេចក្ដីថា បណ្ឌរកនាគរាជសម្លាញ់ អ្នកគប្បីគិតមើលចុះថា យើងត្រូវគ្រុឌចាប់ព្រោះអ្វី ហើយក៏ត្រូវតិះដៀលខ្លួនតែម្នាក់ឯង ព្រោះកាលអ្នកប្រាប់សេចក្ដីកំបាំង រាប់ថា ខ្លួនឯងបានធ្វើសេចក្ដីវិនាសដល់ខ្លួនឯង ។

បណ្ឌរកនាគរាជបានស្ដាប់ដូច្នោះ ទើបពោលគាថាថា

[៥១៨] **សមណោ ហិ មេ សម្មតត្តោ អហោសិ**

**បិយោ ច មេ មនសា ភាវិតត្តោ**

តស្សាហមក្ខឹ វិវរំ គុយ្ហមត្ថំ

អតីតមត្ថោ កបណំ រុទាមិ ។

អចេលកនោះ ជាអ្នកមានអត្តភាពដែលយើងលើកសរសើរ ថាជាសមណៈ ជាទីស្រឡាញ់របស់យើង ទាំងជាអ្នកដែលយើងលើកសរសើរដោយចិត្តពិត យើងទើបបានប្រាប់សេចក្តីកំបាំងដល់វា យើងជាបុគ្គលខូចប្រយោជន៍ហើយ ត្រូវយំដូចជនកំព្រាដូច្នោះ ។

បណ្តាបទទាំងនោះ បទថា សម្មតត្ថោ "អ្នកមានអត្តភាពដែលយើងលើកសរសើរ" សេចក្តីថា មានសភាពដែលយើងសរសើរថា "អចេលកនេះជាសមណៈ ជាសប្បុរសរបស់យើង" ។ បទថា ភាវិតត្ថោ "សរសើរ" សេចក្តីថា មានសភាពដែលយើងបានសរសើរហើយ ។

លំដាប់នោះ ស្តេចគ្រុឌបានពោល ៤ គាថាថា

[៥១៩] ន ចត្ថិ សត្តោ អមរោ បថព្យា
បញ្ញាវិធា នត្ថិ ន និន្ទិតព្វា
សច្ចេន ច ធម្មេន ធិតិយា ទមេន
អលព្ភមព្យាហរតី នរោ ឥធ ។

ដែលពិត សត្វនឹងមិនស្លាប់មិនមានឡើយក្នុងផែនដី សូម្បីមានបញ្ញា តែមិនគួរតិះដៀល បុគ្គលក្នុងលោកនេះរមែងលុះគុណវិសេសដែលមិនទាន់បានលុះដោយសច្ចៈ ធម្មៈ បញ្ញា និងទមៈ ។

មាតាបិតា បរមា ពន្ធវានំ
នាស្ស តតិយោ អនុកម្បកត្ថិ
តេសម្បិ គុយ្ហំ បរមំ ន សំសេ
មន្តស្ស ភេទំ បរិសង្កមានោ ។

មាតាបិតាជាកំពូលនៃផៅពង្ស ជនទីបី ឈ្មោះថា មានសេចក្តី

អនុគ្រោះដល់បុគ្គលនោះមិនមានឡើយ កាលរង្កៀសថា មន្ត នឹងបែកធ្លាយ ក៏មិនគួរប្រាប់សេចក្តីកំបាំងសំខាន់សូម្បីដល់ មាតាបិតានោះ ។

មាតាបិតា ភគនីភាតរោ ច

សហាយា វា យស្ស ហោន្តិ សបក្ខា

តេសម្បិ គុយ្ហំ បរមំ ន សំសេ

មន្តស្ស ភេទំ បរិសង្កមានោ ។

កាលបុគ្គលរង្កៀសថា មន្តនឹងបែកធ្លាយ ក៏មិនគួរបើកបង្ហាញ សេចក្តីកំបាំងដែលសំខាន់ សូម្បីដល់មាតាបិតា បងប្អូនប្រុស បងប្អូនស្រី ឬដល់សម្លាញ់ ដល់ញាតិចំណែកណាមួយជាមួយ ខ្លួនឡើយ ។

ភរិយា ចេ បុរិសំ វជ្ជា កោមារី បិយភាណិនី

បុត្តរូបយសូបេតា ញាតិសង្ឃបុរក្ខតា

តស្សាបិ គុយ្ហំ បរមំ ន សំសេ

មន្តស្ស ភេទំ បរិសង្កមានោ ។

បើកិរិយានិយាយពីរោះ ដល់ព្រមដោយបុត្តធីតា រូបសម្បត្តិ និងយស ហែហមដោយពួកញាតិ គប្បីអន្វស្វាមីឲ្យប្រាប់សេចក្តីកំបាំង កាលបើរង្កៀសថា មន្តនឹងបែកធ្លាយ ក៏មិនគួរប្រាប់សេចក្តីកំបាំងសំខាន់សូម្បីដល់កិរិយានោះ ។

បណ្តាបទទាំងនោះ បទថា អមរោ "មិនស្លាប់" សេចក្តីថា ដែលឈ្មោះថា សត្វនឹងមិនស្លាប់ មិនមានឡើយ ។ ន អក្សរក្នុងបទថា បញ្ញាវិធា នត្ថិ ជាការភ្ជាប់បទ ។ អធិប្បាយថា ប្រភេទនៃបញ្ញាមានហើយ ។ លោកពោលអធិប្បាយទុកដូច្នេះ (ស្តេចគ្រុឌពោលថា) នាគរាជសូម្បីសត្វដែលនឹងមិនស្លាប់ មិនមានក្នុងលោកឡើយ សូម្បីប្រភេទរបស់បញ្ញាមានពិត តែប្រភេទបញ្ញា ពោលគឺចំណែកនៃបញ្ញារបស់អ្នកដទៃនោះ មិនគួរនិន្ទា ព្រោះហេតុនៃជីវិត

របស់ខ្លួន ។

ម្យ៉ាងទៀត បទថា **បញ្ញាវិធា** "ប្រភេទនៃបញ្ញា" សេចក្ដីថា ធម្មជាតិដទៃដែលឈ្មោះថា មិនគួរនិន្ទាដូចជាបញ្ញាមិនមាន ហេតុអ្វីទើបអ្នកនិន្ទាប្រភេទនៃបញ្ញានោះ ។ បាឋៈថា **យេសំ បន បញ្ញាវិធំបិ ន និន្ទិតព្វំ** ដូច្នេះក៏មាន សេចក្ដីថា ម្យ៉ាងទៀត សូម្បីប្រភេទនៃបញ្ញារបស់ជនពួកណា មិនគួរនិន្ទាប្រភេទនៃបញ្ញារបស់ជនពួកនោះដោយត្រង់នោះឯង ។

ក្នុងបទទាំងឡាយមានជាអាទិថា **សច្ចេន** "ដោយសច្ចៈ" នេះ មានអធិប្បាយថា បុគ្គលក្នុងលោកនេះរមែងប្រមូលមក គឺ នាំមកនូវគុណវិសេស ពោលគឺ សមាបត្តិ ៨ មគ្គផល និងព្រះនិព្វាន ដែលខ្លួនមិនទាន់បាន គឺ បានដោយលំបាក បានដល់ ញុំាងគុណវិសេសនោះឲ្យសម្រេច ដោយវចីសច្ចៈ ១ សុចរិតធម៌ ១ ធិតិ ពោលគឺ បញ្ញា ១ ឥន្ទ្រិយទមៈ ការទូន្មានឥន្ទ្រិយ ១ ព្រោះដូច្នោះ

អ្នកមិនគួរតិះដៀលអចេលក៏ ចូរតិះដៀលខ្លួនឯងតែម្យ៉ាងចុះ ព្រោះអចេលក៏ជាបុគ្គលមានបញ្ញា ជាបុគ្គលឈ្លាសក្នុងឧបាយ ទើបលួងសួរសេចក្ដីកំបាំង គឺ មន្តដែលអ្នកលាក់បាំងបាន ។

បទថា **បរមា "ដ៏កំពូល"** សេចក្ដីថា មាតាបិតាទាំងពីរនេះឈ្មោះថា ជាផៅពង្សដ៏ខ្ពង់ខ្ពស់របស់ផៅពង្ស ។ បទថា **នាស្ស តតិយោ "បុគ្គលទីបីនោះ... មិនមាន"** សេចក្ដីថា អ្នកទីបីដទៃអំពីមាតាបិតា នឹងឈ្មោះថា អើពើ អាណិតអាសូរ រមែងមិនមានសម្រាប់បុគ្គលនោះ ។ អធិប្បាយថា បុគ្គលអ្នកឈ្លាសកាលវង្វៀសថា មន្តនឹងបែក មិនគួរប្រាប់សេចក្ដីកំបាំងដែលសំខាន់សូម្បីដល់មាតាបិតាទាំងពីរ តែខ្លួនអ្នកត្រឡប់ជាប្រាប់នូវសេចក្ដីកំបាំងដែលខ្លួនមិនបានប្រាប់ដល់មាតាបិតាដល់អចេលក៏វិញ ។ បទថា **សហាយា វា "ឬដល់សម្លាញ់"** បានដល់ មិត្តអ្នកមានចិត្តល្អ ។ បទថា **សបក្ខា "ញាតិចំណែកខាងខ្លួន"** បានដល់ ញាតិខាងចំណែកមាតាបិតា អ៊ំ

ពូ មីងជាដើម ។ ដោយបទថា **តេសំបិ** នេះ ស្ដេចគ្រុឌសម្ដែង សេចក្ដីថា "បុគ្គលឈ្លាសមិនគួរប្រាប់សេចក្ដីកំបាំងដល់ញាតិ និង មិត្តសម្លាញ់ទាំងនេះ អ្នកបែរជាប្រាប់ដល់អចេលក៍ អ្នកចូរក្រោធនឹង ខ្លួនឯងចុះ" ។ បទថា **ភរិយា ចេ** "**បើភរិយា**" សេចក្ដីថា ភរិយា ចរបាគួរស្រឡាញ់ មានបុត្តធីតាជាមួយគ្នា សម្បូរដល់ព្រមដោយ រូបសម្បត្តិ និងយសសក្តិបែបនេះ បើនិយាយថា "អ្នកចូរប្រាប់នូវ សេចក្ដីកំបាំងដល់ខ្ញុំ" បុគ្គលឈ្លាស ក៏មិនគួរប្រាប់សម្បូរដល់ភរិយា នោះ ។

ស្ដេចគ្រុឌពោលពាក្យជាគាថាតទៅទៀតថា

[៥២០] ន គុយ្ហមត្ថំ វិវរេយ្យ រក្ខេយ្យ នំ យថា និធឹ
ន ហិ បាតុកតោ សាធុ គុយ្ហោ អត្ថោ បជានតា ។

បុគ្គលមិនគួរបើកសេចក្ដីកំបាំងឡើយ គួររក្សាសេចក្ដីកំបាំង នោះទុក ដូចរក្សាកំណប់ទ្រព្យ សេចក្ដីកំបាំងដែលបុគ្គលដទៃ

ដឹង នឹងធ្វើឲ្យផ្សាយទៅមិនល្អឡើយ ។

បិយា គុយ្ហំ ន សំសេយ្យ អមិត្តស្ស ច បណ្ឌិតោ

យោ ចាមិសេន សំហីរោ ហទយត្ថេនោ ច យោ នរោ ។

បុគ្គលអ្នកឈ្លាសមិនគួរបើកសេចក្តីកំបាំងដល់ស្ត្រី និងសត្រូវ

អ្នកបំណងក្នុងអាមិស និងដល់បុគ្គលអ្នកបំណងលួច ។

គុយ្ហមត្ថមសម្ពុទ្ធំ សម្ពោធយតិ យោ នរោ

មន្តភេទភយា តស្ស ទាសភូតោ តិតិក្ខតិ ។

ជនណាឲ្យអ្នកមិនមានគំនិតលួចដឹងសេចក្តីកំបាំង សូម្បីគេ

ជាអ្នកបម្រើរបស់ខ្លួន ក៏ចាំបាច់ត្រូវអត់ទ្រាំទុក ព្រោះខ្លាច

គំនិតនោះនឹងបែកធ្លាយ ។

យាវន្តោ បុរិសស្សត្ថំ គុយ្ហំ ជានន្តិ មន្តិនំ

តាវន្តោ តស្ស ឧព្វេគា តស្មា គុយ្ហំ ន វិស្សជេ ។

ជនមានប្រមាណប៉ុនណាដឹងសេចក្តីកំបាំងដែលប្រឹក្សាគ្នារបស់

បុរស ជនប្រមាណប៉ុណ្ណោះរមែងគំរាមឲ្យបុរសនោះភ័យខ្លាចបាន ព្រោះហេតុនោះ ទើបមិនគួរប្រាប់នូវសេចក្តីកំបាំង ។

វិវិច្ច ភាសេយ្យ ទិវា រហស្សំ

រត្តឹ គិរំ នាតិវេលំ បមុញ្ចេ

ឧបស្សុតិកា ហិ សុណន្តិ មន្តំ

តស្មា មន្តោ ខិប្បមុបេតិ ភេទំ ។

ក្នុងវេលាថ្ងៃក្តី វេលាយប់ក្តី បុគ្គលគួរនិយាយប្រាប់សេចក្តីកំបាំងក្នុងទីស្ងាត់ មិនគួរថ្លែងវាចាឲ្យហួសវេលា ព្រោះជនដែលរង់ចាំលបស្តាប់ ក៏នឹងបានឮការដែលប្រឹក្សាគ្នា ព្រោះហេតុនោះ ប្រការដែលប្រឹក្សាគ្នាក៏ដល់នូវការបែកធ្លាយមួយរំពេច ។

គាថាទាំង ៥ នេះ នឹងមានច្បាស់ក្នុងបណ្ឌិតបញ្ហា ៥ ប្រការក្នុងឧម្មង្គជាតក ។

ស្តេចគ្រុឌបានពោល ២ គាថាបន្តទៀតថា

[៥២១] យថាបិ អយោនគរំ មហន្តំ

អទ្វារកំ អាយសំ ភទ្ទសាលំ[១]

សមន្តខាតាបរិខាឧបេតំ

ឯវម្បិ មេ តេ ឥធ គុយ្ហមន្តា ។

បុគ្គលអ្នកមានគំនិតកំបាំងក្នុងលោក រមែងប្រាកដដល់យើង

ប្រៀបដូចនគរធំ ដែលប្រកបដោយកំពែងដែកសុទ្ធ មិនមាន

ទ្វារ មានរោងសាងឡើងដោយដែក ប្រកបដោយគូដែលជីក

ទុកព័ទ្ធជុំវិញដូច្នោះ ។

យេ គុយ្ហមន្តា អវិកិណ្ណវាចា

ទឡ្ហា សទត្ថេសុ នរា ទុជិវ្ហា

អារា អមិត្តា ព្យវជន្តិ តេហិ

១.អដ្ឋកថា. កណ្ណសាលំ ។

*អាសីវិសា វារិវ សត្ថុសង្ឃា ។*

*នៃបណ្ឌរកនាគរាជអ្នកមានអណ្តាតអាក្រក់ បុគ្គលជំពូកណា មានគំនិតកំបាំង មិននិយាយល្អាច មាំមួនក្នុងប្រយោជន៍ របស់ខ្លួន អមិត្តទាំងឡាយរមែងវៀរឆ្ងាយចាកបុគ្គលជំពូកនោះ ដូចបុគ្គលអ្នករក្សាជីវិត វៀរឆ្ងាយចាកពួកអសិរពិសដូច្នោះ ។*

បណ្តាបទទាំងនោះ បទថា **កណ្ឌសាលំ**[១] “រោង” សេចក្តីថា ដល់ព្រមដោយរោងមានរានផ្សារជាដើម ។ បទថា **សមន្តខាតាបរិខាឧបេតំ** “ប្រកបដោយគូដែលជីកទុកដោយជុំវិញ” សេចក្តីថា ប្រកបដោយគូដែលជីកព័ទ្ធទុកដោយជុំវិញ ។ បទថា **ឯវម្បិ មេ** “ដល់យើង... សូម្បីដូច្នោះ” សេចក្តីថា បុរសទាំងនោះ គឺគ្រប់ជំពូក អ្នកមានសេចក្តីកំបាំងក្នុងទីនេះ រមែងប្រាកដដល់យើងសូម្បីដូច្នោះ ។ លោកអធិប្បាយសេចក្តីទុកថា គ្រឿងឧបភោគ និង

---

១.បិដក. កទ្ទូសាលំ ។

បរិភោគរបស់ប្រជាជនរមែងមាននៅក្នុងនគរដែក ដែលមិនមានទ្វារ ចេញចូលនោះ មនុស្សដែលនៅខាងក្នុង ក៏មិនចេញទៅខាងក្រៅ មនុស្សដែលនៅខាងក្រៅ ក៏មិនចូលទៅខាងក្នុង ជាប់ការសព្ធរទៅមករកគ្នាយ៉ាងណា បុរសទាំងឡាយដែលមានគំនិតកំបាំងក៏ត្រូវជាយ៉ាងនោះ គឺ ឲ្យសេចក្ដីកំបាំងរបស់ខ្លួនវិនាសទៅក្នុងចិត្តរបស់ខ្លួនតែម្យ៉ាង មិនត្រូវប្រាប់អ្នកដទៃឡើយ ។

បទថា *ទល្ហា សទត្ថេសុ* *“មាំមួនក្នុងប្រយោជន៍របស់ខ្លួន”* សេចក្ដីថា ជាអ្នកមាំមួនក្នុងប្រយោជន៍របស់ខ្លួន ។ ស្ដេចគ្រុឌហៅបណ្ឌរកនាគរាជថា ***ទុជិវ្ហ*** *“អ្នកមានអណ្ដាតអាក្រក់”* ។ បទថា ***ព្យវជន្តិ*** *“រមែងវៀរឲ្យឆ្ងាយ”* បានដល់ រមែងគេចចេញឲ្យឆ្ងាយ ។ បទថា ***វា*** ក្នុងបាទគាថាថា ***អាសីវិសា វាវិវ សត្តសង្ឃា*** នេះ ត្រឹមតែជានិបាត អធិប្បាយថា (ដូចប្រជុំជនដែលបំណងនឹងមានជីវិត) វៀរឆ្ងាយចាកពួកសត្វកាច ពួកអសិរពិសដូច្នោះ ។ លោក

ពោលអធិប្បាយទុកថា "សត្រូវរមែងគេចចេញឆ្ងាយពីបុគ្គលអ្នកមានគំនិតកំបាំងទាំងនោះ ដូចជាពួកមនុស្សអ្នកបំណងនឹងមានជីវិតរមែងវៀរឆ្ងាយចាកពួកសត្វកាច ពួកអសិរពិសដូច្នោះ គឺ មិនបានឱកាសដែលនឹងចូលជិត" ។

កាលស្ដេចគ្រុឌពោលធម៌យ៉ាងនេះហើយ បណ្ឌរកនាគរាជទើបពោលគាថាថា

[៥២២] ហិត្វា ឃរំ បព្វជិតោ អចេលោ

នគ្គោ មុណ្ឌោ ចរតិ ឃាសហេតុ

តម្ហិ នុខោ វិវរិំ គុយ្ហមត្ថំ

អត្ថា ច ធម្មា ច អបគតម្ហា ។

អចេលក៏លះបង់ផ្ទះចេញបួស មានសីសៈត្រងោល ត្រាច់ទៅព្រោះហេតុនៃអាហារ យើងបានប្រាប់អាថ៌កំបាំងដល់អចេលក៏នោះ យើងទើបជាអ្នកប្រាសចាកប្រយោជន៍ និងធម៌ ។

កថំករោ ហោតិ សុបណ្ណរាជ

កឹសីលោ កេន វតេន វត្តំ

សមណោ ចរំ ហិត្វា មមាយិតានិ

កថំករោ សគ្គមុបេតិ ឋានំ ។

ស្តេចគ្រុឌ បុគ្គលលះបង់វត្ថុដែលប្រកាន់ថា ជារបស់យើង ហើយមកប្រព្រឹត្តជាអ្នកបួស មានការធ្វើយ៉ាងណា មានសីលយ៉ាងណា ប្រព្រឹត្តវត្តយ៉ាងណា ទើបទីងឈ្មោះថាជាសមណៈ សមណៈនោះមានការធ្វើយ៉ាងណា ទើបចូលដល់ដែនសួគ៌ ។

បណ្តាបទទាំងនោះ បទថា ឃាសហេតុ "ព្រោះតែហេតុនៃអាហារ" សេចក្តីថា អចេលក៍នោះមិនមានសិរី ត្រាច់ស្វែងរករបស់ទំពាររបស់ស៊ីដើម្បីឲ្យពេញពោះ ។ បទថា អបគតម្ហា "ប្រាសចាក" សេចក្តីថា យើងប្រាសចាក គឺ ជាអ្នកវិនាស (ចាកអត្ថ និងធម៌ហើយ) ។ គ្រាស្តេចនាគដឹងនូវភាពជាសមណៈរបស់អចេលក៍ហើយ

កាលនឹងសួរវត្តបដិបត្តិរបស់សមណៈ ទើបពោលពាក្យនេះថា **ក-ថំករោ** "មានការធ្វើយ៉ាងណា" ។ បណ្ដាបទទាំងនោះ បទថា **កិ-សីលោ** "មានសីលយ៉ាងណា" សេចក្ដីថា ប្រកបដោយសីលដូចម្ដេច ។

បទថា **កេន វតេន** "វត្តយ៉ាងណា" សេចក្ដីថា សមណៈឈ្មោះថា មានវត្ត ព្រោះសមាទានវត្តយ៉ាងណា ។ បទថា **សម-ណោ ចរំ** "សមណៈ... ប្រព្រឹត្ត" សេចក្ដីថា អ្នកដែលប្រព្រឹត្តនូវបព្វជ្ជាហើយ ត្រូវលះតណ្ហាដែលប្រកាន់ថា ជារបស់យើងហើយទើបនឹងឈ្មោះថា ជាសមណៈអ្នកបន្សាត់នូវបាបហើយ ។ បទថា **សគ្គំ** "សួគ៌" សេចក្ដីថា សមណៈនោះត្រូវធ្វើយ៉ាងណាទើបចូលទៅនគរដ៏ប្រសើរដោយល្អ ។

ស្ដេចក្រុឧពោលតបជាគាថាថា

[៥២៣] **ហិរិយា តិតិក្ខាយ ទមេន ខន្តិយា**[១]

---

១.ម. ទមេនុបេតោ ។ អដ្ឋកថា បរំ ។

អក្កោធនោ បេសុណិយំ បហាយ

សមណោ ចរំ[(១)] ហិត្វា មមាយិតានិ

ឯវំករោ សគ្គមុបេតិ ឋានំ ។

បុគ្គលលះវត្ថុដែលប្រកាន់ថាជារបស់យើងហើយ មកប្រព្រឹត្តជាអ្នកបួស ត្រូវប្រកបដោយការខ្មាសបាប សេចក្តីអត់ទ្រាំការទូន្មានខ្លួន ការអត់ធន់ មិនក្រោធឆាយ លះបង់វាចាញុះញង់ ទើបឈ្មោះថាជាសមណៈ ឯសមណៈនោះមានការធ្វើយ៉ាងនេះ ទើបទឹងចូលដល់ដែនសួគ៌ ។

បណ្តាបទទាំងនោះ បទថា ហិរិយា "ការខ្មាសបាប" សេចក្តីថា នែនាគរាជសម្លាញ់ បុគ្គលអ្នកប្រកបដោយហិរិឱត្តប្បៈដែលជាសមុដ្ឋានទាំងខាងក្នុងខាងក្រៅ ដោយអធិវាសនខន្តិ ពោលគឺ ការអត់ទ្រាំ និងប្រកបដោយការហ្វឹកហាត់ឥន្ទ្រិយ មានប្រក្រតីមិនក្រោធ

---

១.ម. អក្កោ ។

វៀរវាចាញុះញង់ និងលះបង់វត្ថុដែលប្រកាន់ថាជារបស់យើង ដោយអំណាចតណ្ហាបានហើយ ប្រព្រឹត្តបព្វជ្ជា រមែងឈ្មោះថា ជាសមណៈអ្នកមានបាបបន្សាត់បង់ហើយ ។ បទថា សគ្គំ "ដែនសួគ៌" ន័យថា ស្តេចគ្រុឌពោលថា "សមណៈនោះ កាលធ្វើយ៉ាងនេះឯង រមែងចូលដល់ទេវនគរដ៏ប្រសើរដោយល្អ" ។

បណ្ឌរកនាគរាជបានស្តាប់ធម្មកថារបស់ស្តេចគ្រុឌនេះហើយ កាលនឹងអង្វរសូមជីវិត ទើបពោលគាថាថា

[៥២៤] មាតាវ បុត្តំ តរុណំ តនុជ្ជំ
សម្ផស្សតា សព្វគត្តំ ផរេតិ
ឯវម្បិ មេ ត្វំ បាតុរហុ ទិជិន្ទ
មាតាវ បុត្តំ អនុកម្បមានោ ។

បពិត្រស្តេចគ្រុឌ សូមលោកចូរប្រោកដដល់ខ្ញុំ ឲ្យដូចជាមាតាដែលកូនតូចកើតអំពីខ្លួន បបោសអង្អែលរាងកាយគ្រប់ចំណែក

រក្សា ឬដូចជាមាតាអ្នកអនុគ្រោះបុត្តដូច្នោះចុះ ។

គាថានោះមានអធិប្បាយដូច្នេះ មាតាឃើញបុត្តតូចដែលកើតអំពីខ្លួន កើតហើយក្នុងសរីរៈរបស់ខ្លួន ហើយឲ្យដេកក្នុងទ្រូង ឲ្យបៅដោះ យករាងកាយគ្រប់ចំណែកការពារបុត្ត គឺ មាតាមិនចេញចាកបុត្ត បុត្តក៏មិនចេញចាកមាតា យ៉ាងណា អ្នកចូរប្រោកជ គឺ សម្ដេងឲ្យប្រោកជដល់យើងដូច្នោះចុះ ។ បទថា **ទិជិន្ទ** “**បពិត្រស្ដេចគ្រុឌ**” សេចក្ដីថា ស្ដេចនាគពោលថា “បពិត្ររាជានៃទិជជាតិសូម្បីលោកក៏ចូរមេត្តាឃើញដល់យើង ដូចជាមាតាអាណិតដល់បុត្ត ដោយហឫទ័យដ៏ទន់ភ្លន់ដូច្នោះចុះ” ។

លំដាប់នោះ ស្ដេចគ្រុឌកាលនឹងឲ្យជីវិតដល់ស្ដេចនាគ ទើបពោលមួយគាថាទៀតថា

[៥២៥] **ហន្ទជ្ជ ត្វំ មុច្ច វធា ទុជិវ្ហ**
**តយោ ហិ បុត្តា នហិ អញ្ញោ[១] អត្ថិ**

---

១.ម. អត្ថោ ។

អន្តេវាសី ទិន្នកោ អត្រជោ ច

វេជស្ស បុត្តញ្ញតរោ មេ អហោសិ ។

នៃស្តេចនាគអ្នកមានអណ្តាតអាក្រក់ ណ្ហើយចុះ អ្នកចូររួច

ចាកការត្រូវសម្លាប់ក្នុងថ្ងៃនេះចុះ ក៏បុត្តមាន ៣ ជំពូក គឺ

សិស្ស ១ បុត្តបុញ្ញធម៌ ១ បុត្តរបស់ខ្លួន ១ បុត្តដទៃមិនមាន

អ្នកនឹងត្រេកអរក្នុងបុត្តជំពូកណារបស់យើង ។

បណ្តាបទទាំងនោះ បទថា មុច្ច "ចូររួច" បានដល់ ចូររួច ផុត ។ ម្យ៉ាងទៀត បាឋៈក៏ដូច្នោះដូចគ្នា ។ បទថា ទុជិវ្ហ "អ្នកមានអណ្តាតអាក្រក់" បានដល់ ស្តេចគ្រុឌហៅស្តេចនាគនោះ ។ អធិប្បាយថា ឈ្មោះថា បុត្តទី ៤ ដទៃមិនមាន ។ បទថា អន្តេ-វាសី ទិន្នកោ អត្រជោ ច "សិស្ស ១ បុត្តបុញ្ញធម៌ ១ បុត្តរបស់ខ្លួន ១" បានដល់ បុត្តដែលសិក្សាសិល្បៈ ឬស្តាប់បញ្ហានៅក្នុងសម្នាក់របស់ខ្លួន ។

បទថា **ទិន្នកោ** “បុត្តបុញ្ញធម្មិ” បានដល់ បុត្តដែលជនដទៃប្រគល់ឲ្យថា “ក្មេងនេះចូរជាកូនរបស់លោក” ។ បទថា **វជស្សុ** “ត្រេកអរ” បានដល់ ចូរត្រេកអរ ។ បទថា **អញ្ញតរោ** “ជំពូកណា” នេះ ស្ដេចគ្រុឌសម្ដែងថា “ក្នុងបុត្ត ៣ ជំពូកនោះ អ្នកចូរជាអន្តេវាសិបុត្តតែម្យ៉ាងរបស់យើង” ។ ក៏ស្ដេចគ្រុឌពោលយ៉ាងនេះហើយ ក៏ចុះចាកអាកាសដាក់ស្ដេចនាគលើផែនដី ។

ព្រះសាស្ដាកាលទ្រង់ប្រកាសសេចក្ដីនោះ បានត្រាស់ព្រះគាថា ២ គាថាថា

[៥២៦] ឥច្ចេវ វាក្យំ វិសជ្ជិ សុបណ្ណោ
ភុម្យំ បតិដ្ឋាយ ទិជោ ទុជិវ្ហំ
មុត្តជ្ជ ត្វំ សព្វភយាតិវត្តោ
ថលូទកេ ហោហិ មយាភិគុត្តោ ។
អាតង្កិនំ យថា កុសលោ ភិសក្កោ

បិបាសិតានំ រហទោវ សីតោ

វេស្មំ យថា ហិមសីតដ្ដិតានំ

ឯវម្បិ តេ សរណមហំ ភវាមិ ។

ស្ដេចគ្រុឌជាធំនៃទិជជាតិពោលយ៉ាងនេះហើយ ក៏បន្ទាប ចុះលើផែនដី ហើយលែងស្ដេចនាគទៅ ដោយពោលថា ថ្ងៃ នេះអ្នករួចផុតអំពីសព្វភ័យហើយ ចូរជាអ្នកដែលយើងឃុំគ្រង ហើយទាំងលើគោកទាំងក្នុងទឹក ។

ពេទ្យដែលឈ្លាស ជាទីពឹងរបស់អ្នកជម្ងឺបាន យ៉ាងណា អន្លង់ទឹកដ៏ត្រជាក់ក៏ជាទីពឹងរបស់បុគ្គលស្រេកឃ្លានបាន យ៉ាង ណា ស្ថានទីសម្រាកជាទីពឹងរបស់អ្នកដំណើរបាន យ៉ាងណា យើងក៏ជាទីពឹងរបស់អ្នកក៏យ៉ាងនោះ ។

បណ្ដាបទទាំងនោះ បទថា ឥច្ចេវំ វាក្យំ "ពោលយ៉ាងនោះ ហើយ" សេចក្ដីថា ស្ដេចគ្រុឌពោលពាក្យយ៉ាងនេះ ដោយប្រការ

ដូច្នេះហើយ ក៏លែងនាគរាជនោះ ។ បទថា **កុម្យំ**[១] **“ត្រង់ផែនដី”** សេចក្តីថា ស្តេចគ្រុឌនោះក៏ប្រតិស្ឋានលើផ្ទៃភូមិភាគដោយខ្លួនឯង លែងស្តេចនាគអ្នកមានអណ្តាតផ្លែកនោះ ហើយពោលថា “ថ្ងៃនេះអ្នករួចផុតហើយ រាប់អំពីថ្ងៃនេះទៅ អ្នកកន្លងផុតភ័យទាំងពួង ចូរជាអ្នកដែលយើងឃុំគ្រងរក្សាទាំងផ្លូវគោកទាំងផ្លូវទឹកចុះ” ។ បទថា **អាតន្តិនំ “របស់អ្នកជម្ងឺ”** បានដល់ របស់ជនអ្នកឈឺ ។ បទថា **ឯវម្បិ តេ “របស់អ្នកដូច្នោះ”** សេចក្តីថា យើងនឹងជាទីពឹងរបស់អ្នក (ដូចពេទ្យដែលឈ្លាសជាទីពឹងរបស់អ្នកជម្ងឺជាដើម) ។

ស្តេចគ្រុឌលែងនាគរាជហើយពោលថា “អ្នកចូរទៅចុះ” ។ នាគរាជនោះក៏ទៅកាន់នាគពិភព ។ ចំណែកស្តេចគ្រុឌ ក៏ត្រឡប់ទៅសុបណ្ណពិភព ហើយគិតថា “បណ្ឌរកនាគរាជ យើងបានធ្វើការស្បថឲ្យជឿ និងលែងទៅហើយ នឹងមានចិត្តចំពោះយើងយ៉ាងណា

---

១.បិដក. ភូម្យំ ។

ហ្ន៎ យើងនឹងមើលមើល៍” ហើយទៅកាន់នាគពិភព បានធ្វើខ្យល់របស់គ្រុឌ ។ ស្តេចនាគឃើញដូច្នោះ សម្គាល់ថា “ស្តេចគ្រុឌនឹងមកចាប់យើង” ទើបនិម្មិតអត្តភាពដ៏វែងប្រមាណ ១.០០០ ព្យាម លេបដុំថ្ម និងខ្សាច់ទុកក្នុងខ្លួនរហូតធ្ងន់ធ្ងាយរង្វេលនៅជិតផ្ទារទឹក ។ ខណៈនោះព្រះសរីរកាយរបស់ស្តេចនាគនោះ ជាហេតុឲ្យព្រៃមានពន្លឺតែមួយដូចគ្នា បានដេកបើកពពារ ធ្វើអាការហាក់ដូចជាបំណងនឹងខាំស្តេចគ្រុឌ ។ ស្តេចគ្រុឌឃើញអាការដូច្នោះ ទើបពោលគាថាក្រៅអំពីនេះថា

[៥២៧] សទ្ធឹ កត្វា អមិត្តេន អណ្ឌជេន ជលាពុជ
វិវរិយ ទាឋំ បស្សសិ[(១)] កុតោ តំ ភយមាគតំ ។

នែអ្នកជលាពុជជាតិ (អ្នកកើតអំពីទឹក) អ្នកបញ្ចេញចង្កូមនឹងខាំ សម្លឹងមើលដូចជាសត្រូវ អ្នកអណ្ឌជជាតិ (អ្នកកើតអំពី

---

១. អដ្ឋកថាយំ បន វិវរិ យទា ឌំសយតីតិ បាឋោ ទិស្សន្តិ ។ ម. យសស្សិ ។

ពង) ភ័យរបស់អ្នកមានមកអំពីណាហ្ន៎ ។

ស្តេចនាគបានស្តាប់ដូច្នោះ ទើបពោល ៣ គាថាថា

[៥២៨] សង្កេថេវ អមិត្តស្មឹ មិត្តស្មឹបិ ន វិស្សសេ

អភយា ភយមុប្បន្នំ អបិ មូលានិ កន្តតិ ។

បុគ្គលគប្បីប្រយ័ត្នក្នុងសត្រូវ សូម្បីក្នុងមិត្តក៏មិនគួរទុកចិត្ត ភ័យកើតឡើងបានអំពីទីដែលមិនមានភ័យ មិត្តរមែងកាត់ឫសគល់ (ដកឫសគល់) បានដោយពិត ។

កថំ នុ វិស្សសេ ត្យម្ហិ យេនាសិ កលហោ កតោ

និច្ចយត្តេន ឋាតព្វំ សោ ទិសព្ភិ ន រជ្ជតិ ។

នឹងគប្បីទុកចិត្តក្នុងបុគ្គលដែលធ្វើការឈ្លោះគ្នាមកហើយដូចម្តេចបានហ្ន៎ បុគ្គលណាតាំងនៅបានដោយការត្រៀមខ្លួនជានិច្ច បុគ្គលនោះរមែងមិនត្រេកអរជាមួយសត្រូវរបស់ខ្លួនឡើយ ។

វិស្សាសយេ ន ច នំ វិស្សសេយ្យ
អសង្កិតោ សង្កិតោ ច ភវេយ្យ
តថា តថា វិញ្ញូ បរក្កមេយ្យ
យថា យថា ភាវំ បរោ ន ជញ្ញា ។

បុគ្គលគប្បីធ្វើខ្លួនឲ្យជាទីទុកចិត្តរបស់ជនដទៃ តែមិនគួរនឹងទុកចិត្តជនដទៃហួសពេកទេ មិនគប្បីឲ្យជនដទៃរវាំងនឹងខ្លួន តែគួរប្រយ័ត្នក្នុងអ្នកដទៃ (ខ្លះ) វិញ្ញូជនគប្បីព្យាយាមដោយអ្នកដទៃមិនទាន់ដឹងការប្រព្រឹត្តទៅរបស់ខ្លួន ។

បណ្ដាបទទាំងនោះ បទថា **អភយា** “មិនមានភ័យ” សេចក្ដីថា ភ័យកើតឡើងអំពីមិត្តដែលជាទីតាំងនៃការផុតភ័យ រមែងកាត់នូវឫសគល់ ពោលគឺ ជីវិតបានយ៉ាងពិត ។ បទថា **តម្ហិ** ស្មើនឹង **តស្មឹ** (បានដល់ក្នុងបុគ្គលនោះ) ។ បទថា **និច្ចយត្តេន** “ដោយការត្រៀមខ្លួនជានិច្ច” បានដល់ ដោយការត្រៀមខ្លួនជានិច្ច ។ បទ

ថា **សោ ទិសត្តិ ន វជ្ជតិ** “បុគ្គលនោះរមែងមិនគេចអំពីសត្រូវ” សេចក្តីថា បុគ្គលណាតាំងនៅដោយការប្រយ័ត្នជានិច្ច បុគ្គលនោះរមែងមិនគេចអំពី ដោយអំណាចសេចក្តីស្និទ្ធស្នាលជាមួយសត្រូវរបស់ខ្លួន តពីនោះ កិច្ចដែលគួរធ្វើតាមបំណងរបស់សត្រូវនោះ ក៏មិនមាន ។ បទថា **វិស្សាសយេ** “ឲ្យជាទីទុកចិត្តរបស់អ្នកដទៃ” សេចក្តីថា បុគ្គលគួរឲ្យអ្នកដទៃទុកចិត្តបានចំពោះខ្លួន តែខ្លួនឯងមិនគួរទុកចិត្តគេ ខ្លួនដែលអ្នកដទៃមិនប្រយ័ត្នហើយ ខ្លួននោះឯងត្រូវប្រយ័ត្នចំពោះគេ ។ បទថា **ភាវំ បរេ** “**អ្នកដទៃទឹងមិនដឹងការប្រព្រឹត្តទៅ**” សេចក្តីថា នាគរាជសម្តែងថា “បណ្ឌិតនឹងព្យាយាមដោយវិធីណាៗ ក៏មិនជ្រាបភាវៈ (សេចក្តីបំណង) របស់បរបក្សបានដោយវិធីនោះៗ ទេ ព្រោះដូច្នោះ បណ្ឌិតគួរធ្វើសេចក្តីព្យាយាមរឿយៗ” ។ (ដែលពោលមកនេះ ជាសេចក្តីអធិប្បាយរបស់ស្តេចនាគរាជ) ។

គ្រាសត្វទាំងពីរ (គឺ ស្តេចគ្រុឌ និងស្តេចនាគ) ចរចាគ្នានឹងគ្នាយ៉ាងនេះហើយ ក៏រីករាយស្រុះស្រួលបបួលគ្នាទៅកាន់អាស្រមអចេលក៍ ។

ព្រះសាស្តាកាលទឹងប្រកាសសេចក្តីនោះ ទើបបានត្រាស់ព្រះគាថាថា

[៥២៩] តេ ទេវវណ្ណា សុខុមាលរូបា

ឧភោ សមា សុជយា បុញ្ញកន្ធា

ឧបាគមុំ ករម្បិយំ[១] អចេលំ

មិស្សីភូតា អស្សវាហាវ នាគា ។

សត្វទាំងពីរមានវណ្ណៈដូចទេវតា សុខុមាលជាតិមានរូបសណ្ឋានប្រហាក់ប្រហែលគ្នា មានវ័យស្មើគ្នា មានបុណ្យបារមីបានធ្វើទុក កៀកដៃគ្នា ជាសត្វប្រសើរ ដូចជាសេះទឹមក្នុងរថ នាំគ្នា

១. អដ្ឋកថាយំ បទ កាទម្ពិយន្តិ បាឋោ ទិស្សតិ ។

ចូលទៅរកករម្បិយអចេលក៍ ។

បណ្តាបទទាំងនោះ បទថា **សមា** **"ប្រហែលគ្នា"** សេចក្តីថា សត្វទាំងពីរមានទ្រង់ទ្រាយសណ្ឋានប្រហែលគ្នា ។ បទថា **សុជយា** **"មានវ័យស្មើគ្នា"** សេចក្តីថា មានវ័យជាសុខ គឺ បរិសុទ្ធ ។ បាឋៈ (ព្រះបាលី) ក៏ដូច្នោះដូចគ្នា ។ បទថា **បុញ្ញក្ខន្ធា** **"មានបុណ្យបារមីបានធ្វើទុក"** សេចក្តីថា គំនរបុណ្យ ព្រោះមានកុសលដែលបានធ្វើទុកហើយ ។ បទថា **មិស្សីភូតា** **"កៀកដៃគ្នាទៅ"** សេចក្តីថា សត្វទាំងពីរចាប់ដៃគ្នានឹងគ្នា ចូលដល់ភាពកៀកគ្នាដោយកាយ ។ បទថា **អស្សវាហារ នាគា** **"ជាសត្វប្រសើរ ដូចជាសេះទឹមក្នុងរថ"** សេចក្តីថា បុរសដ៏ប្រសើរ ដូចជាអស្សតរពីរក្បាលទឹមក្នុងនឹមនាំរថទៅ ចូលទៅកាន់អាស្រមរបស់អចេលក៍នោះ ។

គ្រាទៅដល់ហើយ ស្តេចគ្រុឌគិតថា "ស្តេចនាគនេះគង់នឹងមិនឲ្យជីវិតដល់អចេលក៍ យើងក៏មិនសំពះវាដែលជាអ្នកទ្រុស្តសីល"

ស្ដេចក្រុងទើបឈរនៅខាងក្រៅ ឲ្យស្ដេចនាគចូលទៅកាន់សម្នាក់អចេលក៏តែម្នាក់ឯង ។

ព្រះសាស្ដាសំដៅហេតុនោះ ទើបត្រាស់ព្រះគាថានេះ សេចក្ដីថា

[៥៣០] តតោ ហវេ បណ្ឌរកោ អចេលំ

សយមេវុបាគម្ម ឥទំ អវោច

មុត្តជ្ជហំ សព្វភយាតិវត្តោ

ន ហិ នូន តុយ្ហំ មនសោ បិយម្ហា ។

លំដាប់នោះ បណ្ឌរកនាគរាជចូលទៅរកអចេលក៏តែម្នាក់ឯងប៉ុណ្ណោះ ហើយបានពោលថា ថ្ងៃនេះយើងរួចពីសេចក្ដីស្លាប់កន្លងនូវភ័យទាំងពួងហើយ គង់មិនជាទីស្រឡាញ់ជាទីពេញចិត្តអ្នកឯងដោយពិត ។

បណ្ដាបទទាំងនោះ បទថា បិយម្ហា "ជាទីស្រឡាញ់" ន័យ

ថា បណ្ឌរកនាគរាជពោលដេរថា "អើអចេលក៍ទ្រុស្តសីល ចូល ចិត្តនិយាយកុហក យើងគង់ជាអ្នកមិនជាទីស្រឡាញ់ពេញចិត្តរបស់អ្នកឡើយ" ។

លំដាប់នោះ អចេលក៍ទើបពោលគាថាក្រៅពីនេះថា

[៥៣១] បិយោ ហិ មេ អាសិ សុបណ្ណរាជា
អសំសយំ បណ្ឌរកេន សច្ចំ
សោ រាគរត្តោ ច អកាសិ ឯតំ
បាបកម្មំ សម្បជានោ ន មោហា ។

ស្តេចគ្រុឌជាទីស្រឡាញ់របស់យើងក្រៃលែង ជាងបណ្ឌរកនាគរាជដោយពិតមិនបាច់សង្ស័យ យើងមានសេចក្តីស្រឡាញ់ក្នុងស្តេចគ្រុឌ ទាំងដែលបានដឹងធ្វើនូវកម្មដ៏លាមក មិនមែនធ្វើព្រោះសេចក្តីវង្វេងឡើយ ។

បណ្តាបទទាំងនោះ បទថា បណ្ឌរកេន "បណ្ឌរកនាគរាជ"

សេចក្តីថា ស្តេចគ្រុឌនោះ ជាអ្នកដែលយើងស្រឡាញ់ជាងអ្នកជាបណ្ឌរកនាគរាជ ប្រការនេះជាការពិត ។ បទថា សោ "នោះ" គឺយើងនោះជាអ្នកលំអៀងព្រោះស្រឡាញ់ស្តេចគ្រុឌនោះ ទើបបានធ្វើបាបកម្មនោះទាំងដឹងខ្លួន មិនមែនធ្វើព្រោះមោហាគតិក៏ទេ ។

នាគរាជបានស្តាប់ដូច្នោះហើយ បានពោល ២ គាថាថា

[៥៣២] ន មេ បិយំ អប្បិយំ វាបិ ហោតិ

សម្បស្សតោ លោកមិមំ បរញ្ច

សុសញ្ញតានញ្ហិ វិយញ្ជនេន

អសញ្ញតោ លោកមិមំ ចរាសិ ។

សេចក្តីប្រកាន់ថា វត្ថុនេះជាទីស្រឡាញ់របស់យើង ឬវត្ថុនេះមិនជាទីស្រឡាញ់របស់យើង ដូច្នេះ រមែងមិនមានដល់បព្វជិតអ្នកពិចារណាឃើញលោកនេះ និងលោកខាងមុខទេ ក៏អ្នកជាបុគ្គលមិនសង្រួម តែប្រព្រឹត្តកុហកលោកនេះដោយ

ភេទរបស់អ្នកសង្រួម ។

អរិយាវកាសោសិ អនរិយោវ ហោសិ

អសញ្ញតោ សញ្ញតសន្និកាសោ

កណ្ហាភិជាតិកោ អនរិយរូបោ

បាបំ ពហុំ ទុច្ចរិតំ អចារិ ។

អ្នកមិនមែនជាអរិយៈតែបន្ទំខ្លួនជាអរិយៈ មិនជាបុគ្គលសង្រួម តែធ្វើដូចជាបុគ្គលសង្រួម អ្នកជាបុគ្គលមានជាតិថោកទាប មិនមែនបុគ្គលប្រសើរ បានប្រព្រឹត្តបាបទុច្ចរិតដ៏ច្រើន ។

បណ្ដាបទទាំងនោះ បទថា ន មេ "មិន... របស់យើង" គឺនៃជនអាក្រាតទ្រុស្តសីលអ្នកច្រើននិយាយកុហកដ៏ចម្រើន ការពិតចំពោះបព្វជិតអ្នកសម្លឹងឃើញលោកនេះ និងលោកខាងមុខ រមែងមិនប្រកាន់ថា "វត្ថុនេះជាទីស្រឡាញ់របស់យើង វត្ថុនេះមិនជាទីស្រឡាញ់របស់យើងឡើយ" តែអ្នកជាបុគ្គលមិនសង្រួម ប្រព្រឹត្ត

កុហកលោកនេះដោយគ្រឿងសម្គាល់ គឺ ដោយភេទបព្វជិតរបស់អ្នកមានសីល សង្រួមល្អ ។ បទថា **អរិយាវកាសោសិ** **“អ្នកមិនមែនជាអរិយៈ”** សេចក្តីថា មិនមែនអរិយៈក៏បន្ទំខ្លួនជាអរិយៈ ។ បទថា **អសញ្ញតោ** **“មិនមែនជាអ្នកសង្រួម”** សេចក្តីថា មិនមែនជាអ្នកសង្រួមដោយកាយជាដើម ។ បទថា **កណ្ហាភិជាតិកោ** **“ជាបុគ្គលអ្នកមានជាតិថោកទាប”** សេចក្តីថា ជាជនមានសភាពថោក-ទាប ។ បទថា **អនរិយរូបោ**[១] **“មិនមែនជាបុគ្គលប្រសើរ”** ន័យថា គ្មានហិរិការខ្មាសខ្លើមបាប ។ បទថា **អចារិ** **“បានប្រព្រឹត្ត”** គឺ បានធ្វើ (បាបទុច្ចរិតដ៏ច្រើន) ។

លុះបណ្ឌរកនាគរាជតិះដៀលអចេលក៏នោះ យ៉ាងនេះហើយ ឥឡូវនេះ កាលនឹងប្រទេចផ្តាសា ទើបពោលគាថានេះថា

[៥៣៣] **អទុដ្ឋស្ស តុវំ ទុព្ភិ   ទុព្ភី ច បិសុណោ ចសិ**

---

១.បិដក. អនរិយរូបោ ។

ឯតេន សច្ចវជ្ជេន មុទ្ធា តេ ផលតុ សត្តធា ។

នែបុគ្គលថោកទាប អ្នកប្រទូស្តចំពោះអ្នកមិនប្រទូស្ត ទាំងជា

បុគ្គលស៊ីកសៀត ដោយពាក្យសច្ចៈនេះ សូមសីសៈរបស់អ្នក

ចូរបែកចេញជា ៧ ចំណែក ។

គាថានោះ មានអធិប្បាយថា "អើ អ្នកជាបុគ្គលថោកទាប ដោយការពោលពាក្យសច្ចៈនេះ អ្នកដែលជាបុគ្គលប្រទូស្តចំពោះមិត្តអ្នកមិនប្រទូស ទាំងជាអ្នកស៊ីកសៀតផង សូមសីសៈរបស់អ្នកចូរបែកជា ៧ ចំណែក" ។

កាលស្តេចនាគផ្តាសាជូច្នេះហើយ សីសៈរបស់អចេលក៏នោះក៏បែកជា ៧ ចំណែក ។ ផ្ទៃផែនដីត្រង់អចេលក៏អង្គុយនោះឯង ក៏បានបែកចេញជាចន្លោះ អចេលក៏នោះធ្លាក់ចូលក្នុងផែនដី កើតក្នុងអវិចីមហានរក ស្តេចនាគ និងស្តេចគ្រុឌ ក៏បានទៅកាន់ពិភពរៀងៗខ្លួន ដូចដើម ។

ព្រះសាស្តា កាលនឹងប្រកាសសេចក្តីដែលអចេលក៍នោះត្រូវផែនដីស្រូប ទើបត្រាស់ព្រះគាថាចុងក្រោយថា

[៥៣៤] តស្មាហិ មិត្តានំ ន ទុព្ភិតព្វំ
មិត្តទុព្ភា ហិ បាបិយោ នត្ថិ អញ្ញោ
អាសិត្តសត្តោ និហតោ បថព្យា
ឥន្ទស្ស វាក្យេន ហិ សំវរោ ហតោតិ ។

ព្រោះហេតុនោះឯង បុគ្គលមិនគប្បីប្រទូស្តចំពោះមិត្ត ព្រោះអ្នកប្រទូស្តមិត្ត ជាបុគ្គលថោកទាបបំផុត នឹងរកបុគ្គលដទៃដែលថោកទាបជាងមិនមាន អចេលក៍ត្រូវអសិតពិសកម្ចាត់ហើយក្នុងផែនដី ទាំងដែលប្តេជ្ញាថា យើងមានសំវរៈ ក៏ត្រូវបានទម្លាយដោយពាក្យរបស់ស្តេចនាគ ។

បណ្តាបទទាំងនោះ បទថា តស្មា "ព្រោះហេតុនោះ" សេចក្តីថា ព្រោះហេតុនៃផលរបស់កម្ម គឺ ការប្រទូស្តមិត្តជារបស់ដុតពេល ។ បទថា អាសិត្តសត្តោ "ត្រូវអសិរពិសកម្ចាត់ហើយ" គឺ

អចេលក៍នោះត្រូវអសិរពិសកម្ចាត់ហើយ ។ បទថា **ឥន្ទស្ស** “**របស់ស្ដេចនាគ**” ន័យថា ដោយពាក្យរបស់ស្ដេចនាគ ។ បទថា **សំវរេ** “**មានសំវរៈ**” សេចក្ដីថា អាជីវកដែលប្រាកដដោយប្ដេជ្ញាថា “យើងជាអ្នកតាំងនៅក្នុងសំវរៈ ក៏ត្រូវបានទម្លាយ” ។

ព្រះសាស្ដាទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលនេះប៉ុណ្ណោះទេ សូម្បីក្នុងជាតិមុន ទេវទត្តក៏បានធ្វើ មុសាវាទត្រូវផែនដីស្រូបដែរ” ហើយទ្រង់ប្រជុំជាតកថា “អចេលក៍ក្នុងកាលនោះ បានមកជាទេវទត្ត នាគរាជក្នុងកាលនោះ បានមកជាសារីបុត្ត, ចំណែកសុបណ្ណរាជក្នុងកាលនោះ គឺ **តថាគត** នេះឯង ។

ចប់អដ្ឋកថា បណ្ឌរកជាតកទី ៨

# អដ្ឋកថា សម្ពុលាជាតកទី ៩

## (រឿងការជឿសច្ចៈរបស់ព្រះនាងសម្ពុលា)

*ព្រះសាស្តាកាលស្តេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បានប្រារព្ធព្រះនាងមល្លិកាពជទេវី ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **កា វេធមានា "អ្នកជានរណា... ឈររង៉ាញ័រ"** ដូច្នេះ ។*

*រឿងបច្ចុប្បន្ន ខ្ញុំពណ៌នាទុកហើយយ៉ាងពិស្តារក្នុងកុម្មាសបិណ្ឌិកជាតក ។ ក៏ព្រះនាងមល្លិកានោះ ដោយអានុភាពនៃការថ្វាយនំកុម្មាសចំពោះព្រះតថាគត ៣ ដុំ បានដល់នូវភាពជាព្រះអគ្គមហេសីរបស់ព្រះបាទបសេនទិកោសល ក្នុងថ្ងៃនោះឯង ដល់ព្រមដោយកល្យាណធម៌ ៥ ប្រការ មានការភ្ញាក់មុនជាដើម ដល់ព្រមដោយញាណ ជាឧបដ្ឋាយិកាព្រះសម្ពុទ្ធ គោរពចំពោះព្រះស្វាមីដូចជាទេវតា ។ ការដែលព្រះនាងគោរពចំពោះព្រះស្វាមីដូចជាទេវតានោះ បានប្រាកដទូទៅទាំងព្រះនគរ ។ ក្រោយមកថ្ងៃមួយ ភិក្ខុទាំង*

ឡាយសន្ទនាគ្នាក្នុងធម្មសភាថា "អាវុសោទាំងឡាយ ឮដំណឹងថា ព្រះនាងមល្លិកាទេវីជាអ្នកសម្បូរដោយវត្ត ទ្រង់គោរពចំពោះព្រះស្វាមីដូចជាទេវតា" ។ ព្រះសាស្តាយាងមកត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ពេលនេះពួកអ្នកប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎?" កាលភិក្ខុទាំងឡាយក្រាបទូលថ្វាយហើយ ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងពេលនេះប៉ុណ្ណោះទេ សូម្បីក្នុងជាតិមុន ព្រះនាងមល្លិកានេះ ទ្រង់ក៏គោរពព្រះស្វាមីដូចជាទេវតាដូចគ្នា" ហើយទ្រង់នាំអតីតនិទានមកត្រាស់សម្តែងដូចតទៅនេះ ។

ក្នុងអតីតកាល ឱរសរបស់ព្រះបាទព្រហ្មទត្តក្នុងនគរពារាណសី ទ្រង់ព្រះនាមថា **សោត្ថិសេនកុមារ** ព្រះរាជាទ្រង់ស្ថាបនាព្រះរាជឱរសដែលទ្រង់ចម្រើនវ័យហើយនោះទុកក្នុងតំណែងឧបរាជ ។ ព្រះអគ្គមហេសីរបស់សោត្ថិសេនកុមារព្រះនាមថា **សម្ពុលា** មានព្រះរូបឆោមស្អាតដល់ព្រមទៅដោយសរីរៈ ឥន្ទ្រិយផូរផង់ ប្រាកដ

ដូចជាអណ្តាតប្រទីបឆេះហើយក្នុងទីស្ងប់ខ្យល់ ។ ក្នុងវេលាតមក រោគឃ្លង់ក៏បានកើតឡើងក្នុងសរីរៈរបស់សោត្ថិសេនកុមារ ។ ពួកពេទ្យមិនអាចដាក់ថ្នាំរក្សាបាន ។ កាលរោគឃ្លង់បែក ព្រះរាជកុមារក៏ជាអ្នកដែលប្រជាជនគប្បីរង្កៀស ដល់នូវសេចក្តីក្តៅក្រហាយ ទ្រង់បានត្រិះរិះថា រាជ្យសម្បត្តិនឹងមានប្រយោជន៍អ្វីដល់យើង យើងនឹងទៅស្លាប់យ៉ាងអនាថាក្នុងព្រៃ" ហើយក្រាបទូលព្រះរាជបិតាឲ្យទ្រង់ជ្រាប លះបង់ដំណាក់ស្តេចយាងចេញទៅ ព្រះនាងសម្ពុលាជាអគ្គមហេសី សូម្បីព្រះរាជកុមារទូលសូមឲ្យត្រឡប់ដោយឧបាយច្រើនយ៉ាង ក៏មិនព្រមត្រឡប់ឡើយ បានទូលថា "ខ្ញុំម្ចាស់នឹងទៅបដិបត្តិចំពោះព្រះអង្គជាព្រះស្វាមីក្នុងព្រៃ" ហើយបានតាមស្តេចទៅជាមួយ ។ ព្រះរាជកុមារចូលទៅដល់ព្រៃហើយ សាងបណ្ណសាលាអាស្រ័យនៅក្នុងប្រទេសដែលសម្បូរដោយមូលផលាផល មានទម្ងន់កំពង់ទឹកដែលរកបានងាយ ។ ឯព្រះរាជធីតាជាព្រះជាយា ក៏ទ្រង់

បដិបត្តិបម្រើព្រះរាជកុមារ ។ ព្រះនាងប្រណិប័តន៍យ៉ាងណា គឺ ព្រះនាងក្រោកអំពីព្រឹកបោសសម្អាតអាស្រមបទ ដងទឹកប្រើ ទឹកផឹកយកទៅតម្កល់ទុក នាំឈើស្ទន់ និងទឹកខ្ពុរព្រះឱស្ឋចូលទៅថ្វាយ លុះខ្ពុរព្រះឱស្ឋហើយ ក៏បុកថ្នាំផ្សេងៗ លាបដំបៅរបស់ព្រះស្វាមី ហើយឲ្យសោយផលាផលដែលមានរសផ្អែមឆ្ងាញ់ កាលព្រះស្វាមីខ្ពុរព្រះឱស្ឋ លាងព្រះហត្ថហើយ ទូលថា "បពិត្រព្រះស្វាមីអ្នកទ្រទ្រង់គុណដ៏ប្រសើរ សូមព្រះស្វាមីប្រោសកុំមានសេចក្តីប្រមាទ" ថ្វាយបង្គំហើយ កាន់ល្អី ចបជីក និងតម្ពក់ចូលព្រៃ ស្វែងរកផលាផលនាំ ផ្លែឈើមកទុកក្នុងទីមួយ ហើយធ្នាំងដាក់ទឹកមកងូតដល់សោត្ថិសេនរាជកុមារជាព្រះស្វាមី ដោយគ្រឿងងូត មានលម្អិតផ្សេងៗ និងដុំដីស្អិត ហើយបង្អោនផលាផលដែលមានរសផ្អែមចូលទៅថ្វាយទៀត ។ គ្រាសោយស្រេចហើយ ព្រះនាងក៏បង្អោនទឹកផឹកដែលអប់ទុកចូលទៅថ្វាយ ។ ព្រះអង្គឯងទើបបរិភោគផលាផល ហើយ

ចាត់ចែងឈើរៀបជាព្រះទែនត្រៀមទុក កាលព្រះស្វាមីផ្ទំលើឈើដែលរៀបហើយនោះ ទ្រង់ក៏លាងព្រះបាទ ធ្វើការគក់ប្រេបាច់ព្រះសរីរៈកាយ ហើយចូលទៅដេកក្បែរទីព្រះបន្ទំ ព្រះនាងសម្ពុលាទ្រង់បដិបត្តិព្រះស្វាមីដោយឧបាយយ៉ាងនេះឯង ។

ថ្ងៃមួយ ព្រះនាងកំពុងបេះផ្លែឈើនៅក្នុងព្រៃ ក្រឡេកឃើញថ្លុកទឹកជិតជើងភ្នំមួយកន្លែង ទើបដាក់ល្អីអំពីសីសៈទុកត្រង់មាត់ថ្លុកទឹក គិតថា យើងនឹងងូតទឹក ហើយចុះទៅងូតទឹកដុសសរីរកាយដោយរមៀត រហូតព្រះវរកាយស្អាតល្អហើយ ឡើងមកឈរស្លៀកដណ្តប់សំពត់ដែលក្រងដោយសម្បកឈើ នៅត្រង់មាត់ថ្លុកទឹក ខណៈនោះ រស្មីនៃព្រះសរីរកាយរបស់ព្រះនាង ជាហេតុឲ្យព្រៃមានពន្លឺតែមួយ ។

ខណៈនោះ អសុរម្នាក់ត្រាច់ស្វែងរកអាហារ ឃើញព្រះនាងសម្ពុលាក៏មានចិត្តប្រតិព័ទ្ធស្រឡាញ់ ទើបពោល ២ គាថាថា

[៥៣៥] កា វេធមានា គិរិកន្ទរាយំ

ឯកា តុវំ តិដ្ឋសិ សញ្ញិតូរុ

បុដ្ឋាសិ មេ បាណិបមេយ្យមជ្ឈេ

អក្ខាហិ មេ នាមញ្ច ពន្ធវេ ច ។

នែនាង អ្នកមានភ្លៅមូល នាងជានរណាមកឈររង្គោញ័រ នៅតែម្នាក់ឯងត្រង់មាត់ទឹក ម្នាលនាងអ្នកមានជង្គង់ខ្ទួនប្រហោម ដោយដៃ យើងសូមសួរនាង ចូរប្រាប់ឈ្មោះ និងផៅពង្សដល់ យើងចុះ ។

ឱភាសយំ វនំ រម្មំ សីហព្យគ្ឃនិសេវិតំ

កា វា ត្វមសិ កល្យាណី កស្ស វា ត្វំ សុមជ្ឈិមេ

អភិវាទេមិ តំ ភទ្ទេ ទានវាហំ នមត្ថុ តេ ។

នែនាងអ្នកមានចង្កេះមូលក្លំ នាងជានរណា ឬថា ជាកូន ប្រពន្ធរបស់នរណា ជាអ្នកមានរូបរាងដ៏ល្អស្អាត ធ្វើព្រៃជាទី

អាស្រ័យនៅនៃសីហៈ និងខ្លាធំឲ្យគួររីករាយ ស្វាងស្វៃហើយ នាងដ៏ចម្រើន យើង គឺ អសុរសូមសំពះនាង សូមការគោរពចូរមានដល់នាង ។

បណ្ដាបទទាំងនោះ បទថា **កា វេធមានា** "ជានរណាមកឈររន្ធត់ញ័រ" សេចក្ដីថា ព្រោះនាងងូតទឹកក្នុងថ្នាទឹក ព្រោះតែត្រជាក់ទើបឈររន្ធត់ញ័រ ។ បទថា **សញ្ញតូរុ**[១] "អ្នកមានភ្លៅមូល" សេចក្ដីថា អ្នកមានភ្លៅរៀវមូល ។ បទថា **បាណិបមេយ្យមជ្ឈេ** "អ្នកមានចង្កេះគួរប្រលោមដោយដៃ" បានដល់ ម្នាលនាងអ្នកមានរូបរាងដែលគួរឲ្យប្រលោមដោយដៃ ។ បទថា **កា វា ត្វំ**[២] "នាងជានរណាឬ" សេចក្ដីថា នាងជានរណា ឬថា ជាកូនប្រពន្ធរបស់នរណា ។ បទថា **អភិវាទេមិ** "សូមសំពះនាង" បានដល់ យើងសូមសំពះនាង ។ បទថា **ទានវាហំ** "យើង គឺ អសុរ" សេចក្ដីថា អសុរនោះបានពោលថា "យើង គឺ អសុរ សូមការគោរពនេះ ចូរមាន

---

១.បិដក. សញ្ចិតូរុ , ២. កស្ស វា ត្វំ ។

ដល់នាង យើងសូមផ្គងអញ្ជលីដល់នាង" ។

ព្រះនាងសម្ពុលាបានស្តាប់ពាក្យរបស់អសុរនោះហើយ បាន ពោល ៣ គាថាថា

[៥៣៦] យោ បុត្តោ កាសិរាជស្ស សោត្ថិសេនោតិ តំ វិទូ

តស្សាហំ សម្ពុលា ភរិយា ឯវំ ជានាហិ ទានវ

អភិវាទេមិ ភទ្ទន្តេ សម្ពុលាហំ នមត្ថុ តេ ។

ជនទាំងឡាយស្គាល់ឱរសរបស់ព្រះបាទកាសី មាននាមថា សោត្ថិសេនកុមារ យើងឈ្មោះសម្ពុលាជាជាយារបស់សោត្ថិសេនកុមារនោះ ម្នាលអសុរ អ្នកចូរដឹងយ៉ាងនេះ អ្នកដ៏ចម្រើន យើងឈ្មោះសម្ពុលាសូមសំពះអ្នក សូមការគោរពចូរមានដល់អ្នក ។

វេទេហបុត្តោ ភទ្ទន្តេ វនេ វសតិ អាតុរោ

តមហំ រោគសម្មត្តំ ឯកា ឯកំ ឧបដ្ឋហំ ។

អ្នកដ៏ចម្រើន ព្រះឱរសរបស់ព្រះបាទវិទេហរាជ ក្តៅក្រ-ហាយនៅក្នុងព្រៃ យើងមកព្យាបាលព្រះអង្គអ្នកត្រូវរោគបៀតបៀនដល់ខ្លួន ។

អហញ្ច វនមុញ្ឆាយ មធុមំសំ មិគាពិលំ
យទាហរាមិ តំភក្ខោ តស្ស នូនជ្ជ នាធតិ ។

មួយទៀត យើងមកត្រាច់ស្វែងរកសម្បុកឃ្មុំ និងសាច់ម្រឹគដែលជារបស់ព្រៃ យើងរកអាហារយ៉ាងណាទៅ ព្រះស្វាមីរបស់យើងក៏បានសោយអាហារយ៉ាងនោះ ថ្ងៃនេះកាលមិនបានអាហារនោះ លោកគង់នឹងស្រេកឃ្លានដោយពិត ។

បណ្តាបទទាំងនោះ បទថា វេទេហបុត្តោ "ឱរសរបស់ព្រះបាទវិទេហរាជ" បានដល់ ព្រះកុមារជាវេទេហរាជបិយោរស ។ បទ ថា រោគសម្មត្តំ "ត្រូវរោគបៀតបៀន" បានដល់ ជាអ្នកត្រូវរោគបៀតបៀនហើយ ។ បទថា ឧបដ្ឋហី[១] "ព្យាបាល" សេចក្តី

១.បិដក. ឧបដ្ឋហំ ។

ថា យើងត្រូវព្យាបាល គឺ ប្រណិប័តន៍ស្តេច ។ បាឋៈថា **ឧបដ្ឋិតា** ដូច្នេះក៏មាន ។ បទថា **វនមុញ្ឆាយ** **“ត្រាច់ស្វែងរក... ជារបស់ព្រៃ”** សេចក្តីថា យើងត្រាច់ស្វែងរករបស់ព្រៃ ។ បទថា **មធុមំសំ** **“សម្បុកឃ្មុំ”** សេចក្តីថា (យើងត្រាច់ស្វែងរក) ផ្លែឈើ សម្បុកឃ្មុំ ដែលមិនមានកូន និងសាច់ម្រឹគដែលជាចំណែកសល់អំពីរាជសីហ៍ និងខ្លា ។ បទថា **តំភក្ខោ** **“អាហារដូច្នោះ”** សេចក្តីថា យើងនាំនូវអាហារណាទៅ ព្រះស្វាមីយើងក៏បានអាហារនោះសោយ ។ បទថា **តស្ស នូនជ្ជ** **“ថ្ងៃនេះ អាហារនោះ... ដោយពិត”** សេចក្តីថា កាលព្រះស្វាមីរបស់យើងមិនបានសោយអាហារក្នុងថ្ងៃនេះ ព្រះសរីរៈគង់នឹងក្រៀមស្វិតដូចផ្កាបទុម ដែលគេហាលថ្ងៃដូច្នោះ ។ បទថា **នាជតិ** **“អត់ឃ្លាន”** បានដល់ ស្គម គឺ ស្គាំងស្គមទៅ ។

តអំពីនោះ ជាគាថាពោលចរចាគ្នារវាងអសុរ និងព្រះនាងសម្ពុលា ដូចតទៅនេះ

[៥៣៧] កឹ វនេ រាជបុត្តេន អាតុរេន ករិស្សសិ
សម្ពុលេ បរិចិណ្ណេន អហំ កន្តា ភវាមិ តេ ។

នាងសម្ពុលា នាងនឹងធ្វើអ្វីបានជាមួយរាជបុរសអ្នកក្តៅ-ក្រហាយដោយរោគនៅក្នុងព្រៃ យើងនឹងជាកស្តាររបស់នាង ។

សោកដ្ដាយ ទុរត្តាយ កឹ រូបំ វិជ្ជតេ មម
អញ្ញំ បរិយេស ភទ្ទន្តេ អភិរូបតរំ មយា ។

អសុរដ៏ចម្រើន រូបរាងរបស់យើងដែលគួរអាណិតដោយសេចក្តីសោក ជាអត្តភាពលំបាកគ្មានអ្វីស្អាតទេ សូមអ្នកចូរស្វែងរកស្ត្រីដទៃដែលមានរូបរាងល្អស្អាតជាងយើងចុះ ។

ឯហិមំ គិរិមារុយ្ហ ភរិយា មយ្ហំ ចតុស្សតា
តាសំ ត្វំ បវរា ហោហិ សព្វកាមសមិទ្ធិនី ។

មកចុះនាង សូមឡើងមកកាន់ភ្នំនេះ នាងចូរជាធំជាងភរិយា ៤០០ នាក់របស់យើង នាងនឹងសម្រេចសេចក្តីបំណងគ្រប់

យ៉ាង ៗ

ននុ តារកវណ្ណាភេ យន្តិញ្ចិ មនសិច្ឆសិ
សព្វន្តំ បចុរំ មយ្ហំ រមស្សុជ្ជ មយា សហ ៗ

ប្អូនស្រីអ្នកសម្បុរភ្លឺផ្លេកដូចផ្កាយ នាងនឹងបានវត្ថុណាមួយដោយពិត វត្ថុទាំងអស់របស់រកបានងាយ សូមនាងមកអភិរម្យជាមួយយើងក្នុងថ្ងៃនេះចុះ ៗ

នោ ចេ តុវំ មហេសេយ្យំ សម្ពុលេ ការយិស្សសិ
អលំ ត្វំ បាតរាសាយ បណ្ហេ ភក្ខា ភវិស្សសិ ៗ

សម្ពុលាប្អូនស្រី ប្រសិនបើមិនព្រមជាមហេសីរបស់យើង ប្រហែលជានាងនឹងត្រូវជាភក្សាហាររបស់យើង ក្នុងព្រឹកនេះដោយពិត ៗ

តញ្ច សត្តជដា លុទ្ទា កឡារោ បុរិសាទកោ
វនេ នាថំ អបស្សន្តី សម្ពុលំ អគ្គហី កុជេ ៗ

គ្រាអសុរអ្នកមានជដា ៧ ជាន់ដ៏អាក្រក់ មានចង្កូមចេញខាងក្រៅមាត់ ស៊ីមនុស្សជាអាហារ បានចាប់ត្រង់ដើមដៃនាងសម្ពុលា ដែលមិនឃើញមានទីពឹងក្នុងព្រៃ ។

អធិបន្នា បិសាចេន លុទ្ទេនាមិសចក្ខុនា
សា ច សត្តុវសម្បត្តា បតិមេវានុសោចតិ ។

នាងសម្ពុលា ត្រូវបិសាចដ៏អាក្រក់បំណងអាមិសគំរាមហើយ ត្រូវធ្លាក់នៅក្នុងអំណាចសត្រូវ សោកសៅដល់ព្រះស្វាមីប៉ុណ្ណោះ ខ្សឹកខ្សួលថា

ន មេ ឥទំ តថាទុក្ខំ យំ មំ ខាទេយ្យ រក្ខសោ
យញ្ច មេ អយ្យបុត្តស្ស មនោ ហេស្សតិ អញ្ញថា ។

សូម្បីយក្ខនឹងទំពាស៊ីយើង យើងក៏មិនមានសេចក្តីទុក្ខ តែថាព្រះហឫទ័យនៃព្រះអយ្យបុត្តរបស់យើង សង្ស័យក្នុងប្រការដទៃទេ ។

ន សន្តិ ទេវា បវសន្តិ នូន

ន ហិ នូន សន្តិ ឥធ លោកបាលា

សហសា ករោន្តានសញ្ញតានំ

ន ហិ នូន សន្តិ បដិសេធិតារោ ។

ទេវតាទាំងឡាយគង់នឹងមិនមានដោយពិត ស្តេចលោក-

បាលក៏គង់មិនមានក្នុងលោកនេះដោយពិត កាលយក្ខជាអ្នក

មិនសង្រួមធ្វើនូវអាការដ៏អាក្រក់ នឹងរកអ្នកជួយហាមឃាត់

មិនមានឡើយ ។

បណ្តាបទទាំងនោះ បទថា បរិចិណ្ណេន "មានរោគ" សេចក្តី

ថា នាងនឹងធ្វើអ្វីបានជាមួយរាជបុត្តដែលប្រកបដោយរោគនោះ ។

បទថា សោកដ្ដាយ "អ្នកក្តៅក្រហាយ" បានដល់ អ្នកក្តៅក្រហាយ

ដោយសេចក្តីសោក ។ បាឋៈថា សោកដ្ឋាយ ដូច្នេះក៏មាន សេចក្តី

ថា តាំងនៅហើយក្នុងសេចក្តីសោក ។ បទថា ទុរត្តាយ "លំបាក"

សេចក្តីថា មានអត្តភាពដល់ហើយនូវសេចក្តីលំបាក កំព្រា ។ បទ ថា **ឯហិមំ** “**សូមឡើងមកកាន់ភ្នំនេះ**” សេចក្តីថា អសុរលួងលោម ថា “នាងកុំគិតថា ខ្លួនមានរូបរាងអាក្រក់ឡើយ ចូរទៅកាន់ទិព្វវិមាន របស់យើងលើកំពូលភ្នំនេះ ចូរឡើងកាន់ភ្នំនេះចុះ” ។

បទថា **ចតូសតា**[១] “**៤០០ នាក់**” សេចក្តីថា សូម្បីក្នុងវិមាន នោះ បងមានករិយាដទៃដល់ ៤០០ នាក់ ។ បទថា **សព្វត្ថំ** “**គ្រប់ យ៉ាង**” សេចក្តីថា អសុរនោះពោលថា “នាងប្រាថ្នាគ្រឿងឧបភោគ បរិភោគ សំពត់ស្លៀកដណ្តប់ និងគ្រឿងអាករណៈជាដើមយ៉ាងណា មួយ វត្ថុទាំងអស់នោះសម្រាប់បងមានច្រើនណាស់ រកបានងាយ ដូច្នោះ នាងកុំលំបាកចិត្តថា ខ្លួនជាអ្នកកំព្រា មកចុះ មករួមអភិ-រម្យរីករាយជាមួយបង” ។ បទថា **មហេសេយ្យំ** “**មហេសី**” ន័យ ថា នែនាងសម្ពលាដ៏ចម្រើន បើនាងមិនព្រមជាមហេសីយើងសោត

១.បិដក. ចតុស្សតា ។

នាងក៏ចូរត្រៀមខ្លួនដើម្បីជាអាហារព្រឹករបស់យើង ព្រោះហេតុនោះ យើងនឹងនាំនាងទៅកាន់វិមានដោយពលការ កាលនាងមិនព្រមធ្វើតាមយើងនោះ ថ្ងៃនេះនាងនឹងជាអាហាររបស់យើងក្នុងព្រឹកនេះឯងតែម្តង ។ បទថា **តញ្ច** *"នោះ"* សេចក្តីថា អសុរនោះប្រកបដោយផ្លូងសក់ ៧ ជាន់ អាក្រក់ មានចង្កូមដុះចេញក្រៅមាត់ លុះពោលយ៉ាងនេះហើយ បានចាប់ត្រង់ដើមដៃនាងសម្ពុលា ដែលមិនឃើញមានអ្វីជាទីពឹងរបស់ខ្លួនបានក្នុងព្រៃនោះ ។ បទថា **អធិបន្នា** *"គំរាម"* បានដល់ គ្របសង្កត់ហើយ ។ បទថា **អាមិសចក្ខុនា** *"បំណាងនូវអាមិស"* បានដល់ ឡេះឡោះព្រោះត្រូវកិលេសគ្របសង្កត់ ។ បទថា **បតិមេវ** *"ដល់ព្រះស្វាមីប៉ុណ្ណោះ"* សេចក្តីថា មិនបានគិតដល់ខ្លួន សោកសៅទៅដល់ព្រះស្វាមីប៉ុណ្ណោះ ។ បទថា **មនោ ហេស្សតិ** *"ព្រះហឫទ័យ... នឹងជា"* សេចក្តីថា គ្រាព្រះអង្គទ្រង់ជ្រាបថា យើងមកយឺតយូរ ព្រះទ័យរបស់ព្រះអង្គនឹងសង្ស័យទៅក្នុងរឿងផ្សេងៗ ។

បទថា ន សន្តិ ទេវា "ទេវតាទាំងឡាយគង់នឹងមិនមាន" សេចក្ដីថា នាងសម្ពុលាត្រូវអសុរចាប់ត្រង់ដៃ កាលនឹងធ្វើការសរសើរទេវតា ទើបពោលពាក្យនេះ ។ បទថា លោកបាលា "ស្ដេចលោកបាល" សេចក្ដីថា នាងសម្ពុលាពោលបរិទេវនាការថា "បណ្ដាទេវតាអ្នកមានសីលបែបនេះ ស្ដេចលោកបាលជាអ្នករក្សាលោក នឹងមិនមានក្នុងលោកនេះដោយពិត" ។

លំដាប់នោះ ដោយតេជះនៃសីលរបស់ព្រះនាង ពិភពរបស់សក្កទេវរាជក៏ញាប់ញ័រ បណ្ឌុកម្ពលសិលាសនៈសម្ដែងអាការក្ដៅ ។ ស្ដេចសក្កៈទើបសម្លឹងមើល ទ្រង់ជ្រាបហេតុការណ៍នោះហើយ ក៏ទ្រង់កាន់វជិរាវុធស្ដេចមកដោយរហ័ស ប្រថាប់ឈរលើសីសៈរបស់អាសុរយក្ស ត្រាស់ព្រះគាថាក្រៅនេះថា

[៥៣៨] ឥត្ថីនមេសា បវរា យសស្សិនី

សន្តា សមា អគ្គិរិវុគ្គតេជា

តញ្ចេ តុវំ រក្ខសាទេសិ កញ្ញំ

មុទ្ធា ច ហិ សត្តធា តេ ផលេយ្យ

មា ត្វំ ទហិ មុញ្ច បតិព្វតាយ ។

ស្រីនេះមានយសប្រសើរជាងស្រីទាំងឡាយ ស្ងប់ស្ងៀម រៀបរយ មានតេជះផ្សាយឡើងដូចភ្លើង នែអារក្ស បើអ្នកនឹងស៊ីនាង សីសៈរបស់អ្នកនឹងបែកជា ៧ ចំណែក អ្នកកុំធ្វើឲ្យនាងក្តៅ-ក្រហាយ ចូរលែងនាងចុះ ព្រោះនាងជាស្រីបដិបត្តិស្វាមី ។

បណ្តាបទទាំងនោះ បទថា សន្តា "ស្ងប់ស្ងៀម" សេចក្តីថា ស្ងប់រម្ងាប់ ន័យម្យ៉ាងទៀត សំដៅដល់ជាបុគ្គលឆ្លាត សម្បូរដោយសេចក្តីដឹង ។ បទថា សមា "រៀបរយ" សេចក្តីថា ប្រាសចាកការមិនស្មើតាមផ្លូវកាយជាដើម ។ បទថា អទេសិ "នឹងស៊ី" បានដល់នឹងទំពាស៊ី ។ បទថា ផលេយ្យ "នឹងបែក" ន័យថា សីសៈរបស់អ្នកយើងនឹងវាយដោយឥន្ទ្រាជិកាវុធនេះឲ្យបែកដោយពិត ។ បទថា

មា តុំ ទហិ “អ្នកកុំធ្វើឲ្យនាងក្តៅក្រហាយ” សេចក្តីថា អ្នកកុំធ្វើឲ្យនាងអ្នកបដិបត្តិស្វាមីត្រូវក្តៅក្រហាយ ។

អសុរស្តាប់ដូច្នោះ ទើបលែងព្រះសម្ពុលា សក្កទេវរាជទ្រង់ត្រិះរិះថា “អសុរនេះ គប្បីធ្វើដូច្នេះទៀតដោយពិត” ទើបទ្រង់ចងអសុរនោះទុកដោយច្រវាក់ទិព្វ ហើយលែងទុកក្នុងភ្នំទី ៣ ដើម្បីមិនឲ្យវាមកបានតទៅទៀត ទើបទ្រង់ឱវាទដល់រាជធីតាដោយអប្បមាទធម៌ ហើយស្តេចទៅកាន់ទិព្វស្ថានរបស់ព្រះអង្គ ។ ចំណែកព្រះនាងសម្ពុលារាជធីតា គ្រាព្រះអាទិត្យអស្តង្គតហើយ បានត្រឡប់ទៅដល់អាស្រមដោយពន្លឺព្រះច័ន្ទ ។

ព្រះសាស្តាកាលនឹងប្រកាសសេចក្តីនោះ បានត្រាស់ ៨ គាថា មានសេចក្តីថា

[៥៣៩] សា ច អស្សមាគច្ឆិ បមុត្តា បុរិសាទកា
និឌ្ឌំ ផលីនសកុណីវ[១] គតសិង្គីវ អាលយំ ។

១.ម. និប្បលីនសកុណីវ ។

ព្រះនាងសម្ពុលានោះ រួចផុតហើយអំពីយក្សស៊ីមនុស្ស ត្រឡប់មកកាន់អាស្រម ដូចមេបក្សីមានកូនតូច មានអន្តរាយ ហើរមកកាន់សម្បុក ឬដូចមេគោទឹកដោះដែលនៅឆ្ងាយអំពីកូនតូច ដូច្នោះ ។

សា តត្ថ បរិទេវេសិ រាជបុត្តី យសស្សិនី
សម្ពុលា ឧតុមត្តក្ខា វនេ នាថំ អបស្សន្តី ។

ព្រះនាងសម្ពុលារាជបុត្រីដ៏មានយស កាលមិនឃើញព្រះស្វាមីអ្នកជាទីពឹងរបស់ខ្លួនក្នុងព្រៃ ក៏មានព្រះនេត្រស្រវាំងព្រោះកម្តៅ ទ្រង់ព្រះកន្សែងហើយក្នុងទីនោះ ។

សមណេ ព្រាហ្មណេ វន្ទេ សម្បន្នចរណេ ឥសេ
រាជបុត្តំ អបស្សន្តី តុម្ហម្ហិ សរណំ គតា ។

កាលមិនឃើញព្រះរាជស្វាមី ព្រះនាងក៏អង្វរសំពះសមណព្រាហ្មណ៍ និងឥសីទាំងឡាយ អ្នកសម្បូរដោយចរណៈថា

ខ្ញុំសូមជល់លោកទាំងឡាយជាទីពឹង ។

វន្ទេ សីហេ ច ព្យគ្ឃេ ច យេ ច អញ្ញេ វនេ មិគា
រាជបុត្តំ អបស្សន្តី តុម្ហម្ហិ សរណំ គតា ។

កាលមិនឃើញព្រះរាជស្វាមី ព្រះនាងក៏អង្វរសំពះរាជសីហ៍ ខ្លាធំ និងពួកម្រឹគដទៃក្នុងព្រៃថា ខ្ញុំសូមជល់អ្នកទាំងឡាយជាទីពឹង ។

តិណាលតានិ ឱសធ្យោ បព្វតានិ វនានិ ច
រាជបុត្តំ អបស្សន្តី តុម្ហម្ហិ សរណំ គតា ។

កាលមិនឃើញព្រះរាជស្វាមី ព្រះនាងក៏អង្វរសំពះទេវតាដែលស្ថិតនៅនឹងគុម្ពស្មៅ លតាជាតិ និងត្រង់ភ្នំ ដងព្រៃ រហូតដូងតារាក្នុងអាកាសថា ខ្ញុំសូមជល់លោកទាំងឡាយជាទីពឹង ។

វន្ទេ ឥន្ទីវរីសាមំ រត្តិនក្ខត្តមាលិនី[១]

---

១.ម. រត្តីរក្ខត្តមាលិនី ។

រាជបុត្តំ អបស្សន្តី តុម្ហម្ហិ សរណំ គតា ។

កាលមិនឃើញព្រះរាជស្វាមី ព្រះនាងក៏អង្វរសំពះពួកផ្កាយនក្ខត្តឫក្សក្នុងយាមរាត្រី ដែលមានវណ្ណៈស្មើដោយផ្ការាជព្រឹក្សថា ខ្ញុំសូមដល់លោកទាំងឡាយជាទីពឹង ។

វន្ទេ ភគិរសឹ គង្គំ សវន្តីនំ បដិគ្គហំ
រាជបុត្តំ អបស្សន្តី តុម្ហម្ហិ សរណំ គតា ។

កាលមិនឃើញព្រះរាជស្វាមី ព្រះនាងក៏អង្វរសំពះទេវតាដែលស្ថិតនៅទីឯទន្លេឈ្មោះ ភគិរសី ជាទីទទួលនូវការហូរមកនៃស្ទឹងដទៃថា ខ្ញុំសូមដល់អ្នកជាទីពឹង ។

វន្ទេ អហំ បព្វតរាជ- [សេដ្ឋំ] ហិមវន្តំ សិលុច្ចយំ
រាជបុត្តំ អបស្សន្តី តុម្ហម្ហិ សរណំ គតា ។

កាលមិនឃើញព្រះរាជស្វាមី ព្រះនាងក៏អង្វរសំពះទេវតាដែលស្ថិតនៅស្ដេចភ្នំហិមពាន្ត ដែលសុទ្ធទៅដោយថ្មថា ខ្ញុំសូម

ដល់អ្នកជាទីពឹង ។

បណ្ដាបទទាំងនោះ បទថា និឌ្ឌំ ផលិនសកុណីវ[១] "ដូចជាមេបក្សីដែលមានកូនតូចមានអន្តរាយហើរទៅកាន់សម្បុក" សេចក្ដីថា មេបក្សីដែលឈ្មោះថា សកុណីមានកូនតូច ព្រោះជាទីផលិតសកុណបោតកៈទាំងឡាយ ពាំចំណីដោយចំពុះហើយហើរត្រឡប់មកសម្បុក ព្រោះអន្តរាយណាមួយ យ៉ាងណា មួយទៀត មេគោទឹកដោះដែលមានការអាល័យក្នុងកូនតូច គប្បីត្រឡប់មកកាន់ទីនៅដែលកូនតូចចេញទៅហើយ គឺ ក្រោលដែលសូន្យចាកកូនតូចយ៉ាងណា ព្រះនាងសម្មុលានោះ ក៏បានមកកាន់អាស្រមដែលស្ងាត់សូន្យដូច្នោះ ។

ពិតណាស់ គ្រានោះ កាលព្រះនាងសម្មុលាត្រឡប់មកយឺតយូរ សោត្ថិសេនកុមារទ្រង់គិតថា "ដែលឈ្មោះថា ស្រីជាមនុស្ស

---

១.ម. និប្បលីនសកុណីវ ។

ឡេះឡោះ នឹងគប្បីនាំបច្ចាមិត្តរបស់យើងមក" ទើបស្តេចចេញចាក បណ្ណសាលា ចូលទៅអន្ទ្រយពួននៅចន្លោះគុម្ពឈើ ។ ព្រោះហេតុ នោះ ទើបត្រាស់សេចក្តីទុកដូចតទៅនេះ ។ បទថា **ឧត្តុមត្តក្ខា** "**មាន ព្រះនេត្រស្រវាំងព្រោះកម្តៅ**" ន័យថា មានព្រះនេត្រស្រវាំងព្រោះ កម្តៅដែលកើតអំពីកម្លាំងនៃសេចក្តីសោក ។ បទថា **អបស្សន្តី** "**កាលមិនឃើញ**" សេចក្តីថា ព្រះនាងសម្ពុលាកាលមិនឃើញព្រះ ស្វាមីដែលជាទីពឹងរបស់ខ្លួន ក៏បរិទេវនាការត់ទៅមកនៅក្នុងព្រៃ នោះ ។

បណ្តាបទទាំងនោះ បទថា **សមណេ ព្រាហ្មណេ** "**សមណ- ព្រាហ្មណ៍**" បានដល់ សមណព្រាហ្មណ៍អ្នករម្ងាប់បាប បណ្តេតនូវ បាបចេញហើយ ។ បទថា **សម្បន្នចរណេ** "**អ្នកសម្បូរទៅដោយ ចរណៈ**" សេចក្តីថា និងក្រាបសំពះព្រះឥសីដែលដល់ព្រមដោយ ចរណៈ ដោយអំណាចនៃសមាបត្តិ ៨ ព្រមទាំងសីល អធិប្បាយ

ថា គ្រាព្រះនាងសម្តុលាពោលអង្វរយ៉ាងនេះហើយ កាលមិនឃើញព្រះឱរស ទើបបរិទេវនាការថា "ខ្ញុំសូមដល់លោកទាំងឡាយជាទីពឹង បើលោកឃើញស្ថានទីដែលព្រះស្វាមីរបស់ខ្ញុំនៅហើយ សូមប្រាប់ផងចុះ" ។ សូម្បីក្នុងគាថាដ៏សេសទាំងឡាយ ក៏មានន័យនេះដូចគ្នា ។

បទថា **តិណាលតានិ ឱសធ្យោ** "**ដែលស្ថិតនៅត្រង់គុម្ពស្មៅលតាជាតិ... រហូតដល់ផ្កាយក្នុងអាកាស**" សេចក្តីថា ព្រះនាងក៏សំពះអង្វរទេវតាដែលស្ថិតនៅនឹងគុម្ពស្មៅ ដែលមានស្រោយខាងក្នុង មានខ្លឹមខាងក្រៅ សំពះអង្វរទេវតាដែលស្ថិតនៅនឹងលតាជាតិនិងផ្កាយក្នុងអាកាស ។ ព្រះនាងសម្តុលាពោលគាថានេះ សំដៅដល់ទេវតាទាំងឡាយ ដែលកើតហើយក្នុងលតាជាតិជាដើម ។ បទថា **ឥន្ទីវរីសាមំ** "**មានវណ្ណៈដូចផ្កាពជព្រឹក្ស**" បានដល់ ទេវតាអ្នកមានវណ្ណៈស្មើដូចផ្កាពជព្រឹក្ស ។ បទថា **តុម្ហម្ហិ** "**ដល់លោកជា**"

សេចក្តីថា ព្រះនាងសម្ពុលាពោលថា **តំបិ អម្ហិ** (ខ្ញុំសូមជល់សូម្បី លោកថាជាទីពឹង) សំដៅដល់ (ផ្កាយ) ក្នុងយាមរាត្រីនោះ ។ បទ ថា **កតិរសឹ** "ទន្លេឈ្មោះកតិរសី" បានដល់ ទន្លេដែលមានឈ្មោះ ដោយបរិយាយយ៉ាងនេះ ។ បទថា **វសន្ធីនំ**[១] "**ជាទីទទួល**" គឺ ព្រះនាងសម្ពុលាពោលទុក សំដៅដល់ទេវតាអ្នកកើតនៅទីងទន្លេ ដែលជាទីទទួលនូវស្ទឹងទាំងឡាយដទៃដ៏ច្រើននោះឯង ។ សូម្បីទេវតា អ្នកស្ថិតនៅទីងព្រៃហិមពាន្ត ក៏មានន័យនេះដូចគ្នា ។

សោត្ថិសេនកុមារជាព្រះស្វាមី ទតព្រះនេត្រឃើញព្រះនាងប-រិទេវនាការយ៉ាងនេះ ទើបទ្រង់ត្រិះរិះថា "នាងនេះយំសោកក្រៃលែង តែថា យើងមិនដឹងការប្រព្រឹត្តទៅរបស់នាងឡើយ បើនាងធ្វើដូច្នេះ ព្រោះស្នេហាក្នុងយើង គួរដួងហឫទ័យរបស់នាងនឹងបែក យើងនឹង សាកល្បងនាង" ហើយស្តេចទៅប្រថាប់គង់ត្រង់ទ្វារបណ្ណសាលា ។

---

១.បិដក. សវន្តីនំ ។

ព្រះនាងសម្មុលាក៏យំខ្សឹកខ្សួលដើរទៅកាន់ទ្វារបណ្ណសាលា សំពះព្រះបាទព្រះស្វាមីហើយទូលថា "បពិត្រព្រះស្វាមីអ្នកទ្រទ្រង់គុណដ៏ប្រសើរ ព្រះអង្គស្តេចទៅណាទើបនឹងមក" ។

លំដាប់នោះ សោត្ថិសេនកុមារទើបប្រាប់ព្រះនាងថា "នាងដ៏ចម្រើន ក្នុងថ្ងៃដទៃៗ នាងមិនធ្លាប់មកក្នុងវេលានេះឡើយ ថ្ងៃនេះនាងមកក្នុងវេលាយប់ងងឹត" កាលនឹងត្រាស់សួរ ទើបត្រាស់គាថាថា

[៥៤០] អតិសាយំ វតាគច្ឆិ រាជបុត្តី យសស្សិនី
កេន នុជ្ជ សមាគច្ឆិ កោ តេ បិយតរោមយា ។

ព្រះរាជបុត្រីអ្នកមានយស នាងមករហូតដល់យប់តែម្តងហ្ន៎ ថ្ងៃនេះ នាងមកជាមួយនរណា នរណាហ្ន៎ជាទីស្រឡាញ់របស់នាងក្រៃលែងជាងយើង ។

លំដាប់នោះព្រះនាងសម្មុលាទើបក្រាបទូលព្រះស្វាមីថា "ព្រះ

អយ្យបុត្តអើយ កាលខ្ញុំព្រះអង្គបេះផ្លែឈើហើយ ដើរមកក៏ជួបអសុរម្នាក់ វាមានចិត្តស្រឡាញ់ខ្ញុំព្រះអង្គ បានចាប់ដៃខ្ញុំព្រះអង្គទុកហើយនិយាយថា បើនាងមិនព្រមធ្វើតាមពាក្យរបស់យើង យើងនឹងស៊ីនាងជាអាហារ វេលានោះខ្ញុំម្ចាស់សោយសោកគិតដល់ព្រះអយ្យបុត្តតែម្នាក់ ទើបបានយំរៀបរាប់យ៉ាងនេះ” ហើយពោលគាថាថា

[៥៤១] ឥទំ ខោហំ តទាវោចំ  គហិតា តេន សត្តុនា

ន មេ ឥទំ តថា ទុក្ខំ  យំ មំ ខាទេយ្យ រក្ខសោ

យញ្ច មេ អយ្យបុត្តស្ស  មនោ ហេស្សតិ អញ្ញថា ។

ខ្ញុំម្ចាស់ត្រូវសត្រូវចាប់ទុក បានពោលពាក្យនេះថា សូម្បីយក្សនឹងស៊ីយើង យើងក៏មិនមានសេចក្តីទុក្ខ ប៉ុន្តែថា ទុក្ខមានក្នុងព្រះហឫទ័យរបស់ព្រះអយ្យបុត្តយើងនឹងសង្ស័យទៅក្នុងរឿងដទៃ ។

កាលព្រះនាងទូលនូវព្រឹត្តិការណ៍ដ៏សេសតទៅ ទើបទូលថា

"បពិត្រព្រះអយ្យបុត្ត ខ្ញុំម្ចាស់ត្រូវអសុរនោះចាប់ទុកហើយ កាលមិនអាចនឹងឲ្យវាលែងបាន ទើបធ្វើការយំប្តឹងដល់ទេវតា វេលានោះសក្កទេវរាជទ្រង់ប្រដាប់ដោយវជិរាវុធ ក៏ស្តេចមកប្រថាប់ឈរលើអាកាស គំរាមអាសុរឲ្យវាលែងខ្ញុំម្ចាស់ ហើយចងវាទុកដោយច្រវាក់ទិព្វ នាំទៅកាន់វាលនៃភ្នំទី ៣ ហើយស្តេចចៀសចេញទៅ ខ្ញុំម្ចាស់អាស្រ័យស្តេចទេវរាជទើបរួចជីវិតដូចបានទូលមកនេះ" ។

សោត្តិសេនរាជកុមារទ្រង់ស្តាប់រឿងរាវនោះហើយ ទើបទ្រង់ត្រាស់ថា "នែនាងដ៏ចម្រើនការអាងនោះចូរលើកទុកចុះ ដែលឈ្មោះថា សន្តានចិត្តរបស់មាតុគ្រាមលំបាកនឹងរកនូវសច្ចៈបាន ក៏ក្នុងព្រៃហិមពាន្តមានពួកព្រានព្រៃ តាបស វិជ្ជាធរ ជាដើមច្រើន នរណានឹងជឿចិត្តនាងបាន" ហើយត្រាស់គាថាថា

[៥៤២] ចោរីនំ ពហុពុទ្ធីនំ យាសុ សច្ចំ សុទុល្លភំ
ថីនំ ភាវោ ទុរាជានោ មច្ឆស្សេវោទកេ គតំ ។

កាពសច្ចៈលំបាកនឹងរកបានក្នុងស្រីចោរ អ្នកមានកលច្រើន ការប្រព្រឹត្តទៅរបស់ស្ត្រីទាំងឡាយដឹងបានលំបាក ដូចជាការប្រព្រឹត្តទៅរបស់ត្រីក្នុងទឹក ដូច្នោះ ។

ព្រះនាងសម្ពុលាបានឮព្រះតម្រាស់របស់ព្រះស្វាមី ទើបទូលថា "បពិត្រព្រះអយ្យបុត្ត ខ្ញុំម្ចាស់នឹងព្យាបាលព្រះអយ្យបុត្តដែលទ្រង់មិនជឿ ដោយកម្លាំងនៃសច្ចៈរបស់ខ្ញុំម្ចាស់" ហើយដងទឹកដាក់ពេញក្អម ធ្វើសច្ចកិរិយាស្រោចទឹកចុះលើសីសៈព្រះស្វាមី ហើយពោលគាថាថា

[៥៤៣] តថា មំ សច្ចំ បាលេតុ បាលយិស្សតិ ចេ មមំ
យថាហំ នាភិជានាមិ អញ្ញំ បិយតរំ តយា
ឯតេន សច្ចវជ្ជេន ព្យាធិ តេ វូបសម្មតុ ។

ខ្ញុំម្ចាស់មិនធ្លាប់ស្រឡាញ់បុរសដទៃក្រៃលែងជាងព្រះអង្គយ៉ាងណា សូមកាពសច្ចៈចូរជួយរក្សាខ្ញុំម្ចាស់ ដូច្នោះ បើរក្សាខ្ញុំ

ម្ចាស់ ក៏សូមជួយរក្សារហូតទៅ ដោយអំណាចសច្ចវាចានេះ សូមព្យាធិរបស់ព្រះអង្គចូរស្ងប់រម្ងាប់ចុះ ។

បណ្ដាបទទាំងនោះ តថា សព្ពុ បណ្ឌិតគប្បីប្រកបចូលជាមួយបទនេះថា ចេ មម[១] ។ មានអធិប្បាយថា ខ្ញុំម្ចាស់ទូលយ៉ាងណា បើជាការពិតរបស់ខ្ញុំម្ចាស់យ៉ាងនោះ ដូច្នេះ សូមការពិតចូរជួយរក្សាខ្ញុំម្ចាស់សូមប្បីក្នុងកាលឥឡូវនេះ និងក្នុងកាលតទៅ នឹងជួយរក្សាសូមប្បីក្នុងកាលអនាគត ឥឡូវនេះ សូមព្រះអង្គចូរស្ដាប់ពាក្យរបស់ខ្ញុំម្ចាស់ចុះ ។ បទថា **យថាហំ នាភិជានាមិ "ខ្ញុំម្ចាស់មិនធ្លាប់ស្រឡាញ់... យ៉ាងណា"** សេចក្ដីថា ក៏ក្នុងគម្ពីរទាំងឡាយលោកសរសេរទុកថា **តថា មំ សច្ចំ បាលេន** ពាក្យនោះមិនមានក្នុងអដ្ឋកថា ។

កាលព្រះនាងធ្វើសច្ចកិរិយាយ៉ាងនេះ ហើយស្រោចទឹកថ្វាយ

---

១.ឋិជក. ចេ មមំ ។

ប៉ុណ្ណោះ រោគឃ្លង់របស់ព្រះសោត្ថិសេនរាជកុមារក៏វិនាសមួយរំពេច ដូចស្នឹមមាសត្រូវលាងដោយទឹកជូរជូរច្នោះ ។ ទាំងពីរព្រះអង្គទ្រង់នៅក្នុងអាស្រមនោះ ២-៣ រាត្រីក៏ចេញចាកព្រៃធ្វើដំណើរទៅក្រុងពារាណសី ចូលទៅកាន់ព្រះឧទ្យាន ។

ព្រះរាជាទ្រង់ជ្រាបថា ព្រះរាជឱរស និងព្រះសុណិសាត្រឡប់មក ទើបស្ដេចទៅកាន់ព្រះឧទ្យាន ត្រាស់ឲ្យលើកស្វេតឆត្រថ្វាយសោត្ថិសេនរាជឱរស និងឲ្យអភិសេកព្រះនាងសម្ពុលាទុកក្នុងតំណែងអគ្គមហេសីក្នុងព្រះឧទ្យាននោះឯង ហើយយាងស្ដេចចូលកាន់ព្រះនគរ ចំណែកព្រះអង្គឯងទ្រង់បួសជាឥសី ស្ដេចនៅក្នុងព្រះឧទ្យាននោះ ។ ក៏ស្ដេចទៅសោយក្នុងព្រះរាជនិវេសន៍នោះឯងជាប្រចាំ ។ ចំណែកព្រះបាទសោត្ថិសេនបានព្រះរាជទានត្រឹមតែតំណែងជាព្រះអគ្គមហេសីដល់ព្រះនាងសម្ពុលាប៉ុណ្ណោះ មិនបានរាជសក្ការៈអ្វីដទៃឡើយ មិនសមព្រះទ័យសូម្បីថា ព្រះនាងសម្ពុលាមានហើយ រវល់

តែអភិរម្យជាមួយស្នំដទៃៗ ប៉ុណ្ណោះ ។ ដោយសេចក្ដីប្រណៃនទីង ស្រីរួមព្រះរាជស្វាមី ព្រះនាងសុភទ្ទាក៏មានព្រះវរកាយស្គាំងស្គម មានពេកលឿង មានព្រះវរកាយរវាមទៅដោយសរសៃ ។ ថ្ងៃមួយ ព្រះនាងបានទៅកាន់សម្នាក់ព្រះសស្សុរតាបស ដែលស្ដេចនិមន្តមក សោយក្នុងព្រះរាជវាំង ដើម្បីបន្ទោបង់នូវសោកា ថ្វាយបង្គំតាបស ដែលសោយស្រេចហើយ ប្រថាប់ក្នុងទីដ៏សមគួរមួយ ។

ព្រះសស្សុរតាបសនោះ គ្រាទតព្រះនេត្រឃើញព្រះនាងមាន ព្រះឥន្ទ្រិយសៅហ្មង ទើបត្រាស់ព្រះគាថាថា

[៥៤៤] យេ កុញ្ជរា សត្តសតា ឧឡារា
រក្ខន្តិ រត្តិន្ទិវមុយ្យុតាវុធា
ធនុគ្គហានញ្ច សតានិ សោឡស
កថំវិធេ បស្សសិ ភទ្ទេ សត្តវោ ។

នៃនាងដ៏ចម្រើន កុញ្ជរធំខ្ពស់មានច្រើនដល់ ៧០០ ក្បាល

មានពលយោធាកាន់អាវុធជិះដាប្រចាំ រង់ចាំរក្សាហើយទាំង វេលាថ្ងៃ និងវេលាយប់ និងពលយោធាដែលកាន់ធ្នូ ក៏មាន ដល់ ១.៦០០ នាក់ចាំរក្សា នាងឃើញសត្រូវប្រភេទណា ។

ព្រះគាថានោះមានអធិប្បាយថា ព្រះសស្សុរតាបសត្រាស់ថា "នែនាងសម្ពុលាដ៏ចម្រើន កុញ្ជររបស់យើង ៧០០ ក្បាល ប្រកប ទៅដោយអាវុធគ្រប់យ៉ាង ដោយមានទាហានឡើងជិះដំរីទាំងនោះ ហើយ ទាំងទាហានធ្នូ ១.៦០០ នាក់ដទៃទៀត ក៏នាំគ្នាការពាររក្សា ព្រះនគរពារាណសី រហូតទាំងយប់ទាំងថ្ងៃ កាលព្រះនគរមានការ រក្សាយ៉ាងនេះ នាងនៅឃើញមានសត្រូវប្រភេទណាទៀត នែនាង ដ៏ចម្រើន ក្នុងវេលានាងមកអំពីព្រៃដែលគួររន្ធៀស មានភ័យដោយ ជុំវិញ ក៏មានសរីរៈភ្លឺថ្លាផូរផង់ តែឥឡូវនេះ នាងស្គាំងស្គមពណ៌ សម្បុរប្រកបដោយរោគលឿង ឥន្ទ្រិយសៅហ្មងក្រៃលែង នាងក្រែង ក្នុងវត្ថុអ្វីហ្ន៎?" ។

ព្រះនាងសម្ពុលា ស្តាប់ព្រះតម្រាស់របស់ព្រះសស្សុរតាបស ហើយ ទូលថា "បពិត្រព្រះសម្មតិទេព ព្រោះព្រះរាជឱរសរបស់ព្រះអង្គ ទ្រង់មិនករុណាដល់ខ្ញុំម្ចាស់ ដូចក្នុងកាលមុន" ហើយត្រាស់ ៥ គាថាថា

[៥៤៥] អលង្កតា យោ បទុមុត្តរត្តចា
វិរាគិតា បស្សតិ ហំសគគ្គរា
តាសំ សុណិត្វា មិតគីតវាទិតំ
នទានិ មេ តាត តថា យថា បុរេ ។

បពិត្រព្រះរាជបិតា កាលមុនព្រះអយ្យបុត្តទ្រង់ប្រព្រឹត្តចំពោះខ្ញុំម្ចាស់យ៉ាងណា តែពេលនេះមិនដូច្នោះទេ ព្រោះទ្រង់បានឃើញស្រីស្នំប្រដាប់តាក់តែង មានវណ្ណៈដូចកេសរឈូក ចង្កេះរៀវល្អ សំឡេងពីរោះដូចសំឡេងហង្ស និងបានស្តាប់ចម្រៀង និងការប្រគុំ របស់ស្រីទាំងនោះ ។

សុវណ្ណសង្កច្ចធរា សុវិគ្គហា
អលង្កតា មានុសិយច្ឆរូបមា
សេនោបិយា តាត អនិន្ទិតង្គិយោ
ខត្តិយកញ្ញា បដិលោភយន្តិ នំ ។

បពិត្រព្រះរាជបិតា ស្រីស្នំទាំងនោះទ្រទ្រង់នូវគ្រឿងប្រដាប់សុទ្ធតែមាស មានរូបរាងឆើតឆាយ ប្រដាប់ដោយគ្រឿងអលង្ការគ្រប់ប្រភេទ ប្រៀបដូចជាស្រីសួគ៌ ជាទីប្រោសប្រាណរបស់ព្រះបាទសោត្ថិសេន សុទ្ធតែល្អស្អាតរកតិះដៀលមិនបាន ជាខត្តិយកញ្ញា នាំគ្នាប្រលោមព្រះរាជឱរសនោះ ។

សចេ អហំ តាត តថា យថា បុរេ
បតឹ តមុញ្ញាយ បុនា វនេ ករេ
សម្មានយេ មំ ន ច មំ វិមានយេ
ឥតោបិ មេ តាត តតោ វរំ សិយា ។

បពិត្រព្រះរាជបិតា ប្រសិនបើព្រះរាជឱរសទ្រង់សរសើរខ្ញុំម្ចាស់ ដូចដែលខ្ញុំម្ចាស់ធ្លាប់ត្រាច់ស្វែងរកផលាផលក្នុងព្រៃ មកចិញ្ចឹម ព្រះរាជស្វាមីក្នុងកាលមុនទៀត និងទ្រង់មិនតិះដៀលខ្ញុំម្ចាស់ សោត (ក្នុងព្រៃនោះប៉ុណ្ណោះ) ប្រសើរជាងរាជ្យសម្បត្តិក្នុង ព្រះនគរពារាណសីនេះ ។

យមន្នបានេ វិបុលស្មិ ឱហិតេ

នារី វិមដ្ឋាភរណា អលង្កតា

សព្វង្គុបេតា[១] បតិនោ ច អប្បិយា

អវជ្ឈ តស្សា មរណំ តតោ វរំ ។

ស្រីណាដែលនៅក្នុងផ្ទះ មានបាយទឹកសម្បូរ រៀបចំទុកដាក់ រៀបរយ មានគ្រឿងអាភរណៈដ៏វិចិត្រប្រដាប់ហើយ សូម្បីនឹង ជាអ្នកដល់ព្រមដោយគុណសម្បត្តិគ្រប់យ៉ាង តែមិនជាទីស្រឡាញ់

---

១.ម. បញ្ចង្គុបេតា ។

របស់ស្វាមី រង់ចាំតែការកាប់សម្លាប់ សេចក្តីស្លាប់របស់ស្រី នោះ ប្រសើរជាងការនៅគ្រប់គ្រងផ្ទះ ។

អបិ ចេ ទលិទ្ទា កបណា អនាឡ្ហិយា
កជាទុតិយា បតិនោ ច សា បិយា
សព្វង្គុបេតាយបិ អប្បិយាយ
អយមេវ សេយ្យោ កបណាបិ យា បិយា ។

បើសូម្បីស្រីណា ជាស្រីលំបាកទាល់ក្រ គ្មានគ្រឿងប្រដាប់ មានតែកន្ទេលផែងជាទីជេក តែជាទីស្រឡាញ់របស់ស្វាមី ស្រី នោះប្រសើរជាង ស្រីដែលសម្បូរដោយគុណសម្បត្តិគ្រប់យ៉ាង តែមិនជាទីស្រឡាញ់របស់ស្វាមី ។

បណ្តាបទទាំងនោះ បទថា បទុមុត្តរត្តចា "មានវណ្ណៈដូចកេសរ ឈូកដូចៗ គ្នា" សេចក្តីថា ព្រះនាងសម្ពុលាសម្តែងថា "ព្រះ អយ្យបុត្តទតព្រះនេត្រឃើញស្រ្តីមានសម្បុរកាយស្អាតស្រដៀងត្រ-

បកផ្កាឈូក សម្តែងថា មានរស្មីពណ៌មាសភ្លឺចេញអំពីសរីរកាយរបស់នាងគ្រប់គ្នា” ។ បទថា **វិភគិតា “មានចង្កេះរៀវ”** បានដល់មានរូបរាងអែនអន អធិប្បាយថា មានរូបរាងស្រស់ស្អាត ។ បទថា **ហំសគគ្គរា “សំឡេងពីរោះដូចសំឡេងហង្ស”** សេចក្តីថា ទ្រង់ឃើញពួកស្នំនារីដែលស្អាតបែបនេះ មានសំឡេងពីរោះទន់ភ្លន់ដូចសំឡេងហង្ស ។ បទថា **តាសំ “ទាំងនោះ”** សេចក្តីថា ព្រះនាងសម្ពុលាទូលថា “ព្រោះទ្រង់ស្តាប់សំឡេងច្រៀងជាដើមរបស់ស្នំនារីទាំងនោះ ឥឡូវនេះ ព្រះរាជឱរសរបស់នាងខ្ញុំម្ចាស់ ទើបប្រព្រឹត្តក្នុងខ្ញុំម្ចាស់មិនដូចមុន” ។ បទថា **សុវណ្ណសង្កច្ឆធរា “ទ្រទ្រង់នូវគ្រឿងប្រដាប់សុទ្ធតែមាស”** សេចក្តីថា ទ្រទ្រង់គ្រឿងប្រដាប់ដែលសុទ្ធតែមាស ។ បទថា **អលង្កតា “ប្រដាប់ដោយគ្រឿងអលង្ការ”** សេចក្តីថា ប្រដាប់ដោយគ្រឿងអលង្ការគ្រប់ប្រភេទ ។ បទថា **មានុសិយច្ឆរូបមា “ប្រៀបដូចនឹងស្រីសួគ៌”** សេចក្តីថា ប្រដូចនឹងស្រី

សួគ៌ក្នុងពួកមនុស្ស ។

បទថា **សោនោបិយា** “ជាទីប្រោសប្រាណរបស់ព្រះបាទសោ-ត្ថិសេន” សេចក្ដីថា ជាទីប្រោសប្រាណរបស់ព្រះបាទសោត្ថិសេន ។ បទថា **បដិលោកយន្តិ នំ** “ប្រលោមព្រះរាជឱរសនោះ” សេចក្ដីថា នាំគ្នាប្រលោមព្រះរាជឱរសនោះ ។ បទថា **សចេ អហំ** “ប្រសិនបើ... ខ្ញុំម្ចាស់” សេចក្ដីថា ព្រះនាងសម្ពុលាដែលទ្រង់ស្គាំងស្គមព្រោះប្រណែននឹងស្រីអ្នករួមព្រះរាជស្វាមី ក្រាបទូលថា “បពិត្រព្រះរាជបិតា បើព្រះរាជឱរសទ្រង់រាប់អានខ្ញុំម្ចាស់ទៀតដូចក្នុងកាលមុន ដែលខ្ញុំម្ចាស់ធ្លាប់បានបដិបត្តិទំនុកបម្រុងទ្រង់ជាព្រះស្វាមី ក្នុងកាលស្ដេចទៅនៅក្នុងព្រៃព្រោះរោគឃ្លង់ ដោយការស្វែងរកផលាផល និងទ្រង់មិនតិះដៀលខ្ញុំម្ចាស់សោត ព្រៃនោះឯងប៉ុណ្ណោះ នឹងប្រសើរសម្រាប់នាងខ្ញុំម្ចាស់ ក្រៃលែងជាងរាជ្យសម្បត្តិក្នុងព្រះនគរពារាណសីនេះ” ។ បទថា **យមន្នបានេ** កាត់បទជា **យំ អន្នបា-**

នេ ។ បទថា **ឱហិតេ** “តាក់តែង” សេចក្ដីថា ចាត់ចែងតែងតាំងទុកហើយ ។ ព្រះនាងសម្ពុលាសម្ដែងដល់ផ្ទះដែលមានបាយ និងទឹកច្រើន ទុកដោយបទនេះ ។

ន័យថា ព្រះនាងសម្ពុលានោះមានបំណងដូច្នេះថា “នារីណាជាអ្នកមិនមានបុត្ត នៅតែម្នាក់ឯងក្នុងផ្ទះ សូម្បីមានបាយទឹកសម្បូរមានគ្រឿងអាភរណៈពាសពេញ ប្រដាប់តាក់តែងដោយនានាអលង្ការព្រមដោយអង្គគុណគ្រប់យ៉ាង ប៉ុន្តែមិនជាទីស្រឡាញ់របស់ស្វាមីវង់ចាំតែបៀតបៀន ការដែលស្រីនោះយកវល្លិ ឬខ្សែចងកឲ្យស្លាប់ប្រសើរជាង នឹងនៅគ្រប់គ្រងផ្ទះនោះ” ។

បទថា **អនាឡិយា** “គ្មានគ្រឿងប្រដាប់” បានដល់ មិនមានគ្រឿងប្រដាប់ ។ បទថា **កដាទុតិយា** “មានកន្ទេលផែងជាទីដេក” បានដល់ មានតែកន្ទេលផែងជាទីដេក ។ បទថា **សេយ្យា**[១] “ប្រសើរ

១.បិដក. សេយ្យោ ។

ជាង” សេចក្តីថា សូម្បីនាងជាស្រីកំព្រា តែជាទីស្រឡាញ់របស់ស្វាមី នាងនេះឯងជាកំពូល ។

កាលព្រះនាងសម្ពុលាទូលហេតុ ដែលខ្លួនស្គមដល់ព្រះស-ស្សុរតាបសយ៉ាងនេះហើយ ព្រះសស្សុរតាបសទើបប្រាប់ឲ្យយាងព្រះរាជាមក ត្រាស់ថា “ម្នាលសោត្ថិសេន កាលកូនមានរោគឃ្លង់ទៅក្នុងព្រៃ នាងសម្ពុលាទៅជាមួយកូន នាងប្រណិប័តន៍ទំនុកបម្រុងរបួតញ៉ាំងរោគរបស់កូនឲ្យសះស្បើយ ដោយកម្លាំងសច្ចៈរបស់ខ្លួនបានជួយធ្វើឲ្យកូនតាំងនៅក្នុងរាជ្យសម្បត្តិ តែកូនមិនបានធ្វើទុកក្នុងចិត្តដល់ទីឈរ ទីអង្គុយរបស់នាងឡើយ កូនធ្វើមិនសមគួរទេ ដែលឈ្មោះថា ការប្រទូស្តមិត្តនោះជាបាប” កាលនឹងព្រះរាជទានឱវាទព្រះឱរស ទើបត្រាស់ព្រះគាថាថា

[៥៤៦] សុទុល្លភិត្ថី បុរិសស្ស យា ហិតា

ភត្តិត្ថិយា ទុល្លភោ យោ ហិតោ ច

ហិតា ច តេ សីលវតី ភរិយា

ជនិន្ទ ធម្មំ ចរ សម្ពុលាយ ។

ភរិយាអ្នកទំនុកបម្រុងដល់ស្វាមី ជាស្រីរកបានសែនលំបាក ស្វាមីដែលទំនុកបម្រុងដល់ភរិយាក៏រកសែនលំបាក កូនជាធំលើជន មហេសីរបស់កូនជាអ្នកទំនុកបម្រុងដល់កូនផង មានសីលផង ព្រោះដូច្នោះ កូនចូរប្រព្រឹត្តធម៌ចំពោះនាងសម្ពុលាចុះ ។

ព្រះគាថានោះ មានអត្ថាធិប្បាយថា "កូនអើយ ស្រីអ្នកមានការទំនុកបម្រុង មានចិត្តទន់ភ្លន់ សេចក្ដីអើពើមើលរក្សាដល់បុរសជាស្វាមីក្ដី បុរសអ្នកជាស្វាមីមានការទំនុកបម្រុងដឹងគុណដល់ស្រីជាភរិយាដែលធ្វើហើយក្ដី ទាំងពីរជំពូកនេះរកបានលំបាកណាស់ ក៏នាងសម្ពុលានេះ មានការទំនុកបម្រុងដល់កូនផង ដល់ព្រមដោយសីលផង ព្រោះដូច្នោះ កូនត្រូវប្រព្រឹត្តធម៌ចំពោះនាង ត្រូវលើក

ដល់បុញ្ញគុណរបស់នាង ហើយចូរមានចិត្តទន់ភ្លន់ ញុំាងចិត្តរបស់នាងឲ្យរីករាយចុះ” ។

ព្រះរាជឥសីទ្រង់ប្រទានឱវាទដល់ព្រះឱរសយ៉ាងនេះហើយ ក៏ស្តេចក្រោកឡើងចៀសចេញទៅកាន់ព្រះរាជឧទ្យាន ។ លុះព្រះរាជឥសីជាព្រះជនកស្តេចចៀសចេញហើយ ព្រះបាទសោត្ថិសេនត្រាស់ឲ្យព្រះនាងសម្ពុលាមកគាល់ ហើយត្រាស់ថា “នែនាងដ៏ចម្រើន នាងចូរអត់ទោសដល់យើងដែលធ្វើខុសអស់កាល មានប្រមាណប៉ុណ្ណេះ តាំងអំពីនេះទៅ យើងនឹងប្រគល់ឥស្សរិយយសដល់នាងទាំងអស់” ហើយត្រាស់ព្រះគាថាចុងក្រោយថា

[៥៤៧] សាច តុវំ វិបុលេ លទ្ធភោគេ

ឥស្សាវតិណ្ណា មរណំ ឧបេសិ

អហញ្ច តេ ភទ្ទេ ឥមា រាជកញ្ញា

សព្វេវ តេ វចនករា ភវាមាតិ ។

ប្អូនស្រីសម្មុលាដ៏ចម្រើន បើនាងបានភោគសម្បត្តិដ៏ធំនេះ ហើយ តែត្រូវសេចក្ដីប្រចណ្ឌគ្របសង្កត់រហូតនឹងដល់មរណៈ សោត បង និងនាងរាជកញ្ញាទាំងអស់នេះនឹងធ្វើតាមពាក្យរបស់ នាង ។

ព្រះគាថានោះមានអធិប្បាយថា "ព្រះនាងសម្មុលាដ៏ចម្រើន បើនាងបានភោគសម្បត្តិដ៏ធំ ដោយបានទទួលតំណែងជាព្រះអគ្គ-មហេសី ព្រោះការអភិសេកស្ថាបនាទុកក្នុងតំនររតនៈហើយ នៅធ្លាក់ទៅក្នុងភាពឥស្សា នឹងដល់សេចក្ដីស្លាប់សោត យើង និងនាងរាជកញ្ញាទាំងអស់នេះ នឹងជាអ្នកធ្វើតាមពាក្យរបស់នាង នាងចូរចាត់ចែងរាជ្យសម្បត្តិនេះតាមបំណងចុះ" ហើយព្រះរាជទានភាពជាធំទាំងអស់ដល់ព្រះអគ្គមហេសី ។

រាប់តាំងអំពីនោះមក ទាំងពីរព្រះអង្គក៏រស់នៅជាសុខជាមួយគ្នា បំពេញបុណ្យកុសលមានទានជាដើម ហើយស្ដេចទៅតាមយ-

ជាកម្ម ។ ព្រះរាជតាបសធ្វើឈាន និងអភិញ្ញាឲ្យកើតហើយ ក៏ជាអ្នកចូលដល់ព្រហ្មលោក ។

ព្រះសាស្តាគ្រាទ្រង់នាំព្រះធម្មទេសនានេះមកហើយ ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងជាតិមុន ព្រះនាងមល្លិកាក៏គោរពចំពោះស្វាមីដូចជាទេវតាដូចគ្នា” ហើយទ្រង់ប្រជុំជាតកថា “ព្រះនាងសម្ពុលាក្នុងគ្រានោះ បានមកជាព្រះនាងមល្លិកានេះឯង, ព្រះបាទសោត្ថិសេនក្នុងគ្រានោះ បានមកជាព្រះបាទក្រុងកោសលក្នុងគ្រានេះ, ព្រះតាបសជារាជបិតាក្នុងគ្រានោះ គឺ **តថាគត** នេះឯង” ។

ចប់អដ្ឋកថា សម្ពុលាជាតកទី ៩

# អដ្ឋកថា ភណ្ឌុតិណ្ឌុកជាតកទី ១០

## (រឿងព្រះរាជាទ្រង់ស្តាប់ដំណើរអ្នកក្រុង)

ព្រះសាស្តាកាលស្តេចប្រថាប់នៅព្រះជេតពនវិហារ ទ្រង់បានប្រារព្ធរាជោវាទ ត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **អប្បមាទោ** “សេចក្តីមិនប្រមាទ” ដូច្នេះ ។ រាជោវាទមានពិស្តារហើយក្នុងខាងក្រោយ ។

ក្នុងអតីតកាល ព្រះរាជាទ្រង់ព្រះនាមថា **បញ្ចាលៈ** តាំងនៅក្នុងអគតិ ទ្រង់ប្រមាទសោយរាជ្យសម្បត្តិដោយអធម៌ នៅក្នុងឧត្តរបញ្ចាលនគរ ដែនកបិលៈ ។ គ្រានោះ អាមាត្យជាដើមរបស់ព្រះអង្គក៏ទៅជាមនុស្សអធម៌ទាំងអស់ ។ អ្នកដែនត្រូវបៀតបៀនដោយការស៊ីអាករ ត្រូវនាំកូនប្រពន្ធរត់គេចទៅនៅក្នុងព្រៃដូចជាហ្វូងម្រឹគ ។ ក្នុងទីដែលធ្លាប់មានមនុស្ស ក៏ក្លាយជាទីស្ងាត់មនុស្ស ។ ពេលថ្ងៃពួកមនុស្សមិនអាចនៅនឹងផ្ទះបាន ព្រោះភ័យខ្លាចចោរហ្វាយ

ស្រុក នាំគ្នាយកមែកឈើបន្លាជាដើមមកព័ទ្ធជុំវិញផ្ទះ ។ កាលព្រះអាទិត្យរះឡើងក៏លបចូលទៅក្នុងព្រៃ ។ ពេលថ្ងៃចៅហ្វាយស្រុកក៏មករឹបយក ។ ពេលយប់ពួកចោរក៏ប្លន់ ។

គ្រានោះ ព្រះពោធិសត្វបានកើតជារុក្ខទេវតា នៅទីងកណ្ឌុ-តិណ្ឌុកព្រឹក្សខាងក្រៅព្រះនគរ ។ រាល់ៗ ឆ្នាំ បានទទួលពលីកម្មមានតម្លៃ ១.០០០ អំពីរាជសម្នាក់ ។ រុក្ខទេវតាគិតថា "ព្រះរាជានេះទ្រង់ប្រមាទ ទ្រង់សោយរាជ្យសម្បត្តិក្នុងសកលរដ្ឋនឹងត្រូវវិនាសវៀរយើងហើយ មិនមាននរណាអាចនឹងដឹកនាំឲ្យព្រះរាជាតាំងព្រះអង្គក្នុងផ្លូវដែលត្រូវបាន មួយទៀត ព្រះអង្គក៏មានឧបការៈដល់យើងបូជាដោយពលីកម្មមានតម្លៃ ១.០០០ កហាបណៈរាល់ៗ ឆ្នាំមកយើងនឹងថ្វាយឱវាទដល់ព្រះអង្គ" ។ ក្នុងវេលាយប់ រុក្ខទេវតាបានចូលទៅកាន់ផ្ទៃព្រះក្រឡាបន្ទំរបស់ព្រះរាជា ឈរនៅក្នុងអាកាសខាងព្រះសីសៈមានរស្មីចញ្ចាចចិញ្ចែង ។ ព្រះរាជាទតព្រះនេត្រឃើញ

ទេវតារុងរឿងដូចជាព្រះអាទិត្យក្នុងពេលព្រឹក ទើបត្រាស់សួរថា លោកជានរណា មកទីនេះព្រោះហេតុអ្វី?” រុក្ខទេវតាឮព្រះតម្រាស់ហើយទូលថា “មហារាជ យើងគឺ កណ្ឌុតិណ្ឌុកទេវតា គិតថា “នឹងថ្វាយឱវាទដល់ព្រះអង្គ ទើបមកគាល់” ។ ព្រះរាជាត្រាស់សួរថា “លោកនឹងឲ្យឱវាទអ្វីឬ?” កាលព្រះរាជាត្រាស់សួរយ៉ាងនេះហើយ ព្រះមហាសត្វទើបទូលថា “មហារាជ ព្រះអង្គជាអ្នកប្រមាទសោយ-រាជ្យសម្បត្តិ ព្រោះដូច្នោះ ដែនដីទាំងអស់របស់ព្រះអង្គនឹងវិនាសដូចត្រូវចោរដណ្តើម ធម្មតា ព្រះរាជាកាលសោយរាជ្យសម្បត្តិដោយសេចក្តីប្រមាទ មិនមែនជាម្ចាស់នៃដែនទាំងអស់ទេ នឹងដល់សេចក្តីវិនាសក្នុងបច្ចុប្បន្ន និងក្នុងភពខាងមុខត្រូវកើតក្នុងមហានរកទៀតមួយទៀត កាលព្រះរាជាដល់នូវសេចក្តីប្រមាទ សូម្បីជនក្នុងរាជ-សម្នាក់ ក្រៅរាជសម្នាក់រមែងនាំគ្នាប្រមាទ ព្រោះហេតុនោះ ព្រះរាជាមិនគួរប្រមាទឡើយ” ដូច្នេះហើយ កាលនឹងផ្តើមសម្តែងធម៌-

ទេសនា ទើបពោលគាថាថា

[៥៤៨] អប្បមាទោ អមតំ បទំ    បមាទោ មច្ចុនោ បទំ

អប្បមត្តា ន មីយន្តិ    យេ បមត្តា យថា មតា ។

សេចក្តីមិនប្រមាទជាផ្លូវមិនស្លាប់ សេចក្តីប្រមាទជាផ្លូវនៃសេចក្តីស្លាប់ អ្នកមិនប្រមាទរមែងមិនស្លាប់ បុគ្គលប្រមាទដូចជាបុគ្គលស្លាប់ហើយ ។

មទា បមាទោ ជាយេថ    បមាទា ជាយតេ ខយោ

ខយា បទោសា ជាយន្តិ    មា មទោ ភរតូសភ ។

ព្រោះស្រវឹងទើបកើតសេចក្តីប្រមាទ ព្រោះប្រមាទទើបកើតសេចក្តីវិនាស និងព្រោះសេចក្តីវិនាសទើបកើតនូវទោស បុគ្គលមានភារៈគ្រប់គ្រងរដ្ឋ កុំប្រមាទឡើយ ។

ពហូ ហិ ខត្តិយា ជិនា    អត្ថំ រដ្ឋំ បមាទិនោ

អថោបិ គាមិនោ គាមា    អនាគារា អគារិនោ ។

ព្រោះក្សត្រដ៏ច្រើន បើមានសេចក្ដីប្រមាទនឹងត្រូវវិនាស ប្រយោជន៍នៃដែនដី វិនាសទាំងដែនដី មួយទៀត អ្នកស្រុកប្រមាទក៏វិនាសចាកស្រុក បព្វជិតប្រមាទក៏វិនាសចាកអនាគារិយវិន័យ ។

ខត្តិយស្ស បមត្តស្ស    រដ្ឋស្មឹ រដ្ឋវឌ្ឍន
សព្វេ ភោគា វិនស្សន្តិ    រញ្ញោ តំ វុច្ចតេ អឃំ ។

ព្រះអង្គជាទីគោរពស្រឡាញ់របស់រដ្ឋ ភោគសម្បត្តិគ្រប់យ៉ាងក្នុងដែនរបស់ក្សត្រអ្នកប្រមាទហើយ រមែងវិនាសអស់ប្រការនោះលោកពោលថា ជាសេចក្ដីទុក្ខរបស់ព្រះរាជា ។

នេស ធម្មោ មហារាជ    អតិវេលំ បមជ្ជសិ
ឥទ្ធំ ផីតំ ជនបទំ    ចោរា វិទ្ធំសយន្តិ នំ ។

មហារាជ សេចក្ដីប្រមាទនេះមិនមែនជាធម៌របស់បុរាណក្សត្រទេ ចោរទាំងឡាយ រមែងកម្ចាត់ជនបទដែលស្ដុកស្ដម្ភ

សម្បូរបស់ព្រះរាជាអ្នកប្រមាទហួសហេតុ ។

ន តេ បុត្តា ភវិស្សន្តិ ន ហិរញ្ញំ ន ធានិយំ
រដ្ឋំ វិលុម្បមានម្ហិ សព្វភោគេហិ ជិយ្យសិ ។

រាជឱរសអ្នកបន្តវង្សរបស់ព្រះរាជានោះ នឹងមិនមានមាសប្រាក់ ទ្រព្យរបស់ក៏មិនមានដូចគ្នា កាលដែនដីត្រូវប្លន់ ព្រះរាជាអ្នកប្រមាទរមែងវិនាសចាកភោគៈទាំងពួង ។

សព្វភោគបរិជិណ្ណំ រាជានំ វាបិ ខត្តិយំ
ញាតិមិត្តា សុហជ្ជា ច ន តំ មញ្ញន្តិ មន្តិយំ[(១)] ។

ញាតិមិត្ត និងសម្លាញ់ រមែងមិនរាប់អានខត្តិយរាជអ្នកវិនាសចាកសព្វភោគសម្បត្តិ ក្នុងការគិតដល់ ។

ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
តមេវមុបជីវន្តា ន តំ មញ្ញន្តិ មន្តិយំ ។

---

១.ម. មានិយំ, ឱ. ខត្តិយំ ។

ពលដំរីពលសេះពលរថ និងពលថ្មើរជើង ដែលគប្បីព្រះពោធិសម្ភារចិញ្ចឹម រមែងមិនរាប់អានព្រះរាជានោះ ក្នុងការគិតដល់ ។

អសំវិហិតកម្មន្តំ ពាលំ ទុម្មន្តិ មន្តិនំ
សិរី ជហតិ ទុម្មេធំ ជិណ្ណំវ ឧរគោ តចំ ។

សិរី គឺ ការគោរព រមែងលះបង់ព្រះរាជាដែលមិនចាត់ចែងការងារ ល្ងង់ខ្លៅ មានការគិតថោកទាប គ្មានបញ្ញា ដូចពស់សកសំណកដែលគ្រាំគ្រាដូច្នោះ ។

សុសំវិហិតកម្មន្តំ កាលុដ្ឋាយឹ អតន្ទិតំ
សព្វេ ភោគាភិវឌ្ឍន្តិ គាវោ សឧសភាមិវ ។

ព្រះរាជាដែលទ្រង់ចាត់ចែងការងារល្អ ព្យាយាមតាមកាលមិនខ្ជិលច្រអូស ភោគសម្បត្តិទាំងពួងរមែងចម្រើនឡើង ដូចហ្វូងគោដែលមានគោឧសភៈដូច្នោះ ។

ឧបស្សុតី មហារាជ រដ្ឋេ ជនបទេ ចរ

តត្ថ ទិស្វា ច សុត្វា ច តតោ តំ បដិបជ្ជសិ ។

មហារាជ ព្រះអង្គចូរទ្រង់យាងស្តាប់ហេតុការណ៍ក្នុងដែន និងជនបទ គ្រាបានទតព្រះនេត្រឃើញ និងទ្រង់បានស្តាប់ក្នុងដែននោះហើយ តពីនោះ ក៏បដិបត្តិក្នុងវត្ថុនោះៗ ចុះ ។

បណ្តាបទទាំងនោះ បទថា **អប្បមាទោ** “សេចក្តីមិនប្រមាទ” បានដល់ ការមិននៅប្រាសចាកសតិ ។ បទថា **អមតំ បទំ** “ជាផ្លូវមិនស្លាប់” សេចក្តីថា ជាផ្លូវ គឺ ជាហេតុនៃការសម្រេចអមតនិព្វាន ។ បទថា **មច្ចុនោ បទំ** “ជាផ្លូវនៃសេចក្តីស្លាប់” សេចក្តីថា សេចក្តីប្រមាទជាហេតុនៃសេចក្តីស្លាប់ ។ ព្រោះបុគ្គលប្រមាទ ចម្រើនវិបស្សនា កាលមិនអាចសម្រេចអប្បដិសន្ធិកភាព (គឺ ការមិនត្រឡប់មកកើតទៀត) បាន រមែងកើត រមែងស្លាប់ក្នុងសង្សាររឿយៗ ហេតុនោះ សេចក្តីប្រមាទ ទើបឈ្មោះថា ជាផ្លូវនៃសេចក្តី

ស្លាប់ ។ បទថា **ន មីយន្តិ** “រមែងមិនស្លាប់” សេចក្តីថា បុគ្គល មិនប្រមាទចម្រើនវិបស្សនា សម្រេចអប្បដិសន្ធិកភាពហើយ ឈ្មោះ ថា រមែងមិនស្លាប់ ព្រោះមិនកើតក្នុងសង្សារទៀត ។ បទថា **យេ បមត្តា** “បុគ្គលប្រមាទ” សេចក្តីថា មហារាជ បុគ្គលពួកណាប្រមាទ ហើយ បុគ្គលពួកនោះគួរឃើញដូចជាបុគ្គលស្លាប់ហើយ ។ ព្រោះ ហេតុអ្វី ព្រោះហេតុដែលញ៉ាំងកិច្ចឲ្យសម្រេចមិនបាន ។ ពិតហើយ សម្រាប់អ្នកដែលស្លាប់ហើយ រមែងមិនមានការនឹករលឹក សេចក្តី ប្រាថ្នា ឬសេចក្តីខ្វល់ខ្វាយថា “យើងនឹងឲ្យទាន នឹងរក្សាសីល នឹង ធ្វើឧបោសថកម្ម នឹងបំពេញគុណ គឺ សេចក្តីល្អ” ព្រោះជាបុគ្គល ប្រាសចាកវិញ្ញាណ ។ សម្រាប់បុគ្គលប្រមាទក៏មិនមាន ព្រោះខ្វះ ការមិនប្រមាទ ដូច្នោះ បុគ្គលស្លាប់ និងបុគ្គលប្រមាទទាំងពីរនេះ ទើបស្មើគ្នាជាបុគ្គលប្រភេទតែមួយ ។

បទថា **មទា** “ព្រោះស្រវឹង” សេចក្តីថា មហារាជ ដែលឈ្មោះ

ថា សេចក្ដីប្រមាទរមែងកើតព្រោះសេចក្ដីស្រវឹង ៣ ប្រការគឺ ស្រវឹងក្នុងការមិនមានរោគ ស្រវឹងក្នុងវ័យ និងស្រវឹងក្នុងជីវិត ។ មនុស្សយើងពេលស្រវឹងហើយ ក៏ដល់នូវសេចក្ដីប្រមាទ ធ្វើបាបកម្មដូចជាបាណាតិបាតជាដើមបាន ។ គ្រានោះ ព្រះរាជាក៏ត្រាស់ឲ្យកាត់ជើង កាត់ដៃ ឲ្យប្រហារជីវិត ឬឲ្យរឹបអូសទ្រព្យជននោះទាំងអស់ព្រោះសេចក្ដីប្រមាទរបស់គេ ទើបកើតការអស់ញាតិ អស់ទ្រព្យអស់ជីវិតយ៉ាងនេះ ។ គេដល់នូវការអស់ទ្រព្យ ឬអស់យសហើយកាលមិនអាចចិញ្ចឹមជីវិតបានទៀត ក៏ត្រូវធ្វើកាយទុច្ចរិតជាដើមដើម្បីចិញ្ចឹមជីវិតតទៅ និងព្រោះការអស់ទ្រព្យសម្បត្តិរបស់គេយ៉ាងនេះទើបកើតទោសកំហុសឡើង ព្រោះហេតុនោះ យើងទើបត្រូវទូលដាស់តឿនព្រះអង្គ ។ បទថា **មា មទោ ភរតូសភ** **“អ្នកមានភារៈគ្រប់គ្រងរដ្ឋ កុំប្រមាទឡើយ”** សេចក្ដីថា ព្រះអង្គទ្រង់មានភារៈជាធំក្នុងដែន ព្រះអង្គទ្រង់កុំស្រវឹង អធិប្បាយថា ទ្រង់កុំប្រមាទ ។

បទថា **អត្ថំ រដ្ឋំ** “ប្រយោជន៍នៃដែន” សេចក្ដីថា កម្រុត្រជាច្រើន (ប្រសិនបើ) ទ្រង់ប្រមាទ សេចក្ដីចម្រើនរបស់អ្នកជនបទ និងអ្នកដែនទាំងអស់ ក៏វិនាសចុះ ។ ដើម្បីសេចក្ដីជាក់ច្បាស់ក្នុងប្រការនោះៗ បណ្ឌិតគួរសម្ដែងខន្តិវាទីជាតក គុរុកជាតក សរភង្គជាតក និងចេតិយជាតក ។ បទថា **គាមិនោ** “មេស្រុក” ន័យថា សូម្បីមេស្រុកត្រូវព្រាត់ប្រាស វិនាស ហិនហោចចាកស្រុក ក៏ព្រោះទោស គឺ សេចក្ដីប្រមាទច្រើន ។ បទថា **អនាគារា អគារិនោ** **“បព្វជិតប្រមាទក៏វិនាសចាកអនាគារិយវិន័យ”** គឺ រុក្ខទេវតាពោលថា “បព្វជិតវិនាសចាកវត្តបដិបត្តិរបស់បព្វជិត ក៏ព្រោះទោស គឺ ប្រមាទច្រើន សូម្បីគ្រហស្ថក៏ព្រាត់ប្រាស វិនាសចាកការគ្រប់គ្រងផ្ទះ និងធញ្ញាហារជាដើមដ៏ច្រើន ក៏ព្រោះទោស គឺ ការប្រមាទច្រើន ។ បទថា **តំ វុច្ចតេ អឃំ** “សេចក្ដីនោះលោកពោលថាជាទុក្ខ” សេចក្ដីថា មហារាជ ឈ្មោះថា ការវិនាសយស និងភោគ-

*សម្បត្តិ លោកពោលថា ជាទុក្ខរបស់ព្រះរាជា ព្រោះតែមិនមាន ភោគសម្បត្តិ យសរបស់ព្រះរាជាដែលទ្រង់គ្មានទ្រព្យរមែងវិនាស ព្រះរាជាទ្រង់វិនាសយសរមែងបានទទួលទុក្ខយ៉ាងធំ ។*

*បទថា* ***នេស ធម្មោ*** *“**នេះជាធម៌**” សេចក្តីថា មហារាជ ការប្រមាទនេះ មិនមែនធម៌របស់បុរាណក្សត្រទេ ។ បទថា* ***ឥទ្ធំ ផីតំ*** *“**ដែលស្តុកស្តម្ភសម្បូរ**” សេចក្តីថា (ចោរទាំងឡាយរមែងដណ្តើម) ជនបទដែលសម្បូរដោយបាយទឹកជាដើម សម្បូរដោយមាស និងប្រាក់ជាដើម ។ បទថា* ***ន តេ បុត្តា*** *“**រាជឱរស... របស់ព្រះរាជានោះក៏មិនមាន**” សេចក្តីថា មហារាជ រាជឱរសអ្នកបន្តវង្សរបស់ព្រះរាជាដែលប្រមាទនឹងមិនមាន ។ ព្រោះអ្នកដែនទាំងឡាយរមែងមិនថ្វាយស្វេតឆត្រ ដោយគិតថា “ព្រះឱរសរបស់ព្រះរាជានោះមិនតាំងនៅក្នុងធម៌ នឹងធ្វើសេចក្តីចម្រើនអ្វីដល់ពួកយើងបាន ពួកយើងនឹងមិនថ្វាយស្វេតឆត្រដល់ព្រះឱរសនោះ” ព្រះឱរសអ្នកបន្តប្រវេណី*

របស់ព្រះរាជាអ្នកមិនតាំងនៅក្នុងធម៌ទាំងនោះ ឈ្មោះថា មិនមាន ដោយអាការយ៉ាងនេះ ។ បទថា **បរិជិណ្ណំ** “**អ្នកវិនាស**” បានដល់ វិនាសដោយជុំវិញហើយ ។ បទថា **រាជានំ វាបិ** “**ខត្តិយរាជ**” គឺ សូម្បីព្រះរាជាអ្នកវិនាសចាកភោគសម្បត្តិនោះនៅជាព្រះរាជា ក៏ជន ទាំងឡាយរមែងមិនរាប់អានព្រះរាជាអង្គនោះ សូម្បីទ្រង់តាំងព្រះ ជន្មនៅ ។

បទថា **មន្តិយំ** “**ក្នុងការគិតដល់**” ន័យថា ញាតិ មិត្តសម្លាញ់ រមែងមិនសម្គាល់ការធ្វើសេចក្ដីរាប់អានដោយចិត្តគោរពថា អ្នកនេះ ជាព្រះរាជា ។ បទថា **ឧបជីវន្តា** “**អ្នកដែលពឹងព្រះពោធិសត្វ ចិញ្ចឹមជីវិត**” ន័យថា ជនទាំងឡាយនោះ គឺ មានប្រមាណប៉ុណ្ណោះ សូម្បីចូលទៅពឹងព្រះបរមពោធិសត្វហើយ ក៏រមែងមិនឲ្យសេចក្ដី សំខាន់ដល់វត្ថុដែលខ្លួនគួរឲ្យដោយចិត្តគោរព ។ បទថា **សិរិ** “**សិរី គឺ ការគោរព**” បានដល់ យស និងភោគសម្បត្តិ ។ បទថា **តចំ**

"*សំណក*" សេចក្ដីថា កាលពស់វេន្លៀសក្នុងសំណកចាស់ រមែង លះបង់ចេញមិនក្រឡេកមើលទៀតយ៉ាងណា សិរី គឺ យស និង ភោគសម្បត្តិ រមែងលះបង់ព្រះរាជាដូច្នោះក៏យ៉ាងនោះ ។ បទថា **សុសំវិហិតកម្មន្តំ** "*អ្នកចាត់ចែងការងារល្អ*" សេចក្ដីថា អ្នកមិនធ្វើ បាបកម្មដោយកាយទ្វារជាដើម ។ បទថា **អភិវឌ្ឍន្តិ** "*រមែងចម្រើន ក្រៃលែងឡើង*" សេចក្ដីថា រមែងចម្រើនទៅមុខ ។ បទថា **ស-ឧសភាមិវ** "*ដូចហ្វូងគោដែលមានគោឧសភៈដូច្នោះ*" ន័យថា ដូច ហ្វូងគោមានគោឧសភៈជាមេហ្វូង ។ ពិតហើយ ភោគសម្បត្តិទាំង ឡាយរមែងចម្រើនដល់ព្រះរាជាទ្រង់មិនប្រមាទ ដូចហ្វូងគោដែល មានគោឧសភៈជាមេហ្វូងដូច្នោះ ។

បទថា **ឧបស្សុតិ** "*យាងស្ដាប់*" សេចក្ដីថា ព្រះអង្គស្ដេចចូរ ចារិកទៅក្នុងសកលរដ្ឋ និងជនបទរបស់ព្រះអង្គដើម្បីស្ដាប់ហេតុ-ការណ៍ក្នុងជនបទ ។ បទថា **តត្ថ** "*នោះ*" សេចក្ដីថា កាលព្រះអង្គ

ស្តេចយាងទៅក្នុងដែននោះ នឹងបានទតព្រះនេត្រ នឹងទ្រង់បានស្តាប់វត្ថុដែលគួរស្តាប់ ធ្វើនូវគុណានុគុណរបស់ព្រះអង្គឲ្យ ប្រាកដហើយ ទ្រង់នឹងបានបដិបត្តិវត្តបដិបត្តិដែលជាប្រយោជន៍ដ៏ធំដល់ព្រះអង្គ ។

ព្រះមហាសត្វថ្វាយឱវាទព្រះរាជាប្រមាណ ១១ គាថាដោយប្រការដូច្នេះហើយ ទូលថា "ព្រះអង្គចូរប្រញាប់ទៅកុំយឺតយូរ កុំឲ្យដែនវិនាសឡើយ" ដូច្នេះ ទើបត្រឡប់ទៅកាន់ទីនៅរបស់ខ្លួន ។ ឯព្រះរាជាទ្រង់ស្តាប់ពាក្យរបស់ទេវតាហើយទ្រង់ស្លុតព្រះទ័យ ស្អែកឡើងទ្រង់ឲ្យអាមាត្យមើលរាជ្យសម្បត្តិ ព្រមជាមួយបុរោហិតស្តេចចេញចាកព្រះនគរ តាមផ្លូវទ្វារទិសខាងលិចអំពីព្រឹកនោះឯង ស្តេចព្រះរាជដំណើរទៅអស់ចម្ងាយផ្លូវប្រមាណមួយយោជន៍ ។ ត្រង់ទីនោះ បុរសអ្នកស្រុកចំណាស់ម្នាក់នាំមែកឈើបន្លាអំពីព្រៃមកបិទបាំងទ្វារផ្ទះ នាំបុត្តភរិយាចូលទៅក្នុងព្រៃ វេលាល្ងាចកាលពួករាជបុរសទៅអស់ហើយ ក៏ត្រឡប់មកផ្ទះខ្លួនវិញ ត្រូវបន្លាមុតជើងត្រង់

ទ្វារផ្ទះ ទើបអង្គុយប្រហោងជកបន្ទា ពោលជេរព្រះរាជាដោយគាថា
ថា

[៥៤៩] ឯវំ វេទេតុ បញ្ចាលោ សង្គាមេ សរមប្បិតោ
យថាហមជ្ជ វេទេមិ កណ្ឌកេន សមប្បិតោ ។

សូមឲ្យព្រះបាទបញ្ចាលៈត្រូវកូនសរមុតក្នុងសង្គ្រាម សោយ
ទុក្ខវេទនាដូចយើងត្រូវបន្ទាមុតហើយ សោយទុក្ខវេទនានៅ
ក្នុងថ្ងៃនេះ ដូច្នោះ ។

ក៏ពាក្យជេរនោះ បានប្រព្រឹត្តទៅដោយអានុភាពរបស់ព្រះពោ-
ធិសត្វនោះឯង ។ គប្បីជ្រាបថា "បុរសចំណាស់នោះត្រូវព្រះពោ-
ធិសត្វបណ្ដាលចិត្តទើបជេរ" ក្នុងវេលានោះ ព្រះរាជា និងរាជបុ-
រោហិតក្លែងភេទឈរនៅទីជិតៗ បុរសចំណាស់នោះឯង ។ វេលា
រាជបុរោហិតបានឮពាក្យរបស់បុរសចំណាស់ ទើបពោលគាថាថា

[៥៥០] ជិណ្ណោ ទុព្វលចក្ខូសិ ន រូបំ សាធុ បស្សសិ

កឹ តត្ថ ព្រហ្មទត្តស្ស   យន្តំ មគ្គេយ្យ កណ្ណកោ ។

លោកជាមនុស្សចាស់មានចក្ខុងងឹត មើលឃើញអ្វីមិនច្បាស់ បន្ទាមុតលោកខ្លួនឯង ក្នុងរឿងនេះព្រះបាទព្រហ្មទត្ត មានការខុសអ្វីជាមួយ ។

បណ្តាបទទាំងនោះ បទថា **មគ្គេយ្យ** "មុត" បានដល់ មុតចូល ។ មានអធិប្បាយថា បើលោកត្រូវបន្ទាមុតព្រោះខ្លួនខ្វាក់ដោយខ្លួនឯងសោត ក្នុងរឿងនេះហេតុអ្វីទៅជាកំហុសរបស់ព្រះរាជាដែរ លោកជេរព្រះរាជា ព្រោះហេតុអ្វី ព្រះរាជាមាននាទីត្រួតត្រាបន្ទាហើយឲ្យលោកជ្រាបឬ? ។

បុរសជរាបានស្តាប់ដូច្នោះ បានពោល ៣ គាថាថា

[៥៥១] ពហុត្ថ ព្រហ្មទត្តស្ស   យោហំ[១] មគ្គស្មិ ព្រាហ្មណ

អរក្ខិតា   ជានបទា   អធម្មពលិនា ហតា ។

---

១. អដ្ឋកថាយំ បន សោហន្តិ បាឋោ ទិស្សតិ ។

ព្រាហ្មណ៍ យើងត្រូវបន្ទាមុតក្នុងផ្លូវនេះ ជាកំហុសយ៉ាងធំរបស់ព្រះបាទព្រហ្មទត្ត ព្រោះអ្នកជនបទ ដែលព្រះបាទព្រហ្មទត្តមិនបានរក្សា ត្រូវពួករាជបុរសសង្កត់សង្កិនដោយការដែលត្រូវតាមធម៌ ។

រត្តិញ្ហិ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មឹ កូដរាជស្ស ពហុ អធម្មិកោ ជនោ ។

ពេលយប់ត្រូវពួកចោរប្លន់ ពេលថ្ងៃត្រូវមេស្រុកសង្កត់ទារក្នុងដែនរបស់ព្រះរាជាកោង មានមនុស្សអាធម្មដ៏ច្រើន ។

ឯតាទិសេ ភយេ ជាតេ ភយដ្ដា តាត មាណវា
និល្លេន កានិ កុព្វន្តិ វនេ អាហត្វ[1] កណ្ដកំ ។

នែលោកពុក កាលភ័យដូច្នេះកើតឡើង ប្រជាជននាំគ្នាតក់ស្លុតព្រោះខ្លាច ខ្វះក៏នាំគ្នារកឈើមានបន្លាក្នុងព្រៃមកធ្វើ

១.ម. អាហន្ត្វា ។

ជាទីជ្រកពួន ។

បណ្ដាបទទាំងនោះ បទថា **ពហុត្ថ** “**ក្នុងផ្លូវនេះ... យ៉ាងធំ**” សេចក្ដីថា ព្រាហ្មណ៍ ខ្ញុំអន្ទុយចុះក្នុងផ្លូវដែលមានបន្ទា ក្នុងរឿងនេះ ព្រះបាទព្រហ្មទត្តមានកំហុសច្រើន ព្រោះកំហុសរបស់ព្រះរាជាអស់វេលាប៉ុណ្ណោះអ្នកមិនដឹងថា យើងត្រូវត្រាច់ទៅក្នុងផ្លូវដែលមានបន្ទា ព្រោះជនបទដែលព្រះរាជាមិនបានការពាររក្សា ទើបមានបន្ទា ។

បណ្ដាបទទាំងនោះ បទថា **ខាទន្តិ** “**បួន់**” បានដល់ ពួកចោររុកកួនបួន់ ។ បទថា **តុណ្ឌិយា** “**មេស្រុក**” សេចក្ដីថា ពេលថ្ងៃពួកមេស្រុកបៀតបៀនដោយការសម្លាប់ ការចងជាដើម តឹងទារកាស៊ីអាករដោយមិនត្រូវធម៌ ។ បទថា **កូដរាជស្ស** “**ព្រះរាជាកោង**” សេចក្ដីថា ក្នុងដែនរបស់ព្រះរាជាដ៏លាមក ។ បទថា **អធម្មិកោ** “**មនុស្សអាធម្ម**” សេចក្ដីថា មនុស្សទាំងឡាយមានការងារដែលបិទបាំងដ៏ច្រើន បុរសចាស់ហៅបុរោហិតថា ម្នាលព្រាហ្មណ៍ ។

បទថា **មាណវា** “ប្រជាជន” បានដល់ មនុស្សទាំងឡាយ ។ បទថា **និលេនកានិ**[១] “ទីពួន” បានដល់ ស្ថានទីពួនអាស្រ័យ ។ បទថា **វនេ អាហត្វ កណ្ដកំ** “រកឈើមានបន្លាក្នុងព្រៃ” សេចក្ដីថា (ព្រោះភ័យដូច្នេះ) ប្រជាជនទើបយកបន្លាមកបិទទ្វារ លះបង់ផ្ទះនាំកូនប្រពន្ធចូលក្នុងព្រៃ ធ្វើជាទីជ្រកពួនរៀងៗ ខ្លួន ក្នុងព្រៃនោះឯងមួយទៀត បន្លាប្រភេទណាមានក្នុងព្រៃ គេក៏នាំគ្នាយកបន្លាប្រភេទនោះមកលោមព័ទ្ធផ្ទះ ។ ព្រោះកំហុសរបស់ព្រះរាជាដូច្នេះ យើងទើបត្រូវបន្លាមុត លោកកុំជាអ្នកគាំទ្រព្រះរាជាដូច្នេះឡើយ ។

ព្រះរាជាទ្រង់ស្ដាប់ដូច្នោះ ទើបត្រាស់ហៅរាជបុរោហិតមកត្រាស់ថា “លោកអាចារ្យ បុរសជរានិយាយត្រូវ ជាកំហុសរបស់យើងពិតៗ មកចុះ យើងនឹងត្រឡប់ទៅសោយរាជ្យសម្បត្តិដោយធម៌” ។ ទេវតាព្រះពោធិសត្វដែលស្ថិតក្នុងរាងកាយរបស់រាជបុរោ-

---

១.បិដក. និលេន កានិ ។

ហិតទូលថា "បពិត្រមហារាជ ចូរទ្រង់យានទៅត្រួតមើលខាងមុខតទៅទៀតចុះ ព្រះអង្គ" ។ ព្រះរាជា និងរាជបុរោហិតចេញអំពីស្រុកនោះ ទៅកាន់ស្រុកដទៃ បានឮសំឡេងស្ត្រីជរាម្នាក់ក្នុងចន្លោះផ្លូវ ។ ន័យថា ស្ត្រីនោះជាស្ត្រីទាល់ក្រម្នាក់ ចិញ្ចឹមបុត្តស្រីពីរនាក់ដែលចម្រើនវ័យហើយ មិនព្រមឲ្យកូនស្រីទៅព្រៃ ខ្លួនឯងទៅកាប់ឧសមកអំពីព្រៃចិញ្ចឹមកូនស្រីទាំងពីរ ថ្ងៃនោះ នាងឡើងគុម្ពឈើមួយកំពុងកាប់ក៏ភ្លាត់ធ្លាក់មក កាលនឹងជេរព្រះរាជាដោយបំណងឲ្យស្លាប់ទើបពោលគាថាថា

[៥៥២] កទាស្សុ នាមយំ រាជា ព្រហ្មទត្តោ មរិស្សតិ
យស្ស រដ្ឋស្មឹ ជិយ្យន្តិ អបតិកា កុមារិកា ។
ក្នុងដែនរបស់ព្រះបាទព្រហ្មទត្ត ស្រីក្រមុំរកស្វាមីមិនបានរហូតដល់ចាស់ កាលណាព្រះបាទព្រហ្មទត្តនឹងសុគតហ្ន៎ ។

បណ្តាបទទាំងនោះ បទថា អបតិកា "រកស្វាមីមិនបាន"

បានដល់ នឹងរកស្វាមីមិនបាន ។ អធិប្បាយថា បើគេមានស្វាមីគង់នឹងបានចិញ្ចឹមមើលថៃយើង ក្នុងរជ្ជកាលរបស់ព្រះរាជាលាមក យើងបានទទួលសេចក្តីទុក្ខ កាលណាហ្ន៎ព្រះរាជានោះស្លាប់ ។ ស្រីជរាជេរព្រះរាជាយ៉ាងនេះ ក៏ដោយអានុភាពរបស់ព្រះពោធិសត្វ ។

លំដាប់នោះ រាជបុរោហិតកាលនឹងជំទាស់ស្ត្រីនោះ ទើបបានពោលគាថាថា

[៥៥៣] ទុព្ភាសិតញ្ហិ តេ ជម្មិ អនត្ថបទកោវិទេ

កុហឹ រាជា កុមារីនំ ភត្តារំ បរិយេសតិ ។

នែស្ត្រីអាក្រក់មិនស្គាល់ហេតុផល និយាយមិនល្អឡើយ ព្រះរាជាធ្លាប់រកស្វាមីឲ្យនាងកុមារិកាក្នុងទីណាដែរ ។

ស្ត្រីជរាឮដូច្នោះ បានពោល ២ គាថាថា

[៥៥៤] ន មេ ទុព្ភាសិតំ ព្រហ្មេ កោវិទត្ថបទា អហំ

អរក្ខិតា ជានបទា អធម្មពលិនា ហតា ។

រត្តិញ្ហិ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មឹ កូដរាជស្ស ពហុ អធម្មិកោ ជនោ
ទុជ្ជីវេ ទុព្ភរេ ទារេ កុតោ ភត្តា កុមារិយា ។

ព្រាហ្មណ៍អើយ យើងមិនបាននិយាយអាក្រក់ឡើយ យើងដឹងហេតុផល អ្នកជនបទដែលព្រះបាទព្រហ្មទត្តមិនបានរក្សាច្បាប់ត្រូវញាំញីដោយការស៊ីដែលមិនត្រូវតាមធម៌ ។

វេលាយប់ត្រូវចោរប្លន់ វេលាថ្ងៃត្រូវមេស្រុកសង្កត់សង្កិនដោយការស៊ីដែលមិនត្រូវធម៌ ក្នុងដែនរបស់ព្រះរាជាកោងមានមនុស្សអាធម្មច្រើនណាស់ កាលការរស់នៅលំបាក ការចិញ្ចឹមកូនប្រពន្ធក៏លំបាក ស្រីក្មេងនឹងមានស្វាមីអំពីទីណា ។

បណ្ដាបទទាំងនោះ បទថា កោវិទត្ថបទា "យើងដឹងហេតុផល" សេចក្ដីថា យើងដឹងក្នុងហេតុក្នុងផល លោកកុំសរសើរព្រះរាជាលាមកយ៉ាងនេះ ។ បទថា ទុជ្ជីវេ "ការរស់នៅលំបាក" ន័យ

ថា កាលបើដែនដីមានការរស់នៅលំបាក ការចិញ្ចឹមកូនប្រពន្ធក៏លំបាកដែរ ពួកមនុស្សទាំងភ័យខ្លាចទាំងតក់ស្លុតនាំគ្នារត់ទៅនៅក្នុងព្រៃ ។ បទថា **កុតោ ភត្តា កុមារិយា** **"ស្រីក្រមុំនឹងរកស្វាមីបានអំពីទីណា"** សេចក្តីថា ស្រីក្មេងៗ នឹងរកស្វាមីបានក្នុងទីណា ។

ព្រះរាជា និងរាជបុរោហិតស្តាប់ពាក្យរបស់ស្ត្រីជរាហើយ ក៏គិតថា "គាត់និយាយត្រូវ" ទើបនាំគ្នាធ្វើដំណើរទៅមុខទៀត បានឮសំឡេងរបស់អ្នកស្រែម្នាក់ ។ បានឮថា កាលអ្នកស្រែនោះកំពុងភ្ជួរស្រែ គោឈ្មោះសាលិយៈត្រូវផាលមុតទើបដួលចុះ ។ កាលអ្នកស្រែនឹងជេរព្រះរាជា ទើបពោលគាថាថា

[៥៥៥] **ឯវំ សយតុ បញ្ចាលោ សង្គាមេ សត្តិយា ហតោ**

**យថាយំ កបណោ សេតិ ហតោ ផលេន សាលិយោ ។**

សូមឲ្យព្រះបាទបញ្ចាលរាជត្រូវចាក់ដោយលំពែង ត្រូវដេករមៀលក្នុងសង្គ្រាម ដូចគោសាលិយៈនេះ ត្រូវផាលមុតដេក

ហើយ ដូចបុគ្គលកំព្រាដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា យថា "ដូច" សេចក្ដីថា គោឈ្មោះសាលិយៈនេះទទួលទុក្ខវេទនាដេកហើយយ៉ាងណា សូមឲ្យព្រះបាទបញ្ចាលរាជចូរដេកជាទុក្ខដូច្នោះ ។

លំដាប់នោះ រាជបុរោហិតកាលនឹងជំទាស់នឹងអ្នកស្រែនោះទើបពោលគាថាថា

[៥៥៦] អធម្មេន តុវំ ជម្ម ព្រហ្មទត្តស្ស កុជ្ឈសិ

យោ តំ សបសិ រាជានំ អបរជ្ឈិត្វាន អត្តនោ ។

នែមនុស្សជាតិអាក្រក់ អ្នកក្រោធនឹងព្រះបាទព្រហ្មទត្តដោយមិនមែនជាធម៌ អ្នកប្រទូស្តនឹងគោខ្លួនឯង ហេតុអ្វីទើបមកផ្ដាសាព្រះរាជាហ្ន៎ ។

បណ្ដាបទទាំងនោះ បទថា អធម្មេន "ដោយមិនមែនធម៌" សេចក្ដីថា ដោយមិនមានហេតុផល គឺ មិនមានការពិត ។

អ្នកស្រែស្តាប់ដូច្នោះហើយ បានពោល ៣ គាថាថា

[៥៥៧] ធម្មេន ព្រហ្មទត្តស្ស អហំ កុជ្ឈាមិ ព្រាហ្មណ
អរក្ខិតា ជានបទា អធម្មពលិនា ហតា ។
រត្តិញ្ហិ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មិំ កូដរាជស្ស ពហុ អធម្មិកោ ជនោ ។
សា នូន បុន រេ បក្កា វិកាលេ ភត្តមាហរិ
ភត្តាហារិំ អបេក្ខន្តោ ហតោ ផលេន សាលិយោ ។

ព្រាហ្មណ៍ យើងក្រោធនឹងព្រះបាទព្រហ្មទត្តដោយត្រូវតាមធម៌ ព្រោះអ្នកជនបទដែលព្រះបាទព្រហ្មទត្តទ្រង់មិនបានរក្សា ត្រូវមេស្រុកសង្កត់សង្កិនដោយការស៊ីដែលមិនមែនជាធម៌ ។

វេលាយប់ត្រូវពួកចោរប្លន់ វេលាថ្ងៃត្រូវមេស្រុកសង្កត់សង្កិន ដោយការស៊ីដែលមិនមែនជាធម៌ ក្នុងដែនរបស់ព្រះរាជាកោងមានមនុស្សអាធម្មដ៏ច្រើន ។

អ្នកគ្រួគង់នឹងចង្អិនជាថ្មីទៀតដោយពិត ទើបនាំបាយមកឲ្យក្នុងវេលារសៀល យើងរវល់តែមើលអ្នកគ្រួនាំបាយមក គោសាលិយៈទើបត្រូវផាលមុត ។

បណ្ដាបទទាំងនោះ បទថា ធម្មេន "ដោយត្រូវតាមធម៌" គឺយើងជេរដោយមានហេតុផល លោកកុំយល់ថា "អ្នកស្រែជេរដោយមិនមានហេតុផល" ។ បទថា សា នូន បុន រេ បក្កា វិកាលេ កត្តមាហរិ "មេគ្រួគង់នឹងដាំបាយជាថ្មីទៀតដោយពិត ទើបនាំបាយមកក្នុងវេលារសៀល" សេចក្ដីថា ព្រាហ្មណ៍អើយ យើងគិតថា "ស្ត្រីមេគ្រួរបស់យើងនាំបាយមកឲ្យយើង ដាំបាយហើយគង់នឹងនាំមកអំពីព្រឹក តែនាងត្រូវពួកទាសៈរបស់ព្រះបាទព្រហ្មទត្ត ពួករីបកាស៊ីមិនត្រូវធម៌ចាប់ខ្លួន ត្រូវចាត់ចែងឲ្យពួកនោះហើយទើបដាំបាយដើម្បីយើងជាថ្មី ព្រោះហេតុនោះ ទើបនាំបាយមកក្នុងវេលារសៀលថ្ងៃនេះនាំមករសៀលពេក" ដូច្នេះហើយ ត្រូវសេចក្ដីស្រេកឃ្លាន

បៀតបៀន រវល់ចាំមើលមនុស្សប្រញាប់ទាយ ដេញគោយកជន្ទញ ចាក់មិនបានមើល ដូច្នោះ គោសាលិយៈលើកជើងឡើងក៏ត្រូវនឹង ផាល ទើបត្រូវផាលមុត ហេតុនោះ លោកកុំយល់ថាយើងប្រហារ វា ប្រការនេះឈ្មោះថា ព្រះរាជាដ៏លាមកជាអ្នកប្រហារហើយនោះ ឯង លោកកុំរវល់ពោលពណ៌នាគុណរបស់ព្រះរាជានោះឡើយ ។

ព្រះរាជា និងរាជបុរោហិតក៏ធ្វើដំណើរបន្តទៀត ហើយស្នាក់ នៅក្នុងស្រុកមួយ ។ ស្អែកឡើងវេលាព្រឹក មេគោទឹកដោះគោង មួយក្បាល យកជើងធាក់មនុស្សអ្នករឹតទឹកដោះ ដួលទៅព្រមទាំង ទឹកដោះ ។ កាលអ្នករឹតទឹកដោះគោនឹងជេរព្រះបាទព្រហ្មទត្ត ទើប ពោលគាថាថា

[៥៥៨] ឯវំ ហញ្ញតុ បញ្ចាលោ សង្គាមេ អសិនា ហតោ

យថាហមជ្ជ បហតោ ខីរញ្ច មេ បវត្តិតំ ។

សូមឲ្យព្រះបាទបញ្ចាលរាជ ចូរត្រូវកាប់ដោយដាវក្នុងសង្គ្រាម

ក្ដៅក្រហាយដូចយើងត្រូវមេគោទឹកដោះធាក់ក្នុងថ្ងៃនេះ រហូត ទឹកដោះស្រស់របស់យើងកំពប់ទៅដូច្នោះ ។

រាជបុរោហិតបានស្ដាប់ដូច្នោះ ទើបពោលថា

[៥៥៩] យំ បសុ ខីរំ ឆឌ្ឌេតិ បសុ ផាលំ វិហឹសតិ
កឹ តត្ថ ព្រហ្មទត្តស្ស យំ នោ គរហតេ ករំ ។

ការដែលមេគោទឹកដោះធាក់អ្នកឲ្យឈឺចាប់ ទឹកដោះកំពប់នោះ ជាកំហុសអ្វីរបស់ព្រះបាទព្រហ្មទត្ត ទើបអ្នកតិះដៀល ។

គ្រាព្រាហ្មណ៍បុរោហិតពោលគាថាចប់ អ្នករីតដោះមេគោបាន ពោល ៣ គាថាទៀតថា

[៥៦០] គារយ្ហោ ព្រហ្មេ បញ្ចាលោ ព្រហ្មទត្តស្ស រាជិនោ
អរក្ខិតា ជានបទា អធម្មពលិនា ហតា ។

ព្រាហ្មណ៍ ព្រះចៅបញ្ចាលៈគួរនឹងបានទទួលការតិះដៀល ព្រោះអ្នកជនបទដែលព្រះបាទព្រហ្មទត្តមិនបានរក្សា ត្រូវមេ-

ស្រុកសន្តត់សន្ធិនដោយភាសុីដែលមិនមែនជាធម៌ ។

រត្តិញ្ហិ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មឹ កូដរាជស្ស ពហុ អធម្មិកោ ជនោ ។

មួយទៀត វេលាយប់ក៏ត្រូវចោរប្លន់ វេលាថ្ងៃក៏ត្រូវតឹង
ទារភាសុីដែលមិនមែនជាធម៌ ក្នុងដែនរបស់ព្រះរាជាកោងមាន
បុគ្គលអាធម្មដ៏ច្រើន ។

ចណ្ឌា អាកឌ្ឍនា គាវី យំ បុរេ ន ទុហាមសេ
តំទានិ អជ្ជ ទោហាម ខីរកាមេហុបទ្ទុតា ។

មេគោផ្កាងកាច កាលមុនពួកយើងមិនបានរឹតទឹកដោះវា
តែថ្ងៃនេះ យើងត្រូវពួករាជបុរសដែលត្រូវការទឹកដោះមករបៀ
ជាន់ ទើបត្រូវរឹតដោះវានោះឯង ។

បណ្ដាបទទាំងនោះ បទថា ចណ្ឌា “កាច” គឺ អាក្រក់ ។
បទថា អកត្តនា[1] “ផ្កាង” បានដល់ មានប្រក្រតីឆ្វេង ។ បទថា

១.បិដក. អកឌ្ឍនា ។

វីរកាមេហិ[១] “ត្រូវការទឹកដោះ” សេចក្ដីថា យើងត្រូវមេស្រុករបស់ព្រះរាជាអាធម្ម ប្រើឲ្យរកទឹកដោះស្រស់ច្រើនៗ បៀតបៀន ក៏ចាំបាច់ត្រូវរឹត ប្រសិនបើព្រះបាទព្រហ្មទត្តនោះគ្រងរាជ្យសម្បត្តិដោយធម៌ ភ័យបែបនេះនឹងមិនមានមកដល់ពួកយើងឡើយ ។

ព្រះរាជា និងរាជបុរោហិតគិតថា “អ្នកនេះនិយាយត្រូវ ទើបចេញចាកស្រុកនោះឡើងកាន់ផ្លូវធំ បំណងឆ្ពោះទៅកាន់ព្រះនគរ ។ ក្នុងស្រុកមួយ ពួកនាយអាករសម្លាប់កូនគោមួយក្បាលដើម្បីត្រូវការធ្វើស្រោមដាវ ទើបកាន់យកស្បែកទៅ មេគោទឹកដោះដែលកូនត្រូវសម្លាប់ ព្រោះសេចក្ដីសោកដល់កូនក៏មិនស៊ីស្មៅ មិនផឹកទឹក ដើរយំស្រែករកកូន ។ ក្មេងៗ អ្នកស្រុកឃើញដូច្នោះ កាលនឹងនាំគ្នាជេរព្រះរាជា ទើបពោលគាថាថា

[៥៦១] ឯវំ កន្ទតុ បញ្ចាលោ វិមុត្តោ វិប្បសុក្ខតុ

---

១.បិដក. វីរកាមេហុបទុតា ។

យថាយំ កបណា គាវី វិមុត្តា បរិធាវតិ ។

សូមឲ្យព្រះបាទបញ្ចាលរាជចូរព្រាត់ប្រាសចាកឱរស ស្ទុះរត់យំសោក ដូចមេគោកំព្រាព្រាត់ប្រាសចាកកូន ដែលស្ទុះរត់យំសោកហើយដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា បរិធាវតិ "រត់" សេចក្ដីថា រត់ស្រែកយំ ។

លំដាប់នោះ បុរោហិតពោលគាថាក្រៅអំពីនេះថា

[៥៦២] យំ បសុ បសុបាលស្ស សម្ភមេយ្យ រវេយ្យ វា

កោនីធ អបរាធត្ថិ ព្រហ្មទត្តស្ស រាជិនោ ។

ក្នុងការដែលមេគោរបស់អ្នកចិញ្ចឹមគោ ស្ទុះរត់ទៅមក ឬយំស្រែកហើយនេះ ជាកំហុសអ្វីរបស់ព្រះបាទព្រហ្មទត្តហ្ន៎ ។

បណ្ដាបទទាំងនោះ បទថា បត្ថមេយ្យ[១] រវេយ្យ វា "ស្ទុះ

---

១.បិដក. សម្ភមេយ្យ ។

វត់ទៅមក ឬស្រែកយំហើយ” សេចក្តីថា (សត្វចិញ្ចឹម) ក៏ត្រូវវត់ទៅមកបាន ឬស្រែកយំបាន អធិប្បាយថា បាអើយ ធម្មតាសត្វចិញ្ចឹមកាលម្ចាស់វាមិនបានរក្សាហើយ វាក៏វត់បាន មិនស៊ីស្មៅបាន ក្នុងសេចក្តីនេះជាកំហុសអ្វីរបស់ព្រះរាជាហ្ន៎ ។

លំដាប់នោះ ក្មេងអ្នកស្រុកបានពោល ២ គាថាថា

[៥៦៣] អបរាធោ មហាព្រហ្មេ ព្រហ្មទត្តស្ស រាជិនោ
អរក្ខិតា ជានបទា អធម្មពលិនា ហតា ។

មហាព្រាហ្មណ៍ កំហុសរបស់ព្រះបាទព្រហ្មទត្ត មានពិត ព្រោះអ្នកជនបទដែលព្រះបាទព្រហ្មទត្តមិនបានរក្សា ត្រូវមេស្រុកសង្កត់សង្កិនដោយភាស៊ីដែលមិនត្រូវតាមធម៌ ។

រត្តិញ្ហិ ចោរា ខាទន្តិ ទិវា ខាទន្តិ តុណ្ឌិយា
រដ្ឋស្មឹ កូដរាជស្ស ពហុ អធម្មិកោ ជនោ
កថំ នោ អសិកោសត្ថា ខីរបា ហញ្ញតេ បជា ។

វេលាយប់ក៏ត្រូវចោរប្លន់ វេលាថ្ងៃត្រូវមេស្រុកសង្កត់សង្កិន ដោយការស៊ីដែលមិនត្រូវតាមធម៌ ក្នុងដែនរបស់ព្រះរាជាកោង មានមនុស្សអាធម្មដ៏ច្រើន កូនគោរបស់ពួកយើងនៅជៅដោះ ក៏ត្រូវសម្លាប់ ព្រោះត្រូវការស្រោមដាវតែម្យ៉ាង ។

បណ្ដាបទទាំងនោះ បទថា មហាព្រហ្ម "មហាព្រាហ្មណ៍" បានដល់ មហាព្រាហ្មណ៍ ។ បទថា រាជិនោ "របស់ព្រះបាទ" គឺ របស់ព្រះរាជា ។ បទថា កថំ នោ "មានពិត" សេចក្ដីថា យ៉ាងណាហ្ន៎ គឺ ព្រោះហេតុអ្វី ។ បទថា ខីរបា ហញ្ញតេ បជា "កូនគោរបស់ពួកយើងនៅជៅដោះក៏ត្រូវសម្លាប់" សេចក្ដីថា ក្មេងទាំងឡាយជេរព្រះរាជាថា "កូនគោដែលនៅជៅដោះ ត្រូវពួកមេស្រុកទាំងនោះសម្លាប់ដោយអំណាចរបស់ព្រះរាជាលាមក មេគោនោះយំស្រែករកកូនតែម្យ៉ាង សូមព្រះរាជានោះចូរបរិទេវនាការដូចមេគោនោះចុះ ។

ព្រះរាជា និងរាជបុរោហិតនិយាយថា "ល្អហើយ ពួកអ្នកនិយាយមានហេតុផល" ហើយចៀសចេញទៅ ។ តមកក្នុងចន្លោះផ្លូវ ហ្វូងក្អែកកំពុងយកចំពុះចឹកស៊ីកង្កែបទាំងឡាយក្នុងស្រះមួយកន្លែង ។ កាលព្រះរាជា និងរាជបុរោហិតមកដល់ទីនោះ ព្រះមហាសត្វទើបបណ្តាលឲ្យកង្កែបទាំងឡាយផ្តាសាព្រះរាជាដោយអានុភាពរបស់ខ្លួនថា

[៥៦៤] ឯវំ ខជ្ជតុ បញ្ចាលោ ហតោ យុទ្ធេ សបុត្តកោ
យថាហមជ្ជ ខជ្ជាមិ គាមិកេហិ អរញ្ញជោ ។

សូមឲ្យព្រះបាទបញ្ចាលរាជ ព្រមទាំងព្រះរាជឱរសចូរត្រូវប្រហារក្នុងសង្គ្រាម ឲ្យហ្វូងក្អែកចោមរោមចឹកស៊ីដូចយើងអ្នកកើតក្នុងព្រៃ ត្រូវហ្វូងក្អែកស្រុកចឹកស៊ីក្នុងថ្ងៃនេះ ដូច្នោះ ។

បណ្តាបទទាំងនោះ បទថា គាមកេហិ[១] "ក្អែកស្រុក" បាន

---

១.បិដក. គាមិកេហិ ។

ដល់ ក្អែកដែលរស់នៅក្នុងស្រុក ។

រាជបុរោហិតបានឮដូច្នោះ កាលនឹងសន្ទនាជាមួយពួកក្អែក ទើបពោលគាថាថា

[៥៦៥] ន សព្វភូតេសុ វិធេន្តិ រក្ខំ
រាជានោ មណ្ឌុក មនុស្សលោកេ
នេត្តាវតា រាជា អធម្មចារី
យំ តាទិសំ ជីវមទេយ្យុ ធង្កា ។

អើក្អែក ព្រះរាជាទាំងឡាយក្នុងមនុស្សលោក ទ្រង់នឹងចាត់ចែងការពាររក្សាសត្វទូទៅមិនបាននោះទេ ព្រះរាជាមិនបានជាអធម្មចារីបុគ្គលឡើយ ដោយហេតុដែលហ្វូងក្អែកស៊ីសត្វដូចជាពួកអ្នកនោះ ។

បណ្តាបទទាំងនោះ បទថា ជីវំ "សត្វ" បានដល់ សត្វមានជីវិត ។ បទថា អទេយ្យុំ[១] "ស៊ី" បានដល់ គប្បីស៊ី ។ បទថា

១.បិដក. អទេយ្យុ ។

ធន្តា "ហ្វូងក្អែក" បានដល់ ក្អែកទាំងឡាយ ។ អធិប្បាយថា សត្វ ក្អែកទាំងឡាយគប្បីស៊ីសត្វមានជីវិតដោយហេតុត្រឹមណា ដោយ ហេតុត្រឹមប៉ុណ្ណោះ ព្រះរាជានឹងឈ្មោះថា ជាអ្នកមិនប្រព្រឹត្តធម៌ក៏ មិនមែន ព្រះរាជានឹងអាចចូលទៅកាន់ព្រៃ ដើររក្សាអ្នកបានយ៉ាង ណា ។

កន្ទែបបានស្តាប់ដូច្នោះ ទើបពោល ២ គាថាថា

[៥៦៦] អធម្មរូបោ វត ព្រហ្មចារី
អនុប្បិយំ ភាសសិ ខត្តិយស្ស
វិលុម្បមានាយ បុថុប្បជាយ
បូជេសិ រាជំ បរមប្បវាទី ។

លោកជាព្រហ្មចារី ជាតិជាអាធម្មហ្ន៎ ទើបពោលសរសើរ ក្សត្របាន កាលប្រជាករដ៏ច្រើនត្រូវប្លន់ហើយ លោកនៅបូជា ព្រះរាជាដែលគួរតិះដៀលដ៏ក្រៃលែងទៀត ។

សចេ ឥទំ ព្រហ្មេ សុរជ្ជកំ សិយា
ផីតំ រដ្ឋំ មុទិតំ វិប្បសន្នំ
ភុត្វា ពលឹ អគ្គបិណ្ឌញ្ច កាកា
ន មាទិសំ ជីវមាទេយ្យុ ធង្កាតិ ។

ព្រាហ្មណ៍ ប្រសិនបើដែនដីនេះគប្បីមានព្រះរាជាល្អ ក៏នឹងស្តុកស្តម្ភ សប្បាយរីករាយ ហ្វូងក្អែកក៏នឹងបានស៊ីដុំបាយដែលល្អៗ ជាពលី មិនត្រូវមកស៊ីសត្វដូចជាពួកយើងទេ ។

បណ្តាបទទាំងនោះ បទថា ព្រហ្មចារី "ជាព្រហ្មចារី" សេចក្តីថា កន្ទ្កែបកាលនឹងតិះដៀលបុរោហិត ទើបពោលថា "លោកជាព្រហ្មចារី មានជាតិជាអាជម្មហ្ន៍" ។ បទថា **ខត្តិយស្ស** "ក្សត្រ" បានដល់ ព្រះរាជាដ៏អាក្រក់បែបនេះ ។ បទថា **វិលុម្បមានាយ** "ត្រូវប្លន់ហើយ" សេចក្តីថា កាលប្រជាជនត្រូវរឹបជាន់ខ្ទាំងហើយម្យ៉ាងទៀត បាឋៈ (ព្រះបាលី) ក៏យ៉ាងនោះដូចគ្នា ។ បទថា បុ-

ចុះបរជាយ "កាលប្រជាករដ៏ច្រើន" សេចក្តីថា កាលប្រជាជនទូទៅត្រូវមេស្រុកធ្វើឲ្យវិនាសហើយ ។ បទថា **បូជេសិ** "បូជា" បានដល់ លើកសរសើរ ។ បទថា **សុរដ្ឋកំ** "ព្រះរាជាល្អ" សេចក្តីថា បើដែនដីនេះ ដែលព្រះរាជាទ្រង់មិនលុះក្នុងអំណាចឆន្ទាគតិជាដើម មិនញុំាំងទសពិធរាជធម៌ឲ្យកម្រើក ទ្រង់រក្សាហើយ គប្បីជាដែនដីមានកំពូលនៃរាជដ៏ល្អ ។ បទថា **ផីតំ** "ស្តុកស្តម្ភ" សេចក្តីថា មានស្រូវអង្ករសម្បូរ ក្នុងរដូវភ្លៀងក៏ញុំាំងនូវក្រសែទឹកបានដោយល្អ ។ បទថា **មាទិសំ** "ដូចជាពួកយើង" សេចក្តីថា បើដូច្នេះ ក្អែកទាំងឡាយគង់មិនស៊ីសត្វដូចជាយើងឡើយ ។ ការជេរក្នុងឋានៈសូម្បីទាំង ៦ យ៉ាងនេះ បានដោយអានុភាពព្រះពោធិសត្វនោះឯង ។

ព្រះរាជា និងរាជបុរោហិតស្តាប់ពាក្យនោះហើយ ត្រិះរិះថា "ជនទាំងពួង ដោយហោចសូម្បីកង្កែបដែលជាសត្វតិរច្ឆានរស់នៅក្នុងព្រៃ នាំគ្នាជេរយើងតែម្នាក់" ហើយស្តេចចេញចាកអំពីទីនោះ

ទៅកាន់ព្រះនគរ សោយរាជ្យដោយធម៌ តាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ សាងបុណ្យកុសលមានទានជាដើម ។

ព្រះសាស្តា គ្រាទ្រង់នាំព្រះធម្មទេសនានេះមកសម្តែងដល់ព្រះបាទកោសលហើយ ទ្រង់ត្រាស់ថា "មហាបពិត្រ ធម្មតាព្រះរាជាគួរនឹងលះបង់ការលុះក្នុងអំណាចអគតិ សោយរាជ្យដោយធម៌" ហើយទ្រង់ប្រជុំជាតកថា "ភណ្ឌុតិណ្ឌុកទេវតាក្នុងកាលនោះ បានមកជា តថាគត នេះឯង" ។

ចប់អដ្ឋកថា ភណ្ឌុតិណ្ឌុកជាតកទី ១០

**ចប់អដ្ឋកថាតឹសតិនិបាត**

**ដែលប្រដាប់ដោយជាតក ១០ រឿង**

១. កិំឆន្ទជាតក
២. កុម្ភជាតក
៣. ជយទិសជាតក
៤. ឆទ្ទន្តជាតក
៥. សម្ភវជាតក
៦. មហាកបិជាតក
៧. ទករក្ខសជាតក
៨. បណ្ឌរកជាតក
៩. សម្ពុលាជាតក
១០. ភណ្ឌុតិណ្ឌុកជាតក

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

-លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស ......... $ 2.000 USA

-ឧបាសក សោម រតនៈ ព្រមទាំងភរិយា បុត្ត និងចៅ ...... $ 500 USA

-ឧបាសក តាំង សុជល ឧបាសិកា ឡុង កេង

ព្រមទាំងបុត្ត និងចៅ ......... $ 200 USA

-កញ្ញា តាំង សុមាវតី ......... $ 50 USA

-ចៅស្រី ហ៊ាង ឧត្តរា<br>ហ៊ាង ហ៊ានីឡា<br>ហ៊ាង សាហ៊ីយ៉ា ......... $ 50 USA


នត្ថិ សន្តិ បរំ សុខំ
ព្រះរាជាណាចក្រកម្ពុជា